ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ រូបសំណាកសម្រាប់រំឭកដល់សង្គ្រាមនៅកម្ពុជា : ១៩៧០-១៩៧៥

◆ របាយការណ៍នៃសវនាការអង្គបុរេជំនុំជម្រះអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១២៤ ខែមេសា ឆ្នាំ២០១០

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១២៤ ខែមេសា ឆ្នាំ២០១០

## មាតិកា

◆រូបសំណាកសម្រាប់រំឭកដល់សង្គ្រាមនៅកម្ពុជា ....................................១

**ផ្នែកឯកសារ**

◆ឡុង ភិរម្យ កូនស្រីរបស់អ្នកទោសនៅមន្ទីរស-២១ ..............................២

◆យិត សុភក្រ្ត ៖ ចង់ផ្សះផ្សាជាមួយជនដៃដល់ ....................................៦

◆ដំណើររៀបរាប់អំពីជីវិតខ្មោចផ្សា ................................................១០

**ផ្នែកប្រវត្តិសាស្រ្តនិងការស្រាវជ្រាវ**

◆គង់ ហាក់ ៖ ជីវិតយុវជនម្នាក់ក្នុងរបបខ្មែរក្រហម..............................១៧

◆រាជ លឹម ៖ អតីតប្រធានកងក្នុងភូមិភាគបូព៌ា..................................១៨

◆យិន សុធា ៖ គ្រូបង្រៀនប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ .............២០

◆ខ្ញុំមិនចង់សងសឹកគេទៀតទេ .................................................២១

◆នៅតែចង់ធ្វើគ្រូបង្រៀន ..........................................................២៣

◆ម៉ៅ វាសនា ៖ ចង់អប់រំក្មេងជំនាន់ក្រោយ .................................២៤

**ផ្នែកច្បាប់**

◆ការទទួលបាននូវយុត្តិធម៌និងការផ្សះផ្សាជាតិ................................២៦

◆យុត្តិធម៌នៃដំណើរការនីតិវិធី ៖ ការពិនិត្យមើលអំពីប្រព័ន្ធ ...............៣៣

◆របាយការណ៍នៃសវនាការអង្គបុរេជំនុំអំពីបណ្តឹងឧទ្ធរណ៍..................៤០

**វេទិកាពិភាក្សាសាធារណៈ**

◆ការដាក់ឲ្យមានការទទួលខុសត្រូវចំពោះភាពអត់ឃ្លាន .....................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ជិន ស៊ុំ ៖ អតីតពេទ្យខ្មែរក្រហម.............................................៥៩



អ្នកភូមិមើលសៀវភៅណែនាំអំពីសំណុំរឿង០០២



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្រ្តីនិងរដ្ឋមន្រ្តីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ឆាយ ឈុនលី, ម៉ារីឌីត ឌីន និង ណាតាហ្សា បាច, ម៉ារី យូ. អ៊ីរ៉ូហ្សូរូ, សារ៉ា ថូម៉ាស, រ៉េនឌល ឌីហ្វាល់កូ, ចាន់ ដល្លា **អ្នកនិពន្ធនិងស្រាវជ្រាវៈ** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែៈ** ជា ដល្លា, ទេស ម៉ារ៉ែម **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ញាណ សុជាតិ, ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុជាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# រូបសំណាកសម្រាប់រំឭកដល់សង្គ្រាមនៅកម្ពុជា : ១៩៧០-១៩៧៥

សំណូមពររបស់ខ្ញុំដើម្បីធ្វើការរំឭកដល់អ្នកសារព័ត៌មានបរទេសនិងកម្ពុជាដែលបានស្លាប់នៅអំឡុងសង្គ្រាមកម្ពុជាគឺយកគំនិតចេញពីរូបថតរបស់ អាល រ៉ក់អហ្វ និង ហ្វ្រង់ស៊័រ ដឺម៉ាល់ដឺ ។ រូបថតដែលត្រូវបានថតដោយ ខាថឺរីន ឡឺរ៉យ នៅឆ្នាំ១៩៧៣ បង្ហាញពីអ្នកសារព័ត៌មានពីរនាក់ដែលកំពុងដើរនៅលើផ្លូវជាតិលេខ១ដ៏ស្ងាត់ជ្រងំបន្ទាប់ពីមានការទម្លាក់គ្រាប់បែក ។ សម្រាប់រូបសំណាក ខ្ញុំចង់ឲ្យមានមនុស្សពីរនាក់ ប្រុសម្នាក់និងស្រីម្នាក់ឈរដោយមានម៉ាស៊ីនថតជាប់នៅនឹងកហើយសម្លឹងមើលទៅជុំវិញ ។ ឈ្មោះរបស់អ្នកដែលបានស្លាប់នឹងឆ្លាក់ជាជួរដេកនៅក្រោមជើងរបស់រូបចម្លាក់នេះ ។ ទោះបីជាយើងសម្លឹងទៅក្រោមមើលអ្នកទាំងនោះ ក៏អ្នកទាំងនោះសម្លឹងទៅលើមេឃដើម្បីធ្វើឲ្យឋានទរកនៃសង្គ្រាមភ្ជាប់ជាមួយសន្តិភាពនៅស្ថានសួគ៌ដែរ ។ កន្លែងនៅចន្លោះឈ្មោះគួរតែមានផ្កាដើម្បីបង្ហាញថា ទោះបីជាអ្នកទាំងនោះបានស្លាប់បាត់ទៅហើយក្តី ក៏អ្នកទាំងនោះនៅមានជីវិតដដែលនៅក្នុងចិត្តរបស់យើងគ្រប់គ្នា ។

**ឆាំង យុ**

រូបថតដែលថតដោយ ខាថឺរីន ឡឺរ៉យ នៅឆ្នាំ១៩៧៣



រូបគំនូរ



# ឡុង ភិរម្យ កូនស្រីរបស់អ្នកទោសនៅមន្ទីរស-២១

ឡុង ភិរម្យ គឺជាកូនស្រីរបស់អ្នកទោសម្នាក់ឈ្មោះ ឡុង យៀង ដែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅក្នុងមន្ទីរ ស-២១ ក្រោមការគ្រប់គ្រងរបស់ ឌុច ។ តាំងពី ភិរម្យ ដឹងថា ឪពុករបស់គាត់ត្រូវបញ្ជូនយកទៅសម្លាប់នៅស-២១ គាត់តែងតែព្យាយាមស្វែងរកចម្លើយជានិច្ចអំពីការស្លាប់ឪពុករបស់គាត់ ។ ប៉ុន្តែមកដល់ពេលនេះ ទោះបីមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកាត់ទោស ឌុច រួចហើយក៏ដោយ ក៏ ភិរម្យ នៅតែរកចម្លើយពីមូលហេតុនៃការស្លាប់របស់ឪពុកគាត់មិនឃើញដដែល ។

### ថ្ងៃបាត់ខ្លួនឪពុក



ឡុង យៀង

ពេលដែលកងទ័ពខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ ប្រជាជនទាំងអស់ត្រូវបានជម្លៀសឲ្យទៅរស់នៅទីជនបទ ។ ពេលនោះ ស្ថានភាពប្រទេសមានលក្ខណៈច្របូកច្របល់ជាខ្លាំង ដោយខ្មែរក្រហមបានតម្រូវឲ្យប្រជាជននៅគ្រប់ផ្ទះទាំងអស់ធ្វើដំណើរចាកចេញពីលំនៅឋានទៅតាមទិសដៅកំណត់របស់អង្គការ ។ ក្រោយពីរៀបចំអីវ៉ាន់ហើយ ខ្មែរក្រហមក៏បានជម្លៀសគ្រួសាររបស់ ភិរម្យ ឲ្យទៅរស់នៅឃុំព្រែកធាតុ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ។

ប្រហែលជាថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៥ នៅវេលាម៉ោង ៨យប់ ស្រាប់តែកងទ័ពខ្មែរក្រហមមកប្រាប់ឲ្យឪពុករបស់ ភិរម្យ និងគ្នា៦នាក់ទៀតមាន អ៊ឹ ម៉ៅ សំបូរ, កូនឈ្មោះ ម៉ៅ ប៊ុនណា, ឌី វ៉ាម៉ា និងលោកគ្រូ យ៉ាន គីមស៊ុន និងម្នាក់ទៀតដែលគាត់មិនចាំឈ្មោះឲ្យចេញទៅដឹកស្រូវដោយមិនចាំបាច់យកខោអាវទៅជាមួយទេ ។ កងទ័ពខ្មែរក្រហមបាននិយាយថា «ដឹកស្រូវតែមួយភ្លែតប៉ុណ្ណោះ ស្អែកនឹងបានត្រឡប់មកផ្ទះវិញហើយ» ។ នៅយប់នោះ ម្តាយរបស់ ភិរម្យ មិនបានសម្រាន្តលក់ទេ ដោយនៅឈររង់ចាំឪពុករបស់គាត់រហូតដល់ភ្លឺ ។ ព្រឹកឡើង ដោយសារមិនឃើញត្រឡប់មកផ្ទះវិញ ម្តាយរបស់គាត់ក៏ទៅសួរ តាឈិន ដែលជាប្រធានកម្មាភិបាលគ្រប់គ្រងនៅក្នុងវត្តព្រះធាតុអូររាំង ។ ប៉ុន្តែចម្លើយដែលទទួលបានគឺត្រឹមតែភាពអស់សង្ឃឹមប៉ុណ្ណោះ ដោយគាត់និយាយថា «មិត្តឯងកុំចាំអី អង្គការយកគាត់ទៅរៀនសូត្រហើយ» ។ គ្រាន់តែស្តាប់ភ្លាម ម្តាយរបស់ ភិរម្យ ស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន រួចសួរទៅវិញថា «រៀនសូត្រយ៉ាងម៉េចទៅ?» តាឈិន បានតបមកវិញថា «រៀនសូត្រតែបន្តិច គេឲ្យមកវិញហើយ» ។ ដោយសារតែជឿពាក្យទាំងអស់នេះ ម្តាយរបស់ ភិរម្យ បានផ្ញើភួយនិងរបស់របរដែលមានបន្តិចបន្តួចទៅឲ្យឪពុករបស់គាត់តាមរយៈ តាឈិន ។ ប៉ុន្តែ ចាប់តាំងពីពេលនោះមក ឪពុករបស់ ភិរម្យ បានបាត់ដំណឹងរហូត ។

### ក្រោយថ្ងៃបាត់ខ្លួន

ក្រោយពីការចាប់ខ្លួនលោក ឡុង យៀង គ្រួសាររបស់ ភិរម្យ ត្រូវបានជម្លៀសបន្តឲ្យទៅរស់នៅស្រុកសំបូរ ខេត្តក្រចេះ ។ នៅទីនោះ ខណៈពេលដែលអង្គការកំពុងតែប្រកាសជ្រើសរើសនារីៗឲ្យចូលបដិវត្តន៍ ប្អូនស្រីរបស់គាត់ ឡុង ពិដោរ ដែលទើបតែមានអាយុ១៣ឆ្នាំ ក៏បានក្រោកឈរឡើង រួចនិយាយថា ស្ម័គ្រចិត្តទៅតាមអង្គការ ។ ដោយមានការព្រួយបារម្ភពី

ប្អូនស្រី ភិរម្យ ក៏ស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ដែរ ដើម្បីតាមជួយថែរក្សាប្អូន ។ ប៉ុន្តែ ព្រលឹមឡើងស្រាប់តែអង្គការបានសម្រេចដកឈ្មោះរបស់ប្អូនស្រីគាត់ចេញវិញ ដោយហេតុថាប្អូនរបស់គាត់នៅក្មេងពេក ។ បន្ទាប់មក ភិរម្យ និងមនុស្សចំនួន៣០នាក់ទៀតត្រូវបានរៀបចំឲ្យស្នាក់នៅក្នុងឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ ។ អង្គការបែងចែក ភិរម្យ ឲ្យស្ថិតនៅក្នុងកងស្រួចតំបន់ដែលមានគ្នាសរុបទាំងអស់១៥០នាក់ បែងចែកជាប្រាំកងមកពីគ្រប់ភូមិឃុំទាំងអស់ ។ កងរបស់ ភិរម្យ មានតួនាទីធ្វើស្រែចាប់ពីម៉ោង៤ភ្លឺរហូតដល់ពេលល្ងាចទើបអាចសម្រាកបាន ។ លើសពីនេះទៅទៀត ភិរម្យ តែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជានិច្ច ព្រោះអ្នកដែលខ្ជិលធ្វើការគឺបាត់ខ្លួន ហើយពេលខ្លះទោះបីជាខំធ្វើការក៏នៅតែបាត់ខ្លួនដោយមិនដឹងមូលហេតុដែរ ។ ដូច្នេះ ទោះបីជាគាត់ឈឺធ្ងន់យ៉ាងណាក៏ដោយ ក៏គាត់នៅតែទៅធ្វើការរហូតដល់ពេលខ្លះដួលសន្លប់នៅការដ្ឋានក៏មាន ។ ការខស្សាហ៍ព្យាយាមចំពោះការងារបែបនេះ បានធ្វើឲ្យមិត្តភក្តិដែលធ្វើការនៅក្នុងអង្គភាពជាមួយគ្នាចូលចិត្តនិងស្រឡាញ់គាត់ទាំងអស់និងមិនដែលត្រូវអង្គការស្តីបន្ទោសឡើយ រហូតដល់មិត្តនារីនៅក្នុងអង្គភាពខ្លះបានយកគំរូតាមតាមគាត់ទៀតផង ។ ជាក់ស្តែង នៅពេលដែល ភិរម្យ ដាំបានត្រកួន ត្រប់ ត្រសក់ស្រូវ ននោងឬឃ្លោក គាត់តែងតែយករបស់ទាំងអស់នេះទៅដាក់ជារបស់រួមជានិច្ច ។

ផ្ទុយទៅវិញ ទោះបីជាការងាររបស់គាត់ល្អក៏ដោយ ក៏ប្រធានក្រុមឈ្មោះ ទៀង តែងតែមានគំនិតចង់ផ្លាស់គាត់ឲ្យទៅរស់នៅកន្លែងផ្សេងដដែល ហើយក្រោមការឃ្លាំមើលរបស់អង្គការជានិច្ច ព្រោះប្រវត្តិរូបរបស់គាត់មានឪពុកត្រូវអង្គការយកទៅរៀនសូត្រ ។ ភិរម្យ បានរៀបរាប់ថា អ្នកដែលត្រូវអង្គការហៅទៅ អ្នកនោះប្រាកដជាបាត់ខ្លួនជាមិនខាន ។ ដូច្នេះ នៅលើកចុងក្រោយ ភិរម្យ បាននិយាយអង្វរ ទៀង ដែលជាប្រធានក្រុមថា «បងអើយ! បងឯងយកខ្ញុំទៅណា ឲ្យខ្ញុំធ្វើយ៉ាងម៉េចទៀតទៅ បើរាល់ថ្ងៃខ្ញុំតស៊ូនិងខំធ្វើការណាស់ ទោះបីជាឪពុកខ្ញុំជាខ្មាំងមែន ក៏ខ្ញុំបែងចែកវណ្ណៈច្បាស់លាស់ដែរ ខ្ញុំមិនធ្វើខ្មាំងដូចឪពុករបស់ខ្ញុំទេ ។ បើសិនជាខ្ញុំរស់នៅជាមួយអង្គការ គឺខ្ញុំគោរពអង្គការហើយ ។ ចំណែកសីលធម៌រស់នៅនិងការនិយាយស្តីរបស់ខ្ញុំក៏ល្អ ដោយខ្ញុំមិនដែលលួចរបស់របរអង្គការទេ» ។ ភិរម្យ បានរៀបរាប់ថា គាត់មានជីវិតរហូតដល់សព្វថ្ងៃប្រហែលជាគុណសម្បត្តិនិងចិត្តធម៌របស់ប្រធានអង្គភាព ទើបធ្វើឲ្យគាត់រួចខ្លួនពីសេចក្តីស្លាប់ ។

នៅឆ្នាំ១៩៧៩ ភិរម្យ បានត្រឡប់មករកម្តាយរបស់គាត់នៅស្រុកសំបូរវិញ ។ ពេលមកដល់ ភិរម្យ ក៏បានរៀបការជាមួយបុរសម្នាក់ដែលម្តាយរបស់គាត់រៀបចំឲ្យដោយសារតែខ្លាចខ្មែរក្រហមកៀរចូលព្រៃវិញ ។ អាពាហ៍ពិពាហ៍របស់គាត់មិនបានរៀបចំឲ្យអធិកអធមទេ គឺគ្រាន់តែមានធ្វើសម្លម្ជូរដើមចេកទទួលភ្ញៀវប៉ុណ្ណោះ ។ គាត់បានរៀបរាប់បន្តថា ក្រោយពីគាត់រៀបការមិនបានប៉ុន្មានថ្ងៃផង ស្រាប់តែមានការជីករណ្តៅដើម្បីយកមនុស្សទៅសម្លាប់ចោល ។ ប៉ុន្តែសំណាងល្អ នៅយប់នោះវៀតណាមក៏ចូលមករំដោះដល់តំបន់នេះតែម្តង ។ ភិរម្យ សប្បាយចិត្តជាខ្លាំងដែលដែនការរបស់ខ្មែរក្រហមបរាជ័យ ប៉ុន្តែគាត់អាណិតប្អូនស្រីរបស់គាត់ ឡុង ពិដោរ ណាស់ ដោយសារតែគាត់បានទទួលដំណឹងពីមិត្តភក្តិដែលធ្វើការជាមួយនឹងប្អូនស្រីរបស់គាត់ថា ពិដោរ ត្រូវខ្មែរក្រហមសម្លាប់បាត់ហើយ ។ មិត្តភក្តិបានរៀបរាប់ពីហេតុការណ៍នោះថា «ពិដោរ លុតជង្គង់អង្វរខ្មែរក្រហមកុំឲ្យសម្លាប់ដែរ ប៉ុន្តែខ្មែរក្រហមមិនស្តាប់ពាក្យទាំងនោះទេ រួចក៏វាយបំបាក់-កប្អូនស្រីរបស់គាត់» ។ បន្ទាប់ពីរៀបរាប់រួច មិត្តភក្តិរបស់ប្អូនស្រីគាត់ក៏ហុចរបស់ដែលសល់ពី ពិដោរ ឲ្យគាត់ ដោយក្នុងនោះមានកាតាបនិងសំបុត្រមួយច្បាប់សរសេរផ្ញើមកថា «...នឹកបងឯង ខ្ញុំផ្ញើក្រមានិងសៀវភៅមួយក្បាលមកឲ្យបងឯង» ។

## ដឹងដំណឹងពីឪពុក

នៅឆ្នាំ១៩៨០ ក្រោយពីមានការអនុញ្ញាតឲ្យចូលមើលសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង មានប្រជាជនរាប់ម៉ឺននាក់បាននាំគ្នាចូលទៅទីនោះដើម្បីស្វែងរកសាច់ញាតិរបស់ខ្លួនដែលបានបាត់ខ្លួន ។ ពេលទៅដល់ទីនោះដំបូង ប្អូនៗរបស់ ភិរម្យ ក៏នាំគ្នាដើរទៅមើលរូបថតដែលមាននៅតាមអគារ ។ ពេលនោះ ប្អូនរបស់គាត់អាយុទើបតែ១១ឬ១២ឆ្នាំ ក៏ប្រទះឃើញរូបថតឪពុកដែលមានស្នាមញញឹមពព្រាយ ។ ក្រោយពីប្អូនរបស់គាត់យកដំណឹងអំពីការស្លាប់នេះទៅប្រាប់សមាជិកក្រុមគ្រួសារដែលមិនបានឃើញ ម្តាយរបស់គាត់ស្រាប់តែស្រក់ទឹកភ្នែក ព្រោះរឿង

នេះបានប៉ះពាល់ដល់អារម្មណ៍របស់ម្តាយគាត់ជាខ្លាំង រហូតមកដល់សព្វថ្ងៃនេះម្តាយរបស់គាត់នៅតែមិនហ៊ានទៅទស្សនាគុកទួលស្លែងដដែល ។ ដោយសារការស្លាប់របស់ ឡុង យៀង ដែលជាប្តីនិងជាឪពុកដ៏ល្អនៅក្នុងគ្រួសារ ភិរម្យ បានរៀបរាប់ថា «ទោះបីជាម្តាយរបស់ខ្ញុំឃើញ ឌុច ត្រូវបានតុលាការកាត់ទោសឲ្យជាប់គុករយៈពេលយូរឆ្នាំក៏ដោយ ក៏ម្តាយរបស់ខ្ញុំមិនអាចអត់ឱនទោសឲ្យ ឌុច បានដែរ ។ ម្តាយរបស់ខ្ញុំនៅតែមិនអាចប្រឈមមុខនឹងការពិតនេះនៅឡើយ» ។

ចំណែក ភិរម្យ ក៏មិនខុសពីម្តាយរបស់គាត់ដែរ ទើបតែក្នុងពិធីបុណ្យភ្ជុំបិណ្ឌឆ្នាំ២០០៨ប៉ុណ្ណោះដែលគាត់ដាច់ចិត្តចូលទៅមើលរូបថតរបស់ឪពុកគាត់នៅទួលស្លែង ។ គ្រាន់តែចូលទៅដល់គាត់ហាក់ដូចជាមានអារម្មណ៍តក់ស្លុតជាខ្លាំង ។ បន្ទាប់មក គាត់ក៏យករូបថតរបស់ឪពុកគាត់មកផ្តិតយ៉ាងធំដើម្បីបង្ហាញឲ្យកូនៗរបស់គាត់បានឃើញនិងបញ្ជាក់ថារបបនេះហើយដែលបានឆក់ជីវិតគាត់ទៅ ។

## ប្រវត្តិរូប ឡុង យៀង

ដំបូង ឡុង យៀង ធ្វើការនៅពេទ្យស្លូវៀត ក្រោយមកទើបផ្លាស់ទៅធ្វើការនៅពេទ្យអង្គឌួង ។ ក្រោយពីខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ ឡុង យៀង ទៅរស់នៅខេត្តបាត់ដំបងនៅឆ្នាំ១៩៧៦ អង្គការក៏បានចាប់ខ្លួនគាត់ ។ តាមរយៈឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឡុង យៀង ត្រូវបញ្ជូនចូលមកស-២១ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ដោយដាក់ថា «ចាប់ខ្លួនពីខេត្តបាត់ដំបង» ។

## កូនចាំជាតិ

នៅខែមេសា ឆ្នាំ១៩៨០ ភិរម្យ កើតបានកូនប្រុសម្នាក់ឈ្មោះ ទេព ភីរក្ស ។ គ្រាន់តែ ភិរក្ស ចាប់ផ្តើមចេះនិយាយភ្លាម ភិរម្យ មានការងឿងឆ្ងល់ជាខ្លាំង ព្រោះមិនដឹងកូនចង់និយាយអំពីអ្វីដោយឃើញតែវាទះក្បាលពោះខ្លួនឯង ។ ក្រោយពេល ភិរក្ស ធំបន្តិច ហើយអាចនិយាយបាន ភិរក្ស ស្រាប់តែនិយាយប្រាប់ថា «ប្រពន្ធរបស់អូន (ភិរក្ស) ឈ្មោះ វ៉ែម» ដែលឈ្មោះនេះជាឈ្មោះរបស់ម្តាយ ភិរម្យ ។ ពាក្យទាំងអស់ធ្វើឲ្យគាត់ងឿងឆ្ងល់ជាខ្លាំង រួចក៏សួរថាកូនឯងមកពីណា? ពេលនោះ កូនរបស់គាត់ក៏ឆ្លើយថា


ទេព ភិរក្ស

«ម៉ាក់ហ្នឹងជាកូនទេ កាលពីជាតិមុន» ។ ភិរម្យ នៅតែមិនអស់ចិត្តរួចសួរបន្តទៀតថា «គេសម្លាប់កូននៅឯណា?» កូនរបស់គាត់ហាក់ដូចជាចាំជាតិ រួចឆ្លើយថានៅសាលាស្វាយ ដែលកាលណោះគេហៅថា «សាលាទួលស្វាយព្រៃ» ។

ថ្ងៃក្រោយមកទៀត នៅពេលដែលកូនរបស់គាត់អង្គុយលេង ស្រាប់តែកូនរបស់គាត់ទៅទាញខ្សែភ្លើងដែលគាត់ចងម៉ូទ័រម៉ាស៊ីនដេរ រួចយកមកចងជើងរបស់ខ្លួនឯង ហើយស្រែកថា «ចងជើងអូនៗ (ភិរក្ស) ចាប់អូនជ្រមុជទឹក រួចក៏ធ្វើជាឈ្លក់ទឹក» ។ ប៉ុន្មានថ្ងៃក្រោយ កូនរបស់គាត់ក៏ចង្អុលទៅទូរទឹកកក និងទ្វារបន្ទប់របស់គាត់ និងធុងសាំង រួចនិយាយថា មុជទឹកអូន (ភិរក្ស) នឹងធុងសាំង ។

លើសពីនេះទៅទៀត ភិរម្យ បានរៀបរាប់ឲ្យដឹងថា «ពេលពេលខ្លះកូនរបស់គាត់យល់សប្តិឃើញគេកំពុងតែវាយធ្វើទារុណកម្មរហូតឈឺក្រហាយពេញខ្លួន» ។ ពេលគាត់ព្យាយាមសួរទៅកូនថា «តើគេធ្វើបាបម៉េចខ្លះ?» កូនរបស់គាត់ឆ្លើយថា «ឈឺណាស់ម៉ាក់ហើយក្រហាយពេញខ្លួនទៀត» ។ ប៉ុន្តែក្រោយមក គាត់ក៏លែងសួរកូនរបស់គាត់អំពីរឿងនេះទៀត ដោយសារពេលរំឭកអំពីរឿងនេះម្តងៗ កូនរបស់គាត់តែងតែឈឺជានិច្ច ។ ភិរម្យ នៅចាំបានថា មានម្តងនោះ ភិរក្ស ព្យាយាមរកនឹក ស្រាប់តែធ្លាក់ខ្លួនឈឺធ្ងន់រហូតដល់បញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។ តាំងពីថ្ងៃនោះមក ភិរម្យ មិនដែលនិយាយរឿងនេះទៀតទេ ។

សព្វថ្ងៃនេះ ពេលដែល ភិរម្យ រំឭកអំពីរបបខ្មែរក្រហម និងនិយាយអំពីសវនាការកាត់ទោស ឌុច កូនរបស់គាត់ស្រាប់តែប្រាប់គាត់ថា «ម៉ាក់! កូនចាំរឿងដែលម៉ាក់ប្រាប់នៅពេលកូនអាយុ៦ឆ្នាំ» ។ ភិរម្យ ស្មានថាកូនរបស់គាត់ភ្លេចអស់ទៅហើយអំពីរឿងទាំងអស់នោះ ប៉ុន្តែមិននឹកស្មានថា រឿងនេះនៅតែដក់ជាប់ក្នុងចិត្តរបស់កូនគាត់ជានិច្ច ។ ទោះបីជាកូនរបស់គាត់មិនមានពេលវេលាដើម្បីតាមដានសវនាការក៏ដោយ ក៏កូនរបស់គាត់បានរៀបរាប់ថា «គាំទ្រចំពោះការបង្កើតតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនេះដែរ» ។

**គាំទ្រចំពោះការកាត់ទោស ឌុច**

ទោះបីជា ភិរម្យ មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី



គ្រួសាររបស់ ឡុង ភិរម្យ

ដើម្បីប្តឹងទាមទារសំណងពី ឌុច ដែលបានយកឪពុករបស់គាត់ទៅសម្លាប់ក៏ដោយ ប៉ុន្តែក្នុងនាមជាជនរងគ្រោះម្នាក់នៅក្នុងរបបនោះ ភិរម្យ សូមគាំទ្រចំពោះការកាត់ទោស ឌុច ដែលនៅក្រោមការគ្រប់គ្រងរបស់គាត់បានសម្លាប់មនុស្សអស់ប្រហែល១៤០០០នាក់ ។ ភិរម្យ បានរៀបរាប់ថា នៅថ្ងៃដែលគាត់បានតាមដានសវនាការដំបូង គាត់ស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន រហូតដល់ធ្លាក់ខ្លួនឈឺទៀត ។ ប៉ុន្តែការតាមដាននេះក៏បានធ្វើឲ្យគាត់មានទឹកចិត្តក្លាហានក្នុងការនិយាយផងដែរ ព្រោះវាធ្វើឲ្យគាត់បានរសាយពីកំហឹងឈឺចាប់និងធ្វើឲ្យគាត់រឹងប៉ឹងថែមទៀត ។ លើសពីនេះទៅទៀត គាត់គាំទ្រចំពោះអ្នកដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលបានប្តឹងទាមទារសំណងពី ឌុច ។ ភិរម្យ បន្តថា «ខ្ញុំយល់ស្របចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលប្រាប់អង្គសវនាការថាមិនអាចអត់ឱនទោសឲ្យ ឌុច ហើយក៏មិនបើកទ្វារសម្រាប់ ឌុច ដែរ ។ ខ្ញុំមិនទទួលពាក្យសុំទោសរបស់ ឌុច ជាដាច់ខាត» ។ ភិរម្យ មិនជឿថា ឌុច ជាមនុស្សដែលធ្វើការក្រោមការគាបសង្កត់នោះទេ និងគាត់ជាមនុស្សដែលមានចិត្តឃោរឃៅ ។ ដូច្នេះ ភិរម្យ ក៏មិនទទួលការសុំអធ្យាស្រ័យពី ឌុច ដែរ ព្រោះសព្វថ្ងៃនេះការស្លាប់របស់ឪពុកគាត់នៅតែជារឿងមួយដែលមិនអាចបំភ្លេចបានជានិច្ច ។ ការកាត់ទោស ឌុច គឺស័ក្តិសមនឹងទោសកំហុសរបស់គាត់បំផុត ។

ទោះបីជារយៈពេល៣០ឆ្នាំបានកន្លងផុតទៅក៏ដោយ ក៏ ភិរម្យ នៅតែចង់ដឹងចម្លើយថា «តើឪពុកគាត់ឃុំនៅបន្ទប់ណា? តើឪពុករបស់គាត់ឆ្លើយយ៉ាងម៉េចខ្លះ? តើគាត់ទទួលទារុណកម្មអ្វីខ្លះ? តើមានបានជ្រមុជទឹកឪពុកគាត់ដូចអ្វីដែលកូនរបស់គាត់រៀបរាប់ដែរឬទេ?» ភិរម្យ ចង់សួរទៅ ឌុច ថាតើគាត់គិតយ៉ាងម៉េចដែរនៅពេលសព្វថ្ងៃនេះដែលគាត់សម្លាប់មនុស្សអស់ជាច្រើននាក់ ហើយតុលាការកាត់ក្តីឲ្យនៅមានកន្លែងដេកស្រួលទៀត? ចុះឪពុករបស់គាត់និងជនរងគ្រោះដទៃទៀតត្រូវបានធ្វើទារុណកម្មដោយមិនមានសវនាការណាមួយកាត់សេចក្តីឲ្យនោះ តើគិតយ៉ាងម៉េចដែរ?

ភិរម្យ ពេញចិត្តយ៉ាងខ្លាំងដែលតុលាការត្រូវបានបង្កើតឡើងដើម្បីកាត់ទោសលើមេដឹកនាំដែលទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបនេះ ដើម្បីទុកជាគំរូដល់ប្រជាជនខ្មែរយើងបានដឹង ជាពិសេសប្រាប់ពិភពលោកថាប្រជាជនខ្មែររងគ្រោះខ្លាំងណាស់ ។

ចាប់តាំងពី ភិរម្យ បានរៀបរាប់អំពីរឿងនេះមក គាត់មានអារម្មណ៍ធូរស្រាលជាខ្លាំង ។ ប៉ុន្តែ ភិរម្យ នៅតែមានអារម្មណ៍ខឹងនឹង ឌុច ដដែល ទោះបីជាតុលាការកាត់ទោសគាត់ឲ្យជាប់គុករយៈពេលយូរក៏ដោយ ។

**គាត លក្ខិណា**

# យិត សុភក្រ្ត : ចង់ផ្សះផ្សាជាមួយជនដៃដល់

យិត សុភក្រ្ត អាយុ៣៧ឆ្នាំ ជាអតីតគ្រូបង្រៀនអក្សរសាស្រ្តខ្មែរនៅអនុវិទ្យាល័យក្តុលដូនទាវ ខេត្តបាត់ដំបង ហើយសព្វថ្ងៃជាមន្រ្តីនៅនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ។ សុភក្រ្ត មានបងប្អូនប្រុសចំនួនពីរនាក់ឈ្មោះ យិត សុភា (ស្លាប់) និង យិត សុភ័ណ (ស្លាប់) មានឪពុកឈ្មោះ យិត ហៃ (ស្លាប់) ជាអតីតប្រធានប៉ុស្តិ៍នៅផ្សារដើមថ្កូវ និងម្តាយឈ្មោះ យុន សៀន ជាមេផ្ទះ ។ បច្ចុប្បន្ន សុភក្រ្ត រស់នៅរាជធានីភ្នំពេញ ។

## រំឭកប្រវត្តិកាលពី៣៥ឆ្នាំមុន

នៅដើមឆ្នាំ១៩៧៥ ពេលដែល សុភក្រ្ត មានអាយុទើបតែ៥ឆ្នាំ ឪពុកម្តាយរបស់គាត់បានហាមមិនឲ្យគាត់ដើរលេងឬចេញទៅណាឆ្ងាយពីផ្ទះឡើយ ពីព្រោះទីនោះស្ថិតនៅក្បែរផ្សារដើមថ្កូវដែលជាតំបន់កំពុងច្បាំងគ្នា ។ ដោយសារតែមានការប្រយុទ្ធនិងបាញ់សម្លាប់គ្នានៅទីនោះ គ្រួសាររបស់ សុភក្រ្ត និងយាយតា ព្រមទាំងពូមីងខាងឪពុករបស់គាត់ក៏បានប្តូរមករស់នៅផ្ទះរបស់អ៊ំខាងឪពុកដែលស្ថិតនៅជិតសាលារៀនបាក់ទូកវិញ ។ នៅព្រឹកថ្ងៃមួយប្រហែលជាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយសារតែមានទាហានបាញ់សម្លាប់គ្នា ហើយបង្ខំឲ្យប្រជាជនចាកចេញពីផ្ទះ យាយតា ពូមីង និងឪពុកម្តាយរបស់ សុភក្រ្ត ក៏លើកអីវ៉ាន់ដែលបានរៀបចំទុករួចជាស្រេចដាក់លើរថយន្ត រួចបើកចេញទៅកាន់ផ្លូវជាតិលេខ៣ឆ្ពោះទៅស្រុកកំណើតរបស់ជីតាគាត់នៅខេត្តកំពត ។ នៅតាមផ្លូវ ដោយសារតែប្រជាជននាំគ្នាប្រជ្រៀតចេញពីទីក្រុងច្រើនពេកនិងឃើញកងទ័ពខ្មែរក្រហមកំពុងឆែកឆេរអីវ៉ាន់ផងនោះ គ្រួសារ របស់ សុភក្រ្ត ក៏លើកយកអីវ៉ាន់សំខាន់ៗដូចជា ចាន ឆ្នាំង និង សម្លៀកបំពាក់ចាស់ៗចេញពីរថយន្ត ដោយពូៗរបស់គាត់ដើរកាប់មែកឈើធ្វើជាគាវសម្រាប់អូសអីវ៉ាន់ ចំណែកឪពុករបស់ សុភក្រ្ត បានព្រនាក់គាត់នៅលើស្មារហូត ។ ពេលកំពុងធ្វើដំណើរ ដោយឃើញមនុស្សរបួសនិងស្លាប់នៅតាមផ្លូវច្រើនពេក ឪពុក សុភក្រ្ត បានយកដៃមកខ្ទប់ភ្នែករបស់គាត់កុំឲ្យឃើញហេតុការណ៍ទាំងនោះ ។ នៅក្រោមដើមឈើមួយដើមក្បែរបឹងក្រោយពីសម្រាកហូបបាយរួច ឪពុករបស់ សុភក្រ្ត ក៏ប្រញាប់ប្រញាល់បន្តដំណើរទៅមុខទៀត ព្រោះតែឃើញសាកសពជាច្រើនអណ្តែតនៅក្នុងបឹងមួយនេះដែល សុភក្រ្ត មិនស្គាល់ឈ្មោះ ហើយឃើញខ្មែរក្រហមចងមនុស្សយកទៅសម្លាប់ ។ ធ្វើដំណើរអស់រយៈពេលជិតមួយខែ ទើបក្រុមគ្រួសាររបស់ សុភក្រ្ត បានទៅដល់ស្រុកកំណើតខាងជីតារបស់គាត់ដែលស្ថិតនៅភូមិពោធិ៍ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។

## ខ្មែរក្រហមយកឪពុកទៅរៀនសូត្រ

ពេលទៅដល់ស្រុកអង្គរជ័យ ក្រុមគ្រួសាររបស់ សុភក្រ្ត គ្មានផ្ទះសម្រាប់រស់នៅទេ ដោយត្រូវសុំផ្ទះរបស់បងប្អូនស្នាក់នៅជើងភ្នំជ្រោះផ្អោងបណ្តោះអាសន្នសិន ព្រោះជីតារបស់គាត់បានចាកចេញពីផ្ទះយូរហើយ នៅពេលដែលខ្មែរក្រហមដណ្តើមយកបានភូមិនោះតាំងពីឆ្នាំ១៩៧០ម្ល៉េះ ។ នៅទីនេះ ការរស់នៅរបស់ប្រជាជនមានសភាពធម្មតាទេ ដោយទាំងអស់គ្នាចេញទៅធ្វើស្រែចម្ការនិងដាំបាយហូបរៀងៗខ្លួន ។ ក្រោយពីខ្មែរក្រហមបាន


ទេស ម៉ារ៉ែម

អនុញ្ញាតឲ្យគ្រួសាររបស់ សុភក្ត្រ រកឈើដើម្បីសង់ផ្ទះស្នាក់នៅ រួចមក ប្រហែលជាកន្លះខែក្រោយ ខ្មែរក្រហមក៏បានរៀបចំជាក្រុមការងារ ដោយចាត់តាំងឲ្យឪពុករបស់គាត់ធ្វើជាអ្នកធាក់រហាត់ទឹក នៅបឹងត្នោតចាង ។ ធាក់រហាត់ទឹកបានប្រហែលជិតមួយខែ ប្រធានភូមិឈ្មោះ នាង ដែលជាសាច់ញាតិ ហើយក៏មានកូនធ្លាប់ធ្វើការជាមួយឪពុករបស់ សុភក្ត្រ បានមកប្រាប់ឪពុករបស់ សុភក្ត្រ ថា «អង្គការត្រូវការអ្នកដែលមានចំណេះដឹងយកទៅរៀនសូត្រ ដើម្បីជួយបម្រើការងាររបស់អង្គការ» ។ ចាប់តាំងពីពេលចេញទៅរៀនសូត្រ ឪពុករបស់ សុភក្ត្រ មិនដែលឃើញត្រឡប់មកវិញទេ ។ ចំណែកម្តាយ សុភក្ត្រ យំរហូតដោយសារតែមិនឃើញប្តីត្រឡប់មកវិញ ។ មានថ្ងៃមួយប្រហែលជានៅថ្ងៃបុណ្យខួបជ័យជម្នះ ១៧មេសា ខ្មែរក្រហមបានហៅគ្រួសារដែលបានទៅរៀនសូត្រមកជួបជុំគ្នា ។ ដោយសារតែឃើញអ្នកដែលទៅរៀនសូត្របានត្រឡប់មកវិញគ្រប់ៗគ្នា លើកលែងតែឪពុករបស់ សុភក្ត្រ ម្នាក់ប៉ុណ្ណោះ ម្តាយរបស់ សុភក្ត្រ ក៏បានទៅសួរដំណឹងប្តីរបស់គាត់ពីប្រធានភូមិដែលត្រូវជាបងប្អូន ។ ប៉ុន្តែគាត់មិនឆ្លើយតបអ្វីទាំងអស់ បែរជាព្យាយាមនិយាយបង្វែងដានថា «ម្តងគេយកទៅនេះ ម្តងគេយកទៅនោះ» ។ លុះមួយរយៈក្រោយមក ទើបគេឲ្យដំណឹងថា



យិត សុភក្ត្រ

ឪពុករបស់ សុភក្ត្រ ត្រូវខ្មែរក្រហមយកទៅសម្លាប់ហើយ ។

## ពូម្នាក់ទៀតត្រូវខ្មែរក្រហមសម្លាប់

ប្រហែលជាបីបួនខែក្រោយពីឪពុក សុភក្ត្រ ត្រូវបានសម្លាប់ ខ្មែរក្រហមក៏រៀបចំប្រជាជនឲ្យរស់នៅក្នុងផ្ទះដាច់ដោយឡែកពីគ្នា នៅក្នុងភូមិជ្រោះផ្គាង ។ បន្ទាប់មកខ្មែរក្រហមចាប់ផ្តើមបែងចែកការងារឲ្យធ្វើរៀងៗខ្លួន ។ រស់នៅទីនោះបានរយៈពេលបីខែ ខ្មែរក្រហមក៏ផ្លាស់គ្រួសាររបស់ សុភក្ត្រ និងគ្រួសាររបស់យាយតានិងពូមីងទាំងអស់ឲ្យមករស់នៅក្នុងឃុំជីខ្មារ ស្រុកទ្រាំង ខេត្តតាកែវ តំបន់១៣វិញ ។ ដោយសារការធ្វើដំណើរមានរយៈពេលយូរ ហើយយប់ផង ដូច្នេះខ្មែរក្រហមបានឲ្យទៅរស់នៅក្នុងផ្ទះជាមួយប្រជាជនមូលដ្ឋានជាបណ្តោះអាសន្នសិនដោយមិនទាន់បែងចែកប្រជាជនថ្មីឬប្រជាជនចាស់នៅឡើយទេ ។ នៅព្រឹកថ្ងៃបន្ទាប់ពេលកំពុងបន្តដំណើរទៅមុខទៀត ស្រាប់តែពូនិងមីងរបស់ សុភក្ត្រ ឈប់រទេះដើម្បីហូបបាយ ពេលនោះប្រធានឈ្លបដែលរួមដំណើរជាមួយបានចាប់ពូរបស់ សុភក្ត្រ ឈ្មោះ យិត ហឿន យកទៅសម្លាប់នៅព្រៃខាងក្រោយជាបន្ទាន់ ។ ពូរបស់ សុភក្ត្រ ម្នាក់ទៀតស្រែកយំយ៉ាងខ្លាំង ហើយអង្វរឲ្យយាយតារបស់ សុភក្ត្រ ជួយប្អូនរបស់គាត់ផង ។ ក្រោយហេតុការណ៍នោះ ប្រជាជនដែលរួមដំណើរជាមួយនាំគ្នាជ្រួលច្របល់ ។ ពេលទៅដល់ភូមិ ខ្មែរក្រហមបានរៀបចំផ្ទះមួយនៅជិតវត្តជួសដែលគេបានសង់រួចហើយ សម្រាប់ដាក់ប្រជាជន១៧មេសា រួមទាំងគ្រួសាររបស់ សុភក្ត្រ ផង ។ ចំណែកប្អូនរបស់ឪពុក សុភក្ត្រ ពីរគ្រួសារទៀត ខ្មែរក្រហមឲ្យទៅរស់នៅឃុំជីខ្មារដែរ ។

## ការស្លាប់របស់ប្អូនទាំងពីរនាក់

ដោយសារ សុភក្ត្រ នៅក្មេងនៅឡើយ អង្គការក៏បានចាត់តាំងឲ្យគាត់និងប្អូនៗ ទៅរស់នៅក្នុងកងជាមួយយាយៗដើម្បីឲ្យយាយៗជួយមើលថែ ពេលម្តាយរបស់ សុភក្ត្រ ធ្វើការ ។ នៅឆ្នាំ១៩៧៧ ប្អូនប្រុសរបស់ សុភក្ត្រ កើតជំងឺហើម ។ ដូច្នេះ ម្តាយរបស់ សុភក្ត្រ ក៏បានសុំច្បាប់អង្គការចំនួន១៥ថ្ងៃ ដើម្បីយកកូនទៅព្យាបាលនៅមន្ទីរពេទ្យវត្តត្រពាំងខ្ទុរ ខេត្តកំពត ។ ក្រោយពីបានមើលថែទាំកូនបានប្រហែល១៥ថ្ងៃ ម្តាយរបស់ សុភក្ត្រ ក៏ចាប់ផ្តើមដឹងច្បាស់ថា កូនរបស់គាត់ប្រហែលជាមិនរស់ទេ ព្រោះ

ជំងឺរបស់កូនគាត់កាន់តែធ្ងន់ទៅៗ ហើយការកំណត់ពេលសុំច្បាប់ចប់ទៀត គឺមានតែសម្រេចចិត្តផ្ញើកូនរបស់គាត់ជាមួយនឹងគ្រូពេទ្យប៉ុណ្ណោះ ។ ត្រឡប់មកសហករណ៍បានប្រហែល៥ថ្ងៃ ខាងមន្ទីរពេទ្យក៏បានផ្តល់ដំណឹងឲ្យម្តាយរបស់ សុភក្រ្ត ថា កូនរបស់គាត់ស្លាប់ហើយ ។ គ្រាន់តែឮថាប្អូនរបស់ខ្លួនស្លាប់ភ្លាម សុភក្រ្ត យំរហូតដោយសារអាណិតប្អូន ហើយចេះតែដេញសួរម្តាយរបស់ខ្លួនថា «មូលហេតុអ្វីបានជាប្អូនស្លាប់?» ម្តាយរបស់ សុភក្រ្ត ក៏យកដៃខ្ទប់មាត់កូន រួចប្រាប់ថា «កូនឯងកុំយំ ប្រយ័ត្នឈ្លបលួចស្តាប់ឮ ប្អូនកូនឯងស្លាប់ដោយសារជំងឺហើម» ។ ទោះបីជាដឹងថាកូនរបស់ខ្លួនស្លាប់ក៏ដោយ ក៏ម្តាយរបស់ សុភក្រ្ត មិនហ៊ានសុំច្បាប់អង្គការដើម្បីយកកូនមកធ្វើបុណ្យឬខុទ្ទិសកុសលឲ្យដែរ ។ ក្រោយមក ប្អូនម្នាក់ទៀតក៏កើតជំងឺហើមដូចគ្នា ហើយក៏ស្លាប់បន្ទាប់ពីបញ្ជូនមកដល់មន្ទីរពេទ្យវត្តត្រពាំងខ្វារមួយថ្ងៃ ។

## ទឹកចិត្តរបស់ម្តាយចំពោះកូន

ដោយខ្លាច សុភក្រ្ត មានជំងឺហើមហើយស្លាប់ដូចជាប្អូនៗទៀត ម្តាយរបស់ សុភក្រ្ត ចាប់ផ្តើមយកមាសប្រាក់ដែលនៅសេសសល់ទៅលួចប្តូរយកអង្ករនិងស្ករមករំងាស់ទុកឲ្យ សុភក្រ្ត ហូប ។ នៅយប់មួយ សុភក្រ្ត គេងមិនលក់ ហើយចេះតែស្រែកថា «ម៉ាក់ៗ» ស្រាប់តែម្តាយរបស់ សុភក្រ្ត ខ្សឹបប្រាប់កូនវិញថា «កូនឯងកុំហៅថា ម៉ាក់អីចឹង គេអត់ឲ្យហៅទេ ត្រូវហៅថា ម៉ែវិញ» ។ សុភក្រ្ត ក៏និយាយប្រាប់ថា «ម៉ែ! ខ្ញុំគេងទៅដូចជារាងស្រាលម៉េចអីចឹងទេ» ។ ឮដូច្នេះ ម្តាយ សុភក្រ្ត ក៏ក្រោកទៅដួសទឹកស្ករឲ្យកូនបៀម ។ ប៉ុន្តែដោយសារ សុភក្រ្ត អស់កម្លាំងខ្លាំងពេក គាត់ចេះតែរវើរវាយទាររករបស់ហូបរហូតទាល់តែគេងលក់ ។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានផ្លាស់ម្តាយរបស់ សុភក្រ្ត មកធ្វើជាកងចល័តនៅកន្លែងផ្សេងវិញ ដែលស្ថិតនៅឆ្ងាយពីតំបន់ដែល សុភក្រ្ត រស់នៅ ។ ដោយសារមិនធ្លាប់រស់នៅបែកឆ្ងាយពីម្តាយ សុភក្រ្ត យំរកម្តាយរហូតដល់ជីដូនរបស់គាត់សម្រេចចិត្តផ្ញើឲ្យគាត់ទៅជាមួយអ្នកបរទេះគោមករកម្តាយនៅតំបន់ដែលគាត់កំពុងធ្វើការ ។ ពេលទៅដល់ទីនោះភ្លាម សុភក្រ្ត បានរស់នៅជាមួយម្តាយបានបីបួនយប់ ។ នៅទីនោះ រៀងរាល់យប់ សុភក្រ្ត តែងតែអង្គុយជជែកលេងជាមួយម្តាយ ហើយក៏បានឃើញភ្លើងដែលគេបាញ់គ្នានៅតាមព្រំប្រទល់ ។ នៅពេលនោះ ខ្មែរក្រហមចាប់ផ្តើមរករឿងម្តាយរបស់ សុភក្រ្ត ដោយចោទថា «ម៉េចយកកូនមកលាក់ទុកអីចឹង?» ហើយចង់យកម្តាយរបស់គាត់ទៅសម្លាប់ទៀត ។ ក្រោយមក ម្តាយរបស់គាត់បានទៅទាក់ទងជាមួយនឹងកងឈ្លបឲ្យកូនរបស់គាត់បានធ្វើជាអ្នកមើលគោដងដើម្បីកុំឲ្យគាត់និងកូនបែកគ្នាទៀត ។ ម្យ៉ាងដោយសារនៅតំបន់នេះសម្បូរត្រីហូប ហើយការហូបចុកមិនសូវតឹងរ៉ឹងផង គាត់មិនចង់ឲ្យកូនត្រឡប់ទៅវិញទេ ។ ចាប់តាំងពីពេលនោះមក សុភក្រ្ត ធ្វើការជាមួយនឹងកងឈ្លបរហូត ។

## ព្រឹត្តិការណ៍ពេលកងទ័ពវៀតណាមចូល

រស់នៅទីនោះបានប្រហែលជាមួយខែ នៅចុងឆ្នាំ១៩៧៨ តំបន់អន្លង់ទៀនត្រូវបានកងទ័ពវៀតណាមចូលមករំដោះទាំងយប់ ហើយប្រកាសថា «ឥឡូវអ្នកនៅអន្លង់ទៀន ត្រូវឡើងមកវិញទាំងអស់» ។ នៅយប់នោះ ម្តាយរបស់ សុភក្រ្ត ព្រមទាំងអ្នកភូមិទាំងអស់បានរត់ត្រឡប់មកភូមិចាស់វិញ ។ ពេលមកដល់ភ្លាម សុភក្រ្ត និងម្តាយបានទៅស្នាក់នៅក្នុងផ្ទះជាមួយនឹងយាយនៅភូមិជ្រៃ ឃុំជីខ្មារ ស្រុកទ្រាំង ខេត្តតាកែវ ដែលកាលនោះគាត់កំពុងធ្លាក់ខ្លួនឈឺដោយសារជំងឺស្លូតរើឡើងវិញរហូតដល់បាត់បង់ជីវិត ។ ប្រហែលជាប៉ុន្មានថ្ងៃក្រោយមក កងទ័ពវៀតណាមក៏បានវាយសម្រុកចូលតំបន់នេះទៀត ។ ក្រោយពីកងទ័ពវៀតណាមដកទ័ពត្រឡប់ទៅវិញមួយរយៈ ប្រធានភូមិនិងប្រធានកងបានយកចិត្តទុកដាក់ជាមួយប្រជាជនបានច្រើនជាងមុនរហូតដល់ សុភក្រ្ត និងម្តាយបានសម្រេចចិត្តបន្តរស់នៅទីនេះបន្តទៀត ។ ប៉ុន្តែក្រោយមកស្រាប់តែម្តាយរបស់ សុភក្រ្ត បានឮសួរដំណឹងពីប្រជាជនថា «ពួកយើងមួយសប្តាហ៍ទៀតស្លាប់អស់ហើយ ព្រោះភូមិមួយនោះគេកំពុងតែជីករណ្តៅ គេលែងឲ្យប្រជាជនចូលហើយ» ។ គ្រាន់តែឮដំណឹងនេះ ប្រជាជននាំគ្នាជ្រួលច្របល់ ហើយជំនុំគ្នាជារៀងរាល់ថ្ងៃ ។ ចាប់តាំងពីពេលនោះមក ម្តាយរបស់ សុភក្រ្ត មិនអនុញ្ញាតឲ្យ សុភក្រ្ត ទៅណាឆ្ងាយពីគាត់ឡើយ ទោះបីជាមេកងប្រាប់ឲ្យ សុភក្រ្ត ទៅរកស្រូវ ឬឃ្វាលគោក៏ដោយ ។ វេលាព្រឹកមួយនៅពេលដែលភ្ញាក់ពីគេងដោយសារនៅក្នុងភូមិឃើញសុទ្ធតែការភ្លើងធំនិងទាហានខ្មែរក្រហមគ្រប់ទីកន្លែង សុភក្រ្ត និងម្តាយមិន

ហ៊ានចេញទៅណា ឬក៏ទៅធ្វើការទេ ដោយនៅរង់ចាំរហូតដល់ម៉ោងវាយជួងហូបបាយតែម្តង ។ ពីមួយថ្ងៃទៅមួយថ្ងៃ សភាពការណ៍កាន់តែតានតឹងឡើងៗ ហើយដោយបងប្អូនផ្សេងទៀតស្លាប់អស់ហើយ ម្តាយរបស់ សុភក្រ្ត ក៏នាំគាត់រត់ចូលទៅពួននៅក្នុងអាងមួយដើម្បីគេចគ្រាប់កាំភ្លើង ។ ដោយមិនដឹងច្បាស់ថា កងទ័ពវៀតណាមអាចនឹងដកថយ ហើយខ្មែរក្រហមចាប់ផ្តើមដេញម្តងទៀត សុភក្រ្ត និងម្តាយក៏នាំគ្នារត់ទៅដល់ភូមិទន្លាប់ ស្រុកគីរីវង្ស ខេត្តតាកែវ ប៉ុន្តែត្រូវខ្មែរក្រហមកៀរត្រឡប់មកវិញ ។ ពេលនោះ កងទ័ពវៀតណាមក៏ចាប់ផ្តើមវាយត្រឡប់មកជាលើកទីពីរទៀត ។ ដោយឃើញសភាពការណ៍ស្ងប់ស្ងាត់ សុភក្រ្ត និងម្តាយព្រមទាំងប្រជាជនចំនួន១០គ្រួសារទៀតបានត្រឡប់មកកាន់ស្រុកគីរីវង្សវិញ ដោយបានចូលទៅស្នាក់ជុំគ្នានៅក្នុងផ្ទះធំមួយរបស់ខ្មែរក្រហម ។ នៅទីនោះ សុភក្រ្ត និងម្តាយបានដើរប្រមូលស្បៀងដូចជា ស្រូវ និងសម្ភារៈផ្សេងៗទៀតទុកសម្រាប់ហូប ។ កងទ័ពវៀតណាមបានឲ្យទឹកដោះគោ និងត្រីខកំប៉ុងចំនួនមួយឡាំងដល់ សុភក្រ្ត ទុកសម្រាប់ហូបតាមផ្លូវ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៩ គាត់ក៏បានសុំឡានទាហានវៀតណាមទៅជាមួយដើម្បីសួររកដំណឹងប្អូនស្រីរបស់គាត់នៅខេត្តកំពតដែលជាស្រុកកំណើតរបស់ជីតា ។ ក្រោយពីរកឃើញម្តាយរបស់ សុភក្រ្ត ក៏បាននាំគាត់មករស់នៅជាមួយនៅក្នុងស្រុកគីរីវង្សដែរ ។ នៅទីនោះបានមួយរយៈ ម្តាយរបស់ សុភក្រ្ត បានយក សុភក្រ្ត មកធ្វើតេស្តចូលរៀនថ្នាក់ទីបីនៅសាលាបឋមសិក្សាទន្លាប់ ។ នៅដើមឆ្នាំ១៩៨០ សុភក្រ្ត ម្តាយ និងម្តាយមីងបានប្តូរមករស់នៅក្នុងភូមិពោធិ៍ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពតវិញ ។ នៅទីនោះបានប្រហែលជាកន្លះឆ្នាំ សុភក្រ្ត និងម្តាយព្រមទាំងកូនចិញ្ចឹមរបស់គាត់ពីរនាក់ទៀតក៏ធ្វើដំណើរមករស់នៅក្នុងទីក្រុងភ្នំពេញតែម្តង ។ នៅទីនេះ រាជរដ្ឋាភិបាលបានឲ្យផ្ទះទៅម្តាយរបស់ សុភក្រ្ត រស់នៅមួយកន្លែង ដោយសារគាត់ជាស្ត្រីមេម៉ាយ ។

## ក្លាយជាគ្រូបង្រៀនប្រវត្តិដែលធ្លាប់ឆ្លងកាត់

ដោយសារការសិក្សារបស់ សុភក្រ្ត បានផ្អាកមួយរយៈ ម្តាយរបស់គាត់ក៏នាំគាត់ទៅចុះឈ្មោះចូលរៀនម្តងទៀតនៅសាលាបឋមសិក្សាទួលស្វាយព្រៃ ។ មួយឆ្នាំក្រោយមក ម្តាយរបស់ សុភក្រ្ត ក៏ផ្លាស់មករស់នៅខេត្តកំពតវិញ ដោយសារតំបន់ដែលគាត់រស់នៅមិនសូវមានសុវត្ថិភាព ។ ក្រោយពីរៀនចប់នៅថ្នាក់ទីដប់នៅវិទ្យាល័យជាស៊ីមអង្គរជ័យ សុភក្រ្ត ក៏បានប្តូរមករៀននៅសកលវិទ្យាល័យភូមិន្ទភ្នំពេញផ្នែកអក្សរសាស្ត្រខ្មែរវិញ ដោយសារនៅខេត្តដែលគាត់រស់នៅគ្មានសាលាសម្រាប់រៀនបន្ត ។ បន្ទាប់ពីបានរៀនបន្តនៅសាលាគរុកោសល្យនៅភ្នំពេញបានមួយឆ្នាំ សុភក្រ្ត បានចេញទៅបង្រៀននៅអនុវិទ្យាល័យក្តុលដូនទាវ ខេត្តបាត់ដំបង ។ នៅពេលបង្រៀននៅទីនោះ សុភក្រ្ត តែងតែនិយាយអំពីប្រវត្តិនិងការតស៊ូរបស់គាត់នៅសម័យខ្មែរក្រហមប្រាប់ដល់កូនសិស្សនៅចុងម៉ោងបង្រៀនជានិច្ច ។ បង្រៀនបានមួយរយៈ សុភក្រ្ត បានចូលធ្វើជាមន្ត្រីនៅនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ហើយក៏ត្រូវបានក្រសួងចាត់តាំងឲ្យចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្រៀនសៀវភៅកម្ពុជាប្រជាធិបតេយ្យ ។

ឆ្លងកាត់វគ្គបណ្តុះបណ្តាលនេះ សុភក្រ្ត មានអារម្មណ៍សប្បាយចិត្តជាខ្លាំង និងយល់ថាសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះល្អសម្រាប់សិស្សានុសិស្សដើម្បីរៀនសូត្រ ព្រោះធ្វើឲ្យសិស្សមានការយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួនជាពិសេសអប់រំឲ្យសិស្សមើលឃើញពីការដឹកនាំមិនល្អរបស់របបនេះនិងមិនត្រូវយកគំរូតាមនោះទេ ។ ដូច្នេះ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះគឺជាសារមួយប្រាប់ដល់ក្មេងៗជំនាន់ក្រោយកុំឲ្យធ្វើនយោបាយសម្លាប់ជាតិសាសន៍របស់ខ្លួនឯងបែបនេះទៀត ហើយចេះកសាងខ្លួនដើម្បីជួយស្តារសង្គមជាតិរបស់ខ្លួនឡើងវិញ ហើយនាំគ្នាបញ្ចប់កំហឹងនិងការរើសអើងជាតិសាសន៍ខ្លួនឯង ក៏ដូចជាជាតិសាសន៍ដទៃ ។ សុភក្រ្ត សំណូមពរឲ្យបញ្ចប់ការរើសអើងកូនរបស់អតីតកម្មាភិបាលខ្មែរក្រហម ហើយងាកមកចងមិត្តភាពជាមួយគ្នាវិញ ដែលវាជាកត្តាមួយនាំទៅរកការផ្សះផ្សាជាតិក្នុងសង្គមកម្ពុជា ។

ចុងក្រោយ សុភក្រ្ត សំណូមពរឲ្យសៀវភៅនេះត្រូវបានចែកចាយនៅគ្រប់សាលាគរុកោសល្យទាំងប្រាំមួយភូមិភាគ ព្រោះវាអាចជួយដល់គរុសិស្សយកចំណេះដឹងទាំងនេះទៅចែកចាយដល់ក្មេងជំនាន់ក្រោយនៅតាមវិទ្យាល័យនិងអនុវិទ្យាល័យបន្តទៀត ។ **ឆេស ម៉ារ៉ែម**

# ដំណើររៀបរាប់អំពីជីវិតខ្លោចផ្សា

*តេង សុភាលក្ស្មី អាយុ៤១ឆ្នាំ កើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ នៅក្នុងសម័យខ្មែរក្រហម សុភាលក្ស្មី បាត់បង់ប្អូនស្រីម្នាក់ ប្អូនប្រុសម្នាក់និងឪពុកម្នាក់ ។ ចាប់តាំងពីរបបនេះដួលរលំទៅ សុភាលក្ស្មី រស់នៅតែពីរនាក់ម្តាយដែលមានជំងឺផ្លូវចិត្តប៉ុណ្ណោះ ។ ប៉ុន្តែទោះបីគាត់រស់ជាក្មេងកំព្រានិងខ្វះខាតផ្នែកជីវភាពក៏ដោយ ក៏គាត់ខិតខំរៀនសូត្ររហូតបានក្លាយជាមន្ត្រីម្នាក់របស់រដ្ឋាភិបាលនិងមាននាទីជាអ្នកបណ្តុះបណ្តាលគ្រូអំពីរបបកម្ពុជាប្រជាធិបតេយ្យដែរ ។*

សុភាលក្ស្មី បានរៀបរាប់ថាៈ ខ្ញុំជាកូនច្បងក្នុងចំណោមបងប្អូនបង្កើតចំនួនបីនាក់និងមានឪពុកឈ្មោះ តេង អ៊ិន ជានគរបាលនិងម្តាយឈ្មោះ ខៀវ ប៊ុនលីន ជាគ្រូបង្រៀននៅខេត្តកំពង់ធំក្នុងរបបសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ ។

នៅឆ្នាំ១៩៧០ ឪពុកម្តាយខ្ញុំបានផ្លាស់មកធ្វើការនិងរស់នៅក្នុងសង្កាត់លេខ៣ ក្រុងភ្នំពេញ ។ នៅឆ្នាំ១៩៧៣ ក្រុងភ្នំពេញចាប់ផ្តើមមានអសន្តិសុខនិងចលាចលដោយសារតែប្រជាជនជាច្រើនកុះករបានភៀសខ្លួនពីជនបទចូលមករស់នៅ ។ នៅថ្ងៃមួយ ខ្មែរក្រហមបានដាក់គ្រាប់បែកផ្ទាប់ស្ពានជ្រោយចង្វារដែលធ្វើឲ្យឪពុកម្តាយខ្ញុំមានការភ័យខ្លាចពីសុវត្ថិភាពផ្ទាល់ខ្លួន គាត់ក៏សុំផ្លាស់មកធ្វើការងារនៅក្នុងខេត្តពោធិ៍សាត់វិញ ។ នៅពេលកងទ័ពខ្មែរក្រហមចូលមកដល់ខេត្តពោធិ៍សាត់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសឪពុកម្តាយ បងប្អូនរួមទាំងប្រជាជនដែលរស់នៅក្នុងទីរួមខេត្តឲ្យទៅរស់នៅតំបន់ដាច់ស្រយាល



តេង សុភាលក្ស្មី

មួយដែលខ្ញុំមិនធ្លាប់ទៅដល់និងស្គាល់ឈ្មោះពីមុនមក ។ ប៉ុន្តែរស់នៅទីនោះបានមួយរយៈ ឪពុកម្តាយខ្ញុំនិងចាស់ៗនៅទីនោះហៅឈ្មោះថា ភូមិបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

នៅឆ្នាំ១៩៧៦ មេសហករណ៍នៅទីនោះបានចាត់តាំងឪពុកខ្ញុំចូលក្នុងកងភ្ជួរដី ឬកងសមរភូមិមុខ (កងនេះធ្វើការងារនិងស្នាក់នៅការដ្ឋានឆ្ងាយពីភូមិ) ចំណែកម្តាយខ្ញុំត្រូវចូលធ្វើការងារក្នុងភូមិឬហៅថា (កងសមរភូមិក្រោយ) ជាមួយខ្ញុំនិងប្អូនៗពីរនាក់ ។ នៅថ្ងៃមួយ មេសហករណ៍បានអនុញ្ញាតឲ្យឪពុកខ្ញុំរួមទាំងមនុស្សប្រុសចាស់ៗដែលធ្វើការងារនៅកងភ្ជួរជាមួយគាត់មកលេងប្រពន្ធកូននៅភូមិ ។ បន្ទាប់មក អង្គការបានរៀបចំពិធីជប់លៀងឲ្យកងភ្ជួរនេះ ប៉ុន្តែមិនអនុញ្ញាតឲ្យអ្នកនៅកងផ្សេងចូលរួមទេ ។ ខ្ញុំនៅចាំបានថា ក្រោយពេលជប់លៀងចប់ ឪពុកខ្ញុំបានលួចយកបាយដំណើបចំនួនបួនដុំនិងទឹកត្នោតផ្អែមមកឲ្យខ្ញុំនិងប្អូនហូបហើយប្រាប់ថា មេក្រុមបានផ្តាំឲ្យឪពុកប្រញាប់ទៅការដ្ឋានវិញ ព្រោះការងារបន្ទាន់ ។ ពេលនោះ ខ្ញុំបានសុំទៅតាមគាត់ដែរ ប៉ុន្តែឪពុកខ្ញុំបាននិយាយលួងលោមខ្ញុំថាក្មេងៗគេមិនឲ្យទៅទេ កូនត្រូវនៅជាមួយម៉ែនិងប្អូនៗសិន ចាំពេលក្រោយឪពុកនឹងមកលេងកូននិងម៉ែទៀត ។ ទោះបីគាត់និយាយយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែមិនចង់ឲ្យឪពុកទៅធ្វើការនៅឆ្ងាយពីផ្ទះនិងបែកពីម្តាយនិងប្អូនៗដែរ ។ ចំណែកម្តាយខ្ញុំឃើញខ្ញុំទារទៅតាមដូច្នេះ គាត់ក៏បានទៅសុំអង្វរប្រធានសហករណ៍ដើម្បីឲ្យឪពុកខ្ញុំធ្វើការនៅក្នុងភូមិវិញព្រោះគាត់សង្កេតឃើញសុខភាពរបស់ឪពុកខ្ញុំទន់ខ្សោយនិងខស្សោហ៍មានជំងឺទៀត ។ ប៉ុន្តែទោះបីម្តាយខ្ញុំខិតខំនិយាយអង្វរនិងលើកហេតុផលលំបាកយ៉ាងណាក៏ដោយ ក៏គេមិនព្រមស្តាប់ដែរគឺត្រូវតែទៅធ្វើការតាមការចាត់តាំងរបស់អង្គការ ។ ចាប់តាំងពីពេលនោះមកម្តាយខ្ញុំនិងប្អូនៗបានបែកពីឪពុករហូត ហើយក្រោយមកទើបម្តាយខ្ញុំនិយាយប្រាប់ថានៅពេលកងភ្ជួរប្រុសត្រឡប់មកពីការដ្ឋានវិញគាត់បានសួរថា «មិត្តបងៗតើមានឃើញប្តីរបស់ខ្ញុំទេ»? ពេលនោះគេឆ្លើយថា «បើមិនឃើញមិនបាច់សួរទេ» ។ ចំណែកអ្នកខ្លះដែលធ្លាប់ស្គាល់ឪពុកខ្ញុំច្បាស់បានប្រាប់ម្តាយខ្ញុំថាធ្លាប់ឃើញឪពុកខ្ញុំចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ព្រោះគាត់ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការរហូតដល់សំរោងព្រៃទាលស្ថិតក្នុងឃុំស្វាយដូនកែវ ស្រុកបាកានដែលនៅទីនោះគាត់ត្រូវភ្ជួរដីទាំងកណ្តាលថ្ងៃក្តៅស្ទើរគ្មានពេលសម្រាកនិងគ្មានម្ហូបឈើសម្រាប់ជ្រកទេ ។ ទោះបីឪពុកខ្ញុំទទួលបានរបបអាហារប្រចាំថ្ងៃម្នាក់ពីរកំប៉ុងនិងទឹកត្នោតមួយកែវលើសពីអ្នកធ្វើការនៅក្នុងភូមិយ៉ាងណាក៏ដោយ ក៏គាត់មិនអាចមានកម្លាំងគ្រប់គ្រាន់ដើម្បីធ្វើការងារធ្ងន់ធ្ងរនេះដែរ ។ នៅទីនោះ អ្នកធ្វើការនៅក្នុងកងភ្ជួរខ្លះដែលមានជំងឺបានសុំច្បាប់ប្រធានកងដើម្បីឈប់សម្រាក ប៉ុន្តែត្រូវប្រធានបដិសេធរហូតដល់ព្រឹកឡើងក៏ឃើញអ្នកជំងឺនោះដេកស្លាប់នៅក្នុងអង្រឹង ។ នៅពេលធ្វើការងារនៅការដ្ឋានចប់រួចរាល់ សមាជិកនៅក្នុងកងភ្ជួរសរុបទាំងអស់ប្រមាណ១០០នាក់បានត្រឡប់មកភូមិវិញតែប្រាំនាក់ប៉ុណ្ណោះ ។

ចាប់តាំងពីពេលឪពុកខ្ញុំបាត់ខ្លួនមក ប្អូនស្រីខ្ញុំក៏ចាប់ផ្តើមមានជំងឺដែរ ឃើញដូច្នេះ ម្តាយខ្ញុំបានសុំអនុញ្ញាតពីប្រធានភូមិដើម្បីយកទៅព្យាបាលនៅមន្ទីរពេទ្យដោយទុកឲ្យខ្ញុំនិងប្អូនប្រុសដេកតែពីរនាក់នៅផ្ទះមួយដែលអង្គការចែកឲ្យសម្រាប់គ្រួសារជម្លៀសមក ។ នៅថ្ងៃមួយ ខ្ញុំបានឮសំឡេងពូម្នាក់និងប្រពន្ធរបស់គាត់ដែលស្នាក់នៅបន្ទប់ជាប់ខ្ញុំស្រែកថ្ងូរយ៉ាងខ្លាំងដោយសារការធ្វើទារុណកម្មនិងសំឡេងជេរប្រទេចទៅលើឈ្លបខ្មែរក្រហមវិញពេលដែលបានចោទប្រកាន់គាត់ថាលួចមាន់របស់អង្គការហូប ។ ខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង ហើយដោយសារម្តាយខ្ញុំត្រូវដេកកំដរប្អូននៅមន្ទីរពេទ្យច្រើនថ្ងៃទើបនៅពេលឮសំឡេងជួង (ពេលបើករបបអាហារ) ម្តងៗខ្ញុំតែងតែនាំប្អូនប្រុសដើរទៅហូបបបរដែលអង្គការចែកនៅរោងបាយរួម ។ ថ្ងៃមួយដោយសារប្អូនប្រុសខ្ញុំឈឺស្គមនិងដើរមិនបានលឿន ខ្ញុំគៀនប្អូនយ៉ាងខ្លាំងឲ្យដើរប្រញាប់ប្រញាល់ឡើងព្រោះខ្លាចទៅមិនទាន់ម៉ោង គេហូបអស់ ប៉ុន្តែពេលនោះប្អូនប្រុសខ្ញុំឆ្លើយទាំងហត់ហេវនិងសំឡេងខ្សោយថា «កុំបង្ខំខ្ញុំពេកខ្ញុំដើរមិនចង់រួចទេ» ។ នៅពេលឮសម្តីនេះភ្លាម ខ្ញុំអាណិតប្អូនយ៉ាងខ្លាំង ។

មួយរយៈក្រោយមក ប្អូនប្រុសរបស់ខ្ញុំរាកមូល និងហើមខ្លួនដោយសារខ្វះជីវជាតិនិងថ្នាំសម្រាប់ព្យាបាល ។ ពេលនោះដោយឃើញកូនៗឈឺដូច្នេះ ម្តាយខ្ញុំតែងតែលួចយកសម្ភារៈដែលនៅសេសសល់ក្នុងខ្លួនទៅដូរយកអង្ករមកដាំបបរ ហើយពេល

ខ្វះគាត់ប្រថុយនឹងគ្រោះថ្នាក់លួចឡើងយកទឹកត្នោតមកវិងរស់ធ្វើស្ករវង្វ (ស្ករខាប់) និងកាច់ពោតយកមកឲ្យកូនៗហូបទាំងយប់ទៀតផង ។ ទោះបីម្ដាយខ្ញុំខិតខំដើររកអាហារយ៉ាងណាក៏ដោយ ក៏អាហារបន្ដិចបន្តួចនេះមិនគ្រប់គ្រាន់ដើម្បីធ្វើឲ្យប្អូនខ្ញុំមានកម្លាំងដែរ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ប្អូនប្រុសខ្ញុំធ្លាក់ខ្លួនឈឺកាន់តែធ្ងន់ធ្ងរឡើងៗរហូតដល់បញ្ឈរភ្នែកលែងដឹងខ្លួនធ្វើឲ្យម្ដាយខ្ញុំតក់ស្លុតយ៉ាងខ្លាំង ។ ម្ដាយខ្ញុំបានលើកបីប្អូនប្រុសខ្ញុំនិងហៅឈ្មោះប្អូនប្រុសឲ្យដឹងខ្លួនព្រមទាំងយកស្លាបព្រាមកគាស់ធ្មេញរបស់ប្អូនខ្ញុំដើម្បីកុំឲ្យវាខាំអណ្ដាត ប៉ុន្ដែប្អូនប្រុសរបស់ខ្ញុំនៅតែបញ្ឈរភ្នែក និងរឹងថ្គាមដដែល ។ ពេលនោះ ម្ដាយរបស់ខ្ញុំបានលើកបីប្អូនប្រុសរត់ទៅមន្ទីរពេទ្យទាំងទឹកភ្នែក រួចប្រាប់ខ្ញុំឲ្យមួរន្ទេលយកទៅតាមក្រោយគាត់ ។ ទៅដល់មន្ទីរពេទ្យ ម្ដាយខ្ញុំបានរត់ទៅសុំអង្វរគ្រូពេទ្យឲ្យជួយចាក់ថ្នាំដើម្បីសង្គ្រោះជីវិតប្អូនប្រុសខ្ញុំ ប៉ុន្ដែពេទ្យទាំងនោះបានឆ្លើយតបដោយសម្ដីប្រមាថថា «ចាំបាច់ចាក់ថ្នាំធ្វើអីទុកតែបន្ដិចទៀតវាងាប់ហើយ» ។ បន្ដិចក្រោយមក ដោយសារតែប្អូនខ្ញុំអស់កម្លាំងកាន់តែខ្សោយទៅៗ ក៏ដាច់ខ្យល់ស្លាប់នៅទីនោះ ។ ទោះបីប្អូនប្រុសខ្ញុំស្លាប់ទៅហើយក៏ដោយ ក៏មន្ទីរពេទ្យមិនអនុញ្ញាតឲ្យម្ដាយយកសាកសពប្អូនខ្ញុំត្រឡប់មកផ្ទះ ឬយកទៅកប់ដោយផ្ទាល់ដៃឡើយ គឺគេទុកយកទៅកប់នៅក្នុងរណ្ដៅរួមជាមួយក្មេងៗដែលស្លាប់នៅទីនោះ ។

ខ្ញុំបានត្រឡប់មកដេកនៅផ្ទះតែម្នាក់ឯង ចំណែកម្ដាយខ្ញុំទៅមើលថែប្អូនស្រីដែលមិនទាន់ជាសះស្បើយនិងកំពុងដេកព្យាបាលនៅមន្ទីរពេទ្យនៅឡើយ ។ នៅពេលព្រលប់ថ្ងៃមួយ ម្ដាយខ្ញុំបានយកប្អូនចេញពីមន្ទីរពេទ្យត្រឡប់មកផ្ទះវិញ ប៉ុន្ដែនៅពេលនោះដោយសារខ្ញុំនៅក្មេង ក៏មិនបានចាប់អារម្មណ៍សាកសួរគាត់ពីជំងឺប្អូនស្រីដែរ ហើយខ្ញុំក៏ដេកលក់ទៅ ។

នៅពេលខ្ញុំភ្ញាក់ឡើងពេលព្រឹក ស្រាប់តែបាត់ម្ដាយនិងប្អូនស្រីដែលដេកនៅក្បែរខ្ញុំមិនដឹងថាដើរទៅណាទេ បន្ដិចក្រោយមកខ្ញុំឃើញម្ដាយរបស់ខ្ញុំកាន់ប៉ែលនិងចបលាយឡឹងនឹងកែវភ្នែករលីងរលោងដើរត្រឡប់មកផ្ទះវិញ ។ ខណៈនោះ ដោយឃើញម្ដាយខ្ញុំដើរមកផ្ទះតែម្នាក់ឯង ខ្ញុំបានសួរទៅគាត់ថា «ម៉ែតើស្រីទូចទៅណាហើយ»? ម្ដាយខ្ញុំបានឆ្លើយទាំងទឹកភ្នែកថា «ប្អូនរបស់កូនបានស្លាប់ហើយ ចំណែកអ្នកដែលដេកកំដរនៅមន្ទីរពេទ្យដូចគ្នាបានឲ្យគាត់យកប្អូនស្រីដែលមានអាយុ២ឆ្នាំត្រឡប់មកផ្ទះវិញទៅដោយគេនិយាយថាមិនមានសង្ឃឹមទេ ព្រោះប្អូនស្រីរបស់កូនបានក្អួតរហូតចេញព្រូនមួយក្បាលតាមមាត់មកក្រៅ» ។ នៅពាក់កណ្ដាលយប់នោះ ដោយឃើញប្អូនស្រីខ្ញុំឃ្លានរហូបបាយខ្លាំងពេក ម្ដាយរបស់ខ្ញុំបានយកបាយជាមួយនឹងត្រសក់ត្រាំឲ្យប្អូនហូប ។ ប៉ុន្ដែក្រោយពីហូបពីរបីម៉ាត់ គាត់ក៏ពន្ធត់ភ្លើងចង្កៀងចូលដេកវិញ ។ នៅពេលយប់ជ្រៅ ប្អូនខ្ញុំចាប់ផ្ដើមមិនស្រួលខ្លួនខ្លាំងនិងបានស្រែកហៅម្ដាយខ្ញុំ ។ ដោយសារម្ដាយខ្ញុំត្រូវធ្វើការធ្ងន់ធ្ងរនៅពេលថ្ងៃនិងហេវហត់អស់កម្លាំង គាត់បានដេកលង់លក់ដោយឮតែសំឡេងកូនស្រែកហៅល្មើយៗរហូតមិនដឹងថាស្លាប់ពីពេលណាមកទេ ។ ក្រោយពីឮការរៀបរាប់របស់ម្ដាយខ្ញុំ ខ្ញុំបានអង្គុយស្រក់ទឹកភ្នែកដោយសារអាណិតប្អូន ។ រយៈពេលមិនដល់មួយឆ្នាំ គ្រួសាររបស់ខ្ញុំបានបាត់បង់សមាជិកអស់៣នាក់ ។ នៅថ្ងៃប្អូនខ្ញុំស្លាប់ ម្ដាយរបស់ខ្ញុំបាននាំខ្ញុំទៅមុជទឹកស្ទឹងនិងនិយាយទូន្មានខ្ញុំថា «ថ្ងៃក្រោយកូនកុំហូបអ្វីផ្ដេសផ្ដាសខ្លាចបណ្ដាលឲ្យកូនឈឺដូចប្អូនៗទៀត» ព្រោះគាត់ត្រូវចេញទៅដកស្ទូងនិងជីកប្រឡាយនៅឆ្ងាយពីភូមិ ។ មួយរយៈក្រោយមក ដោយសារខ្វះជីវជាតិ ខ្ញុំក៏កើតជំងឺហើមដៃហើមជើង ហើមខ្លួន និង គ្រុនចាញ់ ។ នៅពេលនោះ ម្ដាយរបស់ខ្ញុំបានគ្រាហ៍ខ្ញុំដាក់ឲ្យដេកលើកន្ទេលក្រោមរោងផ្ទាល់ដីមួយ ប៉ុន្ដែគាត់មិនបាននៅមើលថែខ្ញុំទេ ព្រោះអង្គការបានចាត់តាំងគាត់ឲ្យច្រូតស្រូវនៅជ្រៃវារស្ថិតនៅក្នុងភូមិបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ។ ចំណែករបបអាហារ ចុងភៅចែកឲ្យខ្ញុំតែពាក់កណ្ដាលប៉ុណ្ណោះ ព្រោះខ្ញុំឈឺមិនបានជួយធ្វើការងាររែកទឹកដាក់ពាងឬពុសខុសដូចក្មេងឯទៀតៗ ។ នៅពេលម្ដាយខ្ញុំត្រឡប់មកវិញ ឃើញរបបអាហារតិចបែបនេះ គាត់បានទៅសុំមេកងឲ្យចែករបបអាហារឲ្យខ្ញុំស្មើនឹងមនុស្សធំដែរ ដោយសន្យាធ្វើការងារបន្ថែមទៀត ។ ដោយសារជំងឺរបស់ខ្ញុំកាន់តែធ្ងន់ធ្ងរឡើងៗ ហើយហូបបាយមិនបានម្ដាយខ្ញុំក៏យករបបអាហារដែលអង្គការចែកខ្ញុំទៅដូរយកថ្នាំពេទ្យពីអ្នកភូមិម្នាក់ដែលលាក់ទុកបានដោយមិនឲ្យគេដឹងឡើយ ។ បន្ទាប់ពីលេបថ្នាំនោះបានមួយរយៈ ជំងឺខ្ញុំចាប់ផ្ដើមស្រកនិងធូរស្បើយបន្ដិចម្ដងៗ ។

*នៅមុនឆ្នាំ១៩៧៧ នៅពេលដែលពួកអង្គការប្រមូលកង កុមារឲ្យទៅរស់នៅកងផ្សេងនិងបែកពីម្តាយ ខ្ញុំបានរត់ទៅលាក់ ខ្លួននៅក្បែរគុម្ពឫស្សីខាងក្រោយផ្ទះ ។ ប៉ុន្តែក្រោយមកនៅតែ អង្គការរកឃើញនិងប្រមូលក្មេងក្នុងភូមិទាំងអស់ដាក់នៅក្នុងកង កុមារដដែល ។ ខ្ញុំធ្វើការបែកពីម្តាយដោយមិនដឹងថាគាត់រស់នៅ ទីកន្លែងណាទេ ។ ដូច្នេះ ខ្ញុំមានខោអាវតែមួយកំប្លេដែលម្តាយឲ្យខ្ញុំ ប៉ុណ្ណោះ ហើយស្លៀកពាក់ទាំងយប់ទាំងថ្ងៃរហូតរហែកដាច់ជើង ខោមួយកំណាត់ ព្រោះនៅក្នុងកងកុមារអង្គការមិនបានចែករបប ខោអាវឲ្យស្លៀកពាក់ទេ ។*

*នៅឆ្នាំ១៩៧៧ អង្គការបានធ្វើការបែងចែកកុមារៗនៅ ក្នុងភូមិម្តងទៀត ដោយកុមារណាដែលមានឪពុកធ្វើការងារធំនៅ របបចាស់ត្រូវប្រមូលយកទៅដាក់ឲ្យរស់នៅមុំ ហើយចាត់តាំង ឲ្យធ្វើការងារដកស្ទូង ជីកប្រឡាយដូចមនុស្សពេញវ័យដែរ ។ ចំណែកខ្ញុំត្រូវបានកុមារដូចគ្នាចោទប្រកាន់ថា «ជាកូនស័ក្តិប្រាំ» ព្រមទាំងមេកងបានកត់ឈ្មោះខ្ញុំ រួចបញ្ជូនឲ្យទៅរស់នៅកន្លែងផ្សេង ពីកុមារដែលមានឪពុកម្តាយជាអ្នកស្រែចម្ការ ។ នៅពេលនោះ ដោយសារខ្ញុំនៅក្មេងនិងមិនដែលរស់នៅបែកឪពុកម្តាយ ទើបខ្ញុំ យំយ៉ាងខ្លាំង ហើយប្រកែកថា «ឪពុកខ្ញុំមិនមែនពាក់ស័ក្តិប្រាំទេ គាត់ជាអ្នកធ្វើការយកលុយចិញ្ចឹមខ្ញុំប៉ុណ្ណោះ» ។ ទោះបីជាខ្ញុំ ប្រកែកយ៉ាងណាក៏ដោយ ក៏អង្គការនៅតែចោទថាខ្ញុំជាកូនស័ក្តិ៥ ដដែល ព្រោះពេលឪពុកខ្ញុំនៅរស់ គាត់បានប្រាប់ពីមុខងារពិត ប្រាកដរបស់គាត់ទៅដល់កម្មាភិបាលដែលចុះមកធ្វើប្រវត្តិរូបរួច ហើយ ។ ខ្ញុំត្រូវទៅរស់នៅឆ្ងាយពីភូមិ ហើយនៅទីនោះអង្គការ បានចាត់តាំងខ្ញុំឲ្យជីកប្រឡាយ និងរែកដីជាមួយបង្គីធំៗឡើងលើ ទំនប់ ។ នៅថ្ងៃខ្លះ ដោយសារការហេវហត់និងធ្វើការងារច្រើន ម៉ោង ខ្ញុំគ្មានកម្លាំងរែកដីឡើងលើខ្នងទំនប់ទេ ប៉ុន្តែទោះបីជាឃើញ ខ្ញុំនៅក្មេងយ៉ាងនេះក៏ដោយ ក៏មេក្រុមមិនអនុគ្រោះដែរដោយបាន បង្ខំឲ្យខ្ញុំធ្វើការងារបន្តទៀត រួចហើយស្តីបន្ទោសនិងនិយាយពាក្យ គំរោះគំរើយដាក់ខ្ញុំយ៉ាងច្រើន ។ ក្រោយពីពួកពាក្យជេរប្រមាថ នេះ ខ្ញុំក៏បានអង្គុយស្រក់ទឹកភ្នែករហូតធ្វើឲ្យប្រធានកងបានយក ដុំដីគប់មកលើខ្ញុំ ព្រមទាំងព្រមានថា «មិត្តឯងទុកទឹកភ្នែកស្រូប បាយទៅ មិត្តឯងត្រូវប្រឹងធ្វើការថែមទៀត» ។ នៅរដូវវស្សា អង្គការចាត់តាំងការងារឲ្យខ្ញុំដកសំណាប បោចស្មៅដែលដុះក្នុង វាលស្រែនិងដើរកាប់ទន្រ្ទានខែត្រមកលាយជាមួយអាចម៍គោធ្វើ ជី ហើយនៅរដូវប្រាំងខ្ញុំត្រូវច្រូតស្រូវនិងបោកកណ្តាប់រហូតដល់ យប់ជ្រៅស្ទើរគ្មានពេលសម្រាក ។*

*នៅយប់ថ្ងៃមួយ អង្គការបានចាត់តាំងកងកុមារឲ្យទៅជួយ បោកកណ្តាប់នៅកងចាស់ៗ ។ ពេលនោះ ខ្ញុំក៏បានជួបនឹងម្តាយ ដែលកំពុងធ្វើការនៅទីនោះដែរ ។ ខ្ញុំត្រេកអរយ៉ាងខ្លាំង ដោយ ក្រោយពីធ្វើការងាររួច ខ្ញុំក៏រត់ទៅសុំប្រធានកងថា «មិត្តបង! ខ្ញុំសុំទៅដេកជាមួយម៉ែមួយយប់» ព្រោះខ្ញុំបែកពីម្តាយយូរថ្ងៃ ហើយ ។ បន្ទាប់ពីពួការស្នើសុំនេះភ្លាម មេកងមិនបានឆ្លើយ បដិសេធទេ ប៉ុន្តែបែរជានិយាយកុហកថា «ចាំយប់ថ្ងៃស្អែកមិត្តមក ដេកជាមួយម្តាយចុះ» ។ ខ្ញុំរង់ចាំរហូតដល់យប់ថ្ងៃកំណត់ ស្រាប់ តែប្រធានកងបានឆ្លើយបដិសេធវិញ ។ ពួដូច្នេះ ខ្ញុំក៏សួរគាត់ថា «ហេតុអ្វីបានជាមិត្តមិនឲ្យខ្ញុំទៅដេកជាមួយម្តាយ ពីព្រោះម្សិល មិញមិត្តសន្យាជាមួយខ្ញុំរួចហើយ» ។ ភ្លាមនោះ ប្រធានកងស្រែក ខ្លាំងៗដាក់ខ្ញុំថា «មិនអនុញ្ញាតឲ្យទៅដេកជាមួយម្តាយទេ» ។ ទោះបី មានការហាមឃាត់ពីប្រធានកងយ៉ាងនេះក៏ដោយ ក៏នៅពេលពាក់ កណ្តាលយប់នោះខ្ញុំបានលួចរត់កាត់តាមប្រឡាយទៅរកម្តាយ ដោយមិនឲ្យអ្នកនៅក្នុងកងដឹងដែរ ។ ខ្ញុំបានជួបម្តាយមិនបាន ប៉ុន្មានម៉ោងផង ព្រឹកឡើងអង្គការក៏ទៅយកខ្ញុំត្រឡប់មកកងវិញ ។ នៅពេលនោះ ខ្ញុំភិតភ័យនិងយំយ៉ាងខ្លាំង ហើយសុំម្តាយឲ្យ និយាយប្រាប់ប្រធានកងថា «ខ្ញុំមិនចង់ត្រឡប់ទៅកងវិញទេព្រោះ នៅទីនោះអង្គការហៅខ្ញុំថាកូនទាហាន ហើយគេនឹងយកខ្ញុំទៅ សម្លាប់ចោលមិនខាន» ។ ពេលនោះ ម្តាយរបស់ខ្ញុំក៏ដាច់ចិត្តទៅ សុំអង្វរប្រធានកងដើម្បីប្តូរខ្ញុំឲ្យមករស់នៅក្នុងភូមិអូរឫស្សីវិញ ពីព្រោះភូមិនោះសម្រាប់តែកូនដែលមានឪពុកម្តាយជាកសិករ រស់នៅប៉ុណ្ណោះ ។ ប្រធានកងបានយល់ព្រមតាមពាក្យអង្វររបស់ ម្តាយខ្ញុំ ប៉ុន្តែក្រោយមកស្រាប់តែបញ្ជូនខ្ញុំឲ្យទៅរស់នៅនិងធ្វើការ នៅកន្លែងដដែល ។ ទៅដល់កង ខ្ញុំមិនបានជួបនឹងមិត្តភក្តិដែល ធ្លាប់ស្គាល់ខ្ញុំពីមុននោះទេ ហើយកុមារក៏មានចំនួនតិចជាងមុនដែរ ដោយខ្ញុំបានលួចសួរអ្នករស់នៅទីនោះថា «ហេតុអ្វីបានជាបាត់កុមារ ច្រើនហើយមិនឃើញមកធ្វើការ»? គេបានឆ្លើយប្រាប់តាមត្រង់*

ថា «អ្នកទាំងនោះត្រូវអង្គការយកទៅសម្លាប់អស់ហើយ» ។ ចាប់តាំងពីពេលនោះមក ខ្ញុំភិតភ័យយ៉ាងខ្លាំងព្រោះកុមារនៅក្នុងកងបានបាត់ខ្លួនជាបន្តបន្ទាប់ ចំណែករោងស្នាក់នៅមិនមានជញ្ជាំងបាំងជិតទេ ហើយរៀងរាល់យប់ខ្ញុំត្រូវចូលដេកប្រជ្រៀតគ្នាជាមួយកុមារឯទៀតៗ នៅក្នុងកងលើគ្រារបន្ទះដែលមានតែបីសន្ទឹកប៉ុណ្ណោះ ។ នៅពេលមុជទឹកម្តងៗ ខ្ញុំមិនដែលមានសាប៊ូសម្រាប់ដុសលាងខ្លួននិងកក់សក់ទេ ទើបបណ្តាលឲ្យខ្ញុំកើតចៃយ៉ាងច្រើននៅលើក្បាល ។ ស្នាក់នៅក្នុងរោងនោះបានមួយរយៈ មានកុមារខ្លះដែលមិនអាចទ្រាំទ្រនឹងអាកាសធាតុត្រជាក់និងមូសខាំបាន គេក៏រត់ទៅដេកក្នុងផ្ទះរបស់ប្រធានក្រុមនិងមេកងដែលមានប្រក់ដំបូល និងជញ្ជាំងបិទជិត ហើយមានគ្រារបន្ទះដេកធំទូលាយ ។

នៅយប់ថ្ងៃមួយ កុមារនៅក្នុងកងជាមួយខ្ញុំម្នាក់បានមកបបួលខ្ញុំទៅដេកនៅផ្ទះមេកងជាមួយគេ រហូតដល់ពេលពាក់កណ្តាលអធ្រាត្រពេលខ្ញុំដេកលង់លក់ មេក្រុមនិងកុមារៗដែលដេកនៅទីនោះបានផ្លាស់ទៅដេកនៅផ្ទះមួយផ្សេងទៀតដោយមិនបានប្រាប់ឲ្យខ្ញុំដឹងឡើយ ។ នៅពេលអាកាសធាតុត្រជាក់ ខ្ញុំស្មានថាមានមនុស្សមកកេះជើងខ្ញុំតាមប្រឡោះគ្រារ ខ្ញុំបានងើបអង្គុយ រួចហើយនិយាយទាំងមមីមមើថា «ភ្លៀង!» ប៉ុន្តែពុំមានសំឡេងមនុស្សឆ្លើយតបមកវិញទេ ។ ខ្ញុំក៏ដេកបន្តទៀត ព្រោះគិតថាប្រហែលគេដេកលក់មិនបានស្តាប់ឮខ្ញុំនិយាយទេមើលទៅ ។ ប៉ុន្តែខណៈនោះ ខ្ញុំរាវរកអ្នកដែលដេកជាមួយគ្នា ស្រាប់តែមិនមានប៉ះនរណាម្នាក់សោះ ។ ខ្ញុំចាប់ផ្តើមភិតភ័យយ៉ាងខ្លាំង ហើយស្ទុះរត់សំដៅទៅផ្ទះដែលកងកុមារនិងប្រធានកងដេកក្បែរនោះ ប៉ុន្តែខ្ញុំមិនអាចចូលផ្ទះបានទេ ព្រោះទ្វារបានខ្ទាស់គន្លឹះជាប់ស្រេច ។ ខ្ញុំភ័យខ្លាចកាន់តែខ្លាំងឡើងព្រោះយប់ស្ងាត់ណាស់ ខ្ញុំក៏រត់ផង យំផងសំដៅទៅផ្ទះមេកងម្នាក់ទៀតដែលទើបរៀបការហើយថ្មីៗ ដើម្បីសុំកន្លែងដេក ។ ពេលឮសំឡេងគោះទ្វារ ប្រធានកងនោះបានក្រោកឡើងបើកទ្វារនិងសាកសួរពីមូលហេតុរត់មកផ្ទះគាត់ទាំងយប់ ។ បន្ទាប់ពីស្តាប់ការរៀបរាប់របស់ខ្ញុំមក គាត់ក៏មានការអាណិតអាសូរខ្ញុំ ហើយបានអនុញ្ញាតឲ្យដេកនៅផ្ទះគាត់មួយយប់ ។ នៅយប់នោះ ខ្ញុំចាប់ផ្តើមក្អកយ៉ាងខ្លាំង ព្រោះជំងឺគ្រុនចាញ់និងជំងឺហើមខ្លួនដែលខ្ញុំធ្លាប់កើតពីមុនបានរើឡើងវិញ ។ ជារៀងរាល់ថ្ងៃ ខ្ញុំត្រូវធ្វើការងារធ្ងន់ៗដូចមនុស្សចាស់ ក៏ប៉ុន្តែទទួលបានបបររាវៗតែមួយកូនចានប៉ុណ្ណោះ ។ ដោយសារហូបមិនគ្រប់គ្រាន់ នៅពេលសម្រាកថ្ងៃត្រង់ម្តងៗ ខ្ញុំតែងតែដើររើសមើមប្លុងតាមអាចម៍ដីបំណះដែលកងភ្ជួរចោល ដើររើសគ្រាប់ចំបក់និងលូកក្តាមស្រែតាមស្មៅដើម្បីយកមកត្រាំទឹកអំបិលទុកហូប ។ ក្រោយមកដោយសារអត់អាហារកាន់តែខ្លាំង ខ្ញុំបានដើរចាប់សត្វកណ្តូបនិងសត្វថ្លែនដែលសម្ងំនៅក្រោមកន្ទេលខ្ញុំដេកយកមកដុតហូបបន្ថែម ។ ទោះបីជាខិតខំដើររកអាហារយ៉ាងណាក៏ដោយ ក៏មិនអាចឲ្យខ្ញុំហូបគ្រប់គ្រាន់ដែរ រហូតខ្ញុំហ៊ានទៅលួចកាច់ដើមពោតមកជញ្ជក់យកទឹកនិងលួចបូតកួរស្រូវរបស់អង្គការថែមទៀតដោយមិនខ្លាចគេចាប់យកទៅធ្វើទារុណកម្មនិងសម្លាប់ឡើយ ។

ក្រោយពីជំងឺខ្ញុំបានធូរស្បើយ ម្តាយរបស់ខ្ញុំមកជួបខ្ញុំនៅកងកុមារ រួចនាំខ្ញុំទៅលេងកន្លែងធ្វើការរបស់គាត់ ។ ប៉ុន្តែគាត់មិនហ៊ានឲ្យខ្ញុំនៅលេងយូរទេ ព្រោះខ្លាចអង្គការចោទប្រកាន់ខ្ញុំថា «ដើរលេងសេរី» ។ ក្រោយពីដឹងទីកន្លែងម្តាយខ្ញុំធ្វើការរួចហើយ នៅពេលនឹករឭកគាត់ម្តងៗ ខ្ញុំតែងតែលួចរត់ទៅជួបម្តាយជានិច្ចដោយមិនឲ្យប្រធានកងដឹងឡើយ ។

នៅថ្ងៃមួយ ខ្ញុំបានលួចរត់កាត់ព្រៃទៅជួបម្តាយ ប៉ុន្តែនៅពេលទៅដល់ភូមិ គាត់ចេញទៅធ្វើការបាត់ទៅហើយ គឺខ្ញុំបានជួបត្រឹមតែមីងធម៌ប៉ុណ្ណោះ ។ ភ្លាមនោះ គាត់បានរត់មកឱបខ្ញុំ ហើយនិយាយទាំងសំឡេងតក់ស្លុតថា «អាស្មី! ក្មួយឯងអាយុវែងណាស់ មីងភ័យស្ទើរស្លាប់នៅពេលឮថា ពូនង (អ្នកសម្លាប់មនុស្ស) កាន់កាំបិតរត់ចូលទៅព្រៃដែលជាកន្លែងសម្លាប់កុមារនិងមានឪពុកម្តាយមកពីភូមិភាគបូព៌ា» ប៉ុន្តែដោយសារគាត់ធ្លាប់ស្គាល់ក្មួយពីមុនមក ទើបគាត់មិនសម្លាប់ ហើយត្រឡប់មកប្រាប់មីងថា «អាស្មីទេ! ឯងស្មានតែកូនអ្នកបូព៌ាមិនទាន់ងាប់» ។ បន្ទាប់មក មីងបានប្រាប់ខ្ញុំឲ្យត្រឡប់ទៅកងកុមារវិញ ដោយប្រាប់ថា ម្តាយរបស់ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅកាប់ឆ្ការព្រៃជីកប្រឡាយនិងធ្វើស្រែនៅការដ្ឋានដំណាក់ឈើក្រំក្នុងស្រុកភ្នំក្រវាញហើយ ។ នៅពេលឮដូច្នេះ ខ្ញុំភិតភ័យយ៉ាងខ្លាំងព្រោះបែកពីម្តាយ ហើយខ្ញុំក៏បានសុំមីងនៅជាមួយ ប៉ុន្តែគាត់បានបដិសេធថា «នៅកន្លែងមីងគ្មានរបបអាហារឲ្យក្មួយហូបទេ ហើយបើប្រធានក្រុមឬមេកងដឹង គេនឹងស្តី

បន្ទោសមីងមិនខាន» ។ ទោះបីមីងខ្ញុំឆ្លើយបដិសេធយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនព្រមត្រឡប់ទៅកងកុមារវិញដែរ រហូតដំណឹងនេះឮដល់ម្តាយខ្ញុំ ។ ក្រោយមក ម្តាយខ្ញុំក៏ផ្តាំផ្ញើតាមមីងចុងភៅម្នាក់ដែលដាំបាយនៅរោងបាយសហករណ៍ដំណាក់ឈើក្រំដែលត្រូវមកយកកូនរបស់គាត់ទៅនៅជាមួយឲ្យជួយយកខ្ញុំទៅជួបគាត់ផង ។ ខ្ញុំបានចេញដើរតាំងពីព្រឹកព្រលឹមរហូតដល់ថ្ងៃត្រង់ទើបមីងចុងភៅឈប់សម្រាកហូបបានជាមួយកូនរបស់គាត់ដោយមិនបានហៅខ្ញុំឲ្យហូបជាមួយទេ ទោះបីគាត់ឃើញខ្ញុំឃ្លានយ៉ាងណាក៏ដោយ ។ ខ្ញុំទ្រាំដើរទាំងហេវហត់និងអស់កម្លាំងរហូតដល់ពេលរសៀលទើបទៅដល់កន្លែងម្តាយខ្ញុំ ។ ខ្ញុំត្រេកអរយ៉ាងខ្លាំងនៅពេលឃើញម្តាយត្រឡប់មកពីធ្វើការវិញ ។ បន្ទាប់មក គាត់ក៏ទៅសុំបាយនៅរោងបាយសហករណ៍មកឲ្យហូប ប៉ុន្តែចុងភៅបានដួសបាយឲ្យតែបន្តិចប៉ុណ្ណោះ ព្រោះខ្ញុំមិនមែនអ្នកធ្វើការងារនៅសហករណ៍នេះ ។

ខ្ញុំរស់នៅជាមួយម្តាយបានមួយរយៈ អង្គការក៏ដើរប្រមូលក្មេងឲ្យចូលកងធ្វើការងារវិញ ។ ពេលនោះម្តាយខ្ញុំបានខ្សឹបប្រាប់ខ្ញុំឲ្យនិយាយកុហកថា «បើអង្គការសួរកូនថាធ្លាប់កើតជំងឺគ្រុនក្តៅ ហើយឬនៅ? កូនត្រូវឆ្លើយថា ខ្ញុំទើបតែកើតថ្មីៗនេះទេ ព្រោះអង្គការនឹងឲ្យកូនដើររើសខុស ហើយស្នាក់នៅក្នុងភូមិជាមួយម្តាយ» ។ ប៉ុន្តែបើក្មេងណាដែលកើតគ្រុនក្តៅយូរថ្ងៃហើយ អង្គការនឹងចាត់តាំងឲ្យទៅប្រូតស្រូវនិងជីកប្រឡាយដូចកម្លាំងចាស់ៗដែរ ហើយត្រូវរស់នៅបែកពីឪពុកម្តាយទៀត ។ ទោះបីជាខ្ញុំបានដឹងរឿងរ៉ាវទាំងអស់នេះហើយក៏ដោយ ប៉ុន្តែក្រោយមក នៅពេលដែលកម្មាភិបាលពេទ្យខ្មែរក្រហមមកសួរ ខ្ញុំបែរជាឆ្លើយការពិតថាខ្ញុំធ្លាប់កើតយូរហើយគឺតាំងពីសម័យ លន់ នល់ នៅពេលដែលខ្ញុំមានអាយុមួយឆ្នាំមកម្ល៉េះ ព្រោះពេលនោះខ្ញុំមានការភិតភ័យនិងខ្លាចអង្គការស្រាវជ្រាវដឹងពីការពិត ហើយចោទប្រកាន់ថាខ្ញុំកុហកអង្គការ ។

បន្ទាប់ពីដឹងប្រវត្តិរូបរបស់ខ្ញុំមក អង្គការក៏បញ្ជូនខ្ញុំឲ្យទៅជីកប្រឡាយនិងជញ្ជូនកណ្តាប់ស្រូវនៅការដ្ឋានឆ្ងាយពីភូមិ ហើយរៀងរាល់ពេលសម្រាកហូបបាយថ្ងៃត្រង់រួច មេកងតែងតែប្រមូលកុមារៗឲ្យចូលរៀននៅលើផ្ទះ ឬក្រោមផ្ទះប្រជាជនដែលម្ចាស់គេបោះបង់ចោល ។ ប៉ុន្តែដោយសារធ្វើការងារហត់នឿយនិងអស់កម្លាំង នៅពេលដល់ម៉ោងចូលរៀនម្តងៗ ខ្ញុំតែងតែគេចវេះមិនចូលថ្នាក់ទេ ។ ឃើញដូច្នេះ ម្តាយខ្ញុំនិយាយប្រាប់និងដាស់តឿនខ្ញុំឲ្យចូលរៀនជាមួយក្មេងៗនៅក្នុងកងវិញ ព្រោះខ្លាចគ្រូនិងប្រធានកងដឹងហើយចោទថាខ្ញុំខ្ជិល ។ ខ្ញុំចូលរៀនបានមួយរយៈ ប៉ុន្តែមិនមានចេះពាក្យអ្វីក្រៅពីអក្សរ ក, ខ ឬ ស្រៈ អ, អា ឡើយ ។

នៅយប់ថ្ងៃមួយ ខ្ញុំបានឮសំឡេងគ្រាប់កាំភ្លើងដែលបាញ់ជាច្រើនដង នៅពេលនោះកងចាស់ៗនិងក្មេងដែលដេកនៅរោងវែងដែលអង្គការសង់ឲ្យនៅបាននាំគ្នារត់ចុះមកក្រាបលើដីទាំងភ័យស្លន់ស្លោ ។ នៅទីនោះ ខ្ញុំឮស្នូរកាំភ្លើងស្ទើររៀងរាល់ថ្ងៃដែលធ្វើឲ្យម្តាយខ្ញុំមានការបារម្ភយ៉ាងខ្លាំង ព្រោះគាត់តែងតែចេញទៅធ្វើការនៅការដ្ឋានឆ្ងាយពីខ្ញុំ ។ ថ្ងៃមួយ ដោយមានសំឡេងគ្រាប់កាំភ្លើងផ្ទុះកាន់តែខ្លាំង ប្រជាជនមូលដ្ឋានទាំងអស់បានរត់ទៅពួននៅក្នុងព្រៃខាងលិចប្រឡាយដោយទុកតែកងឈ្លបប្រុសៗប៉ុណ្ណោះដើម្បីការពាររោងនិងគ្រប់គ្រងប្រជាជនថ្មី ។

មុនពេលចូលឆ្នាំខ្មែរឆ្នាំ១៩៧៩ នៅថ្ងៃមួយកងទ័ពវៀតណាមបានបើករថក្រោះចូលដល់ភូមិដំណាក់ឈើក្រំនិងបាញ់ស្រោចមកលើរោងដែលកងឈ្លបនិងប្រជាជនថ្មីរស់នៅ ។ ខណៈនោះ ខ្ញុំនិងម្តាយ ព្រមមីងធម៌រត់ទៅពួននៅក្នុងលេណដ្ឋាននៅខាងក្រោយរោង ប៉ុន្តែដោយមានការស្លន់ស្លោនិងភិតភ័យខ្លាំងពេក ខ្ញុំស្រែកយំយ៉ាងខ្លាំងរហូតដល់ម្តាយខ្ញុំយកដៃរបស់គាត់មកខ្ទប់មាត់ខ្ញុំ រួចរុញក្បាលខ្ញុំឱនចុះក្រោម ព្រោះខ្លាចអំបែងគ្រាប់ខ្ទាតត្រូវ ។ ពេលស្នូរកាំភ្លើងស្ងប់ស្ងាត់ទើបម្តាយខ្ញុំដឹកដៃខ្ញុំចេញពីរណ្តៅរួចរត់ចូលទៅក្នុងរោងវិញ ។ ខណៈនោះស្រាប់តែមានសំឡេងស្រែកប្រាប់ថា «យួនដើរចូលមកហើយ» ។ ឮការស្រែកប្រកាសនេះភ្លាម ម្តាយរបស់ខ្ញុំនិងមីងធម៌បានរត់ទៅពួនក្នុងរណ្តៅវិញអស់នៅសល់តែខ្ញុំដែលកៀបជាប់នៅជ្រុងគ្រែហើយស្រែកយំយ៉ាងខ្លាំង រួចហើយខំរើបម្រះរហូតដោះខ្លួនរួច ។ បន្តិចក្រោយមកកងទ័ពវៀតណាមបានចូលមកដល់រោង ហើយបានប្រកាសប្រាប់ប្រជាជនទាំងអស់ឲ្យវិលត្រឡប់ទៅស្រុកកំណើតវិញ ។

ម្តាយខ្ញុំបានប្រមូលយកខោអាវ ចាន ឆ្នាំង និងអង្ករដែលនៅសេសសល់បន្តិចបន្តួចទុកសម្រាប់ហូប ។ នៅតាមផ្លូវធ្វើដំណើរ ខ្ញុំជួយកាន់តែកំសៀវមួយប៉ុណ្ណោះព្រោះខ្ញុំគ្មានកម្លាំងកំហែង

ទេ ។ ខ្ញុំនិងម្តាយមកស្នាក់នៅបណ្តោះអាសន្នជាមួយគ្រួសារមីងធម៌ដែលមានផ្ទះថ្មពីរជាន់នៅខាងកើតស្ទឹងពោធិ៍សាត់ ។ ប៉ុន្តែក្រោយមកដោយសារបងប្អូនរបស់មីងមករស់នៅជាមួយកាន់តែច្រើន ខ្ញុំនិងម្តាយក៏សម្រេចចិត្តបែកផ្ទះចេញមករស់នៅជាមួយប្រជាជនដម្លៀសជាច្រើនគ្រួសារលើផ្ទះឈើមួយខ្នងនៅខាងលិចស្ទឹងវិញ ។ ម្តាយខ្ញុំក៏បានចូលធ្វើគ្រូបង្រៀនដូចមុន ដោយទទួលបានរបបអង្ករតែបន្តិចបន្តួចប៉ុណ្ណោះ ហើយពេលខ្លះគាត់បានដើររកអង្កររហូតដល់ភូមិនិងឃុំឆ្ងាយៗដែលខ្មែរក្រហមបោះបង់ចោល ។ ក្រោយមក ម្តាយខ្ញុំបានមករកផ្ទះជីតារបស់ខ្ញុំដែលស្ថិតនៅក្បែររបងពេទ្យកុមារជាតិប៉ុន្តែមានប្រជាជនចូលមករស់នៅពេញអស់ហើយ ។ ខណៈនោះ ម្ចាស់ថ្មីនេះបានហៅម្តាយខ្ញុំឲ្យមករស់នៅជាមួយ ប៉ុន្តែដោយសារភ័យខ្លាចរបបខ្មែរក្រហមកើតឡើងម្តងទៀត គាត់ក៏ត្រឡប់មករស់នៅក្នុងខេត្តពោធិ៍សាត់វិញ ។

ខ្ញុំរស់នៅតែពីរនាក់ម្តាយប៉ុណ្ណោះ ហើយក្រោយមកម្តាយខ្ញុំបានក្លាយទៅជាមនុស្សមានជំងឺផ្លូវចិត្តដោយសារតែបាត់បង់ប្តីនិងកូនពីរនាក់ ។ នៅរៀងរាល់យប់ ខ្ញុំភ័យខ្លាចសំឡេងកណ្តុរដែលចូលមកកាត់ខ្សែអង្រឹងដែលខ្ញុំដេកជាមួយម្តាយ ។ ចំណែកម្តាយខ្ញុំនៅពេលជំងឺគាត់រើឡើងម្តងៗ គាត់តែងតែនិយាយគ្មានដឹងខុសត្រូវទេ ហើយពេលខ្លះគាត់ស្ទុះរត់ទៅយំខាងមុខផ្ទះទាំងមិនដឹងខុសត្រូវ ។ ឃើញដូច្នេះ ខ្ញុំរត់ទៅចាប់ម្តាយជាប់ព្រោះខ្លាចគាត់ធ្លាក់ទៅដី ប៉ុន្តែគាត់តែងតែរុញខ្ញុំចេញនិងមិនឲ្យនៅជិតគាត់ឡើយ ។ នៅពេលក្រោយមក ដោយឃើញជំងឺរបស់ម្តាយខ្ញុំកាន់តែធ្ងន់ធ្ងរ លោកគ្រូអ្នកគ្រូដែលបង្រៀននៅសាលាជាមួយគាត់បានបញ្ជូនម្តាយខ្ញុំឲ្យទៅសម្រាកព្យាបាលនៅពេទ្យបឹងហ្កាឡូវ (បច្ចុប្បន្នស្ថានីយប្រេងឥន្ធនៈ) រហូតបានធូរស្បើយ ។

ក្រោយមក ម្តាយខ្ញុំបានបញ្ជូនខ្ញុំឲ្យចូលហាត់របាំនៅមន្ទីរវិចិត្រសិល្បៈខេត្តពោធិ៍សាត់ដែលមានចម្ងាយ៥គីឡូម៉ែត្រពីផ្ទះរបស់ខ្ញុំ ។ រៀងរាល់ថ្ងៃ ខ្ញុំត្រូវចូលរៀនពីរពេលនិងនៅពេលថ្ងៃត្រូវដើរត្រឡប់មកដាំហូបទៀត ។ ហ្វឹកហាត់បានមួយរយៈ ខ្ញុំបានប្រាប់ម្តាយថា «ម៉ែកូនសុំឈប់ទៅហាត់ទៀតហើយ ព្រោះដើរឆ្ងាយណាស់កូនមិនមានកម្លាំងទេ» ហើយខ្ញុំក៏សុំគាត់មកចូលរៀនថ្នាក់ទី១នៅសាលាជិតផ្ទះវិញ ។ ខ្ញុំបានខិតខំរៀនរហូតដល់ឆ្នាំ ១៩៨៩ ក៏បានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បន្ទាប់មកបានប្រឡងជាប់ចូលរៀនផ្នែកប្រវត្តិវិទ្យានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញរយៈពេល៤ឆ្នាំ ហើយក្រោយពីរៀនចប់នៅឆ្នាំ១៩៩៤ ខ្ញុំបានបម្រើការងារនៅសាលាគរុកោសល្យភូមិភាគកំពង់ចាម ។ នៅឆ្នាំ១៩៩៨ ខ្ញុំបានផ្លាស់មកធ្វើការនៅសាលាគរុកោលស្យភូមិភាគអូរបែកក្អម និងបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យានៅវិទ្យាល័យបាក់ទូក រហូតដល់ឆ្នាំ២០០០ទើបខ្ញុំប្រឡងជាប់គ្រូអធិការផ្នែកប្រវត្តិវិទ្យា ។ នៅឆ្នាំ២០០១ ខ្ញុំចេញទៅធ្វើការនៅមន្ទីរអប់រំខេត្តមណ្ឌលគិរីមួយឆ្នាំ ទើបប្តូរមកបម្រើការងារនៅនាយកដ្ឋានសិក្សាចំណេះទូទៅក្នុងក្រុងភ្នំពេញ រហូតដល់ឆ្នាំ ២០០៩ ទើបក្រសួងអប់រំជ្រើសរើសឲ្យធ្វើជាគ្រូបង្រៀនថ្នាក់ជាតិបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

សព្វថ្ងៃខ្ញុំមានកូនចំនួន៥នាក់ ហើយខ្ញុំតែងតែនិយាយពីរឿងរ៉ាវរបស់ខ្ញុំដែលបានឆ្លងកាត់និងជួបប្រទះក្នុងរបបខ្មែរក្រហមប្រាប់ដល់កូនៗជានិច្ចដូចពេលដែលខ្ញុំបង្រៀនសិស្សពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់ដែរដើម្បីឲ្យគេចេះគិតពិចារណានិងខិតខំរៀនសូត្រ ។

**សោម ប៊ុនថន**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# គង់ ហាក់ : ជីវិតយុវជនម្នាក់ក្នុងរបបខ្មែរក្រហម


គង់ ហាក់

ក្រោយពីកងទ័ពខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ហាក់ និងប្រជាជនទាំងអស់មានសេចក្តីត្រេកអរជាខ្លាំង ហើយថែមទាំងនាំគ្នាទះដៃអបអរសាទរដើម្បីស្វាគមន៍កងទ័ពខ្មែរក្រហមទៀត ។ ប៉ុន្តែអ្វីៗបានផ្លាស់ប្តូរទាំងស្រុងដោយខ្មែរក្រហមបានផ្តើមជម្លៀសប្រជាជនចេញពីភូមិរួចបង្ខំឲ្យប្រជាជនធ្វើការគ្រប់ៗគ្នា ។ ហាក់ មានអាយុប្រហែល១៧ឆ្នាំត្រូវបានអង្គការចាត់តាំងឲ្យចូលកងចល័តដែលមានសមាជិកទាំងអស់ប្រហែល៤០នាក់ មានភារកិច្ចកើបអាចម៍គោ លើកទំនប់និងជីកប្រឡាយក្រោមការគ្រប់គ្រងរបស់មេកងឈ្មោះ ហឿង ។ នៅទីនោះ ខ្មែរក្រហមមិនមានការរើតបន្តឹងរវាងអ្នក១៧មេសានិងប្រជាជនមូលដ្ឋានទេ ។

ប្រហែលជាឆ្នាំ១៩៧៦ ខ្មែរក្រហមក៏ជម្លៀសគ្រួសាររបស់ ហាក់ ទៅរស់នៅទល់ដែនវៀតណាមវិញ ។ នៅទីនោះខ្មែរក្រហមបានបង្ខំឲ្យ ហាក់ ធ្វើការទាំងថ្ងៃទាំងយប់ ដូចជាលើកទំនប់និងជីកប្រឡាយជម្រៅ២ម៉ែត្រ ទទឹង៥ម៉ែត្រ ។ ពេលខ្លះទោះបីជាជីកប្រឡាយហើយតាមការកំណត់ក៏ដោយ ប៉ុន្តែខ្មែរក្រហមមិនបានឲ្យគាត់ឈប់សម្រាកទេ បែរជាបន្ថែមការងារឲ្យគាត់ទៀត ។ ហាក់ នៅចាំបានថា នៅពេលរដូវទឹកឡើង ខ្មែរក្រហមឲ្យវែកដីទប់ទំនប់ដើម្បីកុំឲ្យទឹកលិចភ្លឺចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង១២យប់ទើបបានសម្រាក ។ លើសពីនេះទៅទៀត ហាក់ មានការបារម្ភអំពីសុវត្ថិភាពរបស់ខ្លួនជានិច្ច ព្រោះពេលដែលអង្គការមានបំណងចង់យកអ្នកណាម្នាក់ទៅសម្លាប់ អង្គការតែងតែប្រាប់ថាហៅទៅណែនាំឬផ្លាស់ទៅការដ្ឋានថ្មីមួយទៀត ។ បន្ទាប់មក អ្នកទាំងនោះនឹងត្រូវបាត់ខ្លួនជាមិនខាន ។

មួយរយៈក្រោយមក ហាក់ បានធ្លាក់ខ្លួនឈឺ ដោយសារតែធ្វើការហួសកម្លាំង និងហូបចុកមិនបានគ្រប់គ្រាន់ រហូតអង្គការបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យឃុំ ។ ដោយសារជំងឺនេះមានសភាពធ្ងន់ធ្ងរពេក ហាក់ ក៏ត្រូវបានបញ្ជូនតាមកាណូតមកព្យាបាលនៅមន្ទីរពេទ្យស្រុក ក្នុងឃុំសំពៅពូន ស្រុកកោះធំ រយៈពេល៦ខែទៀត ។ ដោយសារតែអង្គការមិនអនុញ្ញាតឲ្យមានអ្នកមកសួរសុខទុក្ខអ្នកជំងឺ ដូច្នេះ គ្មានសាច់ញាតិណាម្នាក់បានមកមើល ហាក់ ឡើយ ។ ប៉ុន្តែ ដោយពេលនោះជាថ្ងៃគម្រប់ខួបជ័យជម្នះ១៧មេសា ប្រជាជនទាំងអស់ត្រូវបានអនុញ្ញាតឲ្យសម្រាក ដូច្នេះម្តាយរបស់ ហាក់ ក៏បានមករក ហាក់ នៅមន្ទីរពេទ្យតែមិនបានជួបគាត់ឡើយ ។ ចំណែកការព្យាបាលវិញ ពេទ្យមិនសូវយកចិត្តទុកដាក់ចំពោះអ្នកជំងឺទេ ដោយផ្តល់តែថ្នាំមានលក្ខណៈដូចជាថ្នាំឫសឈើប៉ុណ្ណោះ លេបម្តងក្នុងមួយថ្ងៃនិងមិនមានការព្យួរសេរ៉ូមឲ្យអ្នកជំងឺទេ ។ រយៈពេលមួយសប្តាហ៍ក្រោយមក ហាក់ ក៏បានជាសះស្បើយពីជំងឺ ។

ពេលដែលវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ ហាក់ បានឃើញទាហានខ្មែរក្រហមជាច្រើននាក់បាក់ទ័ពនិងរត់ភៀសខ្លួនត្រឡប់ទៅលំនៅឋានរៀងៗខ្លួនអស់ ។ ពេលនោះ គ្រួសាររបស់ ហាក់ ក៏ដូចជាគ្រួសារដទៃទៀតប្រញាប់ប្រញាល់រត់មកស្រុកកំណើតវិញដែរ ។ មកដល់ផ្ទះ គ្រួសាររបស់ ហាក់ សប្បាយចិត្តជាខ្លាំងព្រោះបងប្អូនរបស់គាត់នៅមានជីវិតទាំងអស់គ្នា ។

ប៉ុន្តែ ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅអស់រយៈពេល៣០ឆ្នាំនិងមានតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមហើយក៏ដោយ ក៏ ហាក់ នៅតែមានអារម្មណ៍ខឹងនឹងមេដឹកនាំខ្មែរក្រហមដដែលព្រោះរបបនេះបានបំផ្លាញសមិទ្ធផលប្រទេសស្ទើរអស់គ្មានសល់ ជាពិសេសបានសម្លាប់ប្រជាពលរដ្ឋអស់ជិតពីរលាននាក់ ។ ដូច្នេះ ហាក់ យល់ថា ការដាក់បញ្ចូលកម្មវិធីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅក្នុងកម្មវិធីអប់រំរបស់សិស្សពិតជាមានសារសំខាន់ខ្លាំងណាស់ ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងនិងជឿថាមានរបបនេះមែន ព្រមទាំងអាចទប់ស្កាត់កុំឲ្យរបបនេះកើតឡើងជាលើកទីពីរទៀត ។ មិនតែប៉ុណ្ណោះ កូនខ្មែរនៅជំនាន់ក្រោយៗនឹងបានដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួនច្បាស់លាស់ ។ **គាត លក្ខិណា**

# រាជ លីម៖ អតីតប្រធានកងក្នុងភូមិភាគបូព៌ា


រាជ លីម

រាជ លីម អាយុ៧២ ឆ្នាំ មានឪពុកឈ្មោះ រាជ នូ និងម្តាយឈ្មោះ ឡុង សោ ជាកសិករ ។ លីម មានបងប្អូនចំនួន៧នាក់គឺឈ្មោះ រាជ សៀង, រាជ ទូច, រាជ សាន់, រាជ កៀង, រាជ លីម (ខ្លួនឯង), រាជ មឿន, និង រាជ លន់ ហើយមានស្រុកកំណើតនៅឃុំធូក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។

នៅអំឡុងឆ្នាំ១៩៧០ កម្មាភិបាលខ្មែរក្រហមបានចូលមកបំផុសបំផុលប្រជាជននៅក្នុងស្រុកស្វាយជ្រុំឲ្យរត់ចូលព្រៃ ហើយគ្រួសាររបស់ លីម និងអ្នកភូមិទាំងអស់បានទៅជាមួយដែរ ។ នៅទីនោះ កម្មាភិបាលខ្មែរក្រហមបានតម្រូវឲ្យធ្វើស្រែរួមនិងចែកអង្ករឲ្យហូបតាមគ្រួសារ ។ នៅឆ្នាំ១៩៧១ ប្តីរបស់ លីម ឈ្មោះ ឃឹម វ៉ាន់ ចូលធ្វើការខាងសង្គមកិច្ច ដោយដើរឃោសនាប្រាប់អ្នកស្រុកអំពីប្រជាជនដែលបានឈឺស្លាប់និងឈឺរ៉ាំរ៉ៃ ព្រមទាំងអង្គាសប្រាក់ពីអ្នកស្រុកទាំងនោះដើម្បីយកមកជួយដល់ជនរងគ្រោះនិងអ្នកស្លាប់ ។ លុះដល់ឆ្នាំ១៩៧២ ខ្មែរក្រហមបានចាត់តាំងឲ្យ ឃឹម វ៉ាន់ ធ្វើជាអ្នកឃោសនាផ្នែកវប្បធម៌ ។ នៅឆ្នាំ១៩៧៤ ឃឹម វ៉ាន់ បានឡើងធ្វើជាប្រធានឃុំស្វាយចេក ចំណែក លីម ធ្វើជាប្រធានកងដែលមានតួនាទីធ្វើជីធម្មជាតិ ហើយមានសមាជិកទាំងអស់ចំនួន ២៨នាក់ ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមបែងចែកជាប្រជាជនចាស់និងប្រជាជនថ្មីដោយមិនអនុញ្ញាតឲ្យរស់នៅជាមួយគ្នាឡើយ ។ នៅពេលមានប្រជុំម្តងៗ ប្រជាជនថ្មីគ្មានសិទ្ធិចូលរួមប្រជុំជាមួយប្រជាជនចាស់ឡើយ ចំណែកការហូបចុកនិងការរស់នៅក៏មានការតឹងរ៉ឹងជាងប្រជាជនចាស់ដែរ ។ លើសពីនេះទៀត កាលណាប្រព្រឹត្តខុសប្រជាជនថ្មីនឹងត្រូវបញ្ជូនទៅរៀនសូត្រ ហើយមានពេលខ្លះក៏បាត់ដំណឹងរហូត ។

នៅឆ្នាំ១៩៧៧ នៅម៉ោងប្រហែលជាប្រាំពីរយប់ ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ លីម ឲ្យទៅរស់នៅក្នុងខេត្តពោធិ៍សាត់ដោយនិយាយថា «សមមិត្តឯងទៅរស់នៅក្នុងស្រុកនោះទៅពីព្រោះនៅស្រុកនោះសម្បូរហូបណាស់» ។ កាលនោះដោយសារភូមិភាគបូព៌ាជាប់និន្នាការក្បត់ក្រោមការចោទប្រកាន់ពីមជ្ឈិមបក្ស គណៈស្រុកឈ្មោះ បូរ៉ា វ៉ាន់ ក៏ត្រូវចាប់ខ្លួន ។ ការចាប់ខ្លួនក៏មានជាបន្តដោយទីបំផុតប្តីរបស់ លីម ក៏ត្រូវជាប់ចោទថាក្បត់ដែរដោយសារគាត់ធ្លាប់ធ្វើការជាមួយគណៈស្រុក ។ ដោយសំណាងល្អ ប្តី របស់ លីម មិនត្រូវបានយកទៅសម្លាប់ទេ តែកម្មាភិបាលថ្មីបានជម្លៀសគ្រួសាររបស់ លីម ទៅរស់នៅខេត្តពោធិ៍សាត់វិញ ។ លីម បាន រៀបរាប់ថា កម្មាភិបាលទាំងនោះមិនបានប្រាប់ដំណឹងឲ្យប្រជាជនរៀបចំអីវ៉ាន់ជាមុនទេ ដោយគ្រាន់តែប្រាប់ថាឲ្យចេញដំណើរទៅពោធិ៍សាត់ភ្លាមៗតែម្តង ។ អ្វីដែលគ្រួសាររបស់ លីម អាចយកទៅបានគឺមានតែខោអាវជាប់នឹងខ្លួននិងអង្ករប្រាំកំប៉ុងប៉ុណ្ណោះ ។ គ្រួសាររបស់ លីម និងអ្នកផ្សេងទៀតបានចេញដំណើរទៅពោធិ៍សាត់ដោយថ្មើរជើងពីស្វាយរៀងទៅកាន់កំពង់ចម្លងព្រែកក្តាម ។ ទៅដល់ព្រែកក្តាមមាន ទូកម៉ាស៊ីននិងទាហានខ្មែរក្រហមជាច្រើនបានឈរចាំនៅទីនោះរួចជាស្រេចដើម្បីដឹកអ្នកមកពីស្វាយរៀងទៅពោធិ៍សាត់ ។

ទៅដល់ពោធិ៍សាត់ ប្រជាជនដែលទើបជម្លៀសមកពីខេត្តស្វាយរៀងក៏មិនត្រូវឲ្យនៅជុំគ្នាដែរ ។ គ្រួសារខ្លះត្រូវបង្ខំឲ្យទៅនៅតំបន់ស្វាយរូងដែលជាកន្លែងមានការកាប់សម្លាប់ជាច្រើន ។ ចំណែកក្រុមរបស់ លីម ត្រូវទៅរស់នៅក្នុងភូមិបឹងព្រៃ ស្រុកបាកានដោយខ្មែរក្រហមបានសង់ផ្ទះជាជួរៗដែលផ្ទះនីមួយៗមានប្រជាជនប្រហែលបីទៅបួនគ្រួសាររស់នៅ ។ ក្រោយមក អង្គការបានចាត់ចែងឲ្យ លីម ទៅកាប់ដី ដាំបន្លែ និងស្រោចទឹកដំណាំនៅក្បែរភូមិ ហើយកូនៗរបស់គាត់ធ្វើជាអ្នកប្រមូលលាមកគោ

ចំណែកប្តីរបស់គាត់ធ្វើជាជាងដែកនិងជួសជុលរទេះចាស់ៗ ។ រំលងបានប្រហែលមួយខែ អង្គការបានបញ្ជាឲ្យ លឹម ទៅកិនអង្ករវិញ ។ លុះក្រោយមក សមាជិកក្នុងក្រុមកិនអង្ករទាំងអស់ត្រូវអង្គការតម្រូវឲ្យលីអង្ករដើម្បីទុកក្នុងឃ្លាំង ។ អ្នកខ្លះបានលីអង្កររហូតដល់បាក់កម្លាំងនិងធ្លាក់ខ្លួនឈឺ ម្យ៉ាងដោយសារខ្វះអាហារហូបចុកគ្រប់គ្រាន់ ។ លឹម បានរៀបរាប់ថា កម្មាភិបាលខ្មែរក្រហមប្រុងនឹងយកគាត់ទៅសម្លាប់ជាច្រើនលើកច្រើនសាមកហើយដោយសារតែកំហុសតិចតួច និងដោយសារគាត់ជាអ្នកមកពីភូមិភាគបូព៌ាផង ។ លឹម រឹតតែមានចិត្តរន្ធត់ថែមទៀតនៅពេលដែលឃើញឆ្អឹងនិងលលាដ៏ក្បាលមនុស្សស្ទើងតែគ្រប់ទីកន្លែង ។ កម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យក្មួយប្រុសរបស់គាត់ម្នាក់ទៅជីករណ្តៅកប់សាកសព ហើយក្មួយនោះតែងតែយករឿងគាត់មកប្រាប់ លឹម ជារៀងរាល់ពេល ។

កម្មាភិបាលខ្មែរក្រហមនៅខេត្តពោធិ៍សាត់មិនដឹងពីប្រវត្តិរបស់ប្តី លឹម ដែលធ្លាប់ធ្វើជាមេឃុំទេ ដោយសារប្រជាជនដែលមកពីខេត្តស្វាយរៀងដូចគ្នាជួយលាក់ការណ៍ ។ លឹម បានរៀបរាប់ពីស្ថានភាពរស់នៅក្នុងនៅស្រុកបាកានថា ពីមួយថ្ងៃទៅមួយថ្ងៃការរស់នៅតែលំបាកទៅៗ ហើយមនុស្សម្នាក់ៗកាន់តែលែងទុកចិត្តគ្នាទៅវិញទៅមកដោយមិនហ៊ាននិយាយរឿងសម្ងាត់អ្វីប្រាប់គ្នាទេ ។

ល្ងាចថ្ងៃមួយ លឹម បានឡើងនិយាយពីការលំបាកក្នុងការរស់នៅការហូបចុក និងធ្វើពលកម្មក្នុងអង្គប្រជុំជាមួយប្រជាជនទាំងអស់ ។ ការនិយាយបែបនេះ ធ្វើឲ្យប្រធានរោងបាយស្រីម្នាក់ឈ្មោះ សឿន ខឹងសម្បា ហើយនិយាយថា «ពួកបូព៌ាស៊ីច្រើនណាស់ ឯងខំដាំស្ងោ ហត់ចង់ងាប់» ។ ភ្លាមនោះ លឹម ក៏សុំមានយោបល់បន្ត ហើយលើកឡើងថា «ទោះជាចែកអង្ករឲ្យខ្ញុំមួយកំប៉ុងបីនាក់ក៏ដោយ ក៏ខ្ញុំសុំឲ្យអង្គការចែកឲ្យដើម្បីក្រុមខ្ញុំដាំបាយហូបខ្លួនឯងដែរ» ។ សឿន កាន់តែខឹងខ្លាំងឡើង ហើយឆ្លើយតបទៅ លឹម វិញថា «អ្នកណាហ៊ាននិយាយអីចឹង?» សំណាងល្អមានមីងម្នាក់បានជួយ លឹម ដោយនិយាយថា «មីងឲ្យ លឹម ខំកិនអង្ករហត់ណាស់ អីចឹងកុំរករឿងគាត់អី» ។ ព្រឹកថ្ងៃបន្ទាប់ វេលាម៉ោងប្រហែលជា៦ព្រឹក ប្តីរបស់នារី សឿន ឈ្មោះ អៀង បានកាន់កាំបិតខ្វែវ ហើយដើរសំដៅទៅផ្ទះរបស់ លឹម ។ ពេលទៅដល់ អៀង បាននិយាយទៅកាន់ លឹម ថា «មួយណាឡើងនិយាយល្ងាចមិញ?» នៅពេលនោះ លឹម ភ័យខ្លាំងណាស់ ហើយគិតថាខ្លួនឯងប្រាកដជាត្រូវស្លាប់ជាមិនខាន ប៉ុន្តែសំណាងល្អមានប្រធានក្រុមម្នាក់ជួយនិយាយទៅវិញថា «អៀង ឯងត្រឡប់ទៅវិញចុះ ទៅគ្រប់គ្រងនៅកន្លែងរបស់ អៀង ឯងទៅ នៅទីនេះមានខ្ញុំមើលការខុសត្រូវហើយ មិនចាំមកត្រួតត្រានៅកន្លែងរបស់ខ្ញុំទេ» ។ ដោយសារតែសម្តីបែបនេះហើយ ទើបធ្វើឲ្យ អៀង លីកាំបិតខ្វែវត្រឡប់ទៅផ្ទះវិញទាំងធ្លាក់ទឹកមុខ ។

មួយរយៈក្រោយមក មានលេចឮដំណឹងថាកងទ័ពវៀតណាមលើកទ័ពចូលមកប្រទេសកម្ពុជា ។ មុនពេលកងទ័ពវៀតណាមចូលមកដល់ សភាពការណ៍នៅក្នុងភូមិមិនទាន់មានភាពជ្រួលច្របល់ខ្លាំងទេ ដោយសារប្រធានកងទាំងអស់ព្យាយាមលាក់បាំង ។ ប៉ុន្តែក្រោយពីប្រជាជនបានដឹងពីរឿងនេះ ក៏នាំអាទ៏និយាយប្រាប់គ្នាពីម្នាក់ទៅម្នាក់ ។ ជាមួយគ្នានោះដែរ កម្មាភិបាលខ្មែរក្រហមបានបង្កើនការសម្លាប់កាន់តែច្រើនឡើងៗជារៀងរាល់ថ្ងៃ ។ ពេលនោះ ខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនជីករណ្តៅដែលមានជម្រៅពីរម៉ែត្រដោយកុហកថាជីកដើម្បីកប់ស្រូវតែតាមការពិតគឺជីកដើម្បីកប់សាកសពប្រជាជនដែលត្រូវកម្មាភិបាលខ្មែរក្រហមសម្លាប់តែប៉ុណ្ណោះ ។

ក្រុមគ្រួសាររបស់ លឹម អាចរស់រានមានជីវិតដោយសារប្រធានកងជួយការពារ តែប្រជាជនជាច្រើនដែលមកពីខេត្តស្វាយរៀងមិនមានសំណាងដូចគាត់ទេ ។ ប្រធានកងនោះបានប្រាប់ឲ្យគ្រួសាររបស់ លឹម រត់គេចទោះបីជាទ័ពខ្មែរក្រហមមិនអនុញ្ញាតក៏ដោយ ។ ប្រធានកងបានប្រាប់ លឹម ថាប្រជាជនមកពីខេត្តស្វាយរៀងគឺជាមុខសញ្ញានៃការសម្លាប់ទាំងអស់ ។

ក្រោយមក គ្រួសាររបស់ លឹម បាននាំគ្នារត់ ហើយក៏ជួបនឹងកងទ័ពវៀតណាមនៅតាមផ្លូវដោយចៃដន្យ ។ សមាជិកគ្រួសាររបស់ លឹម ទាំងអស់បានត្រឡប់មកភូមិកំណើតឯខេត្តស្វាយរៀងវិញតាមរថយន្តរបស់កងទ័ពវៀតណាម ។ លឹម បានរស់នៅខេត្តស្វាយរៀងរហូតមកដល់សព្វថ្ងៃនេះ ។

**ទេស ម៉ារ៉ែម**

# យិន សុធា : គ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

យិន សុធា គឺជាអតីតគ្រូបង្រៀនប្រវត្តិវិទ្យានៅវិទ្យាល័យ ហ៊ុន សែនស្គន់ បច្ចុប្បន្នជាមន្ត្រីការិយាល័យសិក្សាសង្គមរបស់ក្រសួងអប់រំយុវជននិងកីឡា ។ ទោះបី សុធា ជាយុវជនម្នាក់ដែលកើតនៅក្រោយរបបខ្មែរក្រហមក៏ដោយ ក៏គាត់ធ្លាប់ដឹងរឿងរ៉ាវជាច្រើនអំពីរបបនោះតាមរយៈឪពុកម្ដាយនិងបងប្អូនរបស់គាត់ដែរ ។ សុធា បានរៀបរាប់ថាៈ ឪពុករបស់ខ្ញុំបានបញ្ចប់ការសិក្សាថ្នាក់យុតិយភូមិនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច គ្រួសាររបស់ឪពុកខ្ញុំត្រូវខ្មែរក្រហមជម្លៀសពីភ្នំពេញតាមផ្លូវជាតិ ៦A ទៅឃុំបុសខ្នុរ ស្រុកចម្ការលើ ខេត្តកំពង់ចាម ដែលស្ថិតនៅក្នុងតំបន់៤២ ក្រោមការគ្រប់គ្រងរបស់ កុយ ធួន (ប្រធានភូមិភាគឧត្តរ ហើយក្រោយមកតំបន់នេះត្រូវបានបញ្ចូលទៅក្នុងភូមិភាគកណ្ដាលក្រោមការដឹកនាំរបស់ កែ ពក) ។ នៅទីនោះ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនទាំងអស់ធ្វើការជាទម្ងន់ ប៉ុន្តែដោយសារវាជាតំបន់ដែលសម្បូរទៅដោយផ្លែឈើហូបផ្លែ ឪពុកខ្ញុំបានឆ្លៀតឱកាសលួចបេះផ្លែឈើទាំងនោះបរិភោគបន្ថែមលើរបបអាហារដែលមានតែបបររាវពីរវែកប៉ុណ្ណោះ ។ ក្រោយមក ដោយមានការរាប់អានជាមួយគ្រួសារម្ដាយខ្ញុំនិងពេញចិត្តទៅលើម្ដាយខ្ញុំ ឪពុកខ្ញុំបានសុំលោកយាយចូលទៅសួរម្ដាយខ្ញុំ បន្ទាប់មកស្នើទៅអង្គការនិងចាស់ទុំដើម្បីរៀបការ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ឪពុកម្ដាយរបស់ខ្ញុំបានត្រឡប់មករស់នៅក្នុងទីក្រុងភ្នំពេញវិញ ។ ដោយសារឪពុករបស់ខ្ញុំធ្លាប់រៀនសូត្របានច្រើន នៅឆ្នាំ១៩៨១ គាត់ទទួលបានតំណែងជាប្រធានមណ្ឌលទី២៨នៅបឹងរាំង គ្រប់គ្រងការស្នាក់នៅរបស់ប្រជាជននៅក្នុងមណ្ឌលទាំងអ្នកចំណូលថ្មី និងអ្នកមូលដ្ឋាន ហើយគ្រួសារមានជីវភាពធូរធារល្មម ។ ជាអកុសល ឆ្នាំ១៩៨៤ ឪពុកខ្ញុំបានទទួលមរណភាពដោយសារជំងឺ ។

យិន សុធា បានបន្តទៀតថា គាត់ក៏ធ្លាប់ដឹងពីរឿងរ៉ាវខ្មែរក្រហមតាមសាលារៀនផងដែរ ពីព្រោះថានៅពេលដែលគាត់នៅរៀនឃើញមានឆ្លាក់អក្សរនៅតាមជញ្ជាំងជារាងឆ្អឹងខ្មោច និងមានឈាមនៅក្នុងនោះផងដើម្បីរំឭកដល់របបខ្មែរក្រហម ។ ជាងនេះទៅទៀត នៅក្នុងសៀវភៅមេរៀនសីលធម៌ នយោបាយនិងភាសាខ្មែរក៏មានរៀបរាប់ពីរឿង អៀង សារី និង ប៉ុល ពត ព្រមទាំងមានប្រើពាក្យពេចន៍ទាក់ទងនឹងរបបនោះជាច្រើនដែរ ។ រហូតមកដល់ឆ្នាំ១៩៨៦-១៩៨៧ ក៏មានការបញ្ចូលប្រវត្តិខ្មែរក្រហមនៅក្នុងមុខវិជ្ជាប្រវត្តិវិទ្យា ប៉ុន្តែក្រោយមកដោយហេតុផលនយោបាយ ក៏មានការដកកម្មវិធីសិក្សាអំពីរបបខ្មែរក្រហមចេញវិញ ។

យិន សុធា យល់ឃើញថា ការបញ្ចូលកម្មវិធីសិក្សាអំពីរបបខ្មែរក្រហមចូលក្នុងកម្មវិធីសិក្សាម្ដងទៀតនេះ គឺជាការត្រឹមត្រូវល្អណាស់ ព្រោះអាចធ្វើឲ្យក្មេងជំនាន់ក្រោយយល់ដឹងកាន់តែច្បាស់អំពីភាពសាហាវឃោរឃៅនិងការប្រើប្រាស់អំពើហិង្សារំលោភសិទ្ធិមនុស្សដែលមេដឹកនាំរបបនោះបានប្រព្រឹត្ត ។ ម្យ៉ាងវិញទៀត ការបង្ហាត់បង្រៀនអំពីរបបនេះនៅខណៈពេលដែលសាលាក្ដីខ្មែរក្រហមឬអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែដំណើរការកាត់ទោសមេដឹកនាំទាំង៥រូបអាចធ្វើឲ្យក្មេងៗមានការយកចិត្តទុកដាក់និងចាប់អារម្មណ៍ទៅលើប្រធានបទនេះកាន់តែខ្លាំង ។

ខាងក្រោមនេះគឺជាកំណាព្យផ្សះផ្សាដែល យិន សុធា បានសរសេរឡើងនៅពេលដែលគាត់បានចូលរួមវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលថ្នាក់ខេត្តនៅខេត្តព្រៃវែង ៈ

*កូនខ្មែរគ្រប់រូបចូលចាំថា ១៧មេសានាំទុក្ខភ័យ*
*ម្ដាយព្រាត់កូនស្ងួនពិសី នេះជាកម្មអ្វីពីបុព្វ ។*
*ឥឡូវយើងរស់ចាកទុក្ខភ័យ មានសុខសេរីអ្វីគ្រប់យ៉ាង*
*ដូច្នេះយើងត្រូវចេះរួបរួម ពុំគួរគុំកួនគ្នាទៀតឡើយ ។*
*ពៀររំងាប់ដោយមិនចងពៀរ នោះទុក្ខនានានឹងបានស្បើយ*
*គុំកួនគ្នាគ្មានវគ្គចប់ឡើយ រួបរួមគ្នាអើយខ្មែរបានសុខ ។*

**ឌា ផល្លា**

# ខ្ញុំមិនចង់សងសឹកគេនៅទៀតទេ

នៅក្រោមដំបូលអគារសាលាឃុំជើងគ្រាវដែលស្ថិតនៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ខណៈពេលដែលមានការពិភាក្សាគ្នារវាងប្រជាជននៅក្នុងឃុំជាមួយនឹងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពីបទពិសោធដ៏ជូរចត់របស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះ ម៉ូត យូ ដែលជាជនជាតិខ្មែរអ៊ីស្លាមម្នាក់បានរៀបរាប់អំពីជីវប្រវត្តិដ៏លំបាកវេទនារបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះឪពុកម្តាយនិងបងស្រីរបស់គាត់ត្រូវបានគេយកទៅសម្លាប់យ៉ាងសាហាវព្រៃផ្សៃបំផុត ។

នៅឆ្នាំ១៩៧៣ ពេលដែល យូ មានអាយុទើបតែ១០ឆ្នាំ ឈ្លបខ្មែរក្រហមជាច្រើននាក់បានមកដល់ក្នុងស្រុកភូមិដែល យូ រស់នៅ រួចបង្ខំឲ្យប្រជាជនទាំងអស់រៀបចំអីវ៉ាន់ទៅរស់នៅឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ ពេលនោះ គ្រួសាររបស់ យូ បាន រៀបចំរបស់របរមួយចំនួនដូចជា ក្អម ចាន អង្ករបន្តិចបន្តួចនិងក្ដួចសម្រាប់ដាំលាយជាមួយបាយទុកជាស្បៀងសម្រាប់ហូបពេលធ្វើដំណើរ ។ ទៅដល់ទីនោះភ្លាម អង្គការបានចាត់តាំងឲ្យប្រជាជនរស់នៅជាមួយគ្នាជាលក្ខណៈគ្រួសារសិន ដោយបានបែងចែករបបអង្ករមួយកំប៉ុងសម្រាប់មនុស្ស៥នាក់ក្នុងមួយថ្ងៃ នៅក្រោមការគ្រប់គ្រងរបស់ប្រធានភូមិម្នាក់ឈ្មោះ សុះ ជាជនជាតិអ៊ីស្លាមដែលធ្លាប់រស់នៅភូមិជាមួយគ្នាពីមុន ។ នៅទីនោះ ប្រជាជនម្នាក់ៗមិនថាចាស់ឬក្មេងនោះទេ ត្រូវតែធ្វើការដូចៗគ្នាទាំងអស់ ។


ម៉ូត យូ

នៅឆ្នាំ១៩៧៥ ឈ្លបខ្មែរក្រហមប្រហែលជា១០នាក់ ប្រដាប់ដោយអាវុធគ្រប់ដៃបានមកព័ទ្ធជុំវិញផ្ទះរបស់ យូ និង គ្រួសារជនជាតិអ៊ីស្លាមចំនួន៤ទៀតដូចជា គ្រួសាររបស់ តាម៉ាត់ តាសុះ តាឡាង និង តាកែ ជាដើម ។ បន្ទាប់មក តាសុះ ដែលជាប្រធានភូមិក៏បានមកប្រាប់ឲ្យគ្រួសាររបស់ យូ រៀបចំអីវ៉ាន់ទៅរស់នៅភូមិផ្សេងទៀត ។ ពេលនោះ តាសុះ បានបណ្ដើរឪពុកម្តាយនិងបងស្រីរបស់ យូ ចេញទៅធ្វើការបាត់ ដែលធ្វើឲ្យ យូ មានការងឿងឆ្ងល់ក្នុងចិត្តជាខ្លាំង ព្រោះមិនដឹងថាគេយកទៅរស់នៅកន្លែងថ្មីដូចមុនឬក៏យកទៅសម្លាប់នោះទេ ។ ភ្លាមនោះស្រាប់តែគ្រួសាររបស់ តាឡាង នាំគ្នារត់គេចចេញពីផ្ទះ រហូតធ្វើឲ្យកងឈ្លបរត់ដេញចាប់គ្រួសាររបស់គាត់ពេញភូមិ ។ ឆ្លៀតឱកាសដែលមានស្ថានភាពច្របូកច្របល់បែបនេះ បងប្រុសរបស់ យូ ដែលរស់នៅជាមួយប្រពន្ធរបស់គាត់នៅក្នុងភូមិជាមួយគ្នាដែរក៏បានមកបបួល យូ ទៅយកផ្លែឈើហូប ដើម្បីនាំ យូ ទៅលាក់ខ្លួន ។ គ្រាន់តែចូលទៅដល់ក្នុងផ្ទះបងប្រុសភ្លាម គាត់បានប្រាប់ យូ ថា «ឪពុកម្តាយយើងត្រូវគេនាំយកទៅសម្លាប់ហើយ អ្ហែងនៅទីនេះជាមួយនឹងអញសិន» ។ ពេលដែលឮបងប្រុសប្រាប់ដូច្នេះ យូ ចាប់ផ្ដើមស្រែកយំ ហើយស្ទុះចេញពីក្នុងផ្ទះ សំដៅទៅរកឪពុកម្តាយនិងបងស្រី ។ ដោយសារតែព្រួយបារម្ភខ្លាច យូ ត្រូវអង្គការចាប់ខ្លួនដូចជាឪពុកម្តាយនិងបងស្រីទៀត បងប្រុសរបស់ យូ បានចាប់ យូ យ៉ាងជាប់ រួចយកក្រមាមកចងមាត់របស់គាត់ដើម្បីកុំឲ្យស្រែកយំនាំឲ្យឮទៅដល់កងឈ្លប ។ ដោយនៅតែមិនអស់ចិត្ត នៅយប់ថ្ងៃដដែលនោះ យូ បានលួចរត់ទៅផ្ទះរបស់ឪពុកម្តាយគាត់ម្តងទៀត ។ ប៉ុន្តែពេលដែលចូលទៅដល់ក្នុង គឺគ្មានឃើញមនុស្សសូម្បីតែម្នាក់ ចំណែកអ្នកភូមិដែលរស់នៅក្បែរផ្ទះនាំគ្នាសម្លឹងមើលមុខរបស់ យូ ដោយក្តីក្រៀមក្រំនិងមិនហ៊ាននិយាយអ្វីបន្តិចឡើយ ។

នៅតាមផ្លូវត្រឡប់មកផ្ទះរបស់បងប្រុសវិញ យូ ជឿជាក់ថា ឪពុកម្តាយរបស់ខ្លួនពិតជាត្រូវខ្មែរក្រហមយកទៅសម្លាប់ប្រាកដមែន ។ យូ អស់សង្ឃឹមក្នុងចិត្តជាខ្លាំង រហូតដល់គិតថាតើគាត់ត្រូវរស់នៅយ៉ាងដូចម្តេចប្រសិនបើគ្មានឪពុកម្តាយ ព្រោះចាប់តាំងពីតូចមកគាត់មិនដែលរស់នៅបែកពីឪពុកម្តាយឡើយ ។ ជាងនេះទៅទៀត យូ ក៏មិនដឹងថាតើគាត់អាចនឹងមានជីវិតរស់នៅបន្តទៅមុខទៀតដោយរបៀបណាដែរ ព្រោះខ្មែរក្រហមបានដឹងថា នៅក្នុងគ្រួសាររបស់ យូ នៅខ្វះក្មេងប្រុសម្នាក់ទៀតដែលត្រូវនាំយកទៅសម្លាប់ ។ យូ គិតថា មូលហេតុដែលខ្មែរក្រហមសម្លាប់គ្រួសាររបស់គាត់ ដោយសារតែគ្រួសាររបស់គាត់ជាសក្តិភូមិ ឪពុកម្តាយរបស់គាត់ជាអ្នករកស៊ីទិញនិងលក់គោ ។ កន្លងបានប្រហែលជាពីរបីថ្ងៃក្រោយមក យូ បានឃើញកម្មាភិបាលខ្មែរក្រហមនារីពីរនាក់ ដោយម្នាក់ឈ្មោះ មេត ស្លៀកខោអាវបងស្រី និងម្នាក់ទៀតឈ្មោះ ខេន ស្លៀកខោអាវម្តាយគាត់ ។ នៅពេលនោះ យូ មានគំនិតចង់សងសឹកនិងចង់ទៅសម្លាប់កម្មាភិបាលនារីទាំងពីរ ដោយលែងគិតពីជីវិតរបស់ខ្លួនឯងបន្តទៀតហើយ ។ ប៉ុន្តែបងប្រុសម្នាក់ឈ្មោះ អួន ដែលជាប្រធានភូមិម្នាក់ដែរ បានមកជួយលួងលោមគាត់ រួចនាំទៅនៅឯសហករណ៍ផ្សេងទៀត ប៉ុន្តែនៅតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាសុះ ដដែល ។

នៅចុងឆ្នាំ១៩៧៥ យូ ត្រូវបានបំបែកឲ្យទៅរស់នៅក្នុងអង្គភាពកុមារ ហើយតម្រូវឲ្យធ្វើការងារធ្ងន់ៗដូចជា វែកដី និងលើកទំនប់ដូចជាមនុស្សធំដែរ ។ ប៉ុន្តែ យូ រស់នៅទីនោះបានតែមួយរយៈពេលខ្លីប៉ុណ្ណោះ ក៏ត្រូវប្រធានសហករណ៍ចាត់តាំងឲ្យទៅមើលគោជាមួយកូនរបស់ តាសុះ និង តាលាស់ នៅស្រុកលើ ដែលស្ថិតនៅឆ្ងាយពីអង្គភាពរបស់គាត់ប្រហែលជាបីទៅបួនគីឡូម៉ែត្រ ។ ដោយសារខ្លួនជាកូនកំព្រាដែលត្រូវទៅរស់នៅជាមួយគ្រួសារអ្នកដទៃ យូ និង សាន ដែលជាកុមារស្ថិតនៅក្នុងអង្គភាពជាមួយគ្នានោះត្រូវអង្គការបញ្ជាឲ្យមើលគោប្រហែលមួយរយក្បាលតែពីរនាក់ប៉ុណ្ណោះ ព្រោះតាលាស់ និង តាសុះ មិនអនុញ្ញាតឲ្យកូនរបស់គាត់ទៅមើលគោជាមួយ យូ ទេ ។ ចំណែកការហូបចុកវិញ យូ បានហូបតែបបររាវៗ ត្រឹមតែមួយកូនវែកប៉ុណ្ណោះ ។ ដូច្នេះ ដើម្បីចម្អែតក្រពះ និងយកកម្លាំងទៅមើលគោបន្តទៀត យូ តែងតែទៅរកផ្សិតយកមកដុតហូបបន្ថែមទៀត ។ នៅកន្លែងនោះបានតែមួយរយៈ នៅឆ្នាំ១៩៧៧ អង្គការបានបញ្ជាឲ្យ យូ ដេញគោត្រឡប់មកសហករណ៍វិញ ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ស្មានណូ និងធ្វើការងារដូចពីមុនដដែល ។

ក្រោយពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ យូ នៅតែមានគំនុំចង់សងសឹកឲ្យក្រុមគ្រួសារដែលត្រូវបានអង្គការយកទៅសម្លាប់ជានិច្ច ជាពិសេសចង់សម្លាប់ ខេន និង មេត ដែលបានយកសម្លៀកបំពាក់របស់ម្តាយនិងបងស្រីគាត់ទៅស្លៀកពាក់ ។ យូ បានរៀបរាប់ថា នៅពេលនោះគាត់បានយកកាំភ្លើងពីរដើមត្រៀមនឹងបាញ់សម្លាប់អ្នកទាំងពីរចោល ប៉ុន្តែសំណាងល្អត្រូវបងប្រុសរបស់គាត់ឃាត់ទាន់ និងនិយាយថា «កុំចងកម្មចងពៀរនឹងគ្នាទៀត» ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ យូ បានបោះបង់គំនិតចង់សងសឹកនេះចោលហើយ ព្រមទាំងបានរស់នៅជាមួយប្រពន្ធនិងកូនរបស់គាត់ចំនួនបួននាក់យ៉ាងមានសេចក្តីសុខ ។ សព្វថ្ងៃនេះ យូ ជាមន្ត្រីនគរបាលម្នាក់នៅក្នុងឃុំ ។ យូ បានរៀបរាប់ថា «ទោះបីជាកំហឹងនិងការឈឺចាប់មានច្រើនយ៉ាងណាក៏ដោយ ប៉ុន្តែមកដល់ពេលនេះ ការចងពៀរមិនមែនជាដំណោះស្រាយដ៏ប្រសើរសម្រាប់ប្រទេសដែលមានច្បាប់ដូចជាប្រទេសកម្ពុជាទេ ។ លើសពីនេះទៅទៀត ចំពោះដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងតុលាការកម្ពុជាដែលសព្វថ្ងៃកំពុងកាត់ទោសអតីតមេគុកទួលស្លែង កាំង ហ្គេកអ៊ាវ ហៅ ឌុច ហើយដែលគាត់បានធ្វើការសុំទោសជាសាធារណៈចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើជនរងគ្រោះទាំងឡាយនៅក្នុងរបបខ្មែរក្រហម យូ បាននិយាយថារូបគាត់មិនចង់ចងគំនុំសងសឹកបន្តទៀតទេ ហើយក៏មិនចង់ឲ្យការសងសឹកនេះកើតឡើងសាជាថ្មីម្តងទៀតដែរ ។ យូ បន្ថែមថា មិនមែនមានតែរូបគាត់ម្នាក់ទេដែលមានកំហឹង ប៉ុន្តែបើមនុស្សដែលធ្លាប់ប្រព្រឹត្តខុសបានសារភាពពីទោសកំហុសរបស់ខ្លួន នោះវាប្រសើរជាងអ្នកដែលមិនព្រមទទួលថាខ្លួនបានធ្វើខុសឆ្ងាយណាស់ ។ ចុងក្រោយគាត់សង្ឃឹមថា តុលាការនេះនឹងរកយុត្តិធម៌ជូនប្រជាជនខ្មែរគ្រប់រូបដែលបានរងគ្រោះនៅក្នុងរបបនោះតាមនីតិវិធីច្បាប់មិនខាន ។ **ឆាយ ឈុនលី**

# នៅតែចង់ធ្វើគ្រូបង្រៀន


ប៉ែន បុន

នៅឆ្នាំ១៩៧៤ បុន មានអាយុប្រហែលជាង១០ឆ្នាំ រៀនថ្នាក់ទី៩ (ប្រព័ន្ធចាស់) នៅសាលាវត្តសង្ឃារាម ស្ថិតនៅត្រើយគាហោ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខណៈពេល បុន ត្រឡប់មកពីសាលារៀនវិញ ស្រាប់តែឮឪពុករបស់គាត់និយាយប្រាប់ថា «បន្តិចទៀតនឹងមានចលាចលនៅខេត្តស្វាយរៀង ហើយខ្មែរក្រហមនឹងបង្អត់បាយប្រជាជន ព្រមទាំងតម្រូវឲ្យស្រីៗកាត់សក់ឲ្យខ្លីទាំងអស់»។

នៅពេលខ្មែរក្រហមបានឡើងគ្រប់គ្រងអំណាចនៅក្នុងឆ្នាំ១៩៧៥ នៅក្នុងភូមិស្រាប់តែមានសេចក្តីប្រកាសប្រាប់ឲ្យប្រជាជនទាំងអស់ចាកចេញពីលំនៅឋាន បើមិនអីចឹងទេនឹងបាញ់សម្លាប់ចោលភ្លាម ព្រោះអង្គការត្រូវការរៀបចំប្រទេសឡើងវិញ។ ក្រោយពីរៀបចំអីវ៉ាន់រួចរាល់ហើយ គ្រួសាររបស់ បុន ក៏នាំគ្នាធ្វើដំណើរទៅទិសខាងកើតតាមទិសដៅកំណត់របស់អង្គការ។ ប្រជាជនទាំងអស់រួមទាំងគ្រួសាររបស់ បុន គ្មាននរណាម្នាក់ហ៊ានប្រឆាំងនឹងបញ្ហានេះឡើយ ទោះបីជាតាមផ្លូវធ្វើដំណើរមានទាហានខ្មែរក្រហមបីនាក់ឈរចាំឆែកឆេរអីវ៉ាន់របស់ប្រជាជន ដោយយកលេសថាប្រមូលយកទៅដាក់ជារបស់រួមក៏ដោយ។ រយៈពេលជាច្រើនថ្ងៃក្រោយមក គ្រួសាររបស់ បុន ក៏បានមកដល់ភូមិប្រសូត្រ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប។ នៅទីនោះ បុន ត្រូវអង្គការបំបែកឲ្យរស់នៅឆ្ងាយពីឪពុកម្តាយដោយចាត់តាំងឲ្យគាត់ធ្វើការនៅក្នុងកងសហករណ៍មួយដាច់ដោយឡែកពីពួកគាត់និងយប់ឡើងមិនឲ្យត្រឡប់មកសម្រាកនៅក្នុងកងជាមួយគ្នាទេ។

នៅឆ្នាំ១៩៧៦ ប្រជាជននៅក្នុងភូមិដែលធ្លាប់ធ្វើជាគ្រូបង្រៀនកាលពីសម័យមុនៗ ត្រូវបានចាប់យកទៅសម្លាប់ជាបន្តបន្ទាប់ ក្រោយពីខ្មែរក្រហមស៊ើបដឹង។ ពេលនោះ មិត្តភក្តិរបស់ឪពុក បុន ក៏ត្រូវអង្គការហៅទៅប្រជុំដោយយកលេសថាគ្រូបង្រៀនត្រូវតែនាំគ្នាទៅរៀនសូត្របន្ថែមទៀត។ ចាប់តាំងពីពេលនោះមក គាត់ក៏បាត់ខ្លួនរហូត។

នៅឆ្នាំដដែលនោះ បុន បានឃើញខ្មែរក្រហមចាប់យកសមាជិកក្នុងកងជាមួយគាត់ឈ្មោះ ជា ទៅសម្លាប់ដោយផ្ទាល់ភ្នែក។ ថ្ងៃនោះនៅពេលដែល ជា កំពុងតែឈរម្នាក់ឯងនៅក្នុងសហករណ៍ ស្រាប់តែមានកងឈ្លបខាងភូមិភាគនិរតីស្ទុះមកចាប់គាត់រួចចងជើងទាំងសងខាងរបស់គាត់ដោយចោទថា «មានគំនិតក្បត់ជាមួយនឹងអង្គការ»។ បន្ទាប់មក ខ្មែរក្រហមទាំងនោះបានចាប់ដៃរបស់គាត់ចងជាមួយនឹងម៉ូតូសេរ៉ិល រួចបើកអូសរហូតគាត់ដាច់ខ្យល់ស្លាប់។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានផ្លាស់ បុន ឲ្យទៅរស់នៅភូមិកៀនស្វាយ ខេត្តកណ្តាលវិញ។ បុន មានតួនាទីជីកប្រឡាយនៅក្បែរថ្នល់ជាតិក្នុងមួយព្រឹកឲ្យបាន៥ម៉ែត្រក្រោមការគ្រប់គ្រងរបស់គណៈឃុំឈ្មោះ ស៊ុន ដែលមានអត្តចរិតកាចសាហាវ។ បុន រំឭកថា ពេលខ្លះទោះបីជាគាត់ខំធ្វើការហើយមុនការកំណត់ក៏ដោយ ក៏គាត់មិនត្រូវបានអនុញ្ញាតឲ្យសម្រាកដែរ ថែមទាំងបន្ថែមការងារឲ្យគាត់ជីកប្រឡាយ៥ម៉ែត្រទៀត។ ដូច្នេះ ទោះបីជាពេល បុន មានជំងឺស្ទើរតែដើរមិនរួចក៏ដោយ ក៏គាត់មិនដែលហ៊ានសុំច្បាប់ឈប់សម្រាកឡើយ។

នៅឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមចូលមករំដោះនៅទូទាំងប្រទេសគ្រួសាររបស់ បុន បានធ្វើដំណើរត្រឡប់មកផ្ទះវិញ។ ក្រោយមក បុន ក៏សម្រេចចិត្តចូលរៀននិងបានចាប់យកជំនាញជាគ្រូរហូតមកដល់សព្វថ្ងៃនេះ។ **ស៊ិន សុធីតា**

# ម៉ៅ វាសនា : ចង់អប់រំក្មេងជំនាន់ក្រោយ

*ម៉ៅ វាសនា តែងតែចង់ក្លាយជាគ្រូបង្រៀនម្នាក់ដើម្បី បង្ហាត់បង្ហាញក្មេងជំនាន់ក្រោយឲ្យដឹងពីអ្វីបានកើតឡើងពីអតីតកាលនិងអ្វីដែលគាត់បានរៀនសូត្រតាំងពីក្មេងមក ។ ជាភ័ព្វសំណាងថ្មីៗនេះ វាសនា ត្រូវបានជ្រើសតាំងដោយក្រសួងអប់រំដើម្បីធ្វើជាគ្រូបង្គោលថ្នាក់ជាតិ ផ្នែកបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ វាសនា បានទទួលឥទ្ធិពលពីឪពុករបស់គាត់ដែលជាគ្រូបង្រៀនកាលពីជំនាន់សង្គមរាស្ត្រនិយមនិងជំនាន់ លន់ នល់ ហើយ វាសនា យល់ថា មានតែគ្រូទេដែលអាចជួយអប់រំក្មេងឲ្យចាកផុតពីភាពអវិជ្ជាបាន ។*

*ជាអកុសលដូចជាគ្រួសារដទៃទៀតដែរ គ្រួសាររបស់ វាសនា បានពើបប្រទះនឹងរបបខ្មែរក្រហមដែលធ្វើឲ្យការរៀនសូត្ររបស់គាត់ត្រូវអាក់ខាន ។ វាសនា ដែលកាលនោះមានអាយុ១៥ឆ្នាំអាចចងចាំបានថា នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ សមាជិកគ្រួសារទាំងអស់របស់គាត់ដែលនៅផ្ទះបានឃើញប្រជាជនយ៉ាងច្រើនកុះករនាំគ្នាអបអរសាទរនឹងជ័យជម្នះរបស់ទ័ពកុម្មុយនីស្តដែលមានឯកសណ្ឋានពណ៌ខ្មៅ ។ គ្មាននរណាម្នាក់ដឹងថាភាពខ្លោចផ្សានឹងកើតឡើងបន្តិចទៀតនោះឡើយ ។ ស្របពេលដែលប្រជាជនកម្ពុជាកំពុងតែរីករាយនឹងការមកដល់របស់កងទ័ពទាំងនោះ ក៏មានការប្រកាសឲ្យប្រជាជនទាំងអស់ចាកចេញពីលំនៅឋានភ្លាមៗ ។ អ្នកដែលក្រាញនៀលមិនព្រមចេញនឹងត្រូវសម្លាប់ចោល ។ ពេលនោះ ក្រុមគ្រួសាររបស់ វាសនា មានបំណងថានឹងធ្វើដំណើរតាមផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ខេត្តបាត់ដំបង ។ ដោយពេលនោះ មានមនុស្សច្រើនកកកុញតាមផ្លូវ គ្រួសាររបស់ វាសនា មានការលំបាកក្នុងការធ្វើដំណើរឲ្យបានលឿនណាស់ ។ ក្រោយពីចេញផុតពីទីក្រុងភ្នំពេញបានមួយរយៈខ្លី កម្មាភិបាលខ្មែរក្រហមក៏បញ្ជាឲ្យគ្រួសាររបស់ វាសនា ស្នាក់នៅតាមផ្លូវមួយយប់សិន ។ វាសនា ដឹងច្បាស់ថាទីនោះគឺស្ថិតក្នុងទឹកដីខេត្តកណ្តាលនៅឡើយ ។ នៅក្នុងវ័យជំទង់ វាសនា ត្រូវបានចាត់តាំងឲ្យចូលក្នុងកងចល័តដោយមាននាទីប្រមូលដីអាចម៍គោចំនួន ២០គីឡូក្រាមក្នុងមួយថ្ងៃ បើមិនដូច្នេះទេ និងត្រូវពិន័យដោយបង្អត់អាហារមួយថ្ងៃ ។ ក្រោយមក ដោយសារតែ វាសនា មានការរៀនសូត្រចេះដឹងច្រើនជាងគេ ប្រធានសហករណ៍ក៏បានចាត់តាំងឲ្យ វាសនា បង្រៀនមេលេខដល់កុមារក្មេងៗចំនួន៤០នាក់នៅក្នុងកងជាមួយគ្នា ។ ប៉ុន្តែ បង្រៀនបានតែរយៈពេលពីរខែ វាសនា ក៏បានសុំឈប់ពីការងារនេះទៅ ។*

*បន្ទាប់មក អង្គការបានចាត់តាំង វាសនា ឲ្យកាន់បញ្ជីឈ្មោះកុមារនិងទទួលការខុសត្រូវលើ កុមារទាំងនោះដោយតម្រូវឲ្យរើសដីអាចម៍គោឲ្យបាន២០គីឡូក្រាមក្នុងមួយថ្ងៃ ។ ដោយសារនេះជាភារកិច្ចដ៏លំបាកក្នុងការបំពេញ វាសនា បានរៀបរាប់ថា «ការងារនេះពិតជាលំបាកណាស់ព្រោះ អាចមានគ្រោះថ្នាក់ដល់ជីវិតគ្រប់ពេល បើសិនជាមិនបានរាយការណ៍ ប្តូកត់ឈ្មោះអ្នកមិនប្រមូលដីអាចម៍គោឲ្យគ្រប់តាមផែនការកំណត់របស់អង្គការទេ» ។ ថ្ងៃមួយមានសមមិត្តនារីម្នាក់ (សុំមិនបញ្ចេញឈ្មោះ) នៅសហករណ៍ជាមួយគ្នាក៏បានរាយការណ៍ទៅអង្គការពេលដែល វាសនា មិនបានធ្វើតាមផែនការរបស់អង្គការ ។ ភ្លាមនោះ មេកង*



ម៉ៅ វាសនា

ក៏បានបញ្ជាឲ្យឈ្លបពីរនាក់មកចាប់ វាសនា ដោយចងស្លាបសេករួចបណ្តើរយកទៅ។ ដោយភាពភ័យខ្លាច វាសនា បានប្រាប់ទៅអង្គការវិញថា គាត់បានធ្វើគ្រប់តាមផែនការហើយដោយអះអាងចំពោះមេកងថានឹងនាំទៅមើលបើសិនជាមិនជឿ។ ពេលនោះ មេកង ក៏បានជឿ វាសនា ហើយក៏បានដោះលែងឲ្យមានសេរីភាពវិញ។ ប៉ុន្តែ សមមិត្តនារីនោះនៅតែមិនអស់ចិត្ត ហើយនៅតែព្យាយាមរកវិធីផ្សេងទៀតដើម្បីធ្វើបាប វាសនា។ ថ្ងៃមួយ សមមិត្តនារីនោះបានរាយការណ៍ទៅប្រធានសហករណ៍ថា វាសនា បានបំផ្លាញស្រូវរបស់អង្គការ និងនាំកុមារផ្សេងទៀតទៅបង្ហូរទឹកចេញពីស្រែដើម្បីធ្វើឲ្យស្រូវងាប់។ ពេលដែលថ្នាក់លើហៅ វាសនា មកសួរពីដំណើររឿង វាសនា ក៏បានរៀបរាប់ថា គាត់




ប្រាប់ឲ្យក្មេងៗបង្ហូរទឹកចេញពីស្រែដើម្បីចាប់ក្តាម់ ព្រោះបើសិនមិនបង្ហូរទឹកចេញទេគឺមិនអាចចាប់ក្តាមបានទេ។ ឮដូច្នេះ ប្រធានសហករណ៍ក៏យល់ ហើយក៏មិនប្រកាន់ទោសពៃរ៍អ្វីដែរ។ នៅក្នុងសហករណ៍ជាមួយគ្នា វាសនា មានមីងម្នាក់ឈ្មោះ កែម ជាសិល្បករដ៏ប៉ិនប្រសប់ម្នាក់ខាងល្ខោននិយាយនិងជាអ្នកអានព័ត៌មាននៅតាមកញ្ចក់ទូរទស្សន៍នៅក្នុងទីក្រុងភ្នំពេញក្នុងសម័យ លន់ នល់។ ទោះបីជាគាត់ខំលាក់ពីប្រវត្តិរូបរបស់គាត់យ៉ាងណាក៏ដោយ ក៏គាត់មិនអាចបានរួចផុតពីការដឹងឮរបស់កម្មាភិបាលបានដែរ ព្រោះគ្រាន់តែបានដឹងថាគាត់ជាសិល្បករសម័យមុន ឈ្លបពីរនាក់បានមកស្នើគាត់ឲ្យទៅរៀនសូត្រនៅប្រហែលជាម៉ោង៧យប់។ យប់នោះ មីង កែម ត្រូវបានឈ្លបពីរនាក់នោះចងមុខ រួចយកទៅសម្លាប់នៅក្បែរភូមិ។

នៅឆ្នាំ១៩៧៨ អង្គការបានផ្លាស់ក្រុមគ្រួសាររបស់ វាសនា និងអ្នកភូមិប្រហែល៣០គ្រួសារទៀតឲ្យទៅរស់នៅខេត្តបាត់ដំបងវិញ។ នៅបាត់ដំបងបានមួយរយៈ កម្មាភិបាលខ្មែរក្រហមក៏ចាប់ផ្តើមបំបែកក្មេងៗឲ្យទៅធ្វើការឆ្ងាយពីឪពុកម្តាយ។ ឃើញដូច្នេះ វាសនា បានទៅអង្វរប្រធានឃុំ ដោយសារគាត់មិនចង់ឃ្លាតពីឪពុកម្តាយ។ សំណាងល្អ មេឃុំក៏យោគយល់ ហើយក៏មិនបំបែកគាត់ឆ្ងាយពីឪពុកម្តាយដែរ។

ក្នុងឆ្នាំ១៩៧៨ដដែល កម្មាភិបាលខ្មែរក្រហមបានប្រមូលប្រជាជនមួយចំនួនដឹកតាមកាណូតឲ្យទៅនៅកន្លែងផ្សេង។ កាលនោះ វាសនា មានរបួសត្រង់ជើងស្តាំដោយសារធ្លាក់ពីលើដើមឈើដែលនាំឲ្យគ្រួសាររបស់គាត់មិនអាចទៅណាបាន។ ការធ្វើដំណើរនោះត្រូវដឹកតាមកាណូតជាច្រើនជើង។ ប៉ុន្តែគ្រួសាររបស់ វាសនា នៅតែមិនបានទៅដដែលដោយសារកាណូតជើងទីពីរពេញចំណុះដែលមិនអាចផ្ទុកគ្រួសារផ្សេងទៀតបាន។ ទីបំផុត អ្នកដែលបានឡើងជិះកាណូតទៅកន្លែងថ្មីនោះត្រូវបានសម្លាប់ចោលទាំងអស់។ នេះគ្រាន់តែជាការរួចរស់ជីវិតមួយគ្រាប៉ុណ្ណោះ រហូតទីបំផុតគាត់ត្រូវបានសង្គ្រោះដោយការមកដល់នៃកងទ័ពវៀតណាមនៅឆ្នាំ១៩៧៩ ហើយក្រុមគ្រួសាររបស់គាត់ក៏ត្រឡប់មករស់នៅទីក្រុងភ្នំពេញវិញ។

វាសនា បានចូលរៀនសាលារដ្ឋភ្លាមក្រោយពីរដ្ឋាភិបាលបានបង្កើតឲ្យមានគ្រឹះស្ថានសិក្សាឡើងវិញ។ នៅក្នុងឆ្នាំ១៩៨៤ វាសនា ក៏បានប្រឡងជាប់សញ្ញាប័ត្របាក់ឌុប ហើយទទួលបានអាហាររូបករណ៍ទៅសិក្សានៅប្រទេសអាល្លឺម៉ង់ផ្នែកទស្សនវិជ្ជារយៈពេល១០ឆ្នាំ។ ដោយមានគំនិតចង់បង្រៀនក្មេងជំនាន់ក្រោយ វាសនា បានត្រឡប់មកមាតុភូមិវិញ ហើយក៏បានចូលមកបម្រើការងារនៅក្រសួងអប់រំដោយមានភារៈបង្រៀនមុខវិជ្ជាសីលធម៌ពលរដ្ឋ។

**ស៊ិន សុធីតា**

# ការទទួលបាននូវយុត្តិធម៌ និងការផ្សះផ្សាជាតិ នៅកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍

***(តពីលេខមុន)***

## *សេចក្តីសន្និដ្ឋានអំពីឥទ្ធិពលរបស់ អ.វ.ត.ក. ទៅលើយុត្តិធម៌និងការផ្សះផ្សា*

*ថ្វីត្បិតតែ អ.វ.ត.ក. អាចនឹងមានលទ្ធភាពក្នុងការផ្តល់យុត្តិធម៌បែបកាត់ទោសក៏ដោយ តែតុលាការនេះនៅតែប្រឈមមុខនឹងការខ្វះប្រសិទ្ធភាពដោយសារតែមិនមានការផ្សព្វផ្សាយដល់មហាជនទូទៅឲ្យបានទូលំទូលាយ ។ ម្យ៉ាងវិញទៀត ប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជាក៏អាចជះឥទ្ធិពលអាក្រក់ដល់យុត្តិធម៌របស់ អ.វ.ត.ក.ដែរ ព្រោះកត្តាខាងលើអាចធ្វើឲ្យ អ.វ.ត.ក. ជាប់ពាក់ព័ន្ធជាមួយអំពើពុករលួយនិងនិទ្ទណ្ឌភាព ។ លើសពីនេះទៅទៀត ភាពផ្ទុយគ្នារវាងវប្បធម៌កម្ពុជា និងអន្តរជាតិក្នុងការស្វែងរកយុត្តិធម៌ក៏អាចបង្កការគំរាមកំហែងដល់ អ.វ.ត.ក. ផងដែរ ដោយហេតុថាមានប្រជាជនភាគច្រើនមិនយល់អំពីភាពយឺតយ៉ាវ និងការប្រតិបត្តិការមួយចំនួនរបស់ អ.វ.ត.ក.ដែលទាក់ទងទៅនឹងការពង្រឹងដំណើរការអនុវត្តឲ្យបានត្រឹមត្រូវរួមជាមួយវិធាននៃច្បាប់ទៅក្នុងប្រព័ន្ធច្បាប់មួយដែលមិនដែលមានផ្នត់គំនិតបែបនេះសោះ ។*

*អ.វ.ត.ក. ខ្វះខាតលទ្ធភាពក្នុងការផ្តល់យុត្តិធម៌បែបផ្សះផ្សាដោយសារយុត្តាធិការរបស់តុលាការនេះផ្តោតសំខាន់ទៅលើការដាក់ទំនួលខុសត្រូវព្រហ្មទណ្ឌទៅលើជនដៃដល់ដែលបានប្រព្រឹត្តអំពើសាហាវឃោរឃៅក្នុងរបបខ្មែរក្រហម ហើយដំណើរការនេះមិនបានសង្កត់ធ្ងន់ទៅលើជនរងគ្រោះក្នុងលក្ខណៈជាបុគ្គលទេ តែមានបំណង «ពង្រឹង» វិធាននៃច្បាប់ និង រួមចំណែកក្នុងការបង្កើតជាកំណត់ត្រាប្រវត្តិសាស្ត្រក្នុងគោលបំណងអប់រំដែលជាកម្មវត្ថុបន្ទាប់បន្សំបន្ថែមទៅលើការស្វែងរកយុត្តិធម៌ដែលជាកម្មវត្ថុចម្បង ។ ថ្វីដ្បិតតែ អ.វ.ត.ក. អាចផ្តល់សំណងផ្លូវចិត្ត «ជាសមូហភាព និមិត្តរូប និងបែបសីលធម៌ក៏ដោយ តែមិនមែនជាលក្ខណៈហិរញ្ញវត្ថុទេ» ព្រោះការកាត់ក្តីនេះប្រហែលជាមិនអាចបញ្ចប់ក្នុងពេលឆាប់ៗនេះទេដោយសារតែមានការសន្មតទុកជាមុនរបស់ការកាត់ក្តីលើកមុន រួមជាមួយនឹងភាពស្មុគស្មាញក្នុងការកាត់ក្តីមេដឹកនាំខ្មែរក្រហមខ្លះដែលបានទទួលការលើកលែងទោសពីសម្តេចព្រះបាទ នរោត្តម សីហនុ ។*

*ដោយសារតែការផ្តោតអារម្មណ៍តិចតួចបំផុតរបស់ អ.វ.ត.ក.ទៅលើយុត្តិធម៌តាមបែបផ្សះផ្សា ដូច្នេះការផ្សះផ្សាគ្រប់កម្រិតគ្រាន់តែប្រព្រឹត្តទៅយ៉ាងប្រយោលប៉ុណ្ណោះ នៅពេលដែលជនរងគ្រោះបានឮសក្ខីកម្មដែលសម្តែងអំពីវិប្បដិសារី និងការសុំអភ័យទោសរបស់ជនដៃដល់ក្នុងដំណើរការកាត់ក្តី ។ សក្ខីកម្មទាំងនេះអាចជំរុញឲ្យមានការលើកលែងទោសក្នុងកម្រិតបុគ្គល ហើយនេះអាចជាការចាប់ផ្តើមនៃដំណើរព្យាបាលរបួសផ្លូវចិត្តនិងការផ្សះផ្សាក្នុងកម្រិតបុគ្គលផងដែរ ។ វត្តមាននៃការកាត់ក្តីនេះក៏អាចរួមចំណែកក្នុងការពង្រឹងយុត្តិធម៌តាមបែបផ្សះផ្សា ដំណើរការផ្សះផ្សាជាតិនិងការស្តារសង្គមសាជាថ្មីតាមរយៈការទទួលស្គាល់ទុក្ខវេទនារបស់ជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ ហើយព្រមទាំងខ្ទិសដល់អ្នកដែលបានបាត់បង់ជីវិតក្នុងសម័យនោះផង ។ បន្ថែមពីលើនេះ ការដាក់ទោសចំពោះបទឧក្រិដ្ឋរបស់ខ្មែរក្រហមអាចជួយដល់បុគ្គលមួយចំនួនដើម្បីព្យាបាលរបួសផ្លូវចិត្តរបស់ខ្លួននឹងជំរុញឲ្យមានការផ្សះផ្សាក្នុងកម្រិតបុគ្គល ។ កំណត់ត្រាប្រវត្តិសាស្ត្រដែលរៀបរៀងដោយអ.វ.ត.ក.ប្រហែលជាមិនមានភាពច្បាស់លាស់ និងពេញលេញនោះទេ តែទោះយ៉ាងណាក្តីកំណត់ត្រានេះនឹងអាចជំរុញឲ្យមានការផ្សះផ្សាជាតិដែរ ។ ដោយការផ្សះផ្សាក្នុងកម្រិតបុគ្គល សង្គម និងជាតិសុទ្ធតែមានទំនាក់ទំនងនឹងគ្នាយ៉ាងស្អិតល្មួត ហើយអាចជំរុញឲ្យមានឥទ្ធិពល*

វិជ្ជមានចំពោះគ្នាទៅវិញទៅមក យើងអាចសន្និដ្ឋានថា អ.វ.ត.ក. អាចមានសក្តានុភាពក្នុងការជំនួយដល់ការផ្សះផ្សាគ្រប់កម្រិតក្នុងប្រទេសកម្ពុជា ថ្វីត្បិតតែអ.វ.ត.ក. មិនមានភាពសកម្មគ្រប់គ្រាន់ក៏ដោយ ។

## កិច្ចផ្តួចផ្តើមផ្សេងៗទៀតដើម្បីសម្រេចបាននូវយុត្តិធម៌ មជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ក្នុងលក្ខណៈជាការិយាល័យមួយរបស់កម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់សកលវិទ្យាល័យយែលសហរដ្ឋអាមេរិក ក្រោយមកទៀតបានក្លាយជាស្ថាប័នស្រាវជ្រាវឯករាជ្យក្នុងឆ្នាំ១៩៩៧ ហើយបច្ចុប្បន្នត្រូវបានទទួលស្គាល់ថាជា «ទីកន្លែងដែលរក្សាទុកឯកសារទាក់ទងនឹងខ្មែរក្រហមដ៏ធំបំផុតក្នុងពិភពលោក» ។ កម្មវត្ថុសំខាន់បំផុតរបស់អង្គការនេះគឺបង្កើតជាកំណត់ត្រាប្រវត្តិសាស្ត្រពីអំពើប្រល័យពូជសាសន៍ដើម្បីរក្សាការចងចាំចំពោះអ្នកដែលបានបាត់បង់ជីវិត និងស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាក្រោយពេលដែលបានឆ្លងកាត់របបដ៏សាហាវយង់ឃ្នងរបស់ខ្មែរក្រហម ។ ដូច្នេះ មជ្ឈ-មណ្ឌលឯកសារកម្ពុជាបានខិតខំប្រមែប្រមូលប្រវត្តិសាស្ត្រខ្មែរក្រហម ហើយចងក្រងជាឯកសារ និងរក្សាទុកទៅតាមប្រភេទនីមួយៗសម្រាប់ឲ្យអ្នកជំនាន់ក្រោយសិក្សាស្រាវជ្រាវ ព្រមទាំងរៀបចំព័ត៌មានដែលអាចយកទៅធ្វើជាភ័ស្តុតាងក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ កម្មវត្ថុទាំងនេះទទួលបានទទួលការជឿជាក់ថានឹងអាចលើកស្ទួយការចងចាំ រួមទាំងផ្តល់យុត្តិធម៌ជូនជនរងគ្រោះទាំងឡាយផង ។

ថ្វីដ្បិតតែកម្មវត្ថុចម្បងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តោតសំខាន់ទៅលើការរៀបចំឯកសារទាក់ទិនទៅនឹងខ្មែរក្រហម តែអង្គការក្រៅរដ្ឋាភិបាលមួយនេះបានអនុវត្តគម្រោងមួយចំនួនដែលសង្កត់ធ្ងន់ទៅលើ «ការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការអប់រំ» ផងដែរ ។ ក្នុងចំណោមគម្រោងផ្សព្វផ្សាយទាំងអស់ទស្សនាវដ្តីស្វែងរកការពិតដែលចុះផ្សាយកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ភាពងាយស្រួលក្នុងការពិភាក្សាអំពីបញ្ហាខ្មែរក្រហម ។ អង្គការនេះក៏បានចូលរួមក្នុងវិស័យអប់រំមួយចំនួនតាមរយៈគម្រោងផ្សព្វផ្សាយដល់សិស្សានុសិស្សដើម្បី «លើកកម្ពស់ស្មារតីបម្រើការងារដោយស្ម័គ្រចិត្តរបស់យុវជន អប់រំយុវជនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងជំរុញឲ្យមានការផ្លាស់ប្តូរយោបល់គ្នារវាងអ្នកដែលនៅរស់រានមានជីវិតជាមួយនឹងកូនចៅរបស់ខ្លួន» ។ ដើម្បីបម្រើដល់វិស័យអប់រំ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានបោះពុម្ពផ្សាយសៀវភៅមេរៀនស្តីអំពីកម្ពុជាប្រជាធិបតេយ្យជាលើកដំបូងផងដែរក្នុងខែមេសា ឆ្នាំ២០០៧ ហើយបានចែកចាយជូនទៅដល់សាលារៀន បណ្ណាល័យនិងក្រសួងរាជរដ្ឋាភិបាលបានចំនួនប្រមាណ៣០០០ក្បាលរួចមកហើយ ។

ការបង្កើនការចូលរួមរបស់ជនរងគ្រោះក៏ជាគោលបំណងសំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ឧទាហរណ៍ដូចជាគម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់របស់ចាមមូស្លីមដែលបានកត់ត្រាប្រវត្តិរឿងដែលចាមមូស្លីមជួបប្រទះក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនិងផ្តល់កម្លាំងចិត្តដល់ស្ត្រីជនជាតិចាមមូស្លីមឲ្យរៀបរាប់ពីការប៉ះទង្គិចលើស្មារតីដែលបានឆ្លងកាត់ក្នុងអំឡុងពេលនោះ រួមទាំងគម្រោងជួយដល់ជនរងគ្រោះដែលមានគោលដៅផ្តល់ជំនួយដល់ «ជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងហោចមួយម៉ឺននាក់ឲ្យមានឱកាសចូលរួមបំពេញទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ មិនថាក្នុងនាមជាអ្នកប្តឹង ឬ (ជាដើមបណ្តឹងរដ្ឋប្បវេណី) របស់អង្គជុំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងឆ្នាំ២០០៨នោះទេ» ។ ដោយសារតែមានចំនួនអ្នកឯកទេសចិត្តសាស្ត្រតិចជាង៣០នាក់ប៉ុណ្ណោះនៅក្នុងប្រទេស គម្រោងជួយជនរងគ្រោះដែលធ្លាប់ទទួលរងអំពើទារុណកម្មត្រូវបានបង្កើតឡើងដើម្បីផ្តល់ជំនួយដល់អ្នកនៅរស់រានមួយចំនួនដែលមានវិបត្តិផ្លូវចិត្ត ។ ឆ្លងកាត់សហការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ គម្រោងនេះបានរកឃើញជនរងគ្រោះ និងជនដៃដល់រាប់រយនាក់ដែលមានវិបត្តិផ្លូវចិត្តក្រោយពេលឆ្លងកាត់របបប្រល័យពូជសាសន៍ ហើយបានផ្តល់ការព្យាបាលតាមរយៈរាជរដ្ឋាភិបាលនិងមណ្ឌលសុខភាពរបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ ។

ខណៈពេលដែលគម្រោងចងក្រងឯកសាររបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាដើរតួនាទីជាអ្នកជំនួយ នៅក្នុងដំណើរការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់តាមរយៈសហការជាមួយនឹង

អ.វ.ត.ក. ការងារមួយផ្នែកធំទៀតរបស់អង្គការនេះបានផ្ដល់យុត្តិធម៌តាមបែបផ្សះផ្សាដល់ប្រជាជនកម្ពុជា ។ ជាបឋមគឺតាមរយៈការផ្ដល់ឱកាសឲ្យជនរងគ្រោះអាចនិយាយរឿងរ៉ាវដែលខ្លួនធ្លាប់ឆ្លងកាត់ចេញមក ហើយនិងចុះផ្សាយរឿងមួយចំនួននៅក្នុងគម្រោងទស្សនាវដ្ដីរបស់ខ្លួន គម្រោងផ្ដោតសំខាន់ទៅលើជនរងគ្រោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់ជាយន្ដការសម្រាប់ព្យាបាលផ្លូវចិត្តអ្នកដែលកំពុងរងទុក្ខដោយសាររឿងអតីតកាលដ៏គួរឲ្យឈឺចាប់របស់ខ្លួន ។ លើសពីនេះ ការសិក្សាអំពីបទពិសោធន៍របស់ក្រុម ពួកគាត់ប្រាកដជានឹងអាចជួយជនរងគ្រោះនិងជនដៃដល់ឲ្យហ៊ានប្រឈមមុខជាមួយរឿងអតីតកាលរបស់ខ្លួន និងបោះជំហានទៅកាន់អនាគតដ៏ភ្លឺស្វាងមួយ ។ ការរកត់ត្រាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាមរយៈសំឡេងរបស់អ្នកដែលនៅសេសសល់ពីសម័យនោះបានធ្វើឲ្យការទាមទារស្វែងរកការពិតរបស់ប្រជាជនកម្ពុជាមិនគ្រាន់តែជាការស្រមើស្រមៃតទៅទៀតឡើយ តែបានប្រែក្លាយជារឿងដែលអាចនឹងសម្រេចបាន ។ លើសពីនេះទៀត ក្នុងខណៈពេលដែលគម្រោងជួយដល់ជនរងគ្រោះបានផ្ដល់ជំនួយដល់ប្រជាជនទូទៅរបស់កម្ពុជាឲ្យចូលរួមក្នុងដំណើរការនាំយកអ្នកដឹកនាំខ្មែរក្រហមមកកាត់ទោស គម្រោងនេះក៏ត្រូវបានចាត់ទុកថាជាការចាប់ផ្ដើមសាជាថ្មីនៃ «គណៈកម្មការស្វែងរកការពិត» ក្រៅផ្លូវការដែលបានបង្កើតឡើងក្នុងដើមទសវត្សរ៍៨០ដែរ ។ ទីបញ្ចប់ តាមរយៈគម្រោងអប់រំទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរាប់បញ្ចូលជំនាន់អ្នកដែលមិនបានរស់ផុតពីរបបកម្ពុជាប្រជាធិបតេយ្យឲ្យចូលរួមក្នុងដំណើរការផ្សះផ្សាជាតិតាមរយៈការអប់រំក្មេងជំនាន់ក្រោយពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។ តាមការអប់រំដល់ក្មេងជំនាន់ក្រោយ កម្មវិធីនេះក៏មានបំណងការពារកុំឲ្យមានរឿងដូចគ្នាកើតឡើងសាជាថ្មីក្នុងអនាគតផងដែរ ។

តួនាទីកត់ត្រាប្រវត្តិសាស្ត្រខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានមុខងារសំខាន់ជាខ្លាំងក្នុងដំណើរការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ និងបង្កើនការទទួលខុសត្រូវ ។ ការរួមបញ្ចូលទាំងជនរងគ្រោះ និងជនដៃដល់តាមរយៈការសម្ភាសន៍ ។ល។ និង បង្កើតកម្មវិធីដែលទាក់ទងទៅនឹងការផ្សព្វផ្សាយ និងការអប់រំ គេអាចសម្រេចបានការផ្សះផ្សាក្នុងកម្រិតសហគមន៍ និងបុគ្គលផងដែរ ។ អាស្រ័យហេតុនេះ ការគួបផ្សំរវាងវិធីសាស្ត្រពីលើចុះក្រោម និងពីក្រោមឡើងលើក្នុងការសម្រេចបានការផ្សះផ្សា មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់នូវយន្ដការមួយដែលអាចជឿទុកចិត្តបាន និងមានប្រសិទ្ធភាពក្នុងការស្វែងរកទាំងយុត្តិធម៌តាមបែបផ្សះផ្សា និងតាមផ្លូវច្បាប់ជូនប្រជាជនកម្ពុជា ។ ដូច្នេះយន្ដការទាំងនេះអាចរួមសហការនិងសម្រួលដល់គ្នា ហើយបង្កើតជាគំរូនៃយុត្តិធម៌អន្តរកាលដែលអាចពន្លឿនការផ្សះផ្សាក្នុងកម្រិតបុគ្គល សហគមន៍និងជាតិក្នុងប្រទេសកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍ ។

## ញត្តិរណសិរ្ស

ក្រោយពេលដែលវៀតណាមបានរំដោះប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៩ រណសិរ្សសង្គ្រោះជាតិនិងសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតគណៈកម្មការស្រាវជ្រាវមួយដើម្បីស៊ើបអង្កេតពីបទឧក្រិដ្ឋរបស់របបខ្មែរក្រហម ។ គណៈកម្មការស្រាវជ្រាវនេះមានគោលបំណង «ប្រមូលភស្តុតាងដែលអាចប្រើសម្រាប់បញ្ចុះបញ្ចូលអង្គការសហប្រជាជាតិឲ្យបញ្ឈប់ការទទួលស្គាល់ខ្មែរក្រហមថាជាអ្នកតំណាងពេញសិទ្ធិរបស់ប្រទេសកម្ពុជា ហើយបង្ហាញពីទុក្ខវេទនារបស់ប្រជាជនកម្ពុជាចំពោះមុខអង្គការសហប្រជាជាតិ ក៏ដូចជាបណ្ដាប្រទេសនានាដើម្បីជំរុញឲ្យមានការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស» ។ ក្រោយពីការធ្វើដំណើរក្នុងខេត្តចំនួន១៩ក្នុងផ្ទៃប្រទេស គណៈកម្មការស្រាវជ្រាវនេះប្រមូលបានញត្តិចំនួន១២៥០ដែលសសេរដោយដៃ ហើយ «មានចុះហត្ថលេខា ឬ មានស្នាមម្រាមដៃប្រជាជនរាប់លាននាក់» ។ ថ្វីត្បិតតែគណៈកម្មការមានឆន្ទៈក្នុងការសម្រេចកិច្ចការនេះក្ដី តែទីបញ្ចប់ញត្តិទាំងនោះមិនបានបង្ហាញជូនអង្គការសហប្រជាជាតិ ឬប្រទេសណាដែលមានឥទ្ធិពលគ្រប់គ្រាន់ក្នុងការបញ្ឈប់ការទទួលស្គាល់របបខ្មែរក្រហមក្នុងមជ្ឈដ្ឋានអន្តរជាតិឡើយ ។

ថ្វីត្បិតតែគណៈកម្មការស្រាវជ្រាវនេះមិនបានសម្រេចគោលបំណងជាក់លាក់របស់ខ្លួនក្នុងពេលនោះក៏ដោយ តែលោកអាមី ហ្គោឌុន បានបង្ហាញថា គណៈកម្មការនេះអាចមានសក្ដានុភាព

ក្នុងការបំពេញតួនាទីមួយចំនួនក្នុងអ.វ.ត.ក. ក៏ដូចជាក្នុងដំណើរការនៃការផ្សះផ្សាដែរ ។ តួនាទីទាំងនេះរួមមាន ៖ ប្រភពឯកសារសម្រាប់ការស៊ើបអង្កេត មធ្យោបាយក្នុងការកំណត់អ្នកដែលអាចធ្វើជាសាក្សី ឬជនរងគ្រោះ ភ័ស្តុតាងក្នុងការកាត់ក្តីនឹងអាចជួយគណៈកម្មការស្វែងរកការពិតក្នុងថ្ងៃអនាគតនិងមានប្រយោជន៍ក្នុងការផ្តល់យុត្តិធម៌បែបផ្សះផ្សា ។ លោក អ៊ិចឆេសាន់ បានកត់សម្គាល់ថា ការប្រមូលញត្តិ និងការងារខ្លះទៀតដែលគណៈកម្មការនេះបានបំពេញមានសមាសភាពមួយចំនួនស្រដៀងនឹងគណៈកម្មការស្វែងរកការពិតដទៃទៀតដែរ ប៉ុន្តែលោកក៏បានទទួលស្គាល់ផងដែរថាគណៈកម្មការនេះមានចំណុចខ្សោយពីរ ។ ទីមួយ ដោយហេតុមានតែប្រជាជនខ្មែរយ៉ាងតិចតួចប៉ុណ្ណោះដែលបានយល់ដឹងអំពី «គណៈកម្មការស្វែងរកការពិត» មួយនេះ ដែល «គោលបំណងចម្បងរបស់យន្តការនេះគឺចង់ផ្សព្វផ្សាយព័ត៌មានដើម្បីឲ្យសង្គមទាំងមូលយល់ដឹងអំពីរឿងអតីតកាល តែមិនត្រូវបានសម្រេចនោះទេ» ។ ទីពីរ គាត់បានបញ្ជាក់ថា ការងាររបស់គណៈកម្មការនេះមានភាព «លម្អៀងទៅតែម្ខាង» ព្រោះថា ញត្តិទាំងនេះហាក់ដូចជាមិនមានការទទួលយកមកធ្វើជាសាក្សីពីកម្មាភិ-បាលខ្មែរក្រហមផងទេ ។ យ៉ាងណាមិញ ប្រសិនបើមានការបង្កើតសកម្មភាពដែលមានគោលដៅបង្កើនការយល់ដឹងទូទៅ និងទាក់ទិនទៅនឹងញត្តិរណសិរ្ស ការងារទាំងនោះអាចបម្រើដល់ដំណើរការរបស់គណៈកម្មការស្វែងរកការពិតដែលអាចនឹងមានក្នុងថ្ងៃអនាគតដោយផ្តល់ឯកសារប្រវត្តិសាស្ត្រទាក់ទងនឹងរបបខ្មែរក្រហមសម្រាប់ស្រាវជ្រាវ ហើយជំរុញបង្កើនការផ្សះផ្សា និង ការស្តារប្រទេសកម្ពុជាសាឡើងវិញ ។

## បញ្ញត្តិទាក់ទងនឹងគោលការណ៍

តាមរយៈការវិភាគទៅលើប្រតិកម្ម និងស្ថិតិក្នុងស្រុកទាក់ទិនទៅនឹងយុត្តិធម៌អន្តរកាល និងការផ្សះផ្សាសង្គម ឯកសារនេះសូមលើកបញ្ញត្តិទាក់ទងនឹងគោលការណ៍មួយចំនួន ៖

## កំណែទម្រង់ អ.វ.ត.ក.

អ.វ.ត.ក. ត្រូវផ្តោតអារម្មណ៍ទៅលើបញ្ហាបីដែលរាំងស្ទះដល់ការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ បញ្ហាទីមួយគឺកង្វះខាតការយល់ដឹងរបស់មហាជនអំពីការកាត់ក្តី ជាពិសេសក្មេងជំនាន់ក្រោយ ។ ការសិក្សារបស់សាកលវិទ្យាល័យកាលីហ្វ័រញ៉ានៅប៊ឺឃ្លី បានបង្ហាញថា «ក្នុងចំណោមអ្នកដែលចូលរួមការស្ទង់មតិក្នុងប្រទេសទាំងមូលមាន ៣៩ភាគរយមិនមានការយល់ដឹងអំពីអ.វ.ត.ក. ទាំងស្រុង ក្នុងខណៈពេលជាមួយគ្នានេះដែរ មាន៤៦ភាគរយទៀតមានចំណេះដឹងតែបន្តិចបន្តួចប៉ុណ្ណោះអំពីតុលាការនេះ អ្នកដែលមិនធ្លាប់រស់នៅក្រោមរបបខ្មែរក្រហមភាគច្រើនឆ្លើយថាមិនយល់ដឹងអំពី អ.វ.ត.ក. (៥០ភាគរយ) បើប្រៀបធៀបទៅនឹងអ្នកដែលធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម (៣៥ភាគរយ)» ។ ដំណោះស្រាយក្នុងរយៈពេលខ្លីនេះគឺការបង្កើនកិច្ចខិតខំក្នុងការពង្រីក និងអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយរបស់អ.វ.ត.ក. ហើយកិច្ចខិតខំនេះគប្បីធ្វើឡើងក្នុងសហប្រតិបត្តិការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជារួមជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាជាដើម ដែលអង្គការនេះបានចាប់ផ្តើមធ្វើការផ្សព្វផ្សាយដូចជាការផ្តល់មធ្យោបាយធ្វើដំណើរទៅកាន់សាលាក្តីដល់ជនរងគ្រោះដែលចង់មើលឃើញការកាត់ក្តីដោយផ្ទាល់ភ្នែក ។ តាមរយៈការពង្រីកកិច្ចផ្តួចផ្តើមដើម្បីផ្តល់ភាពងាយស្រួលដល់ជនរងគ្រោះក្នុងការធ្វើដំណើរមកកាន់សាលាក្តី យើងនឹងអាចចាប់ផ្តើមជំហានដំបូងក្នុងការផ្តល់យុត្តិធម៌អន្តរកាលរបស់អ.វ.ត.ក. ទៅកាន់មហាជនដែលមានអារម្មណ៍ថាតុលាការនេះមិនទាន់បានធ្វើការងារអ្វីសោះឡើយ ។ ការពង្រីកកម្មវិធីទាំងនេះអាចធ្វើឡើងក្នុងទម្រង់ដូចជាការកាត់បន្ថយថ្លៃសាហ៊ុយធ្វើដំណើររបស់អ្នកដែលរស់នៅតាមតំបន់ដាច់ស្រយាល ។ លោក អ៊ិចឆេសាន់ បានបញ្ជាក់ថា អ្នកទាំងនោះយកចិត្តទុកដាក់លើការងារចិញ្ចឹមជីវិតរបស់ខ្លួនជាងអ្វីៗទាំងអស់ ហើយមិនមានឱកាសប្រើប្រាស់មធ្យោបាយធ្វើដំណើរទៅកាន់សាលាក្តីដែលស្ថិតនៅឆ្ងាយពីក្រុមអ្នកទាំងនោះពេក ។

រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគប្បីតម្រូវឲ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឃោសនាអំពីឱកាសដូចខាងលើនេះ ជាពិសេសតាមរយៈវិទ្យុដែលការសិក្សារបស់សាកលវិទ្យាល័យកាលីហ្វ័រញ៉ានៅប៊ឺឃ្លី បានបញ្ជាក់ថាជាមធ្យោបាយចម្បងដើម្បីទទួលព័ត៌មានអំពីការកាត់ក្តីនេះ ព្រោះមានអ្នកចូលរួមក្នុងការស្ទង់មតិដល់ទៅ៨០,២ភាគរយបានផ្តល់ចម្លើយបែបនេះ ។ លើសពីនេះ

ទៀត រាជរដ្ឋាភិបាលគប្បីបង្កើតប៉ុស្តិ៍ទូរទស្សន៍ក្នុងស្រុកដែលផ្សាយអំពីដំណើរការកាត់ក្តីរបស់អ.វ.ត.ក. និងកម្មវិធីផ្សេងៗទៀតដែលទាក់ទងទៅនឹងអ.វ.ត.ក. ព្រោះថាការសិក្សារបស់សាកលវិទ្យាល័យកាលីហ្វ័រញ៉ានៅប៊ឺឃ្លីបានបង្ហាញឲ្យឃើញថា «មានប្រជាជនប្រហែលជាង៩៨ភាគរយបានបញ្ជាក់ថាមានបំណងទស្សនាដំណើរការកាត់ក្តីរបស់អ.វ.ត.ក. ប្រសិនបើមានការចាក់ផ្សាយបន្តផ្ទាល់នៅលើកញ្ចក់ទូរទស្សន៍» ។ កិច្ចប្រឹងប្រែងក្នុងការផ្សព្វផ្សាយបែបនេះគួបផ្សំជាមួយការចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដូច្នេះគួរតែអាចបំពេញសក្តានុភាពក្នុងការជំរុញឲ្យមានការចូលរួមពីសំណាក់ជនរងគ្រោះក្នុងដំណើរការកាត់ក្តីរបស់អ.វ.ត.ក. កាន់តែច្រើនៗ បច្ចុប្បន្ន ការចូលរួមរបស់ជនរងគ្រោះនៅមានកម្រិតទាបនៅឡើយ ព្រោះអ្នកដែលចូលរួមក្នុងការស្ទង់មតិក្នុងការសិក្សារបស់សាកលវិទ្យាល័យកាលីហ្វ័រញ៉ានៅប៊ឺឃ្លីបានបង្ហាញថាមិនមានអង្គការណាមួយធ្លាប់អញ្ជើញគាត់ឲ្យទៅចូលរួមក្នុងដំណើរការកាត់ក្តីរបស់ អ.វ.ត.ក. ឡើយ... ហើយមានប្រជាជនតិចជាងមួយភាគរយដែលបញ្ជាក់ថា អ.វ.ត.ក. ឬ អង្គការក្រៅរដ្ឋាភិបាលធ្លាប់ទាក់ទងជាមួយខ្លួនអំពីរឿងនេះ» ។ ដើម្បីផ្តល់ជំនួយដល់ដំណើរការរបស់អ.វ.ត.ក. អង្គការក្រៅរដ្ឋាភិបាលគប្បី «ធានានូវការផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយស្តីអំពីដំណើរការកាត់ក្តី... សេវាកម្មផ្លូវច្បាប់សម្រាប់ជនរងគ្រោះ និងជនដែលដល់ កម្មវិធីការពារសាក្សី អង្គប្រជុំសាធារណៈដែលមានអ្នកចូលរួមច្រើន... និងកម្មវិធីនីតិក្រម» ។ អង្គការក្រៅរដ្ឋាភិបាលអាចផ្តល់ជំនួយដល់ដំណើរការរបស់អ.វ.ត.ក. ដោយដើរតួជាអ្នកឃ្លាំមើលការកាត់ក្តី ហើយ «...បង្កើត និងអនុវត្តវិធីសាស្ត្រដើម្បីជួយដំណើរការកាត់ក្តីរបស់អ.វ.ត.ក. ហើយបំពេញតួនាទីជាអ្នកឃ្លាំមើលយ៉ាងតឹងរ៉ឹងចំពោះដំណើរការទាំងមូលដោយមិនមានជម្លោះផលប្រយោជន៍ ។ កត្តាមួយដែលធ្វើឲ្យកិច្ចផ្តួចផ្តើមទាំងនេះមិនសូវមានប្រសិទ្ធភាពគឺកង្វះខាតការគាំទ្រខាងហិរញ្ញវត្ថុដែលនេះទាមទារឲ្យមានជំនួយពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននិងសហគមន៍ស៊ីវិលអន្តរជាតិ ។

លើសពីនេះទៀត អ.វ.ត.ក. គប្បីបង្កើនឱកាសក្នុងការអប់រំអ្នកជំនាន់ក្រោយដោយខ្លួនឯង និងពង្រឹងរូបភាពខ្លួនជាការកាត់ក្តីដ៏ត្រឹមត្រូវមួយ និងជាឧទាហរណ៍នៃវិធានគតិយុត្តិក្នុងការចងចាំរបស់អ្នកជំនាន់ថ្មីដើម្បីឈានទៅរកការបង្កើតផ្នត់គំនិតយុត្តិធម៌នៅប្រព័ន្ធតុលាការក្នុងស្រុកនិងដំណើរការកាត់ក្តី ។ ទាំងនេះអាចសម្រេចបានតាមរយៈការពង្រីកកម្មវិធីផ្សព្វផ្សាយដោយមានការសហការពីវិទ្យាល័យនានាក្រោមការសម្របសម្រួលរបស់ក្រសួងអប់រំ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ។ ឧទាហរណ៍កម្មវិធីផ្សព្វផ្សាយដល់សិស្សានុសិស្សរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអាចយកមកពង្រីកបន្ថែម ឬប្រើប្រាស់ជាគំរូក្នុងការបង្កើនការចូលរួមរបស់អ្នកជំនាន់ក្រោយក្នុងដំណើរការកាត់ក្តី ។ កម្មវិធីទាំងនេះអាចធ្វើឡើងតាមរយៈការសម្រួលនិងឧបត្ថម្ភដល់ការចុះកម្មសិក្សាដើម្បីបម្រើដល់អ្នកដែលមានចំណង់ចំណូលចិត្តក្នុងការទស្សនាការកាត់ក្តីដោយផ្ទាល់ ឬតាមរយៈការចែកចាយសៀវភៅដែលទាក់ទងទៅនឹងអ.វ.ត.ក. ដល់វិទ្យាល័យនានាដើម្បីបំពេញបន្ថែមទៅលើសៀវភៅអំពីប្រវត្តិខ្មែរក្រហមដែលមជ្ឈ-មណ្ឌលឯកសារកម្ពុជាកំពុងចែកចាយ ។

កម្មវិធីដែលបានរៀបរាប់ខាងលើនេះមិនត្រឹមតែអាចបង្កើនការផ្សព្វផ្សាយព័ត៌មានអំពី អ.វ.ត.ក. ដើម្បីសម្រេចបានយុត្តិធម៌តាមផ្លូវច្បាប់ប៉ុណ្ណោះទេ ថែមទាំងអាចលើកស្ទួយយុត្តិធម៌បែបផ្សះផ្សាដោយបំពេញតម្រូវការបឋមនៃយុត្តិធម៌បែបការផ្សះផ្សាដូចដែលបានកំណត់ដោយស្ថាប័នយុត្តិធម៌ជាតិភ្នាក់ងារមួយនៃក្រសួងយុត្តិធម៌របស់សហរដ្ឋអាមេរិក ។ ស្ថាប័នយុត្តិធម៌ជាតិបានពណ៌នាថា ជនរងគ្រោះត្រូវការ «ដំណឹងទទួលស្គាល់ ដំណោះស្រាយ កសិណសាក្សី សុវត្ថិភាព និង ការគាំទ្រ» ដើម្បីជាកិច្ចចាប់ផ្តើមនៃយុត្តិធម៌ ហើយកម្មវិធីផ្សព្វផ្សាយរបស់ អ.វ.ត.ក. ជាពិសេសកម្មវិធីដែលផ្តោតទៅលើកិច្ចផ្តួចផ្តើមក្នុងការអប់រំបានផ្តល់ដំណឹងនិងជាសក្ខីកម្មអំពីបទឧក្រិដ្ឋក្នុងសម័យខ្មែរក្រហម ហើយថែមទាំងបានទទួលស្គាល់នូវទុក្ខវេទនារបស់ជនរងគ្រោះជាច្រើនៗ ដូច្នេះ តាមរយៈការបង្កើននិងពង្រីកការផ្សព្វផ្សាយរបស់អ.វ.ត.ក. តុលាការនេះមិនត្រឹមតែអាចសម្រេចបានគោលដៅចម្បងក្នុងការផ្តល់យុត្តិធម៌តាមផ្លូវច្បាប់ទេ ថែមទាំងអាចជំរុញឲ្យមានយុត្តិធមបែបផ្សះផ្សាថែមទៀតផង ។

បញ្ហាទីពីរដែល អ.វ.ត.ក. កំពុងតែជួបប្រទះគឺសម្ពាធ

មកពីភាគីទាំងសងខាងទាក់ទិនទៅនឹងពេលវេលា ។ ក្នុងខណៈដែលមេធាវីការពារក្តីរបស់ ឌុច ចោទប្រកាន់ថាការកាត់ក្តីនេះមានភាពអយុត្តិធម៌ដោយសារតែមានពេលវេលាខ្លីពេកក្នុងការឆ្លើយតបទៅនឹងប្រធានបទមួយចំនួន មតិជាច្រើនលើសលុបក្នុងចំណោមអ្នកដែលត្រូវបានជួបសម្ភាសនិងស្ទង់មតិបានបង្ហាញថា ការកាត់ក្តីនេះចំណាយពេលយូរហួសពេករួចទៅហើយក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែលត្រូវបានបញ្ចប់អស់រយៈពេល៣០ឆ្នាំមកហើយ ។ ដើម្បីដោះស្រាយជម្លោះនេះ អ.វ.ត.ក. គួរសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីធានានូវភាពយុត្តិធម៌របស់តុលាការនេះ ។ ក្នុងខណៈពេលជាមួយគ្នានេះ ត្រូវបង្កើនកិច្ចប្រឹងប្រែងដើម្បីជួយពន្យល់អំពីមូលហេតុនៃភាពយឺតយ៉ាវនេះដល់អ្នកដែលមានអារម្មណ៍បែបនេះ ហើយបញ្ជាក់ថាតុលាការនេះបង្កើតឡើងដើម្បីនាំយកជនដៃដល់មកកាត់ទោស មិនមែនផ្តល់ឱកាសឲ្យជនទាំងនោះគេចផុតពីទណ្ឌកម្មនោះឡើយ ។ រាជរដ្ឋាភិបាលកម្ពុជារួមជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនអាចបង្កើតជាកម្មវិធីផ្សព្វផ្សាយក្នុងទម្រង់ជាការពិភាក្សាដើម្បីបកស្រាយអំពីភាពអូសបន្លាយរបស់ការកាត់ក្តីក្នុងបំណងធានានូវយុត្តិធម៌ ហើយនិងមូលហេតុដែលជនដៃដល់ទាំងនោះមានសិទ្ធិទទួលបានយុត្តិធម៌បែបនេះ ។ ការធ្វើបែបនេះនឹងជួយផ្សារភ្ជាប់គំនិតខ្វែងគ្នារវាងផ្នត់គំនិតនៃយុត្តិធម៌របស់ប្រជាជនខ្មែរនិងសហគមន៍អន្តរជាតិដូចដែលបានរៀបរាប់រួចមកហើយនោះ ។ ដោយសារការយល់ដឹងអំពីសារសំខាន់នៃការផ្សព្វផ្សាយនេះ ដូច្នេះហើយ អ.វ.ត.ក.ត្រូវប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដើម្បីផ្សព្វផ្សាយផ្នត់គំនិតទាំងនេះ ឧទាហរណ៍ដូចជាសារសំខាន់នៃការកាត់ក្តីប្រកបដោយយុត្តិធម៌ដែលធ្វើឲ្យមេធាវីការពារក្តីមានអារម្មណ៍ថាកូនក្តីរបស់ខ្លួនទទួលបានការកាត់ក្តីត្រឹមត្រូវមួយ ។ ទោះយ៉ាងណាមិញ យើងគួរកត់សម្គាល់ថា មេធាវីការពារក្តីអាចនឹងបន្តធ្វើការចោទប្រកាន់បែបនេះដើម្បីធ្វើឲ្យចៅក្រមបង្ហាញភាពអាណិតអាសូរចំពោះកូនក្តីខ្លួននៅក្នុងសាលក្រម ។

បញ្ហាទីបីរួមមានការចោទប្រកាន់ពីអំពើពុករលួយ និងកង្វះខាតតម្លាភាពរបស់អ.វ.ត.ក. ។ ប្រសិនបើ អ.វ.ត.ក. ចង់រក្សានូវកេរ្តិ៍ឈ្មោះយុត្តិធម៌ និងភាពមិនលម្អៀងរបស់ខ្លួន តុលាការនេះត្រូវតែដោះស្រាយជាមួយការចោទប្រកាន់ទាំងនោះ ។ រាជរដ្ឋាភិបាលកម្ពុជាគួរបង្កើតការស៊ើបអង្កេតផ្ទៃក្នុងមួយដែលមានសមាជិកជាបុគ្គលដែលមិនមានគោលជំហរ មិនមានឈ្មោះក្នុងជួររាជរដ្ឋាភិបាល ឬក្រសួងយុត្តិធម៌ដើម្បីកុំឲ្យមានការចោទប្រកាន់ពីអំពើពុករលួយបន្ថែមទៀត បែបនេះទើបអាចលុបបំបាត់អំពើពុករលួយដែលបានរកឃើញ និងបញ្ចប់ពាក្យចចាមអារ៉ាមទាំងអស់ ។ ប៉ុន្តែដោយសារតែរាជរដ្ឋាភិបាលខ្លួនឯងក៏ទទួលរងការចោទប្រកាន់អំពីភាពពុករលួយដែរនោះ ដំណោះស្រាយដែលអាចទទួលយកបានប្រហែលជាការស៊ើបអង្កេតដែលធ្វើឡើងដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ ប្រសិនបើគំនិតនេះអាចធ្វើទៅបាន ហើយការស៊ើបអង្កេតតាមរយៈសារព័ត៌មានអាចទទួលបន្ទុកក្នុងការស្វែងរកការពិត នោះអង្គការក្រៅរដ្ឋាភិបាលគប្បីទាក់ទងផ្ទាល់ជាមួយសារព័ត៌មានហើយស្នើសុំឲ្យគេបង្ហាញការពិតដោយមិនមានភាពលាក់លៀមដោយផ្តោតទៅលើបុគ្គលទាំងឡាយដែលជាប់ពាក់ព័ន្ធ ។ នេះនឹងអាចធានានូវភាពមិនលម្អៀងរបស់តុលាការនេះដើម្បីសម្រេចបាននូវការផ្សះផ្សានិងកសាងសង្គមសាជាថ្មី ។ នេះមិនមានន័យថា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននឹងត្រូវ «កាឡៃ» ការពិត ឬធ្វើយ៉ាងនេះដោយសារតែសម្ពាធរបស់រាជរដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាលនោះទេ តែអង្គការក្រៅរដ្ឋាភិបាលគប្បីបង្ហាញឲ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដឹងអំពីការបាក់បែកក្នុងសង្គមកម្ពុជា រួមជាមួយនឹងសារសំខាន់នៃការផ្សះផ្សាច្រើនកម្រិតដែលការកាត់ក្តីនេះអាចនឹងសម្រេចបាន ។ បែបនេះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននឹងរក្សាភាពមិនលម្អៀងរបស់ខ្លួន ធ្វើការរាយការណ៍អំពីការពិត និងធ្វើការបន្ទោសទៅលើជនដែលទទួលខុសត្រូវក្នុងការបង្កឲ្យមានអំពើពុករលួយកើតឡើងក្នុង អ.វ.ត.ក. តែមិនបណ្តាលឲ្យការចោទប្រកាន់ទាំងនោះរីករាលដាលធំទៅៗរហូតដល់បំផ្លាញ អ.វ.ត.ក. ទាំងមូលទេ ។

## គណៈកម្មការស្វែងរកការពិត

គណៈកម្មការស្វែងរកការពិតអាចផ្តល់ផលប្រយោជន៍មួយចំនួនដូចជា : រកការពិតនៃបទឧក្រិដ្ឋដែលធ្វើឡើងដោយខ្មែរក្រហម បង្កើតឲ្យមានការពិភាក្សាក្នុងប្រទេស ជំរុញឲ្យមាន

ការផ្សះផ្សា បង្កើនការទទួលខុសត្រូវរបស់ជនដៃដល់ ផ្តល់ឲ្យជនរងគ្រោះជាមួយយុត្តិធម៌តាមការផ្សះផ្សា ដូចជាការការពារ និងគាំទ្រ និងផ្តល់ជូនជនដៃដល់នូវយុត្តិធមតាមការផ្សះផ្សានិងការការពារដែលជាទិដ្ឋភាពក្នុងការផ្សះផ្សា ។ ប៉ុន្តែ គណៈកម្មការស្វែងរកការពិតនេះមិនសមស្របក្នុងករណីបទឧក្រិដ្ឋដែលប្រព្រឹត្តដោយខ្មែរក្រហមទេ ដោយសារតែមូលហេតុចម្បងពីរ ។ ទីមួយ យើងអាចឃើញតាមរយៈការស្ទង់មតិថា «ប្រជាជនកម្ពុជាមិនមានចំណាប់អារម្មណ៍ក្នុងការបង្កើតគណៈកម្មការស្វែងរកការពិត» នោះទេ ។ ទីពីរ គណៈកម្មការស្វែងរកការពិតនេះអាចបង្កើតឲ្យមានជម្លោះជាជាងបង្កើនការផ្សះផ្សា ។

លោក ថាយ យើ បានបកស្រាយក្នុងអត្ថបទ «យឺតប្រសើរជាងមិនមកដល់ៈ តុលាការចម្រុះនៅកម្ពុជា» ថា «គណៈកម្មការស្វែងរកការពិតអាចមានប្រសិទ្ធភាពល្អនៅក្នុងកាលៈទេសៈដែលទាមទារឲ្យមានការស្វែងរកការពិតមួយចំនួនធំពីអតីតកាលដែលទើបតែកន្លងផុតទៅ» ប៉ុន្តែចំពោះប្រទេសកម្ពុជាវិញ «ការពិត» ភាគច្រើនត្រូវបានទទួលដឹងឮរួចទៅហើយ ហើយបទឧក្រិដ្ឋនោះក៏បានបញ្ចប់ទៅអស់រយៈពេល៣០ឆ្នាំទៅហើយដែរ ។ លោក ថាយ យើ បានបញ្ជាក់ទៀតថា «នៅក្នុងប្រទេសកម្ពុជា សាក្សីភាគច្រើនទទួលរងអំពើហិង្សា និងការគំរាមកំហែង» ហើយនេះនឹងធ្វើឲ្យប្រជាជនមិនហ៊ានមកកាន់គណៈកម្មការស្វែងរកការពិតដោយខ្លួនឯង លុះត្រាតែគាត់ត្រូវបានដាក់កំហិតឲ្យធ្វើដូច្នេះ ។ អ្នកជំនាញខាងជំងឺផ្លូវចិត្តក៏បានកត់សម្គាល់ថា គណៈកម្មការស្វែងរកការពិតអាចនឹងផ្សងជាមួយគ្រោះថ្នាក់កកូរកកាយអារម្មណ៍ដែលបានលាក់ទុកអស់រយៈពេលជាច្រើនឆ្នាំនោះតាមរយៈការនិយាយរំឭកអំពីភាពសាហាវឃោរឃៅរបស់របបខ្មែរក្រហម ហើយនេះអាចនឹងនាំឲ្យមានការកើនឡើងយ៉ាងរហ័សនៃចំនួនអ្នកដែលមានជំងឺផ្លូវចិត្តក្នុងប្រទេសកម្ពុជា ។

នៅក្នុងកម្រិតសហគមន៍ គណៈកម្មការនេះហាក់ដូចជាមិនមានភាពចាំបាច់ទាល់តែសោះ ព្រោះថាជនរងគ្រោះ និងជនដៃដល់បានរស់នៅជាមួយគ្នាយ៉ាងសន្តិភាពនៅក្នុងភូមិជាមួយគ្នារួចទៅហើយ ។ នេះបានបញ្ជាក់យ៉ាងច្បាស់តាមរយៈការជួបសម្ភាសន៍ជាមួយអ្នកជិតខាងពីររូបរបស់ ហ៊ឹម ហ៊ុយ ដែលជាអតីតកងសន្តិសុខក្នុងមន្ទីរស-២១ ។ ក្នុងបទសម្ភាសម្នាក់បានសម្តែងនូវការយោគយល់ដល់ ហ៊ឹម ហ៊ុយ ដោយនិយាយថាគាត់មិនគិតថា ហ៊ឹម ហ៊ុយ គួរទទួលការកាត់ទោសនោះទេ ព្រោះគេគ្រាន់តែធ្វើតាមតែបញ្ជាប៉ុណ្ណោះ រីឯប្អូន ស្រេង ស្រឿន ដែលមានអាយុ២០ឆ្នាំ មិនបានដឹងអំពីឋានៈរបស់ ហ៊ឹម ហ៊ុយ ឬ ឧក្រិដ្ឋកម្មដែលគេបានប្រព្រឹត្តនោះទេ ហើយគាត់ជឿជាក់ថា មានតែអ្នកដឹកនាំខ្មែរក្រហមដូចជា ប៉ុល ពត ប៉ុណ្ណោះទេដែលគួរទទួលការកាត់ទោស ។ ហេតុដូច្នេះ ដោយសារមានចន្លោះយ៉ាងស្រពេចស្រពិលក្នុងការបែងចែករវាងជនរងគ្រោះនិងជនដៃដល់ គណៈកម្មការស្វែងរកការពិតអាចបង្កឲ្យមានបញ្ហាដល់សហគមន៍ដែល «ជនរងគ្រោះ» និង «ជនដៃដល់» រស់នៅយ៉ាងមានសន្តិភាពបែបនេះ ។ លើសពីនេះទៀត គណៈកម្មការនេះមិនត្រឹមតែមិននាំមកនូវការផ្សះផ្សានោះទេ ថែមទាំងអាចនឹងធ្វើឲ្យជនរងគ្រោះទទួលការឈឺចាប់សាជាថ្មី ព្រោះថាគណៈកម្មការស្វែងរកការពិតតម្រូវឲ្យមានការអត់ទោសទៅជនដៃដល់ដែលនិយាយរៀបរាប់ការពិតមិនថាជននោះប្រព្រឹត្តអំពើសាហាវព្រៃផ្សៃទាំងនោះដោយសារតែមានឬមិនមានទទួលការគំរាមកំហែងដល់ជីវិតក៏ដោយ ។ លីនគុន បាននិយាយយ៉ាងខ្លី តែច្បាស់ថា «ការផ្សះផ្សាមិនគួរចាត់ទុកជាកាតព្វកិច្ចសីលធម៌មួយនោះទេ ហើយយើងក៏មិនគួរស្នើសុំឲ្យជនរងគ្រោះស្រឡាញ់អ្នកដែលធ្លាប់ធ្វើបាបគេនោះទេ» ។

*(នៅមានត)*

**ម៉ារីឌីត ឌីន និង ណាតាហ្សា បាច**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ* ***http://www.voanews.com/ khmer/democratic-kampuchea.cfm*** *របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។* **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# យុត្តិធម៌នៃដំណើរការនីតិវិធី ៖ ការពិនិត្យមើលអំពីប្រព័ន្ធ បណ្តឹងជំទាស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដំណើរការស្របច្បាប់នៃការកាត់ក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវបានវិនិច្ឆ័យក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីធានាបាននូវភាពយុត្តិធម៌តាមផ្លូវច្បាប់មិនត្រឹមតែសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហមប៉ុណ្ណោះទេ តែថែមទាំងជនជាប់ចោទផងដែរ ។ ការដែលភាគីទាំងសងខាងអាចឈានទៅរកការស្នើសុំឧទ្ធរណ៍ចូលរួមលទ្ធផលជាមុនក្នុងដំណើរការទៅរកយុត្តិធម៌ សម្រាប់ភាគីទាំងសងខាងគឺមានសារសំខាន់ណាស់ក្នុងការធានាបាននូវទម្រង់យុត្តិធម៌និងភាពស្មើគ្នានេះ ។ ការសុំលទ្ធផលជាមុនក្នុងអំឡុងពេលនៃការពិចារណានេះគឺជាឧទ្ធរណ៍នៃការសម្រេចចិត្តមិនមែនចុងក្រោយ នៅពេលដែលអង្គជំនុំជម្រះកំពុងតែដំណើរការនៅឡើយ ។ នៅក្នុងដំណើរការកាត់ក្តីព្រហ្មទណ្ឌអន្តរជាតិ ការសុំលទ្ធផលជាមុននេះគឺជាដំណើរការក្នុងលក្ខណៈពិនិត្យមើលដំណើរការទុកជាមុនថាតើសិទ្ធិនៃភាគីមួយអាចមានភាពប្រថុយនឹងការរំលោភច្បាប់ដែលនឹងត្រូវចេញសេចក្តីសម្រេចដោយតុលាការដែរឬអត់ ។ ភាគីនីមួយៗអាចស្នើសុំលទ្ធផលមុននឹងសេចក្តីសម្រេចចុងក្រោយត្រូវបានប្រកាសជាផ្លូវការដូច្នេះភាគីធ្វើសំណើអាចនឹងដឹងខ្លួនមុនថាត្រូវទទួលទោសបែបណា ។ ទោះបីជាវិធីនេះគឺជាករណីពិសេសដែលមិនមែនតុលាការអន្តរជាតិទូទៅសុទ្ធតែធ្វើបានក៏ដោយ ក៏តុលាការអន្តរជាតិជាច្រើនបានអនុញ្ញាតឲ្យមានករណីនៃការសុំមើលលទ្ធផលមុនផងដែរ ។

ក្នុងការបង្កើតវិធានទាំងនេះសម្រាប់ការសុំមើលលទ្ធផលជាមុន ឬក៏ហៅថាលទ្ធផលបណ្តោះអាសន្ន តុលាការអន្តរជាតិ តុលាការចម្រុះជាតិនិងអន្តរជាតិមិនត្រឹមតែត្រូវផ្តល់លទ្ធភាពឲ្យមានករណីបែបនេះនៅក្នុងដំណើរការព្រហ្មទណ្ឌអន្តរជាតិប៉ុណ្ណោះទេ តែតុលាការទាំងនោះត្រូវតែថ្លឹងថ្លែងក្នុងការប្រកួតប្រជែងផលប្រយោជន៍ ដូចជាសិទ្ធិរបស់ភាគីការពារក្តីក្នុងការធានាបាននូវតុលាការយុត្តិធម៌និងសិទ្ធិក្នុងការកាត់ក្តីដែលមានរយៈពេលខ្លីហើយមានប្រសិទ្ធភាពខ្ពស់ ។ ទោះជាមានការអះអាងបែបនេះក្តី ការប្រកាសឧទ្ធរណ៍បណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានផ្តល់ការការពារសិទ្ធិគ្រប់គ្រាន់របស់ភាគីចុងចោទ ហើយក៏មិនស៊ីគ្នាទៅនឹងការអនុវត្តកន្លងមករបស់តុលាការអន្តរជាតិទាំងឡាយផងដែរ ។ អត្ថបទនេះឆ្លុះបញ្ចាំងអំពីការព្រួយបារម្ភមួយចំនួន ហើយនិងដើម្បីបកស្រាយអំពីវិធានការត្រឹមត្រូវមួយចំនួនដែលអង្គជំនុំជម្រះវិសាមញ្ញបានធ្វើ ។

**១) អង្គជំនុំជម្រះវិសាមញ្ញមិនគួរធ្វើការប្រកាសឧទ្ធរណ៍បណ្តោះអាសន្នដែលនាំឲ្យមានការបង្អាក់ដល់ភាគីនីមួយៗឡើយ ហើយក៏មានការប៉ះពាល់ដល់សេចក្តីសម្រេចចុងក្រោយដែរ**

នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ភាគីការពារក្តីមានសិទ្ធិតិចតួចចំពោះសេចក្តីសម្រេចឧទ្ធរណ៍បណ្តោះអាសន្ន ។ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី និង រ៉្វាន់ដា ឬដែលគេស្គាល់ជាទូទៅថា «តុលាការដែលគ្មានការគ្រោងទុក» និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ជនត្រូវចោទមានសិទ្ធិឧទ្ធរណ៍ច្រើនជាងជនត្រូវចោទរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ រយៈពេលដ៏តឹងតែងរបស់អង្គជំនុំជម្រះវិសាមញ្ញក៏មិនសមស្របសម្រាប់រយៈពេលដ៏តឹងតែងតាមកាលៈទេសៈទាល់តែសោះ ។ ដើម្បីធានាបានថាសេចក្តីសម្រេចទាំងអស់ដែលទាក់ទងទៅនឹងភាពស្មើគ្នាអាចនឹងត្រូវបានយកមកត្រួតពិនិត្យឡើងវិញដោយគ្មានការពន្យារពេលដំណើរការ ដំណាក់កាលឧទ្ធរណ៍បណ្តោះអាសន្នដែលគេបានអនុញ្ញាតគួរតែធ្វើឡើងជាមួយគ្នានឹងសេចក្តីសម្រេចឧទ្ធរណ៍ចុងក្រោយដែលមិនត្រូវបានអនុញ្ញាតឬក៏ធ្វើឡើងក្នុងពេលវេលាខុសគ្នា ។

មុននឹងការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញកាលពីឆ្នាំ២០០៨ ជនត្រូវចោទអាចធ្វើសំណើឲ្យមានការវិនិច្ឆ័យលើរឿង «ភាពពិតជាក់ស្តែងនិងតាមផ្លូវច្បាប់ដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ» ។ ប៉ុន្តែ ចាប់ពីវិធានផ្ទៃក្នុងបង្កើតមក សិទ្ធិរបស់ភាគីការពារក្តីដែលធ្លាប់មានត្រូវ

បានកាត់បន្ថយ ថ្មីៗនេះ តុលាការជាន់ខ្ពស់របស់អង្គជំនុំជម្រះគ្រាន់តែបើកអង្គសវនាការខ្ទួរណ៍ចុងក្រោយលើករណីមួយចំនួនប៉ុណ្ណោះដូចជាៈ ក) កំហុសឆ្គងទៅលើសំណួរអំពីការធ្វើសេចក្តីសម្រេចនិងការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវតាមផ្លូវច្បាប់ ខ) កំហុសឆ្គងការពិតដែលបណ្តាលឲ្យមានភាពមិនត្រឹមត្រូវផ្នែកយុត្តិធម៌ ។ លើសពីនេះទៅទៀត វិធានដែលបានធ្វើវិសោធនកម្មរួចទាមទារឲ្យមានបទដ្ឋានខ្ពស់ជាងវិធានចាស់ចំពោះការបញ្ចូលបណ្តឹងខ្ទួរណ៍នាដំណាក់កាលចុងក្រោយ ។ នៅក្នុងវិធានថ្មីនេះជនត្រូវចោទលែងមានសិទ្ធិក្នុងការដាក់ជូនសំណើសង្ខេបដែលរៀបរាប់ពីហេតុផលទៅកាន់ខ្ទួរណ៍ទៀតបានហើយ ។ វិធានផ្ទុយក្នុងនេះបានផ្តល់ដល់ជនជាប់ចោទដូចជា ជនជាប់ចោទអាចកំណត់ជាក់លាក់បាននូវការចោទប្រកាន់មួយចំនួនដែលមិនសមហេតុផលច្បាប់និងបញ្ជាក់អំពីថាតើកំហុសនោះអាចប៉ះពាល់ដល់សេចក្តីសម្រេចបែបណាឬក៏ជនជាប់ចោទអាចកំណត់ឲ្យជាក់លាក់នូវការចោទប្រកាន់មួយចំនួនដើម្បីបញ្ជាក់ថាតើកំហុសនៃការចោទប្រកាន់នោះបណ្តាលឲ្យមានភាពមិនត្រឹមត្រូវផ្នែកយុត្តិធម៌ប៉ុនណា ។ ហេតុផលនីមួយៗនៃខ្ទួរណ៍ត្រូវតែមានការតវ៉ានិងការប្រើប្រាស់សិទ្ធិ ។

ការឈានទៅរកវិធានការដ៏តឹងរ៉ឹងជាងមុនក្នុងខ្ទួរណ៍នៅឯដំណាក់កាលក្នុងសេចក្តីសម្រេចចុងក្រោយគួរតែមានច្រើនជាងមុនចំពោះការពិនិត្យមើលអំពីប្រព័ន្ធដោះស្រាយបណ្តឹងជំទាស់សម្រាប់ភាគីការពារក្តី ។ ល្គឹកណាភាគីការពារក្តីគ្មានសិទ្ធិនៅក្នុងអំឡុងពេលសវនាការ ឬបន្ទាប់ពីតុលាការដើម្បីស្នើសុំពិនិត្យរឿងរ៉ាវទាក់ទងទៅនឹងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ភាពស្របច្បាប់នៃដំណើរការទាំងមូលនឹងត្រូវគេចោទសួរជាមិនខាន ។ រឿងទាក់ទងទៅនឹងសិទ្ធិរបស់ភាគីការពារក្តីក្នុងការធ្វើឲ្យសវនាការប្រព្រឹត្តទៅដោយលឿននិងមានប្រសិទ្ធភាព ហើយការបន្ទរក់ដោយសារតែលទ្ធភាពរបស់ភាគីការពារក្តីដើម្បីអនុវត្តយុត្តិសាស្ត្រការពារក្តី ប្រហែលជាមិនអាចដាក់បណ្តឹងជំទាស់បានទេក្នុងដំណើរការសវនាការនេះ ។

**២) ការប្តឹងជំទាស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនស៊ីគ្នាទៅនឹងអ្វីដែលតុលាការអន្តរជាតិនានាបានអនុវត្តកន្លងមកទេ**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជាបានផ្តល់សិទ្ធិបន្តិចបន្តួចដល់ភាគីការពារក្តីក្នុងការប្តឹងខ្ទួរណ៍ទាមទារការដឹងព្រួពីសេចក្តីសម្រេចបណ្តោះអាសន្ន ប៉ុន្តែបានផ្តល់សិទ្ធិយ៉ាងច្រើនដល់ព្រះរាជអាជ្ញា ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និងតុលាការអន្តរជាតិនានាមិនបានផ្តល់សិទ្ធិតិចតួចដល់ជនជាប់ចោទបែបនេះទេ ។ មិនតែប៉ុណ្ណោះ តុលាការខាងលើទាំងអស់នេះមិនបានចាំដល់ពេលចេញសេចក្តីសម្រេចទើបជនត្រូវចោទមានសិទ្ធិក្នុងការតវ៉ាទេ ហើយចំណុចនេះមានលក្ខណៈតឹងរ៉ឹងនិងស្មុគស្មាញសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តុលាការទាំងអស់នេះហាក់ដូចជាផ្តល់ឱកាសឲ្យមានការត្រួតពិនិត្យទាំងស្រុងតែម្តង ដោយអនុញ្ញាតឲ្យមានការត្រួតពិនិត្យការដោះស្រាយបណ្តឹងចំពោះរឿងរ៉ាវសំខាន់ៗនៅដំណាក់កាលចុងក្រោយនៃការវិនិច្ឆ័យដែលករណីបែបនេះពិតជាមិនអាចធ្វើបាននៅដំណាក់កាលមុនពេលចេញសេចក្តីសម្រេចទេ ។

ឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិដែលជាអង្គភាពមានការតឹងរ៉ឹងជាងគេបង្អស់ក្នុងការដាក់ឲ្យមានការតវ៉ាមុននឹងចេញសេចក្តីសម្រេច យ៉ាងហោចណាស់ក៏បានផ្តល់សិទ្ធិដល់ជនជាប់ចោទឲ្យមានការតវ៉ាចំពោះសេចក្តីសម្រេចចុងក្រោយដែរ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានផ្តល់សិទ្ធិមួយចំនួនដូចខាងក្រោមៈ ១) កំហុសឆ្គងកំហុសបែបបទ ២) កំហុសការពិត ៣) កំហុសផ្លូវច្បាប់ ឬ ៤) ហេតុផលផ្សេងទៀតដែលប៉ះពាល់ដល់ភាពស្មើគ្នាឬការទុកចិត្តនៃដំណើរការកាត់ក្តីនិងសេចក្តីសម្រេច ។ តម្រូវការដែលកំហុសផ្លូវច្បាប់ធ្វើឲ្យសេចក្តីសម្រេចមានប្រសិទ្ធភាព និងតម្រូវការចាំបាច់ដែលកំហុសផ្នែកច្បាប់បណ្តាលឲ្យមានភាពមិនសមស្របនៃភាពយុត្តិធម៌អាចនឹងយកមកពិចារណាក្នុងបទដ្ឋានខ្ពស់សម្រាប់កំហុសផ្លូវច្បាប់និងកំហុសពិត ។ ផ្ទុយពីអ្វីដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានធ្វើ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនបានតម្រូវឲ្យមានបទដ្ឋានខ្ពស់បែបនេះទេ ។ លើសពីនេះទៅទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិបានអនុញ្ញាតឲ្យមានការពិនិត្យមើលការតវ៉ាមុននឹងចេញសេចក្តីសម្រេចនៃកំហុសឆ្គងបែប

បទ និងហេតុផលផ្សេងៗទៀតដែលប៉ះពាល់ដល់ដំណើរការយុត្តិធម៌ និងភាពទុកចិត្តដែលត្រូវបានប្រើប្រាស់ជាទូទៅ ។

តុលាការដទៃទៀតដែលបានរៀបរាប់នៅក្នុងអត្ថបទនេះក៏បានអនុញ្ញាតឲ្យមានការតវ៉ាចំពោះសេចក្ដីសម្រេចចុងក្រោយដែរ ។ ឧទាហរណ៍ដូចជា តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនបានអនុញ្ញាតឲ្យមានការពិចារណាទៅលើកំហុសឆ្គងបែបបទបន្ថែមទៅលើហេតុផលផ្សេងទៀតដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុញ្ញាត ។ ទោះបីជាតុលាការដែលមិនមានការគ្រោងទុកថា កំហុសផ្លូវច្បាប់បានធ្វើឲ្យសេចក្ដីសម្រេចមានប្រសិទ្ធភាព ហើយកំហុសការពិតតម្រូវឲ្យមានភាពមិនត្រឹមត្រូវផ្នែកយុត្តិធម៌ តុលាការទាំងនោះនៅតែមានលក្ខណៈខុសពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាចំណុចសំខាន់ ។ បណ្ដឹងឧទ្ធរណ៍របស់តុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនត្រូវបានអនុញ្ញាតឲ្យផ្លាស់មូលហេតុក្នុងបណ្ដឹងឧទ្ធរណ៍ចុងក្រោយ ដោយបង្ហាញនូវហេតុផលអាចទទួលយកបាន ។ ករណីនេះមិនត្រឹមតែផ្ដល់ដល់តុលាការនូវភាពបត់បែនតាមកាលៈទេសៈទេ ថែមទាំងបានអនុញ្ញាតឲ្យមានបណ្ដឹងជំទាស់ផងដែរចំពោះករណីជាក់លាក់ណាមួយនាដំណាក់កាលធ្វើសេចក្ដីសម្រេចចុងក្រោយដែលបណ្ដឹងនោះមិនត្រូវបានអនុញ្ញាតកាលពីសវនាការកំពុងតែដំណើរការ ។

ការពិចារណាទៅលើករណីបណ្ដឹងពេលដែលតុលាការកំពុងតែដំណើរការ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺមិនមានភាពស៊ីគ្នាទៅនឹងការអនុវត្តរបស់តុលាការទាំងឡាយក្នុងប្រព័ន្ធច្បាប់របស់បារាំងទេ ។ តុលាការបារាំង «រកមើលភាពស្មើគ្នានៃទម្រង់បែបបទជាទូទៅ ដោយអនុញ្ញាតឲ្យភាពអវត្តមានរបស់ភាគីមួយថាមិនមានគុណប្រយោជន៍ចំពោះភាគីម្ខាងទៀត» ។ ដូចគ្នាទៅនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ប្រព័ន្ធច្បាប់ឧក្រិដ្ឋកម្មរបស់បារាំងផ្ដល់សិទ្ធិដ៏មានកំណត់ចំពោះជនជាប់ចោទក្នុងការតវ៉ាជំទាស់ចំពោះលទ្ធផលនៃសេចក្ដីសម្រេចបណ្ដោះអាសន្ន ។ អ្វីដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនដូចគ្នាទៅនឹងច្បាប់ស៊ីវិលបារាំងត្រង់ថា ព្រះរាជអាជ្ញានិងភាគីការពារក្ដីអាចបង្កើតឲ្យមានការពិចារណាទៅលើហេតុការណ៍ពិតនិងច្បាប់នាដំណាក់ការធ្វើសេចក្ដីសម្រេចចុងក្រោយ ។ ករណីនេះដូចជាបង្កើតតុលាការមួយថ្មីដូច្នោះដែរ ។ ករណីមួយចំនួនដែលមិនត្រូវបានពិចារណាពេលដែលតុលាការកំពុងដំណើរការ និងត្រូវបានយកមកពិចារណានាដំណាក់កាលទីពីរ ។ ករណីនេះមិនត្រូវបានយកមកពិចារណាទេ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ៣) ភាពតឹងរ៉ឹងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការពិចារណាលើករណីបណ្ដោះអាសន្នបានជ្រៀតជ្រែកដល់សិទ្ធិរបស់ភាគីការពារក្ដីក្នុងការធានាឲ្យតុលាការមានភាពសមស្រប

ជាប្រវត្តិសាស្ត្រ កិច្ចខំប្រឹងប្រែងរបស់មេធាវីការពារក្ដីក្នុងការផ្ដល់តំណាងឲ្យបានគ្រប់គ្រាន់ចំពោះកូនក្ដីរបស់ខ្លួននៅក្នុងដំណើរការតុលាការអន្តរជាតិត្រូវបានបក្ខជាឧបសគ្គដោយកង្វះខាតធនធានមនុស្ស និងធនធានសេដ្ឋកិច្ច បើប្រៀបធៀបទៅនឹងកិច្ចខំប្រឹងប្រែងដូចគ្នាសម្រាប់ព្រះរាជអាជ្ញា ។ ដូច្នេះ «ចំណុចសំខាន់» នៃយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិនាសម័យទំនើបគឺជាគោលការណ៍នៃការស្មើភាពគ្នា ដែលជាសមាសភាពនៃសិទ្ធិចំពោះការការពារក្ដីដ៏យុត្តិធម៌មួយ ។ គោលការណ៍នេះមានន័យថា «ភាគីទាំងសងខាងត្រូវបានផ្ដល់ឱកាសដ៏សមរម្យមួយដើម្បីបង្ហាញចំពោះករណីនេះ រួមបញ្ចូលទាំងភ័ស្ដុតាងរបស់ភាគីនីមួយៗក្រោមលក្ខខណ្ឌដែលមិនត្រូវដាក់ភាគីណាមួយឲ្យអន់ជាងភាគីណាមួយផ្សេងទៀតទេ» ។ ចំណុចខាងក្រោមនេះនឹងបកស្រាយអំពីឧទាហរណ៍ពីរនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលភាគីការពារក្ដីមានលទ្ធភាពតិចតួចក្នុងការតវ៉ាពេលសវនាការកំពុងដំណើរការ ចំណែកភាគីព្រះរាជអាជ្ញាមានសិទ្ធិច្រើនក្នុងករណីបែបនេះ ។

### ក) តួនាទីដ៏តិចតួចរបស់ភាគីការពារក្ដីក្នុងការស្វែងរកការពិតស្របពេលដែលខ្លួនមានសិទ្ធិតិចតួចក្នុងការតវ៉ាចំពោះសកម្មភាពស៊ើបអង្កេតបានធ្វើឲ្យខ្លួនមានភាពអន់ជាងភាគីសហព្រះរាជអាជ្ញា

នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ភាគីការពារក្ដីមិនត្រូវបានអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងទេ ។ ភាគីការពារក្ដីគ្រាន់តែមានសិទ្ធិស្នើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតនិងរកមើលរបាយការណ៍

របស់អ្នកជំនាញបន្ថែមទៀតជំនួសខ្លួនប៉ុណ្ណោះ ។ ទោះបីជាការិយាល័យសហចៅក្រមស៊ើបអង្កេតមិនតម្រូវឲ្យធ្វើសំណើខាងលើនេះក៏ដោយ ក៏ភាគីការពារក្តីត្រូវបានផ្តល់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ជំទាស់ដែរ ។ ប៉ុន្តែ ភាគីការពារក្តីមិនមានសិទ្ធិជំទាស់តវ៉ាទេ បើសិនជាសំណើនោះត្រូវបានទទួលយកហើយ ។

តាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យសហចៅក្រមស៊ើបអង្កេតអាចចេញបញ្ជាឲ្យប៉ូលិសតុលាការនិងអ្នកស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការស៊ើបអង្កេតបាន ។ ប៉ូលិសតុលាការបានបើកការស៊ើបអង្កេតក្រោមការណែនាំរបស់សហព្រះរាជអាជ្ញានៅអំឡុងពេលនៃការស៊ើបអង្កេតដំបូង ការិយាល័យស៊ើបអង្កេតនៅដំណាក់កាលស៊ើបអង្កេតផ្លូវច្បាប់និងអង្គបុរេជំនុំជម្រះអំឡុងពេលការស៊ើបអង្កេតបន្ថែម ។ ប៉ូលិសតុលាការមិនត្រូវបានអនុញ្ញាតឲ្យធ្វើការស្វែងរកនិងទទួលបញ្ជាពីភាគីផ្សេងទៀតដើម្បីធ្វើការស៊ើបអង្កេតលើករណីផ្សេងៗទេ ។ ប៉ូលិសតុលាការក៏មិនត្រូវបានអនុញ្ញាតឲ្យចោទសួរទៅលើជនត្រូវចោទដែរ ។ ស្រដៀងគ្នាដែរ អ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវធ្វើការស៊ើបអង្កេតតាមសំណើរបស់សហព្រះរាជអាជ្ញា ឬការិយាល័យសហចៅក្រមស៊ើបអង្កេតនៅអំឡុងពេលសវនាការកំពុងដំណើរការ ហើយក៏មិនអនុញ្ញាតឲ្យចោទសួរទៅលើជនត្រូវចោទដែរ ។

តើភាគីការពារក្តីគួរធ្វើសំណើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតទេ? ហើយតើការិយាល័យស៊ើបអង្កេតគួរតែយល់ព្រមស៊ើបអង្កេតដោយគ្មានការធានាបានទេថា ការស៊ើបអង្កេតបែបនេះមិនមានប្រយោជន៍ចំពោះជនជាប់ចោទទេ? លើសពីនេះទៅទៀត គ្មានដំណោះស្រាយដែលថា ភាគីការពារក្តីអាចធ្វើការឬស្វែងរកការស៊ើបអង្កេតបន្ថែមទៀតឡើយ ។ បើសិទ្ធិក្នុងការប្តឹងតវ៉ាមិនត្រូវបានផ្តល់សិទ្ធិឲ្យច្រើនជាងនេះទេ លទ្ធភាពរបស់ភាគីការពារក្តីក្នុងការបង្ហាញករណីរបស់ខ្លួនគឺមិនមានលក្ខណៈស្មើភាពដូចភាគីព្រះរាជអាជ្ញាទេ ។

លទ្ធភាពនៃមេធាវីចុងចោទក្នុងការដាក់ឥទ្ធិពលលើការស៊ើបអង្កេតឬភស្តុតាងទាំងឡាយដែលតុលាការប្រើប្រាស់សម្រាប់កាត់សេចក្តីនៅក្នុងតុលាការអន្តរជាតិគឺមានលក្ខណៈប្រសើរជាង ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ មេធាវីចុងចោទក៏មិនមានសិទ្ធិចូលរួមក្នុងការស៊ើបអង្កេតមុនសវនាការដែរ ។ ប៉ុន្តែ មេធាវីចុងចោទអាចនឹងជជែកតវ៉ាចំពោះភស្តុតាងទាំងនោះយ៉ាងពេញទំហឹង និងផ្តល់នូវភស្តុតាងរបស់ខ្លួននៅក្នុងសវនាការដើម្បីអះអាងបន្ថែម ។ ក្រោយពីនោះ មេធាវីចុងចោទក៏អាចស្នើសុំការអនុញ្ញាតក្នុងការប្តឹងឧទ្ធរណ៍ចំពោះរាល់ការសម្រេចមុនសវនាការទាំងឡាយណា «ដែលអាចប៉ះពាល់ដល់យុត្តិធម៌និងដំណើរការឆាប់រហ័សរបស់សវនាការ ឬលទ្ធផលនៃសវនាការនោះ» ។ ស្រដៀងគ្នានេះដែរ តុលាការដែលមិនមានការគ្រោងទុកដោយមិនអនុញ្ញាតឲ្យមេធាវីការពារចុងចោទចូលរួមនៅក្នុងការស៊ើបអង្កេតឡើយ ប៉ុន្តែ មេធាវីនេះអាចស្នើសុំការប្តឹងតវ៉ាចំពោះសកម្មភាពស៊ើបអង្កេតបាន ។

អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺកង្វះខាតនៃការត្រួតពិនិត្យលើបែបផែននៃការស៊ើបអង្កេតដែលជាចំណុចទិតៀនទូទៅមួយនៅក្នុងប្រព័ន្ធច្បាប់ឧក្រិដ្ឋកម្មរបស់បារាំង ដែលច្បាប់កម្ពុជានិងច្បាប់ផ្ទៃក្នុងរបស់អង្គជំនុំជម្រះបានប្រើប្រាស់ជាមូលដ្ឋាននោះ ។ ថ្វីដ្បិតថាប៉ូលិសស៊ើបអង្កេតអនុវត្តកិច្ចការក្រោមបញ្ជារបស់អង្គចៅក្រមក៏ដោយ សូម្បីតែចៅក្រមផ្ទាល់ក៏ «មិនប្រាកដថាបញ្ជាទាំងនោះពិតបានអនុវត្តពេញលេញយ៉ាងណាដែរ» ។ ការអនុម័តរបស់អង្គជំនុំជម្រះវិសាមញ្ញលើប្រព័ន្ធច្បាប់បារាំងនេះដំណើរការដោយមិនបានឆ្លើយតបចំពោះការតវ៉ាលើការស៊ើបអង្កេតនៃសវនាការអន្តរជាតិឡើយ ។ សារសំខាន់នៃភាពស្មើគ្នារវាងភាគីទាំងសងខាងនៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិក៏ជាបញ្ហាដែរ ។

**ខ) ភាពគ្មានលទ្ធភាពរបស់មេធាវីចុងចោទក្នុងការតវ៉ាដោយឯករាជ្យចំពោះចំណុចសំខាន់នៃសេចក្តីសម្រេចចុងក្រោយបានបង្ហាញនូវភាពអវិជ្ជមាននៃការចោទប្រកាន់ ហើយថែមទាំងមានលក្ខណៈខុសពីការអនុវត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត**

នៅអង្គជំនុំជម្រះវិសាមញ្ញ ដីកាបញ្ចប់រឿងស៊ើបសួរឲ្យគឺមានតួនាទីដូចគ្នាទៅនឹងដីកាបណ្តោះអាសន្នដែរ ។ ដីកាបញ្ចប់រឿង

ឲ្យស៊ើបសួរមានវត្តមានជាច្រើននៃដីកាបណ្ដោះអាសន្ន ទ្រង់ទ្រាយច្បាប់និងបទបញ្ញត្តិនៃបទល្មើសដែលទាក់ទងនឹងសភាពដើមនៃការទទួលខុសត្រូវលើបទល្មើសរបស់ជនត្រូវចោទ ។ នៅពេលដែលព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតក្នុងការប្ដឹងឧទ្ធរណ៍ចំពោះដីកាបញ្ចប់រឿងឲ្យស៊ើបសួរដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ មេធាវីការពារចុងចោទមិនត្រូវបានអនុញ្ញាតឲ្យធ្វើដូច្នេះឡើយ ។ លក្ខខណ្ឌបែបនេះបានដាក់មេធាវីចុងចោទឲ្យស្ថិតក្នុងជំហរមិនស្មើភាពមួយជាមួយនឹងភាគីដើមចោទ ហើយថែមទាំងបង្កការលំបាកដល់ភាគីចុងចោទរៀបចំសំណុំរឿងរបស់ខ្លួនឲ្យបានគ្រប់គ្រាន់ទៀតផង ។

កំហុសឆ្គងនៅក្នុងដីកាបញ្ចប់រឿងឲ្យស៊ើបសួរជាមួយនឹងអត្ថប្រយោជន៍ដើម្បីផ្លាស់ប្ដូរសភាពដើមនៃដំណើរការនិងវិធានការច្បាប់សម្រាប់ភាគីទាំងសងខាងគួរតែត្រូវកែតម្រូវដោយការត្រួតពិនិត្យបណ្ដោះអាសន្ន ។ ប៉ុន្តែ ផ្អែកលើវិធានផ្ទៃក្នុង មានតែព្រះរាជអាជ្ញាប៉ុណ្ណោះដែលមានសិទ្ធិតវ៉ាចំពោះកំហុសឆ្គងទាំងនេះ ។ ការអនុវត្តនៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀត ដោយការគោរពចំពោះដីកាចោទប្រកាន់និងនីតិវិធីសម្រាប់បញ្ជាក់អំពីការចោទប្រកាន់ គឺបានបង្ហាញអំពីសារសំខាន់នៃអសមត្ថភាពរបស់ភាគីការពារចុងចោទក្នុងការចោទសួរអំពីខ្លឹមសារទាំងឡាយនៃដីកាបញ្ចប់រឿងឲ្យស៊ើបសួរនៅអង្គជំនុំជម្រះវិសាមញ្ញ ។ ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិវិញ ការចោទប្រកាន់ចំពោះភាគីត្រូវចោទត្រូវតែបញ្ជាក់នៅក្នុងសវនាការមុននឹងបុគ្គលនោះនាំមកកាត់ទោសនៅតុលាការ ។ ប៉ុន្តែមុននឹងមានសវនាការបញ្ជាក់នេះ ភាគីការពារចុងចោទត្រូវតែទទួលបាននូវឯកសារចម្លងដែលបង្ហាញអំពីការចោទប្រកាន់ទាំងនោះ ព្រមទាំងព័ត៌មានផ្សេងទៀតទាក់ទងនឹងភស្តុតាងដែលនឹងប្រើប្រាស់សម្រាប់ជំនួយដល់ការចោទប្រកាន់ ។ នៅក្នុងសវនាការ ភាគីការពារចុងចោទអាច ក) ធ្វើការប្រឆាំងចំពោះការចោទប្រកាន់ ខ) តវ៉ាចំពោះភស្តុតាងដែលបង្ហាញដោយសហព្រះរាជអាជ្ញា និង គ) បង្ហាញភស្តុតាងថ្មីៗ ។ ចំពោះតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការគ្មានការគ្រោងទុក ភាគីចុងចោទអាចតវ៉ាចំពោះទម្រង់បែបបទឬចំណុចសំខាន់នៃដីកាចោទប្រកាន់តាមរយៈការប្ដឹងឧទ្ធរណ៍ ។

ដោយសារការចោទប្រកាន់សំខាន់ចំពោះដីកាបញ្ចប់រឿងឲ្យស៊ើបសួរអាចធ្វើបានដោយព្រះរាជអាជ្ញាតែប៉ុណ្ណោះ ធ្វើឲ្យភាគីចុងចោទស្ថិតនៅក្នុងជំហរអសមត្ថភាព ។ លើសពីនេះទៅទៀត ការឈានទៅដល់ការកែសម្រួលប្រព័ន្ធតុលាការរបស់ភាគីការពារចុងចោទទាក់ទងនឹងការកាត់ទោសក៏មានកម្រិត ហើយលទ្ធភាពក្នុងការរៀបចំការការពារដ៏មានប្រសិទ្ធភាពរបស់ភាគីនេះក៏ត្រូវសម្របសម្រួលដោយមិនផ្ដល់ប្រសិទ្ធភាពចំពោះការប្ដឹងឧទ្ធរណ៍ឡើយ ។ ការព្រមព្រៀងទូទៅនៅក្នុងដំណើរការនេះគឺថា ដីកាចោទប្រកាន់ត្រូវបានរកឃើញថាមិនច្បាស់លាស់ឬខ្វះនូវភាពជាក់លាក់ នោះលទ្ធភាពរបស់ភាគីការពារចុងចោទក្នុងការរៀបចំសំណុំរឿងឲ្យមានប្រសិទ្ធភាពនោះប្រហែលជាត្រូវបានរារាំង ។ នៅពេលដែលលទ្ធភាពក្នុងការឈានចូលដល់ការកែសម្រួលដូចក្នុងករណីខាងលើនេះពឹងផ្អែកលើភាគីប្រឆាំងទាំងស្រុងនោះ គោលការណ៍ស្មើភាពគ្នាសម្រាប់ភាគីទាំងសងខាងនឹងមិនអាចធានាឲ្យបានឡើយ ។

## ៤) តើអង្គជំនុំជម្រះវិសាមញ្ញអាចដោះស្រាយនូវការព្រួយបារម្ភទាំងនេះដោយរបៀបណា?

ដូចដែលបានពិភាក្សាខាងលើរួចមកហើយថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញចំពោះការត្រួតពិនិត្យបណ្ដឹងជំទាស់ឡើងវិញអាចសម្របសម្រួលដល់ភាពស្របច្បាប់និងយុត្តិធម៌នៅក្នុងដំណើរការរបស់ខ្លួន ។ ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញផ្លាស់ប្ដូរជំហរបច្ចុប្បន្នឲ្យប្រសើរជាងនេះ ការព្រួយបារម្ភខ្លះចំពោះសិទ្ធិស្មើគ្នារវាងព្រះរាជអាជ្ញានិងភាគីការពារចុងចោទអាចនឹងត្រូវដោះស្រាយនិងលុបចោលប្រសិនបើអាចទៅរួច ។ ផ្នែកនេះនឹងសិក្សាលើវិធីបីយ៉ាងដែលអង្គជំនុំជម្រះវិសាមញ្ញអាចទទួលបាននូវវិធីសាស្ត្រប្រសើរជាងមុនចំពោះការប្ដឹងឧទ្ធរណ៍ ៖ ការយកមកអនុវត្តនូវការត្រួតពិនិត្យចំពោះភាពស្មើគ្នា វិធីសាស្ត្រឆាប់រហ័សនិងការប្រើប្រាស់នូវការបកស្រាយទូលំទូលាយចំពោះមាត្រា ។

*ក) ការយកមកអនុវត្តនូវការត្រួតពិនិត្យដើម្បីផ្ដល់ភាពស្មើគ្នា*

អ្វីដែលពុំមានវត្តមាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែមាននៅគ្រប់តុលាការអន្តរជាតិទាំងអស់នោះគឺអំណាចនៃការសម្រេចចិត្តក្នុងការប្តឹងឧទ្ធរណ៍ចំពោះភាពស្មើគ្នាដែលជាការប្តឹងឧទ្ធរណ៍មួយដែលផ្តល់ឲ្យអាស្រ័យទៅលើការកាត់សេចក្តី ឬការយល់ឃើញរបស់អង្គជំនុំជម្រះ ។ ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការគ្មានការគ្រោងទុក គឺប្រើប្រាស់ភាសាប្រហាក់ប្រហែលគ្នាក្នុងការផ្តល់នូវអំណាចនៃការសម្រេចចិត្តដល់អង្គជំនុំជម្រះឧទ្ធរណ៍ដើម្បីពិនិត្យឡើងវិញនូវការសម្រេចចិត្តទាំងឡាយដែលទាក់ទងនឹងបញ្ហាចោទជាសំខាន់ដែលជះឥទ្ធិពលដល់ដំណើរការយុត្តិធម៌ឆាប់រហ័សនិងមានប្រសិទ្ធភាពឬលទ្ធផលរបស់តុលាការ ដោយនៅក្នុងគំនិតរបស់អង្គជំនុំជម្រះនេះគឺសម្រាប់ស្វែងរកដំណោះស្រាយយ៉ាងឆាប់រហ័សមួយដែលនឹងបន្តឲ្យដំណើរការឈានទៅមុខដែលអាចទទួលយកនូវការប្តឹងឧទ្ធរណ៍បាន ។ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនវិញប្រើប្រាស់បទដ្ឋានពីរផ្សេងគ្នាដោយអាស្រ័យទៅលើបញ្ហាដែលកើតមានឡើងពីការសម្រេចចិត្តមុនឬនៅក្នុងសវនាការ ។ បញ្ហាដែលកើតមានឡើងនៅពេលមុនតុលាការដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការយុត្តិធម៌និងឆាប់រហ័សឬលទ្ធផលរបស់តុលាការផ្ទាល់ គឺអាចត្រូវផ្ទេរទៅអង្គជំនុំជម្រះឧទ្ធរណ៍ដើម្បីធ្វើការវិនិច្ឆ័យ ។ ចំពោះការសម្រេចចិត្តនៅក្នុងពេលសវនាការវិញ ការប្រើប្រាស់នៅក្នុងកាលៈទេសៈលើកលែងជាច្រើន និងដើម្បីចៀសវាងនូវភាពលម្អៀងមិនអាចកែសម្រួលបានចំពោះភាគីណាមួយដែលអាចជាការទទួលបន្ទុករបស់ការប្តឹងឧទ្ធរណ៍ ។ បញ្ហាមួយចំនួនដែលបញ្ឈាក់អំពីការប្តឹងឧទ្ធរណ៍តាមរយៈការផ្តល់ឲ្យទាំងនេះរួមមានសិទ្ធិដែលចាំបាច់ត្រូវផ្តល់ដល់ភាគីការពារចុងចោទនិងការអនុញ្ញាតចំពោះភស្តុតាង ។

អង្គជំនុំជម្រះវិសាមញ្ញនឹងទទួលបាននូវផលប្រយោជន៍ដូចគ្នាពីការបន្ថែមនូវការត្រួតពិនិត្យដើម្បីផ្តល់ភាពស្មើគ្នានេះ ។ ការត្រួតពិនិត្យបែបនេះនឹងផ្តល់ដល់អង្គជំនុំជម្រះវិសាមញ្ញនូវលទ្ធភាពបត់បែនដើម្បីដោះស្រាយការព្រួយបារម្ភជាច្រើនអំពីភាពយុត្តិធម៌ដែលបានពិភាក្សានៅផ្នែកខាងលើរួចមកហើយ ។

*ខ) ការយកមកអនុវត្តនូវយុទ្ធសាស្ត្រដំណើរការឆាប់រហ័ស*

អង្គជំនុំជម្រះវិសាមញ្ញក៏អាចយកមកអនុវត្តនូវយុទ្ធសាស្ត្រដំណើរការឆាប់រហ័សដែលបានធ្វើឡើងនៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះផ្ទេរបញ្ហាណាមួយទៅអង្គជំនុំជម្រះឧទ្ធរណ៍ផ្ទាល់ និងទទួលបាននូវ «អញ្ញាតក្រឹត» ចំពោះបញ្ហាសំខាន់ណាមួយដែលកើតមានមុនសវនាការដោយពុំចាំបាច់ចេញសេចក្តីសម្រេចចំពោះបញ្ហានោះទេ ។ ដោយសារការផ្ទេរការដោះស្រាយនេះកើតមានឡើងមុនពេលមានសេចក្តីសម្រេចណាមួយចំពោះបញ្ហាដែលបានចោទនោះ ភាគីទាំងសងខាងពុំចាំបាច់បង្ហាញបញ្ហាទាំងនោះនៅចំពោះមុខអង្គជំនុំជម្រះទេ គឺគ្រាន់តែបង្ហាញនៅអង្គជំនុំជម្រះឧទ្ធរណ៍ម្តងទៀតប៉ុណ្ណោះ ។ ការធ្វើដូច្នេះ ការអនុវត្តនូវយុទ្ធសាស្ត្រនេះតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនមានការជឿជាក់ថា «បានជំរុញជាជាងការបន្ថយនូវសិទ្ធិជាមូលដ្ឋានសម្រាប់ដំណើរការយុត្តិធម៌ដ៏ឆាប់រហ័សមួយ» ។

*គ) ការប្រើប្រាស់ការបកស្រាយនូវសិទ្ធិដែលមានលក្ខណៈបត់បែន*

ដើម្បីជាជម្រើសមួយទៀតឬការបន្ថែមចំពោះយុទ្ធសាស្ត្រទាំងពីរខាងលើ អង្គជំនុំជម្រះវិសាមញ្ញអាចបកស្រាយច្បាប់ផ្ទៃក្នុងរបស់ខ្លួនចំពោះការត្រួតពិនិត្យលើការប្តឹងឧទ្ធរណ៍ ។ ចំពោះតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការពិសេសប្រទេសសេរ៉ាឡេអូនពឹងផ្អែកទៅលើការបកស្រាយយ៉ាងទូលំទូលាយនៃច្បាប់ចំពោះការត្រួតពិនិត្យសាឡើងវិញនៅពេលដោះស្រាយបញ្ហាដើម្បីភាពយុត្តិធម៌ ។ ឧទាហរណ៍តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដំបូងស្នើសុំឲ្យមានការត្រួតពិនិត្យមើលសាឡើងក្នុងករណីតវ៉ាគ្នារវាងព្រះរាជអាជ្ញានិងលោក ដាស្កូ តាឌីក ដែលដោះស្រាយបញ្ហាមូលដ្ឋានបំផុតនិងភាពស្របច្បាប់នៅក្នុងតុលាការ ។ បញ្ហាទាំងនេះមិនទាក់ទងនឹងសំណួរអំពីយុត្តាធិការដូចជាកម្មវត្ថុនៃពាក្យបណ្តឹង ឬលើបុគ្គលណាមួយឡើយ ។ ប៉ុន្តែតុលាការទទួលយកនូវការស្នើសុំដោយស្ថិតនៅក្រោមច្បាប់មួយដែលអនុញ្ញាតនូវការត្រួតពិនិត្យសាឡើងវិញនៃបញ្ហាយុត្តាធិការ ។ ការបកស្រាយដ៏ទូលំទូលាយនៃយុត្តាធិការបែបនេះបានផ្តល់ឲ្យតុលាការនូវលទ្ធភាពបន់បែនតាមកាលៈទេសៈសម្រាប់ដោះស្រាយលទ្ធផលចុងក្រោយនៃ

បញ្ហាដ៏សំខាន់ណាមួយបាន ។ ទោះបីជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានប្រើប្រាស់នូវការបកស្រាយចំពោះយុត្តាធិការហួតចត់ជាងការបកស្រាយដែលមានលទ្ធភាពក្នុងការបត់បែនបានច្រើនបែបនោះគឺមានសារសំខាន់ណាស់សម្រាប់បង្កើតតួនាទីតុលាការឲ្យមានលក្ខណៈស្របច្បាប់និងត្រឹមត្រូវបាន ។

ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញអាចទទួលបាននូវអត្ថប្រយោជន៍បែបនេះពីការបកស្រាយដែលមានលក្ខណៈបត់បែន ហើយសំខាន់ក្នុងការលើកស្ទួយដល់ភាពយុត្តិធម៌នៅក្នុងដំណើរការនេះ ។ ការយល់ឃើញបែបនេះពិតជាត្រឹមត្រូវចំពោះការព្រួយបារម្ភទៅលើសកម្មភាពស៊ើបអង្កេត ។ ដូចដែលបានបង្ហាញពីខាងលើរួចមកហើយថា ភាគីចុងចោទមិនសូវមានសិទ្ធិនៅអំឡុងពេលនៃការស៊ើបអង្កេត ហើយអាចមានសិទ្ធិប្តឹងឧទ្ធរណ៍ក្រោមបញ្ញត្តិមួយចំនួនរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ ។ ការខូចខាតអត្ថប្រយោជន៍ដែលភាគីការពារចុងចោទបានជួបប្រទះនឹងកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀត ដោយសារការប៉ុនប៉ងរបស់អង្គបុរេជំនុំជម្រះក្នុងការបកស្រាយដ៏ហួតចត់នូវពាក្យ «សកម្មភាពស៊ើបអង្កេត» នោះ ។ ប៉ុន្តែប្រសិនបើពាក្យនេះត្រូវបានឲ្យនិយមន័យទូលំទូលាយជាងនេះដោយមិនគ្រាន់តែឲ្យអត្ថន័យថាជាសកម្មភាពប៉ុណ្ណោះទេ (ឧទាហរណ៍ដូចជាការស្នើសុំចំពោះការធ្វើបទសម្ភាសន៍ជាមួយនឹងសាក្សី) គឺថែមទាំងបញ្ជាក់អំពីបែបបទនៃសកម្មភាពស៊ើបអង្កេតដែលនឹងត្រូវអនុវត្តឡើងនោះផង (ឧទាហរណ៍សំណើដល់ការធ្វើបទសម្ភាសន៍ជាមួយសាក្សីនិងការសួរដេញដោលនូវសំណួរមួយចំនួនអំពីហេតុការណ៍ជាក់លាក់ណាមួយ) ។ ការធ្វើដូច្នេះ អនុញ្ញាតឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចបង្កើនលទ្ធផលដ៏ប្រសើរជាងមុនមួយនៃភាពស្មើគ្នារវាងភាគីទាំងសងខាង ។

***សេចក្តីសន្និដ្ឋាន***

តាមយោបល់ខាងភាគីការពារចុងចោទវិញ របបនៃការប្តឹងឧទ្ធរណ៍បច្ចុប្បន្នរបស់អង្គជំនុំជម្រះវិសាមញ្ញគឺមានលក្ខណៈចង្អៀតនិងមិនមានលទ្ធភាពបត់បែនឡើយ ។ ដោយសារតែភាពចង្អៀតចង្អល់របស់របបនេះដែលធ្វើឲ្យសមត្ថភាពរបស់អង្គជំនុំជម្រះមានកំណត់ក្នុងការដោះស្រាយតម្រូវការរបស់ភាគីការពារចុងចោទឲ្យបានប្រសើរ ។ ម្យ៉ាងទៀត ដោយសារភាពមិនស៊ីចង្វាក់គ្នានៃផ្នែកក្នុងរបស់របបនេះ គឺធ្វើឲ្យមានផលប៉ះពាល់ដល់ដំណើរការដែលប្រកបដោយភាពយុត្តិធម៌និងស្របច្បាប់នោះ ។ ប៉ុន្តែ ដោយការយកមកអនុវត្តនូវយុទ្ធសាស្ត្រត្រួតពិនិត្យដើម្បីផ្តល់ភាពស្មើគ្នា ឬយុទ្ធសាស្ត្រដំណើរការឆាប់រហ័ស ឬការប្រើប្រាស់នូវការបកស្រាយនូវសិទ្ធិដែលមានលក្ខណៈបត់បែន អង្គជំនុំជម្រះវិសាមញ្ញនឹងមានលទ្ធភាពដោះស្រាយបញ្ហាយុត្តិធម៌បានប្រសើរជាងនេះជាមិនខាន ។ **ម៉ារី យូ. អ៊ីរ៉ូហ្សូ**

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។

អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីអង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីរិ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។ **សូមអរគុណ**

# របាយការណ៍នៃសវនាការអង្គបុរេស្តីអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួន

## ១) សេចក្តីណែនាំអំពីសវនាការអង្គបុរេ

នៅថ្ងៃទី១១, ១២ និង១៥ ខែកុម្ភៈ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការផ្ទាល់មាត់ដើម្បីជជែកដេញដោលទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនរបស់ជនត្រូវចោទបីនាក់ក្នុងចំណោមជនត្រូវចោទ៤នាក់នៅក្នុងសំណុំរឿង០០២ អៀង សារី, ខៀវ សំផន, និង អៀង ធីរិទ្ធ។ ចាប់តាំងពីអ្នកទាំងនេះត្រូវបានចាប់ខ្លួននៅខែវិច្ឆិកា ឆ្នាំ២០០៧ ដោយយោងទៅតាមវិធានផ្ទៃក្នុងរបស់តុលាការ សហចៅក្រមស៊ើបអង្កេតបានចេញដីកាឃុំខ្លួនបណ្តោះអាសន្នអ្នកទាំងនោះ ព្រមទាំងពន្យារពេលឃុំខ្លួនជារៀងរាល់ឆ្នាំ។ ចៅក្រមបានចេញដីកាពន្យារពេលឃុំខ្លួនចុងក្រោយបង្អស់នៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០០៩ គឺនៅមុនការពន្យារពេលឃុំខ្លួនលើកទីពីរ ហើយជនត្រូវចោទទាំងបីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានោះនៅដើមខែធ្នូ។ នៅក្នុងសវនាការ សហមេធាវីការពារក្តីបានស្នើឲ្យអង្គជំនុំជម្រះដោះលែងកូនក្តីរបស់ខ្លួនឬឃុំខ្លួនកូនក្តីរបស់ខ្លួននៅផ្ទះ។ សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការចេញដីកាពន្យារពេលឃុំខ្លួន ពីព្រោះភស្តុតាងទាំងអស់មិនបានបញ្ជាក់ទៅលើសេចក្តីសន្និដ្ឋានដែលថាជនត្រូវចោទបានប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់ ហើយចៅក្រមមិនបានផ្តល់ហេតុផលច្បាស់លាស់ថាហេតុអ្វីត្រូវឃុំខ្លួនជនត្រូវចោទនោះទេ។ នៅក្នុងសវនាការ មានអ្នកចូលរួមជាច្រើនត្រូវបានអញ្ជើញដោយអង្គភាពគាំពារជនរងគ្រោះ និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយចំនួន។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានចូលរួមស្តាប់សវនាការជារៀងរាល់ថ្ងៃ។

## ២) ប្រវត្តិច្បាប់សម្រាប់ឃុំខ្លួនបណ្តោះអាសន្ននៅអង្គជំនុំជម្រះ

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតឬអង្គបុរេជំនុំជម្រះអាចចេញដីកា «ឃុំខ្លួនបណ្តោះអាសន្ន» ឃុំខ្លួនជនត្រូវចោទ។ ខណៈពេលដែលជនត្រូវចោទត្រូវសន្មតថាគ្មានទោស ការឃុំខ្លួនមិនមែនជាទម្រង់នៃការដាក់ទណ្ឌកម្មទេ ហើយវាត្រូវបានអះអាងដោយសហចៅក្រមស៊ើបអង្កេតថាជា «ជាករណីលើកលែងមួយនៅក្នុងវិធានដាក់ឲ្យមានសេរីភាពនៅដំណាក់កាលមុនពេលជំនុំជម្រះ»។ ដោយរំពឹកពី



អៀង ធីរិទ្ធ



អៀង សារី

ករណីលើកលែង សហចៅក្រមស៊ើបអង្កេតអាចចេញដីកាឃុំខ្លួនបណ្ដោះអាសន្ននៅដំណាក់កាលមុនពេលជំនុំជម្រះប្រសិនបើរកឃើញករណីពីរដែលតម្រូវដោយវិធានផ្ទៃក្នុង៦៣(៣) ។ ទីមួយ មានហេតុផល «ដែលត្រូវបានរកឃើញច្បាស់លាស់» ដែលធ្វើឲ្យមានការជឿជាក់ថាជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសមួយឬច្រើនដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ «ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម» វិធាន៦៣(៣)(ក)) ។ ទីពីរ ការឃុំខ្លួនបណ្ដោះអាសន្នគឺជាវិធានដ៏ចាំបាច់ដើម្បី ៖ ក) រារាំងមិនឲ្យជនត្រូវចោទនោះគាបសង្កត់ទៅលើសាក្សីឬជនរងគ្រោះ ឬរារាំងមិនឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទនិងអ្នកសមគំនិត ។ ខ) ថែរក្សាភស្តុតាង ឬការពារមិនឲ្យមានការបំផ្លាញភស្តុតាង ។ គ) ធានានូវវត្តមានរបស់ជនត្រូវចោទនៅអំឡុងពេលសវនាការ ។ ឃ) ការពារសន្តិសុខជនត្រូវចោទ ឬ ង) រក្សាសណ្ដាប់ធ្នាប់សាធារណៈ ។

ជនត្រូវចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ននៅអង្គបុរេជំនុំជម្រះ (វិធាន៦៣(៤)) ។ សហចៅក្រមស៊ើបអង្កេតអាចចេញដីកាឃុំខ្លួនរហូតដល់មួយឆ្នាំប្រសិនបើបទល្មើសដែលចោទគឺជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាមឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ចំពោះឧក្រិដ្ឋកម្មផ្សេងទៀតមិនអាចលើសពី៦ខែទេ) វិធាន៦៣(៦) ។ សហចៅក្រមស៊ើបអង្កេតអាចចេញដីកាពន្យារពេលឃុំខ្លួនមួយឆ្នាំទៀត ហើយជនត្រូវចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបែបនេះនៅអង្គបុរេជំនុំជម្រះ (វិធាន៦៣(៧)) ។ ខណៈពេលដែលសហចៅក្រមស៊ើបអង្កេតមិនអាចចេញដីកាពន្យារពេលពីរដង (វិធាន៦៣(៧)) ជនត្រូវចោទមិនអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្នលើសពី៣ឆ្នាំនៅដំណាក់កាលមុនពេលជំនុំជម្រះទេ ។ សហចៅក្រមស៊ើបអង្កេតមានអំណាចចេញដីកាដោយសម្អាងហេតុជាក់លាក់សម្រាប់បន្តការឃុំខ្លួនជនត្រូវចោទនៅក្នុងដីកាដំណោះស្រាយរហូតដល់ជនត្រូវចោទត្រូវនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះ ៦៨(១) ។ ជនត្រូវចោទត្រូវយកទៅជំនុំជម្រះនៅក្នុងរយៈពេលបួនខែក្នុងរយៈពេលចេញសេចក្ដីសម្រេច (វិធាន៦៨(៣) ។


ខៀវ សំផន

## ៣) ប្រវត្តិដំណើរការនីតិវិធីនៅសវនាការអង្គបុរេជំនុំជម្រះ

នៅពាក់កណ្ដាលខែវិច្ឆិកា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាពន្យារពេលឃុំខ្លួនបណ្ដោះអាសន្នលើកទីពីរដើម្បីឃុំខ្លួន អៀង សារី, ខៀវ សំផន, និង អៀង ធីរិទ្ធ មិនលើសពីមួយឆ្នាំ ។ នៅក្នុងដីកា សហចៅក្រមស៊ើបអង្កេតរកឃើញថាតាមវិធាន៦៣(៣)(ក) ដោយផ្អែកទៅលើភស្តុតាង មានការសម្អាងឲ្យជឿជាក់ថាជនត្រូវចោទទាំងបីពិតជាបានប្រព្រឹត្តបទល្មើស ។ សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋានបន្តថា ដោយអនុលោមទៅតាមវិធាន៦៣(៣)(ខ) ការបន្តការឃុំខ្លួនបណ្ដោះអាសន្នគឺជាការចាំបាច់ដើម្បីធានានូវវត្តមានរបស់ជនត្រូវចោទ (អៀង សារី, អៀង ធីរិទ្ធ) នៅសវនាការ, ធានាសន្តិសុខ (អៀង សារី, ខៀវសំផន), ចៀសវាងការគំរាមកំហែងដល់សាក្សី (អៀង ធីរិទ្ធ), និងរក្សាសណ្ដាប់ធ្នាប់សាធារណៈ (អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ) ។ ជាជាងការបង្ហាញពីករណីទាំងនេះ សហចៅក្រមស៊ើបអង្កេតគ្រាន់តែសម្អាងទៅលើសេចក្ដីសម្រេចចម្បងរបស់អង្គបុរេជំនុំជម្រះ ហើយសន្និដ្ឋានថាស្ថានភាពទាំងអស់មិនទាន់មានការប្រែប្រួលទេ ។ ខណៈពេលដែលទទួលស្គាល់ថា២៤ខែគឺមានរយៈពេល«យូរ» សហចៅក្រមស៊ើបអង្កេតរកឃើញថារយៈពេលឃុំខ្លួននេះមានគឺស័ក្តិសមសម្រាប់ភាពស្មុគស្មាញក្នុងការស៊ើបអង្កេត ។

នៅដើមខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទទាំងបីបានដាក់បណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នាប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ។ នៅក្នុងសេចក្តីសង្ខេបរបស់បណ្តឹងឧទ្ធរណ៍ សហមេធាវីបានអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការចេញដីកាបន្តឃុំខ្លួនកូនក្តីរបស់ខ្លួននៅមន្ទីរឃុំឃាំង ។ សេចក្តីសង្ខេបរបស់សហមេធាវី អៀង សារី ខុសពីសេចក្តីសង្ខេបរបស់អ្នកផ្សេងទៀត គឺថាសហមេធាវីនេះមិនបានស្នើឲ្យមានការដោះលែង ប៉ុន្តែបែរជាស្នើឲ្យឃុំខ្លួននៅផ្ទះទៅវិញ ។ តាមការពិត បណ្តឹងឧទ្ធរណ៍ទាំងបីបានអះអាងថាការឃុំខ្លួនមានលក្ខណៈមិនត្រឹមត្រូវ គ្មានភ័ស្តុតាង ហើយវាមិនជាការចាំបាច់ ។ សហមេធាវីបាននិយាយថា សហចៅក្រមស៊ើបអង្កេតមានភ័ស្តុតាងដាក់បន្ទុកជាច្រើន ប៉ុន្តែសហចៅក្រមស៊ើបអង្កេតបែរជាមិនបានផ្តល់ការបកស្រាយអំពីសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរបុសមហេតុផលដែលថាការឃុំខ្លួនបណ្តោះអាសន្នគឺជាការចាំបាច់ទេ ។ បន្ទាប់មក សហព្រះរាជអាជ្ញានិងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការឆ្លើយតបដោយស្នើឲ្យបដិសេធបណ្តឹងឧទ្ធរណ៍ រួចអះអាងថាការពន្យារពេលឃុំខ្លួនពិតជាត្រឹមត្រូវ ហើយវាគឺជាការប្រើឆន្ទានុសិទ្ធិដ៏ត្រឹមត្រូវ ។

### ៤) សេចក្តីសង្ខេបអំពីសវនាការអង្គបុរេ

#### ក) សវនាការបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ថ្ងៃ១១ កុម្ភៈ

សហមេធាវីការពារក្តីជាតិ (អាង ឧត្តម) និងអន្តរជាតិ (ម៉ៃឃើល ខាណាវ៉ាស់) បានចូលរួមនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍


អាង ឧត្តម

របស់ អៀង សារី ។ សហមេធាវីទាំងពីរបានអះអាងថា សហ


ម៉ៃឃើល ខាណាវ៉ាស់

ចៅក្រមស៊ើបអង្កេតមានកំហុសដោយ ក) មិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ ពីព្រោះភ័ស្តុតាងមិនបានធ្វើឲ្យអ្នកអង្កេតសន្និដ្ឋានបានថាជនត្រូវចោទបានប្រព្រឹត្តបទល្មើសដូចដែលត្រូវបានចោទប្រកាន់ ។ ខ) មិនបានបកស្រាយបង្ហាញអំពីទស្សនៈរបស់ខ្លួនជាលាយលក្ខណ៍អក្សរនិងត្រឹមត្រូវឲ្យស្របទៅនឹងលក្ខខណ្ឌឃុំខ្លួនខណៈពេលដែលសហចៅក្រមស៊ើបអង្កេតមានភ័ស្តុតាងដាក់បន្ទុកជាច្រើន ។ គ) មិនបានពិចារណាទៅលើជម្រើសផ្សេងពីការឃុំខ្លួន ។ សហមេធាវីបានអះអាងថា ការឃុំខ្លួនបណ្តោះអាសន្នមិនមែនជាការចាំបាច់ពីព្រោះ ក) មិនមានហានិភ័យដល់ជម្ងឺរទះ ពីព្រោះ អៀង សារី មានសុខភាពមិនល្អ និងមានគេស្គាល់ច្រើន ។ ខ) មិនមានហានិភ័យដល់សន្តិសុខ ពីព្រោះសំណុំរឿង ឌុច មិនអាចមានឥទ្ធិពលទៅលើសំណុំរឿងនេះទេ ហើយ គ) មិនមានហានិភ័យដល់សណ្តាប់ធ្នាប់សាធារណៈទេ ។ សហមេធាវីបានស្នើឲ្យឃុំខ្លួនកូនក្តីរបស់ខ្លួននៅក្នុងផ្ទះឬនៅមន្ទីរពេទ្យដោយបញ្ជាសុខភាព ។

ជំនួយការសហព្រះរាជអាជ្ញាជាន់ខ្ពស់ជាតិ (ចាន់ ដារ៉ារស្មី) និងអន្តរជាតិ (អានីស អាហម៉េដ) បានធ្វើសេចក្តីសន្និដ្ឋានដាក់ទៅការិយាល័យសហព្រះរាជអាជ្ញា ។ ជំនួយការសហព្រះរាជអាជ្ញាជាន់ខ្ពស់បានអះអាងអំពីការបដិសេធនឹងបណ្តឹងឧទ្ធរណ៍ដោយលើកឡើងថាមានសម្អាងគួរឲ្យជឿជាក់មួយចំនួនផ្អែកលើភ័ស្តុតាងជាច្រើនបញ្ជាក់ថា អៀង សារី បានប្រព្រឹត្តបទល្មើស ។ អានីស អាហម៉េដ បានលើកឡើងថា របាយការណ៍លើសពី៩៦ទំព័រ

មានរៀបរាប់អំពីតួនាទីរបស់ អៀង សារី ។ ជំនួយការសហព្រះរាជអាជ្ញាជាន់ខ្ពស់បានបន្តទៀតថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាការចាំបាច់ពីព្រោះមានចំណុចបីត្រូវបានរកឃើញស្របនឹងចំណុចដែលមាននៅក្នុងវិធាន៦៣(៣)(ខ) ។ ស្របនឹងចំណុចទាំងនេះ ជំនួយការសហព្រះរាជអាជ្ញាជាន់ខ្ពស់បានអះអាងថាចំណុចសំខាន់គឺស្ថិតនៅលើជនត្រូវចោទ ដោយអាចបង្ហាញពីស្ថានភាពដែលបានផ្លាស់ប្តូរ ប៉ុន្តែជនត្រូវចោទមិនបានធ្វើដូច្នោះទេ ។ ឆ្លើយតបទៅនឹងការស្នើឲ្យឃុំខ្លួននៅផ្ទះ អាទីស អាហម៉េដ បានអះអាងថា ការឃុំខ្លួនបណ្តោះអាសន្នគឺត្រឹមត្រូវចំពោះបទល្មើសដែលត្រូវ


អាទី អាម

បានចោទប្រកាន់ ហើយសម្ភារៈនៅមន្ទីរឃុំឃាំងនៅអង្គជំនុំជម្រះគឺល្អ សម្រាប់ជំងឺរបស់ អៀង សារី ។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិទាំងអស់មិនបានចូលរួមក្នុងសវនាការនេះទេ លើកលែងតែ ដេវីឌ ប៉េកមែន ដែលឡើងការពារក្តីមុនគេ ។ នី ចាន់ឌី និង ប៉េកមែន បានឡើងធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ។ ខណៈពេលដែលតែងតែលើកឡើងពីសម្តីរបស់សហព្រះរាជអាជ្ញាជាន់ខ្ពស់ នី ចាន់ឌី បានស្នើមិនឲ្យអង្គជំនុំជម្រះដោះលែងជនត្រូវចោទទេ ដោយផ្អែកទៅលើលទ្ធភាពមានកំណត់របស់មន្ត្រីប៉ូលិសតុលាការក្នុងការចាប់ខ្លួន អៀង សារី ម្តងទៀត ពីព្រោះ នី ចាន់ឌី ចោទប្រកាន់ថា អៀង សារី មាន «ទំនាក់ទំនងជាមួយអាជ្ញាធរ» ។ នី ចាន់ឌី បានបន្តថា ដោយមានការយល់ដឹងតិចចំពោះដំណើរការនីតិវិធី ប្រជាជនកម្ពុជាអាចនឹងមានការយល់ខុសថាការឃុំខ្លួននៅផ្ទះគឺជាការដោះលែង នោះវានឹងបណ្តាលឲ្យមានការប្រឆាំងពីប្រជាជនស៊ីវិល ។ ប៉េកមែនបានបកស្រាយការព្រួយបារម្ភនេះថា ការធ្វើដំណើររបស់ អៀង សារី ពីផ្ទះមកតុលាការជារៀងរាល់ថ្ងៃនឹងបន្តឲ្យមានការរំខាន


ដេវីឌ ប៉េកមែន

ជាខ្លាំង ហើយធ្វើឲ្យប្រជាជននៅក្នុងទីក្រុងភ្នំពេញមានការមិនពេញចិត្ត ។ ខណាវ៉ាស់ ក៏បន្ថែមទៀតថា ការឃុំខ្លួនបន្តនឹងផ្តល់ «សន្តិសុខ» ព្រមទាំង «ភាពងាយស្រួល» នៅក្នុងដំណើរការជំនុំជម្រះ ។

## ១) សវនាការបណ្តឹងឧទ្ធរណ៍ ខៀវ សំផន នៅថ្ងៃ១២ ខែកុម្ភៈ

សហមេធាវីអន្តរជាតិរបស់ ខៀវ សំផន, ហ្សាក់ វែហ្សេស មិនបានចូលរួមក្នុងសវនាការនៅថ្ងៃសុក្រទេ ។ មិនមានការផ្តល់ហេតុផលទាក់ទងអវត្តមានរបស់ ហ្សាក់ វែហ្សេស ទេ ។ សហមេធាវីជាតិ ស សូវ៉ាន ការពារក្តីតែម្នាក់ឯង ។ នៅក្នុងសេចក្តីសង្ខេប សហមេធាវីបានអះអាងថាគួរតែមានការដោះលែងកូនក្តីរបស់ខ្លួន ដោយសារតែភាពលម្អៀងដែលត្រូវបានចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត ព្រមទាំងមិនមានការបកស្រាយជាលាយលក្ខណ៍អក្សរនិងត្រឹមត្រូវទៅលើការឃុំខ្លួន ។ ការអវត្តមានរបស់ ហ្សាក់ វែហ្សេស មិនមានផលប្រយោជន៍ដល់កូនក្តីរបស់ខ្លួនទេ ពីព្រោះ ស សូវ៉ាន ធ្វើការការពារក្តីតែម្នាក់ឯង ។ ស សូវ៉ាន បែរជាប្រើប្រាស់ពេលវេលាទៅរៀបរាប់ពីការស្លាប់របស់ឪពុករបស់គាត់នៅក្នុងរបបនោះ ហើយគាត់ក៏នៅអង្គជំនុំជម្រះ «ស្វែងរកការពិតដែរ» ។ ដោយស្គាល់កូនក្តីរបស់ខ្លួនជាច្រើនឆ្នាំ ស សូវ៉ាន បានអះអាងថា គាត់ជឿទៅលើភាពស្អាតស្អំរបស់កូនក្តី

របស់គាត់ ហើយគាត់បាននិយាយថា កូនក្តីរបស់ខ្លួនមិនដែលនឹង «លួចមាន់» ផង ។ បន្ទាប់ពីបញ្ចប់សេចក្តីសង្ខេប ស សូវ៉ាន បានស្នើឲ្យអង្គជំនុំជម្រះពិចារណាទៅលើការប្រើប្រាស់យុត្តិសាស្ត្រផ្សេងសម្រាប់ឃុំខ្លួន (ឧទាហរណ៍ដូចជាឃុំខ្លួននៅផ្ទះ) ។


ស សូវ៉ាន

ជំនួយការសហព្រះរាជអាជ្ញាជាន់ខ្ពស់ជាតិ (វ៉េង ហួត) និង អន្តរជាតិ (ថារីក អេបដុលហាក់) បានគាំទ្រនឹងការបដិសេធបណ្តឹងឧទ្ធរណ៍ដោយតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញា ។ ដោយនិយាយពីអ្វីដែលតម្រូវឲ្យមាននៅក្នុងវិធាន៦៣(៣)(ក)


ថារីក អេបដុលហាក់

អេបដុលហាក់ បាននិយាយថា មានភ័ស្តុតាងបញ្ជាក់ថា ខៀវ សំផន បានដឹងពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំងការបោសសម្អាតសត្រូវដែលសង្ស័យទៀត ។ អេបដុលហាក់ បន្តទៀតថា មានភ័ស្តុតាងបញ្ជាក់ថា ខៀវ សំផន មានជាប់ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីភ្នំពេញ ។ អេបដុលហាក់ បានអះអាងថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាការចាំបាច់ពីព្រោះវានឹងមាន «ហានិភ័យពិត» ដល់សន្តិសុខរបស់ ខៀវ សំផន ហើយសង្គមដ៏ផុយស្រួយរបស់កម្ពុជាងាយស្រួលនឹងបង្កឲ្យមានការប្រឆាំងពីប្រជាជនស៊ីវិល ។ បន្ទាប់ពីត្រូវបានរំឭកថាខ្លួនមានពេលពីរនាទីទៀតសម្រាប់និយាយ អេបដុលហាក់ មិនអាចនិយាយអំពីការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតនិងការរំលោភបំពានទៅលើសិទ្ធិដំណើរការនីតិវិធីដូចដែលបានគ្រោងទុកទេ ។ អេបដុលហាក់ បានសន្និដ្ឋានថា ការស្នើឲ្យប្រើប្រាស់ជម្រើសផ្សេងសម្រាប់ឃុំខ្លួនគឺមិនត្រឹមត្រូវ ។

ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សេចក្តីឆ្លើយតបក៏ដោយ ក៏ប្រធានចៅក្រម ប្រាក់ គឹមសាន បានអនុញ្ញាតឲ្យសហមេធាវីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដើម្បីសម្រេចទៅលើការស្នើឲ្យឃុំខ្លួនជនត្រូវចោទនៅផ្ទះដែរ ។ ប្រេកមែន និង សហមេធាវីជាតិបានធ្វើសេចក្តីសន្និដ្ឋានសង្ខេបផ្ទាល់មាត់ដោយស្នើឲ្យបន្តឃុំខ្លួនជនត្រូវចោទនៅមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បន្ទាប់មក ស សូវ៉ាន បានឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ដោយចោទប្រកាន់សហចៅក្រមស៊ើបអង្កេត ឡឺម៉ុង ថា ស្វែងរកតែភ័ស្តុតាងដាក់បន្ទុក ហើយស្នើឲ្យចៅក្រមកុំវិភាគទៅលើវិធាន៦៣(៣)(ក) ដោយផ្អែកទៅលើភ័ស្តុតាងដែលប្រមូលបានដោយ ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ស សូវ៉ាន បានធ្វើសន្និដ្ឋានដោយរំឭកដល់ចៅក្រមថា ទោះបីជាយ៉ាងណាក៏ដោយ កូនក្តីរបស់ខ្លួននឹងត្រូវបានដោះលែងបន្ទាប់ពី៣៦ខែនៃការហាមមិនឲ្យមានការធ្វើវិសោធនកម្មច្បាប់ដែលលោកហៅថា «មិនទំនង» ព្រមទាំងស្នើឲ្យដោះលែងកូនក្តីរបស់ខ្លួនដោយអនុលោមទៅតាមអំណាចរបស់តុលាការ ។

សវនាការបានបញ្ចប់បន្ទាប់ពី ខៀវ សំផន ឡើងអះអាងថាគាត់មិនមានអំណាចទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខៀវ សំផន ប្រាប់អង្គជំនុំជម្រះទៀតថា គាត់ធ្វើជាគណៈប្រធានរដ្ឋគ្រាន់តែដើម្បី «តំណាងឲ្យប្រជាជាតិកម្ពុជាទាំងមូល» នៅពេលដែលប្រទេសស្ថិតនៅក្នុងស្ថានភាពច្របូកច្របល់ ។ ខៀវ សំផន

សង្កត់ធ្ងន់ថា គាត់មិនមានទាហាននៅក្រោមបញ្ជាទេ ហើយប្រជាជនទាំងអស់ចាត់ទុកគាត់ថាជាមេដឹកនាំដែលគ្មានអំណាច ។ គាត់បង្ហាញទៀតថា គាត់គឺជាសមាជិកគណៈកម្មាធិការមជ្ឈិមមិនមែនគណៈកម្មាធិការអចិន្ត្រៃយ៍ទេ ។

### ក) សវនាការបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ថ្ងៃ១៩ កុម្ភៈ

សហមេធាវីអន្តរជាតិរបស់ អៀង ធីរិទ្ធ ដាយអាណា អេលីស អវត្តមាននៅក្នុងសវនាការនៅថ្ងៃច័ន្ទ ។ កាលីញ វេន ដឺ វូត ដែលជាទីប្រឹក្សាច្បាប់អន្តរជាតិរបស់ក្រុមបានធ្វើសេចក្តីសន្និដ្ឋានកំបាំងមុខដោយផ្ទាល់មាត់ជាមួយសហមេធាវីជាតិ ផាត់ ពៅសៀង ។ ផាត់ ពៅសៀង បានបង្ហាញពីមូលហេតុដែលថាដីកាគួរតែត្រូវ



កាលីញ វេន ដឺ វូត

បានដកចេញ ។ គាត់បានអះអាងថា ក) សហចៅក្រមស៊ើបអង្កេតចេញដីកាបន្តការឃុំខ្លួនដោយមិនពិចារណាទៅលើកាលៈទេសៈដែលបានផ្លាស់ប្តូរ ។ ខ) សហចៅក្រមស៊ើបអង្កេតមិនបានប្រើប្រាស់បទដ្ឋានត្រឹមត្រូវនៅពេលដែលតម្រូវឲ្យមេធាវីការពារក្តីបង្ហាញពីកាលៈទេសៈដែលផ្លាស់ប្តូរទេ ។ គ) មិនមានសម្អាងច្បាស់លាស់ដែលបង្ហាញថា អៀង ធីរិទ្ធ ពិតជាបានប្រព្រឹត្តបទល្មើស ។ ឃ) មិនមានមូលហេតុបង្ហាញស្របទៅនឹងវិធាន៦៣(៣)(ខ) ។ ផាត់ ពៅសៀង បានបង្ហាញថា មាត្រា៩(៣) នៃកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិនយោបាយនិងស៊ីវិល បានចែងពីការណែនាំដ៏តឹងរ៉ឹងសម្រាប់ការឃុំខ្លួន ហើយគាត់បានអះអាងទៀតថា ការអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺផ្ទុយពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។

ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញាជាតិ (សេង ប៊ុនកាង) និងអន្តរជាតិ (វ៉ាំងសង់ ដឺ វីលដ៍) បានបដិសេធនឹងបណ្តឹងឧទ្ធរណ៍ដោយតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញា ។ ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញាបានអះអាងថាមានសម្អាងត្រឹមត្រូវដែលបង្ហាញថា អៀង ធីរិទ្ធ បានប្រព្រឹត្តបទល្មើសដែលត្រូវបាន



វីនស៊ិន ដឺ វីលដ៍

ចោទប្រកាន់ ។ ដើម្បីជាជំនួយដល់ការបកស្រាយនេះ ដឺ វីលដ៍ បានរំឭកអំពីលិខិតពីរដែលបញ្ជាក់ថា អៀង ធីរិទ្ធ បានគ្រប់គ្រងមន្ទីរពេទ្យ កន្លែងផលិតថ្នាំ និងក្រសួងសង្គមកិច្ច ។ គាត់បានអះអាងទៀតថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាការចាំបាច់ដោយយោងទៅវិធានបីក្នុងចំណោមវិធានទាំងប្រាំរបស់វិធាន៦៣(៣)(ខ) ។ ដើម្បីបន្ថែមទៅលើលទ្ធភាពដែលអាចគំរាមកំហែងដល់សាក្សី ដឺ វីលដ៍ បានលើកឡើងពីការគំរាមកំហែងរបស់ អៀង ធីរិទ្ធ ទៅលើមន្ត្រីតុលាការនៅក្នុងសវនាការមុន ហើយយ៉ាងហោចណាស់ក៏មានការគំរាមកំហែង៧០ដងទៅលើអ្នកយាមនិងអ្នកជាប់ឃុំដូចគាត់ដែរ ។ គាត់បន្តទៀតថា សាក្សី និងជនរងគ្រោះងាយនឹងទទួលឥទ្ធិពលពីការគំរាមកំហែងពីព្រោះអ្នកទាំងនោះមានជំងឺបាក់ស្បាត ។

សហមេធាវីនិងដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សេចក្តីឆ្លើយតបនិងធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទេ ។ សហមេធាវីរបស់ អៀង ធីរិទ្ធ បានឆ្លើយតបនឹងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញា ។ ផាត់ ពៅសៀង បានចោទប្រកាន់ ដឺ វីលដ៍ ថាព្យាយាម «ទាញយកផលប្រយោជន៍ពីកូនក្តីរបស់ខ្លួន» និងព្យាយាម «ធ្វើឲ្យកូនក្តីខឹង» ដោយតែងតែរំឭកពីការ

គំរាមកំហែងមុនរបស់គាត់ ។ ដើម្បីឆ្លើយតបនឹងការចោទប្រកាន់ថា អៀង ធីរិទ្ធ មានធនធានដែលអាចធ្វើគាត់រត់បាន ផាត់ ពៅសៀង បានរំឭកដល់អង្គជំនុំជម្រះថាគាត់មិនមានលទ្ធភាពចំណាយទៅលើថ្លៃច្បាប់ក្នុងការស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិទេ ។ វេន ជី វូត បាន អះអាងថា ការផ្លាស់ប្តូរសម្ភារៈបានកើតមានឡើងដោយអនុលោមទៅតាមលក្ខខណ្ឌវិធាន៦៣(៣)(ខ) ហើយទោះបីជាការផ្លាស់ប្តូរនេះមិនបានកើតមាន វាក៏មិនមែនជាបន្ទុករបស់មេធាវីការពារក្តីក្នុងការបង្ហាញពីកាលៈទេសៈដែលបានផ្លាស់ប្តូរដែរ ។ គាត់បន្តទៀតថា ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញាមិនបានបង្ហាញពីទំនាក់ទំនងរវាងភ័ស្តុតាងដាក់បន្ទុកនិងដីកាបញ្ជូនរឿងទៅស៊ើបសួរទេ ។

សវនាការបានបញ្ចប់ដោយ អៀង ធីរិទ្ធ ឡើងនិយាយ ។ គាត់បានប្រាប់ចៅក្រមថា គាត់កើតចេញពីគ្រួសារអ្នកចេះដឹងដែលមានចំណេះដឹងខាងច្បាប់ ។ គាត់បានអះអាងថា គាត់ធ្លាប់ជាសិស្សច្បាប់ ហើយឪពុករបស់គាត់ធ្លាប់ធ្វើការនៅក្នុងតុលាការខេត្តបាត់ដំបង ។

## ៤) ការតវ៉ាប្រឆាំងតាមផ្លូវច្បាប់ដ៏សំខាន់

### ក) ការខ្វះខាតភ័ស្តុតាងបង្ហាញពីការប្រព្រឹត្តបទល្មើសឬការទទួលខុសត្រូវ

មេធាវីការពារក្តីទាំងអស់បានអះអាងថាសហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការចេញដីកាពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន ពីព្រោះគេមិនបានធ្វើសេចក្តីសន្និដ្ឋានដោយផ្អែកទៅលើភ័ស្តុតាងដែលថាមានសម្អាងច្បាស់លាស់បញ្ជាក់ថាកូនក្តីរបស់ខ្លួនបានប្រព្រឹត្តបទល្មើសដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលតម្រូវតាមវិធាន៦៣(៣)(ក) ទេ ។ សហមេធាវីរបស់ អៀង ធីរិទ្ធ, លោក ផាត់ ពៅសៀង បានអះអាងថា ភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង «ពិបាកនឹងបញ្ជាក់» ថា កូនក្តីរបស់គាត់មានទំនាក់ទំនងជាមួយបទល្មើសដែលបានចោទប្រកាន់ណាស់ ។ ទីប្រឹក្សាច្បាប់អន្តរជាតិ កាលីញ វេន ជី វូត បានចោទប្រកាន់ស្រដៀងគ្នាថាជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញាមិនបានបង្ហាញពីទំនាក់ទំនងរវាងភ័ស្តុតាងដាក់បន្ទុកនិងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទេ ។

### ខ) កាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការផ្តល់សម្អាងនិងដាក់បន្ទុកលើភ័ស្តុតាងដើម្បីបង្ហាញពីកាលៈទេសៈដែលបានផ្លាស់ប្តូរ

យោងទៅតាមលក្ខខណ្ឌដែលតម្រូវដោយវិធាន៦៣(៣)(ខ) មេធាវីការពារក្តីទាំងអស់បានប្រឆាំងនឹងការអនុម័តរបស់សហចៅក្រមស៊ើបអង្កេតនៃសេចក្តីសម្រេចពីមុនរបស់អង្គបុរេជំនុំជម្រះនិងសេចក្តីសន្និដ្ឋានដែលគ្មានសម្អាងដែលថាកាលៈទេសៈមិនបានផ្លាស់ប្តូរទេ ។ សហមេធាវីបានអះអាងថា វិធាន៦៣(៧) បានដាក់បន្ទុកទៅលើសហចៅក្រមស៊ើបអង្កេតឲ្យបកស្រាយពីវត្តមានដូច្នេះហើយសហមេធាវីបានលើកឡើងថា ការសរុបន័យចុងក្រោយរបស់សហចៅក្រមអន្តរជាតិថា ជនត្រូវចោទមិនបានបង្ហាញករណីប្រែប្រួលដែលមិនគ្រប់គ្រាន់ក្នុងការដោះបន្ទុកនេះទេ ។ ជាការឆ្លើយតបទៅវិញ ជំនួយការព្រះរាជអាជ្ញាបានលើកឡើងថា វិធាន៦៣(៧) មិនបានទាមទារឲ្យសហចៅក្រមអន្តរជាតិបង្ហាញភ័ស្តុតាងនៃការឃុំឃាំងបណ្តោះអាសន្ននោះទេ ដោយជំនួសមកវិញ គេបានលើកឡើងថា វាគ្រាន់តែទាមទារឲ្យសហចៅក្រមអន្តរជាតិផ្តល់ហេតុផលសម្រាប់ការពន្យារពេលប៉ុណ្ណោះ ។ គេបានលើកឡើងថា បន្ទុកនេះគឺស្ថិតនៅលើជនត្រូវចោទក្នុងការបង្ហាញពីករណីប្រែប្រួលនិងបង្ហាញនៅក្នុងការអនុវត្តជាអន្តរជាតិនិងតុលាការអន្តរជាតិដែលទាមទារឲ្យជនត្រូវចោទបង្ហាញករណីប្រែប្រួលនៅក្នុងការធ្វើពាក្យស្នើសុំឲ្យដោះលែង ។

### គ) តម្រូវការនៃភាពចាំបាច់ដែលមានលក្ខណៈឯករាជ្យនៃវិធាន៦៣(៣)(ខ) :

មេធាវីការពារក្តីអន្តរជាតិរបស់ អៀង ធីរិទ្ធ ឈ្មោះ កាលីញ វេន ជី វូត បានលើកឡើងថា ភាពចាំបាច់គឺជាធាតុដាច់ដោយឡែកមួយនៃវិធាន៦៣(៣)(ខ) ហើយថាការកើតឡើងរបស់វាត្រូវតែចាត់ទុកជាការកើតឡើងដោយឯករាជ្យនៃលក្ខខណ្ឌទាំងប្រាំ ។ ដោយសម្អាងទៅលើច្បាប់នៃសំណុំរឿងពីតុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប គាត់បានលើកឡើងថា ភាពចាំបាច់ទាមទារថាវិធាននេះអាចទៅរួចបានតិចតួច ។ ដោយមិនបានគិតពីភាពចាំបាច់ជាឯករាជ្យ គាត់បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញពីវិធាន៦៣(៣)(ខ) ទេ ។

### ឃ) សំណើសុំឃុំខ្លួននៅផ្ទះនិងមិនត្រូវបានចាត់ទុកជាទម្រង់នៃការបន្ធូរបន្ថយការឃុំឃាំង

ជាមួយនឹងវិធីសាស្ត្រពីដំបូងរបស់គេ សហមេធាវីរបស់ អៀង សារី បានស្នើថា កូនក្តីរបស់គេគួរតែត្រូវបានឃុំខ្លួននៅផ្ទះរបស់គាត់ ឬក៏នៅក្នុងមន្ទីរពេទ្យជំនួសឲ្យការស្នើសុំដោះលែង ។ សហមេធាវីបានលើកឡើងថា ការឃុំខ្លួននៅផ្ទះ ក) ប្រហែលជាអាចកាត់បន្ថយការរំលោភលើសិទ្ធិសេរីភាពកូនក្តីរបស់គាត់ និងការសន្មតទុកថាគ្មានកំហុស ខ) ប្រហែលជាមានផលប្រយោជន៍សម្រាប់សុខភាពរបស់គាត់ ហើយគ) ប្រហែលជាចំណាយតិច ពីព្រោះរាជរដ្ឋាភិបាលគ្រាន់តែត្រូវការរកឆ្មាំការពារម្នាក់មកយាមនៅផ្ទះរបស់គាត់តែប៉ុណ្ណោះ ។ នៅក្នុងសំណើផ្ទាល់មាត់របស់គាត់ ខាណាវ៉ាស់ បានអះអាងថា ការឃុំខ្លួននៅក្នុងផ្ទះនឹងអាចធ្វើទៅបាន ហើយនឹងមិនបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពកូនក្តីរបស់គាត់ទេ ។ នៅក្នុងការឆ្លើយតបដ៏គួរឲ្យភ្ញាក់ផ្អើលមួយចំពោះការអះអាងដែលធ្វើឡើងដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី ខាណាវ៉ាស់ បាននិយាយថា គាត់បានកត់សម្គាល់ឃើញថា វានឹងមាន «សុវត្ថិភាព» និង «ងាយស្រួល» ជាង ដែលជនត្រូវចោទឃុំឃាំងនៅក្នុងតុលាការនៅក្នុងបន្ទប់សវនាការ ។ ជំនួយការព្រះរាជអាជ្ញាអន្តរជាតិ អានីស អាហាម៉េដ បានអះអាងថា មិនថាវិធានផ្ទៃក្នុងឬក៏ក្រមនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជាសុទ្ធតែមិនបានចែងពីការឃុំខ្លួននៅផ្ទះនោះទេ យោងតាមវិធាន៦៥(១) ដែលនិយាយអំពីប្រាក់ធានានោះ ។

គាំទ្រទៅនឹងការឃុំខ្លួននៅផ្ទះ អាង ឧត្តម បានលើកឡើងពីអ្វីដែលធ្លាប់កើតមានតាំងពីមុនមកជាលក្ខណៈជាតិនិងអន្តរជាតិ ហើយបានសម្អាងទៅលើការដោះលែងរបស់តុលាការកំពូលចំពោះអ្នកដែលត្រូវចោទប្រកាន់ថាជាអ្នកបានសម្លាប់មេដឹកនាំសហជីបម្នាក់ឈ្មោះ ជា វិជ្ជា ។ ជាការឆ្លើយតប អានីស អាហាម៉េដ បានលើកឡើងពីភាពខុសប្លែកគ្នាលើករណីរបស់ ជា វិជ្ជា ដោយបង្ហាញថាតុលាការកំពូលបានដោះលែងចុងចោទបន្ទាប់ពីសេចក្តីថ្លែងការណ៍ត្រូវបានចាត់ទុកជាមោឃៈ ។ គាត់បានលើកឡើងបន្ថែមទៀតថា គ្មានតុលាការព្រហ្មទណ្ឌអន្តរជាតិណាដែលចង់ឲ្យមានការឃុំខ្លួននៅផ្ទះនោះទេ មានតែការកំណត់ការលើកលែងមួយចំនួនប៉ុណ្ណោះនៅក្នុងសំណុំរឿងច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ នៅក្នុងការជជែកដេញដោលរវាងសហព្រះរាជអាជ្ញានិងជនជាប់ចោទ ប្លាស៊ីក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីយល់ឃើញថា ការឃុំខ្លួននៅផ្ទះត្រូវបានអនុញ្ញាតប្រសិនបើ ក) គ្មានភ័ស្តុតាងបញ្ជាក់ថា មនុស្សម្នាក់នោះនឹងរត់គេច ខ) មិនមានភ័ស្តុតាងនិងសាក្សី គ) មិនមានការបន្តឧក្រិដ្ឋកម្ម និង ឃ) គ្មានការគំរាមកំហែងទៅលើសន្តិភាពនិងសុវត្ថិភាព ។ ចំពោះករណីរបស់ អៀង សារី, អានីស អាហាម៉េដ បានអះអាងថា វាមិនបានប៉ះពាល់ទៅលើករណីទាំងអស់នេះទេ ។ ខាណាវ៉ាស់ បានបង្ហាញពីភាពខុសប្លែកគ្នារបស់ ប្លាស៊ីក ពីព្រោះវាទាក់ទងនឹងការឃុំខ្លួនឲ្យនៅក្នុងនៅផ្ទះនៅក្នុងប្រទេសហូឡង់ ។ គាត់បានអះអាងថា នៅក្នុងសំណុំរឿងលើកក្រោយ ប្លាស៊ីក ត្រូវបានឃុំខ្លួននៅក្នុងផ្ទះនៅអំឡុងពេលបើកសវនាការនិងកាត់ទោស ។

សហមេធាវីបាននិយាយថា ដោយមិនបានចាត់ទុកថាការឃុំខ្លួននៅក្នុងផ្ទះជាការបន្ធូរបន្ថយជំនួសឲ្យការឃុំឃាំង សហចៅក្រមស៊ើបអង្កេតបានរំលោភទៅលើសិទ្ធិសេរីភាពរបស់កូនក្តីរបស់គាត់និងការកំណត់ទុកជាមុនថាគ្មានទោសនៅក្នុងវិធាន ២១(១)(ខ) ។ អាង ឧត្តម បាននិយាយថា សហចៅក្រមស៊ើបអង្កេតមិនបានគាំទ្រដល់ការបង្ហាញថាតើវាអាចទៅរួចដែលឬទេនៅក្នុងការឃុំខ្លួន អៀង សារី នៅក្នុងផ្ទះ ដែលមានអ្នកយាមម្នាក់នោះ ។ ខាណាវ៉ាស់ បានអះអាងថា ការឃុំខ្លួននៅក្នុងផ្ទះគួរតែអាចធ្វើទៅបាននិងមិនបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពកូនក្តីរបស់គាត់ទៀត ។ គាត់បាននិយាយដោយចម្អកថា គាត់មិនអាចជឿថារដ្ឋអំណាចកម្ពុជា «គ្មានសមត្ថភាពឃុំខ្លួនជនណាម្នាក់ឲ្យនៅក្នុងផ្ទះដែលស្ទើរតែមិនអាចដើរទៅកាន់បន្ទប់ទឹកបាន» ។ គាំទ្រទៅនឹងការអះអាងផ្នែកច្បាប់របស់គេ សហមេធាវីបានសម្អាងលើការកំណត់សម្គាល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិរបស់អង្គបុរេជំនុំជម្រះនៅក្នុងករណីឧក្រិដ្ឋកម្មរបស់ បេមបា ដែលការឃុំឃាំងបណ្តោះអាសន្នមិនមែនជាទម្រង់មួយនៃការដាក់ទណ្ឌកម្ម ហើយត្រូវតែមានការបន្ធូរបន្ថយដែលអាចទៅរួច ។

ទោះបីមិនបានស្នើសុំនៅក្នុងសេចក្តីសង្ខេបបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏សហមេធាវីជាតិរបស់ ខៀវ សំផន, ស សូវ៉ាន បានស្នើសុំការឃុំខ្លួននៅផ្ទះសម្រាប់កូនក្តីរបស់គាត់នៅអំឡុងពេល

សួរដេញដោលផ្ទាល់មាត់ដែរ ។

### ៦) បញ្ហាដែលគួរឲ្យកត់សម្គាល់បានលើកឡើងអំឡុងពេលបើកសវនាការ

#### ក) ភាពលម្អៀងរបស់សហចៅក្រមស៊ើបអង្កេតប្រឆាំងនឹងជនត្រូវចោទ

ក្រុមមេធាវីការពារទាំងអស់បាននិយាយថា មានភាពលម្អៀងជាប្រព័ន្ធមួយប្រឆាំងនឹងជនត្រូវចោទនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយនិយាយទៀតថា ទាំងនេះហើយដែលបណ្តាលឲ្យសហចៅក្រមស៊ើបអង្កេតច្រានចោលតួនាទីរបស់គេនៅក្នុងលក្ខណៈលម្អៀង និងគ្មានការយកចិត្តទុកដាក់ ។ សហមេធាវីរបស់ អៀង សារី បានថ្លែងនូវការប្រឆាំងដោយសំឡេងខ្លាំងៗថា សហចៅក្រមស៊ើបអង្កេតគឺជា «ព្រះរាជអាជ្ញាទីពីរ» ។ ខាណាវ៉ាស់ បានសួរអំពីភាពមិនលម្អៀងរបស់ ដេវីឌ ប៊ីយលី និង ស៊ីវ ហេឌី ហើយបានលើកឡើងនូវសេចក្តីណែនាំដែលបាននិយាយដោយសហចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុង ទៅកាន់អ្នកស៊ើបអង្កេតរបស់គាត់ដើម្បីរកឲ្យឃើញនូវភស្តុតាងពិរុទ្ធភាពបន្ថែម ។ គាត់បានរិះគន់អង្គជំនុំជម្រះដែលបានបដិសេធមិនស្តាប់ភស្តុតាងនៃភាពលម្អៀងនេះ ។ ចៅក្រម ឡាវីស មានអារម្មណ៍ខឹងសម្បារយ៉ាងខ្លាំងចំពោះការប្រឆាំងរបស់ ខាណាវ៉ាស់ ដោយគាត់បាននិយាយប្រាប់ដោយសម្តីគំរោះគំរើយថា ខាណាវ៉ាស់ «ធ្វើជ្រុលហួសហេតុពេក» និង «ធ្វើឲ្យគាត់មានអារម្មណ៍ថាមិនស្រួល» ។ ដោយមិនឲ្យ ខាណាវ៉ាស់ និយាយ ចៅក្រម ឡាវីស អនុញ្ញាតឲ្យជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញាអន្តរជាតិ (អានីស អាហម៉េដ) ឡើងនិយាយវិញ ។

នៅក្នុងការឆ្លើយតប អានីស អាហម៉េដ បានលើកបង្ហាញថាការនិយាយលម្អៀងទាំងនេះប្រឆាំងនឹង ឡឺម៉ុង ត្រូវបានគេរកឃើញថាគ្មានសុពលភាពទេ ។

បន្ថែមពីលើនេះទៀត អានីស អាហម៉េដ បានលើកឡើងថា អង្គបុរេជំនុំជម្រះមិនមែនជាយុត្តាធិការដ៏សមរម្យមួយក្នុងការលើកយកបញ្ហានេះមកនិយាយឡើយ ។ នៅអំឡុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញាអន្តរជាតិ (វ៉ាំងសង់ ដឺ វ៉ុលដ៏) បានលើកឡើងថាមានការសន្និដ្ឋាន ដ៏រឹងមាំមួយពីភាពមិនលម្អៀងរបស់ចៅក្រម ។ អានីស អាហម៉េដ អះអាងថា ប្រសិនបើភាគីម្ខាងចង់សួរពីភាពមិនលម្អៀងរបស់សហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែដាក់ពាក្យស្នើសុំទៅកាន់អង្គបុរេជំនុំជម្រះដើម្បីចៀសវាងការមានកំហុស ដោយអនុលោមទៅតាមវិធានផ្ទៃក្នុង ៣៤ ។

#### ខ) សុខភាពរបស់ អៀង សារី

តាមរយៈការលើកឡើងផ្ទាល់មាត់ សហមេធាវីរបស់ អៀង សារី បានសង្កត់ធ្ងន់ពីការវិវឌ្ឍនៃអាយុរបស់កូនក្តីរបស់ខ្លួន (ដោយលើកឡើងថា នៅពេលឆាប់ៗនេះគាត់នឹងមានអាយុ៨៥ ឆ្នាំហើយ) និងសុខភាពជំងឺរបស់គាត់ (ដោយលើកឡើងថា អៀង សារី ពិបាកដើរ មិនអាចអង្គុយបានយូរលើសពី៣០នាទី ហើយគាត់ត្រូវតែទៅបន្ទប់ទឹកឲ្យបានទៀងទាត់ពេលវេលាទៀត) ។ អៀង សារី មាន បញ្ហាបេះដូង ជំងឺសន្លាក់ឆ្អឹង (ឈឺឆ្អឹងខ្នង) ហើយនិងបញ្ហាទឹកនោម ។ អៀង សារី ធ្លាប់មានការលំបាកក្នុងការធ្វើចលនាជុំវិញបន្ទប់សវនាការ ហើយត្រូវការជំនួយពីអ្នកយាម ។ នៅមុនពេលបញ្ចប់ការដេញដោលផ្ទាល់មាត់របស់ជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញា សហមេធាវីបានស្នើសុំថា អៀង សារី ត្រូវតែត្រូវបានអនុញ្ញាតឲ្យសម្រាកនៅក្នុងបន្ទប់មួយផ្សេងទៀត ហើយចូលរួមនៅក្នុងសវនាការតិចតួច ។ ចៅក្រមអនុញ្ញាតចំពោះការស្នើសុំនេះ ហើយ អៀង សារី បានចាកចេញពីក្នុងបន្ទប់សវនាការ ។ ក្រោយមក អៀង សារី មិនបានត្រឡប់មកវិញទេ ដោយបោះបង់ចោលសិទ្ធិរបស់គាត់ក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ។ សហមេធាវីបានប្រើប្រាស់សុខភាពជំងឺរបស់ អៀង សារី ដើម្បីពន្យល់អំពីការលើកឡើងរបស់គេថា អៀង សារី គួរតែឃុំខ្លួននៅក្នុងផ្ទះរបស់គាត់ ឬក៏នៅក្នុងមន្ទីរពេទ្យ ហើយបានបញ្ជាក់បន្ថែមទៀតថា អៀង សារី មិនអាចរត់គេចខ្លួនបានទេ ។

ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញានិងសហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានប្រឆាំង ថា អៀង សារី មិនគួរត្រូវបានឃុំនៅក្នុងផ្ទះរបស់គាត់ដោយសារតែបញ្ហាសុខភាពនោះទេ ពីព្រោះ អៀង សារី បានទទួលការព្យាបាលយ៉ាងយកចិត្តទុកដាក់នៅបន្ទប់ឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជំនួយការជាន់ខ្ពស់ចៅក្រមឈ្មោះ អានីស អាហម៉េដ បានទាញ

យកនូវយុត្តិសាស្ត្រអន្តរជាតិដែលបានបង្កើតឡើងថា ប្រាក់ធានាមានភាពចាំបាច់ទៅលើបញ្ហាសុខភាពប្រសិនបើការព្យាបាលផ្នែកវេជ្ជសាស្ត្រមិនអាចទៅរួចនៅក្នុងអង្គភាពឃុំឃាំងឬក៏នៅក្នុងប្រទេសដែលត្រូវបានឃុំខ្លួន ។ គាត់បានអះអាងបញ្ជាក់ នេះមិនមែនជាករណីនៅទីនេះទេ ។ គាត់បានបកស្រាយថា តាមពិតទៅ អៀង សារី បានទទួលផលប្រយោជន៍ពីសេវាកម្មរបស់មនុស្សមួយក្រុមដែលរួមមានការព្យាបាលដោយធម្មជាតិ ឧបករណ៍ឈើច្រត់ពិសេសមួយ ប្រព័ន្ធសំឡេងរោទិ៍សម្រាប់ការមើលថែទាំ ២៤ម៉ោងនិងមានវិជ្ជបណ្ឌិតសរុបចំនួន១៧នាក់ដែលអាចទូរស័ព្ទទៅបានគ្រប់ពេលវេលា ។ អាទីស អាហម៉េដ បានលើកបង្ហាញថាជំងឺរបស់ អៀង សារី មិនអាចគំរាមកំហែងដល់អាយុជីវិតរបស់គាត់ភ្លាមៗនោះទេ ហើយបានលើកឡើងពីយុត្តិសាស្ត្រដែលបានចែងថាជំងឺដែលមានសភាពធ្ងន់ធ្ងរមិនអាចយកមកសម្អាងដើម្បីដោះលែងនោះទេ លុះត្រាតែជំងឺនោះមានសភាពធ្ងន់ធ្ងរមិនអាចព្យាបាលបាន អាចនឹងស្លាប់ ហើយមិនអាចព្យាបាលនៅក្នុងមន្ទីរឃុំឃាំងបាន ។

ជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញានិងសហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរបានកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះបានយកអាយុនិងសុខភាពរបស់ អៀង សារី ចូលទៅក្នុងការសម្រេចចិត្តជាចម្បង ។ បន្ថែមពីលើនេះទៀត ភាគីទាំងសងខាងបានលើកឡើងថា អាយុនិងសុខភាពរបស់ អៀង សារី គឺជាកត្តាសំខាន់មិនមែនកត្តាបន្ធូរបន្ថយទេពីព្រោះវាអាចជំរុញឲ្យ អៀង សារី រត់គេចខ្លួនបាន ប៉ុន្តែកត្តានេះក៏អាចធ្វើឲ្យ អៀង សារី ស្លាប់នៅក្នុងគុកដែរប្រសិនបើចៅក្រមសម្រេចឃុំខ្លួនគាត់ ។ អាទីស អាហម៉េដ បានលើកឡើងថាការប៉ាន់ប្រមាណមិនអាចផ្តល់យោបល់ថា បញ្ហាសុខភាពរបស់ អៀង សារី គឺជាការគំរាមកំហែងដល់អាយុជីវិត ឬក៏ធ្វើឲ្យគាត់មិនស័ក្តិសមនឹងឈរនៅក្នុងសវនាការទេ ។ ខាណាវ៉ាស់ បានចង្អុលបង្ហាញថា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានជ្រើសរើសវេជ្ជបណ្ឌិតដែលមានជំនាញដ៏សមរម្យមួយដោយគ្មានការបម្រុងទុកសម្រាប់ដាក់បញ្ចូលទៅលើការជ្រើសរើសពីមេធាវីការពារក្តី ។ ជាងនេះទៅទៀត គាត់បាននិយាយថា ការពិនិត្យដ៏ត្រឹមត្រូវទាំងនេះមិនមែនជាការពិនិត្យដោយទៀងទាត់ឬផ្នែកចិត្តវិទ្យាដ៏ត្រឹមត្រូវនោះទេពីព្រោះអ្នកពិនិត្យទាំងនោះបានសួរតែសំណួរធម្មតាប៉ុណ្ណោះដូចជាឈ្មោះរបស់កូនក្តីគាត់ជាដើម ។ គាត់បានរៀបរាប់ពីរបាយការណ៍ទៅលើភាពសមរម្យក្នុងការឈរនៅក្នុងសវនាការជា «ការចម្លក» ។

### គ) សុខភាពផ្លូវចិត្ត និងការបាត់ការចងចាំរបស់ អៀង ធីរិទ្ធ

នៅសវនាការដំបូងរបស់គាត់ អៀង ធីរិទ្ធ បានតវ៉ាថាបានភ្លេចព័ត៌មានសំខាន់ៗអំពីខ្លួនគាត់នៅពេលដែលត្រូវបានសួរដោយលោកប្រធាន ប្រាក់ គឹមសាន ។ នៅពេលសួរអំពីឈ្មោះប្តីរបស់គាត់ អៀង ធីរិទ្ធ មានការយល់ច្រឡំ ហើយមើលជុំវិញបន្ទប់សវនាការ ហើយនិងក្រុមមេធាវីការពារក្តីរបស់គាត់ ហើយនិយាយថា គាត់មិនបានចងចាំឈ្មោះរបស់ប្តីគាត់នោះទេ ប៉ុន្តែគ្រាន់តែដឹងថា គាត់ក៏ត្រូវបានជាប់ឃុំឃាំងដងដែរ ។ អៀង ធីរិទ្ធ បានសួរអ្នកដែលនៅក្នុងបន្ទប់សវនាការឲ្យជួយ ហើយដោយមានការរំឭកពីក្រុមមេធាវីការពាររបស់គាត់ គាត់និយាយថាឈ្មោះ «អៀង សារី» ។ ក្រោយមក នៅពេលសួរអំពីចំនួនកូនរបស់គាត់ អៀង ធីរិទ្ធ ហាក់ដូចជាយល់ច្រឡំម្តងទៀត ហើយនិយាយថា គាត់មិនបានចងចាំទេ ពីព្រោះគាត់ «រវល់ខ្លាំងណាស់» ប៉ុន្តែក្រោយមក គាត់បានប្រាប់ថា មានចំនួនបួននាក់ ។

### ឃ) ការនិយាយពីការបន្តរឿងរបស់ អៀង ធីរិទ្ធ ដោយជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញា

ដើម្បីគាំទ្រដល់ការលើកឡើងរបស់គាត់ដែលថាការឃុំឃាំងបណ្តោះអាសន្នមានភាពចាំបាច់ខ្លាំងដើម្បីការពារការដាក់សម្ពាធបន្ថែមទៅលើសាក្សីនិងជនរងគ្រោះ ជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញាអន្តរជាតិ (វ៉ាំងសង់ ដឺ វ៉ុលដឺ) បានធ្វើសំណើដោយរំឭកទៅដល់អង្គជំនុំជម្រះអំពីពាក្យសម្តីរបស់ អៀង ធីរិទ្ធ នៅសវនាការអង្គបុរេជំនុំជម្រះលើកចុងក្រោយទៅលើការឃុំឃាំងបណ្តោះអាសន្ននៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៩ ។ នៅពេលនោះ អៀង ធីរិទ្ធ បានគំរាមថា អ្នកដែលចោទប្រកាន់រូបគាត់នឹងត្រូវ «ធ្លាក់នរកប្រាំពីរជាន់» ។ វេន ដឺ វូត ភ្លាមនោះបានកាត់សម្តីរបស់ វ៉ាំងសង់ ដឺ វ៉ុលដឺ ដោយស្នើថា ចៅក្រមបានបញ្ជាមិនឲ្យគាត់និយាយរាលដាលប៉ះពាល់ដល់កូនក្តីរបស់គាត់ទេ ។

វេន ដឺ វូត បានសុំឲ្យចៅក្រមគិតទៅលើ «ពាក្យសម្ដីឈឺចាប់» របស់កូនក្ដីគាត់ ។ ចៅក្រម រ៉ូហ្វេន ដូណឺង បាននិយាយទៅកាន់អង្គជំនុំជម្រះ ដោយបដិសេធការស្នើសុំនេះ ហើយបកស្រាយថា វាមិនមែនជាពេលសម្រាប់ចៅក្រមក្នុងការស្នើឲ្យគាត់ទោសដោយផ្ទាល់ទេ ។

**ង) ការបង្ហាញដដែលៗ និងការអូសបន្លាយពេលនៃនីតិវិធី ដោយជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញា**

ជាទម្លាប់ ចៅក្រមជាតិម្នាក់អានរបាយការណ៍អំពីការត្រួតពិនិត្យនៅពេលចាប់ផ្ដើមសវនាការនីមួយៗ ។ ក្រៅពីបង្ហាញនូវគោលបំណង «ក្នុងការជួយអ្នកដែលមិនមែនជាភាគីនៃដំណើរការនីតិវិធីដើម្បីឲ្យយល់ពីបញ្ហាមុនពេលបើកសវនាការ» របាយការណ៍នេះបានរៀបរាប់យ៉ាងវែងពីនីតិវិធីរបស់បណ្ដឹងឧទ្ធរណ៍ ។ ជាការមិនសប្បាយចិត្តមួយផងដែរ សហព្រះរាជអាជ្ញាជាតិនីមួយៗបានអានដំណើររឿងដែលស្រដៀងគ្នាខ្លាំងណាស់រៀបរាប់អំពីប្រវត្តិនៃនីតិវិធី ។ នៅថ្ងៃសុក្រ ស សូវ៉ាន បាននិយាយកាត់ជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញាជាតិ (វ៉េង ហួត) ដោយឲ្យយោបល់ថាអ្នកតាមដានមានអារម្មណ៍ធុញ ហើយលើកឡើងថា វ៉េង ហួត និយាយដដែលអំពីប្រវត្តិនៃនីតិវិធី ។ ការឡើងបង្ហាញរបស់ វ៉េង ហួត ពីប្រវត្តិនៃនីតិវិធីដែលត្រូវបានអូសបន្លាយប្រហែលជាកន្លះម៉ោងចំណាយទៅលើសហព្រះរាជអាជ្ញា ហើយទុកគោលបំណងជាអន្តរជាតិរបស់គាត់ចោលដែលវាជាពេលវេលាតិចតួចណាស់ទាក់ទងនឹងសំណើនៃវិធាន៦៣(៣)(ខ) ។ ដោយសារតែខ្វះពេលវេលា អាប់ដុលហាក់ មិនអាចបង្ហាញការលើកឡើងរបស់គាត់ទាក់ទងទៅនឹងការអនុវត្តរបស់សហចៅក្រមស៊ើបអង្កេតនិងការប្រព្រឹត្តខុសនីតិវិធីដូចដែលគាត់បានប្រាប់ទៅដល់អង្គជំនុំជម្រះថាគាត់នឹងធ្វើ ។

**៧) ការចូលរួមជាសាធារណៈនៅក្នុងសវនាការ**

**ក) ទិដ្ឋភាពនៃការចូលរួម និងប្រតិកម្មជាសាធារណៈ**

សវនាការនេះមានការចូលរួមយ៉ាងច្រើនកុះករពីសំណាក់សាធារណជនដែលមានចំនួនអង្គុយជិត៥០០កៅអីក្នុងរយៈពេលបីថ្ងៃពេញ ហើយក៏អរគុណចំពោះកិច្ចខិតខំប្រឹងប្រែងពីសំណាក់ក្រុមកិច្ចការសាធារណៈនិងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយចំនួន ។ នៅថ្ងៃព្រហស្បតិ៍ ដោយមានការជួយជ្រោមជ្រែងពីសំណាក់ក្រុមកិច្ចការសាធារណៈ ប្រជាជនមួយក្រុមធំដែលអញ្ជើញមកពីខេត្តសៀមរាបបានចូលមកទស្សនាសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ។ នៅថ្ងៃសុក្រ ដោយមានការជួយជ្រោមជ្រែងពីសំណាក់ក្រុមកិច្ចការសាធារណៈនេះផងដែរ ក្រុមកូនសិស្សនិងគ្រូដែលមានចំនួន៣៥០នាក់មកពីសាលាបណ្ដុះបណ្ដាលគ្រូបង្រៀន ហ៊ុន សែន នៅក្នុងស្រុកស្ទឹងសែន ខេត្តកំពង់ធំ និងសិស្សមកពីវិទ្យាល័យភ្នំពេញបានមកតាមដានសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ។ នៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រ អ្នកចូលរួមចំនួន៩៣នាក់ដែលអញ្ជើញមកពីខេត្តបន្ទាយមានជ័យ ស្វាយរៀង និងខេត្តកណ្ដាល បានអញ្ជើញមកចូលរួមដោយមានការជួយជ្រោមជ្រែងពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អង្គភាពគាំទ្រជនរងគ្រោះក៏បានអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីមកចូលរួមក្នុងសវនាការផងដែរ ។ ក្រុមដែលបានអញ្ជើញមកចូលរួមសវនាការនៅថ្ងៃច័ន្ទលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ មិនបានដឹងទេ ។ នៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រ ក្រុមបុគ្គលិកបានសម្ភាសន៍អ្នកមកចូលរួមអំពីបទពិសោធន៍របស់គេ ។

ភាគច្រើននៃអ្នកដែលត្រូវបានសម្ភាន៍ដូចជា សំ ចាន់ ជាអ្នកដែលមជ្ឈមណ្ឌលឯកសារកម្ពុជាអញ្ជើញមកពីខេត្តកណ្ដាល បាននិយាយថា ពួកគេយល់ថាសវនាការនេះគួរឲ្យចាប់អារម្មណ៍ ហើយបានបង្ហាញនូវសុទិដ្ឋិនិយមចំពោះដំណើរការតុលាការ ។ សំ ចាន់ បាននិយាយប្រាប់អ្នកសម្ភាសន៍ថា គាត់ជឿជាក់ថា «តុលាការនេះគួរតែស្វែងរកយុត្តិធម៌សម្រាប់យើងនិងផ្ដល់នូវការកាត់ទោសដ៏ត្រឹមត្រូវសម្រាប់ជនជាប់ចោទ» ។ ស៊ីង ស៊ីតា ដែលអញ្ជើញមកពីខេត្តស្វាយរៀងបានរាយការណ៍ថា គាត់មិនយល់ស្របចំពោះដំណើរការយុត្តិធម៌របស់តុលាការនៅមុនការបើកសវនាការទេ ប៉ុន្តែ «បន្ទាប់ពីបានឃើញដោយផ្ទាល់ភ្នែក គាត់ជឿជាក់ថាតុលាការនេះកំពុងធ្វើរឿងមួយដោយត្រឹមត្រូវនិងធ្វើទៅតាមច្បាប់ជាតិពន្ធ» ។ អ្នកតាមដានដំណើរការសវនាការភាគច្រើនបានរាយការណ៍ថា ធ្លាប់បានតាមដានដំណើរការសវនាការតាមទូរទស្សន៍ឬធ្លាប់បានស្ដាប់វិទ្យុពីមុនមក ។ អ្នកត្រូវបានសម្ភាសន៍ភាគច្រើនបានត្អូញត្អែរថាគ្មានសមត្ថភាពយល់ពីសវនាការនេះ ។

ម៉ុក សុផាត អ្នកដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញមកនិង គឹម វុទ្ធី ជាដើមបណ្តឹងរដ្ឋប្បវេណីដែលអញ្ជើញមកពីខេត្តកំពតបានបង្ហាញនូវការអស់សង្ឃឹមទៅកាន់អ្នកសម្ភាសន៍ថា ជនត្រូវចោទមិនបានទទួលស្គាល់នូវកំហុសរបស់ខ្លួនឯងទេ ។ ម៉ុក សុផាត បាននិយាយថា គាត់មានអារម្មណ៍ឈឺចាប់ចំពោះភាសាដ៏យង់ឃ្នងរបស់ ស សូវាន សហមេធាវីជាតិរបស់ ខៀវ សំផន ។

### ១) គាំទ្រអ្នកតាមដានដំណើរការសវនាការពីតុលាការនិងអង្គការក្រៅរដ្ឋាភិបាល

បទសម្ភាសន៍បានបង្ហាញថា មានការគាំទ្រពីអ្នកតាមដានដំណើរការសវនាការដែលអង្គការផ្សេងៗបានអញ្ជើញមក ។ អ្នកមកតាមដានដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញមកបានមកចូលរួមក្នុងសវនាការរយៈពេលបីថ្ងៃនៅទីក្រុងភ្នំពេញដោយ នៅអំឡុងពេលនោះពួកគេក៏បានចូលរួមស្តាប់ការធ្វើបទបង្ហាញទាក់ទងនឹងរឿងតុលាការ ដោយលោក វីលៀម ស្មីត (សហព្រះរាជអាជ្ញារងអន្តរជាតិ) ទស្សនាភាពយន្តឯកសារទាក់ទងនឹងរបបនោះ ទស្សនាបូជនីយដ្ឋានជើងឯក សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងព្រះបរមរាជវាំង និងទស្សនាល្ខោនសម្តែងមួយដែលមានចំណងជើងថា «ទម្លាយភាពស្ងប់ស្ងាត់» ។ គឹម វុទ្ធី ជាជំនួយការដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គការអាដហុកមកពីខេត្តកំពង់ស្ពឺបានប្រាប់អ្នកធ្វើបទសម្ភាសន៍ថា គាត់ត្រូវបានអញ្ជើញឲ្យចូលរួមដោយអង្គភាពជនរងគ្រោះ ប៉ុន្តែមិនបានផ្តល់លុយកាក់ឲ្យទេ ។ អ្នកតាមដានដែលអញ្ជើញដោយអង្គភាពកិច្ចការសាធារណៈបានមកកាន់តុលាការដោយរថយន្តក្រុងពីភូមិរបស់គេតាំងពីព្រលឹម ហើយត្រឡប់ទៅវិញនៅពេលរសៀល ។ អ្នកដែលអញ្ជើញមកពីខេត្តកំពង់ធំបានរាយការណ៍ថា នៅល្ងាចថ្ងៃព្រហស្បតិ៍ អង្គភាពកិច្ចការសាធារណៈបានបញ្ចាំងវីដេអូមួយនៅសាលារៀនរបស់គេដើម្បីណែនាំពួកគេអំពីដំណើរការនិតិវិធីរបស់តុលាការ ។ បទសម្ភាសន៍បានបង្ហាញថា ខណៈដែលអ្នកទាំងនោះពេញចិត្តនឹងការជួយនេះ អ្នកដែលត្រូវបានអញ្ជើញទាំងនេះភាគច្រើនយល់ថា តារាងកាលវិភាគដែលបានរៀបចំសម្រាប់គាត់មានការពិបាកខ្លាំងណាស់ ។ ទីរួមខេត្តកំពង់ធំនិងខេត្តសៀមរាបស្ថិតមានចម្ងាយ១៦២គីឡូម៉ែត្រ និង ៣២១ គីឡូម៉ែត្រពីភាគខាងជើងទីក្រុងភ្នំពេញ ។ នៅថ្ងៃព្រហស្បតិ៍ អ្នកដែលចូលរួមមកពីខេត្តសៀមរាបបានរាយការណ៍ថា ពួកគេបានចេញមកកាន់ទីក្រុងភ្នំពេញនៅម៉ោង៣ព្រឹក រួចមកដល់បន្ទប់សវនាការយឺត ហើយចេញទៅខេត្តសៀមរាបវិញបន្ទាប់ពីហូបអាហារថ្ងៃត្រង់រួច ។

នៅថ្ងៃសុក្រ អ្នកចូលរួមមកពីខេត្តកំពង់ធំបានរាយការណ៍ថា ពួកគេបានចេញមកកាន់ទីក្រុងភ្នំពេញនៅម៉ោង៥ព្រឹក ហើយមិនបានផ្តល់នូវអាហារអ្វីទាំងអស់រហូតដល់ពេលអាហារថ្ងៃត្រង់ ។ អ្នកចូលរួមភាគច្រើនត្អូញត្អែររឿងអស់កម្លាំងដោយសារតែគេងមិនបានគ្រប់គ្រាន់និងឃ្លាន ។ ចាន់ ស្រី ភុំ អាយុ២២ឆ្នាំ ជាគ្រូហ៊ឹកហ៊ឺនមកពីខេត្តកំពង់ធំបានប្រាប់អ្នកធ្វើសម្ភាសន៍ថា គាត់បានភ្ញាក់តាំងពីម៉ោងពីរព្រឹក ហើយមានអារម្មណ៍ថាវិលមុខ ។ អង្គភាពកិច្ចការសាធារណៈបានបដិសេធមិនបកស្រាយ ។

### ៨) ការរំពឹងទុកពីការអភិវឌ្ឍន៍នាពេលអនាគត

នៅក្នុងសេចក្តីបញ្ចប់របស់សវនាការ លោកប្រធាន ប្រាក់ គឹមសាន បានប្រាប់ទៅដល់សាធារណជនថា អង្គជំនុំជម្រះនឹងប្រកាសកាលបរិច្ឆេទនៃការអានសេចក្តីសម្រេចចិត្តពីរថ្ងៃមុន ។ ការអនុវត្តពីអតីតកាលបានបង្ហាញថា អង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំណាយរយៈពេលបីទៅប្រាំខែដើម្បីដោះស្រាយការសម្រេចចិត្តលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការឃុំឃាំងបណ្តោះអាសន្ន និងបន្តដីកានេះទោះបីជានៅពេលនេះប្រហែលត្រូវកាត់បន្ថយ ប៉ុន្តែតុលាការបានប្រកាសនៅចុងខែកុម្ភៈ ឆ្នាំ២០១០ថា អង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងធ្វើការយ៉ាងមមាញឹក ។

ក្រឡេកមើលទៅខាងមុខវិញ វិធានផ្ទៃក្នុងបានចែងថា សហចៅក្រមស៊ើបអង្កេតមិនអាចចេញដីកាច្រើនជាងពីរដងក្នុងការបន្តការឃុំឃាំងបណ្តោះអាសន្នសម្រាប់ការឃុំខ្លួនរយៈពេលសរុបបីឆ្នាំនៅដំណាក់កាលអង្គបុរេជំនុំជម្រះសម្រាប់ការដាក់បន្ទុកបុគ្គលម្នាក់ៗជាមួយនឹងឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ (វិធាន៦៣(៦)(៧)) ។ ពេលនេះ វាបានកន្លងហួសដល់ខែតុលា ឆ្នាំ២០១០ សម្រាប់ករណី នួន ជា ហើយខែវិច្ឆិកា ឆ្នាំ២០១០ សម្រាប់ករណី

អៀង សារី, អៀង ធីរិទ្ធ, និង ខៀវ សំផន។ ដូច្នេះ ទោះបីជាអង្គបុរេជំនុំជម្រះការពារដីការបស់សហចៅក្រមស៊ើបអង្កេតក្នុងការបន្តការឃុំឃាំងបណ្តោះអាសន្នក៏ដោយ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតមិនអាចចេញដីកាពន្យារពេលតទៅទៀតនៅឆ្នាំនេះទេ ហើយត្រូវតែដោះលែងជនត្រូវចោទ។ ទោះបីជាសហចៅក្រមស៊ើបអង្កេតទទួលបានជោគជ័យក្នុងការចេញដីកាដំណោះស្រាយមុនខួបលើកទីបីក្នុងការឃុំឃាំងអ្នកទាំងនោះក៏ដោយ ក៏ពួកគេមានអំណាចក្នុងការបញ្ជាដោយធ្វើការសម្រេចចិត្តសមហេតុផលក្នុងការបន្តការឃុំឃាំងបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយដែរ (វិធាន៦៨(១)) ។





វិធានផ្ទៃក្នុងបានកំណត់ថ្ងៃផុតកំណត់យ៉ាងតឹងរ៉ឹងបំផុតសម្រាប់បូកសរុបដំណាក់កាលអង្គបុរេជំនុំជម្រះ ប្រសិនបើជនត្រូវចោទនៅតែស្ថិតនៅក្រោមការឃុំឃាំងបណ្តោះអាសន្ន។ ដោយសារ នួន ជា ត្រូវបានជាប់ឃុំឃាំងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាដំណោះស្រាយនៅត្រឹមថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០ ឬក៏បញ្ជាឲ្យដោះលែងគាត់។ ទាំងនេះទំនងជាបកស្រាយពីសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតដែលពួកគេនឹងចេញដីកាដំណោះស្រាយនៅត្រឹមខែតុលា ឆ្នាំ២០១០ ។ ជាងនេះទៅទៀត ប្រសិនបើដីកាដំណោះស្រាយនៅតែបន្តតាមរយៈសវនាការ ជនត្រូវចោទត្រូវតែនាំខ្លួនមុនអង្គជំនុំជម្រះនៅក្នុងរយៈពេលបួនខែនៃការសម្រេចចិត្តបន្តការឃុំឃាំងបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ (វិធាន៦៨(៣)) ។

**សារ៉ា ថូម៉ាស**



អ្នកភូមិមកពីខេត្តបន្ទាយមានជ័យ



អ្នកភូមិមកពីខេត្តបន្ទាយមានជ័យ

# ការដាក់ឱ្យមានការទទួលខុសត្រូវចំពោះភាពអត់ឃ្លាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល និង "សកម្មភាពអមនុស្សធម៌ផ្សេងទៀត"

## ១) សេចក្តីផ្តើម

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដើម្បីកាត់ទោស «មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម» និង «អ្នកទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មក្នុងស្រុកនិងអន្តរជាតិដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាពីឆ្នាំ១៩៧៥-១៩៧៩ ។ ប្រជាជនកម្ពុជារាប់សែននាក់បានជួបប្រទះនូវភាពអត់ឃ្លានយ៉ាងធ្ងន់ធ្ងរបំផុតនៅអំឡុងសតវត្សរ៍២០នេះ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចង់បំពេញតួនាទីរបស់ខ្លួន អង្គជំនុំជម្រះចាំបាច់ត្រូវតែដោះស្រាយនូវភាពឈឺចាប់ដោយភាពស្រេកឃ្លាន ។

ការកាត់ទោសពីការបង្អត់អាហារនៅអង្គជំនុំជម្រះវិសាមញ្ញមានភាពស្មុគស្មាញពីព្រោះមិនមានបទល្មើសជាតិឬអន្តរជាតិរួមបញ្ចូលភាពឈឺចាប់របស់ជនរងគ្រោះដែលទទួលការបង្អត់អាហារទេ ។ ខណៈពេលដែលមិនមានការចែងអំពីបទល្មើសបង្អត់អាហារ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមប្រហែលជាត្រូវបានរំពឹងទុកថានឹងរួមបញ្ចូលការបង្អត់អាហារចំពោះករណីជាក់លាក់ខ្លះ ។

អត្ថបទដែលជាផ្នែកធំមួយនៃគម្រោងដែលកំពុងដំណើរការនៅក្នុងផ្នែកបទល្មើសព្រហ្មទណ្ឌអន្តរជាតិទាក់ទងនឹងការបង្អត់អាហារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះផ្តោតទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលជាឧក្រិដ្ឋកម្មមួយស័ក្តិសមបំផុតសម្រាប់យកមកដោះស្រាយការបង្អត់អាហារនៅកម្ពុជាពីឆ្នាំ១៩៧៥-១៩៧៩ ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានឥទ្ធិពលទៅលើស្ថានភាពដែលសកម្មភាពឧក្រិដ្ឋកម្មបង្កើតជាការវាយប្រហារជាប្រព័ន្ធនិងនៅគ្រប់ទីកន្លែងដើម្បីប្រឆាំងនឹងប្រជាជនស៊ីវិល ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់មួយចំនួនដែលនឹងយកមកបង្ហាញនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅក្នុងបរិបទការបង្អត់អាហាររួមមាន ៖ ការសម្លាប់ផុតពូជ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» និងការធ្វើទុក្ខបុកម្នេញ ។

ការសម្លាប់ផុតពូជមានជាប់ពាក់ព័ន្ធនឹងសកម្មភាពឬអ្វីដែលមិនបានរួមបញ្ចូលបណ្តាលឲ្យមានការសម្លាប់រង្គាល ហើយវានឹងត្រូវយកបង្ហាញប្រសិនបើមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យបានអនុវត្តគោលនយោបាយសង្គមដែលបណ្តាលឲ្យមានការបង្អត់អាហារហើយបណ្តាលឲ្យមានការស្លាប់ជាច្រើន ។ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» គឺជាសកម្មភាពទាំងឡាយដែលមិនស្ថិតនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនៅក្នុងច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប៉ុន្តែមានលក្ខណៈធ្ងន់ធ្ងរដូចគ្នា ។ សកម្មភាពទាំងនោះអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការធ្វើឲ្យមានជំងឺផ្លូវចិត្តនិងរបួសលើរូបរាងកាយដែលកើតមានជាបណ្តោះអាសន្ននិងយូរអង្វែងបណ្តាលមកពីការបង្អត់អាហារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការធ្វើទុក្ខបុកម្នេញគឺជាការមិនទទួលស្គាល់សិទ្ធិមូលដ្ឋានរបស់សមាជិកនៃក្រុមដែលទទួលការការពារ ។ សកម្មភាពឧក្រិដ្ឋកម្មដូចគ្នាប្រហែលជាអាចបង្កើតឲ្យមានទាំងការធ្វើទុក្ខបុកម្នេញនិង «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» ។ ប៉ុន្តែជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញត្រូវតែជាគោលដៅដែលគេធ្វើបាបដោយមូលហេតុ «នយោបាយ ពូជសាសន៍ ឬសាសនា» ។ ការធ្វើទុក្ខបុកម្នេញនឹងត្រូវបានលើកឡើងនៅក្នុងករណីដែលមេដឹកនាំជាន់ខ្ពស់របបកម្ពុជាប្រជាធិបតេយ្យមានចេតនាបង្អត់អាហារក្រុមនយោបាយ ពូជសាសន៍ឬសាសនាដែលខ្លួនមិនពេញចិត្តដែលបណ្តាលឲ្យសមាជិកនៃក្រុមនោះមានការឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត ។

ដោយរួមបញ្ចូលគ្នា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងបីនេះអាចផ្តល់ជារូបភាពនៃការឈឺចាប់បណ្តាលមកពីការបង្អត់

អាហារនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនិងដាក់ឲ្យមានការទទួលខុសត្រូវ ។ ការសម្លាប់ផុតពូជអាចត្រូវយកមកចោទប្រកាន់ចំពោះការស្លាប់ជាច្រើនដែលបណ្តាលមកពីការបង្អត់អាហារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ «សកម្មភាពប្រឆាំងមនុស្សជាតិផ្សេងទៀត» អាចត្រូវដាក់ឲ្យទទួលខុសត្រូវនៅក្រោមទម្រង់នៃការឈឺចាប់ជាច្រើនជាជាងការស្លាប់ដែលមានជាប់ពាក់ព័ន្ធនឹងការបង្អត់អាហារដែលប្រជាជនកម្ពុជាជួបប្រទះនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាទីបញ្ចប់ ការធ្វើទុកបុកម្នេញអាចត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះការបង្អត់អាហារយ៉ាងធ្ងន់ធ្ងរទៅលើសមាជិកនៃក្រុមនយោបាយដែលខ្លួនមិនពេញចិត្ត ដូចជាប្រជាជន «ថ្មី» ដែលទទួលបានអាហារតិចបំផុតនិងត្រូវបានបង្ខំឲ្យធ្វើការធ្ងន់ ។ អាស្រ័យហេតុនេះ ឧក្រិដ្ឋកម្មនីមួយៗនឹងត្រូវយកមកវិភាគ ។

### ២) បទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានជាប់ពាក់ព័ន្ធនឹងការបង្អត់អាហារ

ដូចដែលបានរៀបរាប់ខាងលើ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ដែលយកមកចោទប្រកាន់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែបង្កើតជាទម្រង់នៃការវាយប្រហារជាប្រព័ន្ធឬនៅគ្រប់ទីកន្លែងទៅលើប្រជាជនស៊ីវិល ។ នៅពេលដែលមានការបង្កើតថាការវាយប្រហារបែបនោះធ្លាប់បានកើតមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនីមួយៗដែលនឹងពិភាក្សានៅខាងក្រោមត្រូវតែបង្ហាញថាមានការវាយប្រហារ ។

#### ២.១) ការសម្លាប់ផុតពូជ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់ផុតពូជមានជាប់ពាក់ព័ន្ធនឹងការសម្លាប់ជាទ្រង់ទ្រាយធំ ។ ជនរងគ្រោះដែលត្រូវបានសម្លាប់ផុតពូជមិនចាំបាច់មាន «ជាតិសាសន៍ ជាតិពន្ធុពូជសាសន៍ ឬ សាសនាដូចគ្នាទេ» ។ អំពើពិរុទ្ធនៃសកម្មភាពសម្លាប់ផុតពូជគឺជា «សកម្មភាពសម្លាប់ជាទ្រង់ទ្រាយធំ» និងរួមទាំងការដាក់ឲ្យប្រជាជនមួយចំនួនស្ថិតនៅក្រោមស្ថានភាពរស់នៅដែលបណ្តាលមានការស្លាប់» ។ សេចក្តីសម្រេចថ្មីៗរបស់សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសម្រេចថា អំពើពិរុទ្ធនៃសកម្មភាពសម្លាប់ផុតពូជបានរួមបញ្ចូល «សកម្មភាពអ្វីដែលមិនបានរួមបញ្ចូលឬការរួមបញ្ចូលទាំងឡាយណាដែលបណ្តាលឲ្យមានការសម្លាប់ប្រជាជនជាច្រើនដោយផ្ទាល់និងមិនផ្ទាល់» ។ ជាងនេះទៅទៀត បទល្មើសសម្លាប់ផុតពូជស័ក្តិសមនឹងយកមកចោទប្រកាន់អ្នកដែល «មានអំណាចឬមានឥទ្ធិពលក្នុងការសម្លាប់មនុស្សជាច្រើន» ។

បំណងពិរុទ្ធដែលតម្រូវឲ្យមាននៅក្នុងឧក្រិដ្ឋកម្មសម្លាប់ផុតពូជគឺ «ជនត្រូវចោទមានចេតនាសម្លាប់ជាទ្រង់ទ្រាយធំ ឬដាក់ឲ្យប្រជាជនស្ថិតនៅក្នុងស្ថានភាពរស់នៅដែលអាចឈានទៅដល់ការស្លាប់ជាប្រព័ន្ធនិងនៅគ្រប់ទីកន្លែង» ។ មានការមិនយល់ស្របគ្នានៅតុលាការថាតើបទដ្ឋាននៃបំណងពិរុទ្ធមានរួមបញ្ចូលបទល្មើសដែលបណ្តាលមកពីការធ្វេសប្រហែសយ៉ាងធ្ងន់ធ្ងរ ឬការធ្វេសប្រហែសដែលបណ្តាលឲ្យមានទោសព្រហ្មទណ្ឌដែរឬទេ ។ យុត្តិសាស្ត្រថ្មីៗទាក់ទងនឹងករណីនេះបានបង្ហាញថាការប្រព្រឹត្តមិនគិតពីលទ្ធផលគឺជាបំណងពិរុទ្ធទម្រង់តូចបំផុតដែលព្រះរាជអាជ្ញាត្រូវតែធ្វើការអះអាង ។

#### ២.១.១) ការសម្លាប់ផុតពូជមិនចាំបាច់ត្រូវតែប្រព្រឹត្តដោយហិង្សាទេ

អំពើពិរុទ្ធនៃការសម្លាប់ផុតពូជរាប់បញ្ចូលទាំងខណៈពេលនៃការសម្លាប់ផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ការសម្លាប់ផុតពូជអាចជាការប្រព្រឹត្តដោយផ្ទាល់ដោយបង្កើតឲ្យមានស្ថានភាពរស់នៅដែលធ្វើឲ្យប្រជាជនស៊ីវិលស្លាប់ដូចជាការមិនទទួលស្គាល់ភាពចាំបាច់នៃអាហារជាដើម ។ ជាឧទាហរណ៍ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងថា ការសម្លាប់ផុតពូជ «រួមបញ្ចូលទាំងការធ្វើឲ្យស្ថានភាពរស់នៅមានភាពលំបាក ដូចជាការមិនផ្តល់អាហារនិងថ្នាំពេទ្យដែលបណ្តាលឲ្យមានភាពវិនាសអន្តរាយដល់ប្រជាជនមួយចំនួន» ។ ឧទាហរណ៍មួយនៃសកម្មភាពឧក្រិដ្ឋកម្មសម្លាប់ផុតពូជដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានចែងគឺ «ការឃុំឃាំងប្រជាជនជាច្រើននិងការដកហូតរបស់សំខាន់សម្រាប់ជីវិតដែលបណ្តាលឲ្យមានការស្លាប់ជាច្រើន» ។

#### ២.១.២) ចំណុចត្រូវពិចារណាដំបូង

ការស្លាប់ «ជាច្រើន» គឺជាចំណុចសំខាន់នៃការសម្លាប់ផុត

ពូជដែលមានលក្ខណៈខុសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់ ។ ជនរងគ្រោះមិនអាចបង្កើតជាចំណុចសំខាន់សម្រាប់ចំណុចត្រូវពិចារណាទេ ។ ប៉ុន្តែ ការកំណត់ទៅលើករណីនីមួយៗមានជាប់ពាក់ព័ន្ធនឹងការវិភាគយ៉ាងហ្មត់ចត់ទៅលើកត្តាដែលមានជាប់ពាក់ព័ន្ធ វារួមមាន «ពេលវេលា និងទីកន្លែងនៃការសម្លាប់ជនរងគ្រោះដែលត្រូវបានជ្រើសរើសនិងចរិតលក្ខណៈដែលនាំឲ្យអ្នកទាំងនោះក្លាយជាគោលដៅនៃការសម្លាប់» ។ ទោះបីជាយ៉ាងណាក៏ដោយ ជនរងគ្រោះម្នាក់ៗមិនចាំបាច់បង្ហាញឈ្មោះដូចដែលជនត្រូវចោទមិនចាំបាច់មានឈ្មោះជនរងគ្រោះជាក់លាក់នៅអំឡុងពេលធ្វើបេសកកម្មឧក្រិដ្ឋកម្មទេ ។ ជាងនេះទៅទៀត ការស្លាប់ដោយសារព្រឹត្តិការណ៍សម្លាប់ផ្សេងៗពីគ្នាអាចត្រូវបានរួមបញ្ចូលគ្នាដើម្បីបង្កើតជាចំណុចត្រូវពិចារណាដំបូង ។

## ២.១.៣) ការសម្លាប់ផុតពូជដោយការបង្អត់អាហារ

វាទំនងជាមានមូលដ្ឋានដ៏រឹងមាំមួយ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការចោទប្រកាន់អំពីការសម្លាប់ផុតពូជដោយប្រើប្រាស់ការបង្អត់អាហារ ។ មេដឹកនាំរបបខ្មែរក្រហមបានរៀបផែនការនិងអនុវត្តប្រព័ន្ធនៃការបង្ខំឲ្យធ្វើការធ្ងន់និងឲ្យរស់នៅជាសហករណ៍នៅទូទាំងប្រទេសកម្ពុជាពីឆ្នាំ ១៩៧៥-១៩៧៩ ។ គោលនយោបាយរបស់ខ្មែរក្រហមបានហាមប្រាមមិនឲ្យប្រជាជនដើររកអាហារនិងដាំដំណាំឡើយ ។ ការហូបជាបុគ្គលត្រូវបានហាមប្រាម ហើយអ្នកដែលរំលោភទៅលើបំរាមនេះត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ដល់ជីវិត ។ ច្បាប់ដ៏តឹងរ៉ឹងនេះបានធ្វើប្រជាជនកម្ពុជាទាំងអស់ពឹងផ្អែកទៅលើរបបអាហាររបស់សហករណ៍ដែលផ្តល់ដោយរដ្ឋាភិបាលរបបកម្ពុជាប្រជាធិបតេយ្យ ។ របបអាហារទាំងនេះមិនគ្រប់គ្រាន់សម្រាប់ប្រជាជនទេ វាខ្វះទាំងកាឡូរីនិងអាហារូបត្ថម្ភជាមូលដ្ឋាន ពីព្រោះវាមានតែបបរពីរវែកក្នុងមួយថ្ងៃប៉ុណ្ណោះ ។ របបអាហារទាំងនេះកាន់តែមិនគ្រប់គ្រាន់សម្រាប់ប្រជាជនដែលត្រូវបង្ខំឲ្យធ្វើការយូរជារៀងរាល់ថ្ងៃ ។ លើសពីនេះទៅទៀត ការខ្វះថ្នាំ រចនាសម្ព័ន្ធគ្រប់គ្រងឬអ្នកធ្វើការដែលមានសមត្ថភាពបានបង្កើនចំនួនមនុស្សស្លាប់ដែលខ្វះអាហារនៅទូទាំងប្រទេស ។ មានការអះអាងថាស្ថានភាពទាំងនេះបង្កើតឡើងដោយមេដឹកនាំខ្មែរក្រហមដែលប្រើប្រាស់អំណាចដាច់ខាតរបស់ខ្លួនដែលណ្តាលឲ្យមានការបង្អត់អាហារជាច្រើន ។

អំពើពិរុទ្ធនៃការសម្លាប់ផុតពូជដោយបង្អត់អាហាររួមមានការបង្កើតផែនការនិងការអនុវត្តប្រព័ន្ធផ្លាស់ប្តូរសង្គមដែលធ្វើឲ្យប្រជាជនស៊ីវិលស្ថិតនៅក្រោមស្ថានភាពរស់នៅដែលអាចបណ្តាលឲ្យមានការស្លាប់ដោយភាពស្រេកឃ្លាន ។ ទោះបីជាការអនុវត្តនិងការបង្ខំឲ្យអនុវត្តផែនការនេះមានជាប់ពាក់ព័ន្ធនឹងសកម្មភាពនៃការប្រើអំពើហិង្សាយ៉ាងព្រៃផ្សៃនិងការសម្លាប់ក៏ដោយ ក៏ផែនការនេះមិនចាំបាច់មានជាប់ពាក់ព័ន្ធនឹងអំពើហិង្សាដូចដែលបានពិភាក្សាខាងលើទេ ។ ទាំងយុទ្ធនាការសម្លាប់ផុតពូជជាទូទៅទៅលើប្រជាជនកម្ពុជានិងព្រឹត្តិការណ៍សម្លាប់ផុតពូជតូចមួយនៅក្នុងតំបន់ឬ ភូមិភាគជាក់លាក់ណាមួយសុទ្ធតែអាចយកមកចោទប្រកាន់បានទាំងអស់ ។ ដោយមិនគិតពីដែនកំណត់នៃបទល្មើសហេតុការណ៍សម្លាប់ផុតពូជដែលត្រូវបានចោទប្រកាន់មានចំណុចជាច្រើនលើសពីចំណុចត្រូវពិចារណាទៅទៀតពីព្រោះប្រជាជនកម្ពុជារាប់សែននាក់បានស្លាប់ដោយការបង្អត់អាហារពីឆ្នាំ១៩៧៥-១៩៧៩ ។

ចំណុចដែលលំបាកក្នុងការចោទប្រកាន់ពីការសម្លាប់ផុតពូជដោយប្រើការបង្អត់អាហារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺបង្កើតថាជនត្រូវចោទមានបំណងពិរុទ្ធដោយមិនគិតដល់លទ្ធផល ។ ការស្រាវជ្រាវពីមុនបានបង្ហាញថា ប្រហែលជាមិនមានឯកសារឬសេចក្តីថ្លែងការណ៍ជាផ្លូវការបង្ហាញថាសមាជិកមេដឹកនាំខ្មែរក្រហមដឹងពីការបង្អត់អាហារនៅជុំវិញខ្លួនទេ ។ អាស្រ័យហេតុនេះ ជនត្រូវចោទប្រហែលជាអាចអះអាងថាខ្លួនមានការធ្វេសប្រហែសទៅលើគោលនយោបាយសង្គម ។ ដើម្បីយកឈ្នះទៅលើបញ្ហានេះ ព្រះរាជអាជ្ញាត្រូវតែបង្ហាញយ៉ាងច្បាស់លាស់ថាការមិនដឹងពីការបង្អត់អាហារគឺដោយសារតែការមិនអើពើរបស់ជនត្រូវចោទមិនមែនដោយសារតែមិនដឹងពីព័ត៌មាននោះទេ ។ ការពិនិត្យទៅលើឯកសារដើមនិងបន្ទាប់ដែលកើតឡើងនៅពេលជាមួយគ្នាបានបង្ហាញថា ព្រះរាជអាជ្ញាអាចបំពេញការងារនេះបាន ។ ការស្រាវជ្រាវយ៉ាងល្អិតល្អន់ប្រហែលជាអាចបង្ហាញថាមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យដឹងពីកង្វះអាហារយ៉ាងធ្ងន់ធ្ងរដែលកើតឡើងនៅទូទាំងប្រទេសកម្ពុជា ប៉ុន្តែ

មេដឹកនាំទាំងនោះមិនអើពើនឹងរឿងនោះឡើយ ។ ប្រសិនបើមានការបង្កើតថាវាបណ្ដាលមកពីការធ្វេសប្រហែស នោះអាចនឹងមានការចោទប្រកាន់ការសម្លាប់ផុតពូជដោយការបង្អត់អាហារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ២.២) «*សកម្មភាពអមនុស្សធម៌ផ្សេងទៀត*»

មាត្រា៥ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារួមមានបទបញ្ញត្តិដែលផ្ដល់យុត្តាធិការទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» ។ ការមិនកំណត់ភាពច្បាស់លាស់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» គឺជាចេតនា ការតាក់តែងនេះដើម្បីបត់បែនតាមមនុស្សដែលប្រើប្រាស់វិធីសាស្ត្រថ្មីសម្រាប់រំលោភបំពានលើអ្នកដទៃ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានអះអាងថា ប្រសិនបើសកម្មភាពមួយត្រូវចាត់ទុកថាជាអំពើ «អមនុស្សធម៌» សកម្មភាពនោះត្រូវតែមាន «ភាពធ្ងន់ធ្ងរស្រដៀងគ្នា» នឹងសកម្មភាពដទៃដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ លើសពីនេះទៅទៀត សកម្មភាពអមនុស្សធម៌ផ្សេងទៀតត្រូវតែមានការអះអាងបញ្ជាក់ជាជាងគ្រាន់តែបង្ហាញពីការមិនយកចិត្តទុកដាក់ទៅលើប្រជាជនស៊ីវិល ។ ជនដែលដល់ដែលប្រព្រឹត្ត «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» ត្រូវតែមានបំណងពិរុទ្ធដោយមិនគិតពីលទ្ធផលនៅពេលដែលប្រព្រឹត្តសកម្មភាពអមនុស្សធម៌ជាក់លាក់ណាមួយដែលត្រូវបានចោទប្រកាន់ទេ ។

### ២.២.១) និយមន័យនៃពាក្យ «*ភាពធ្ងន់ធ្ងរស្រដៀងគ្នា*»

ធាតុផ្សំសំខាន់នៃ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» គឺសកម្មភាពបែបនោះត្រូវតែមានភាពធ្ងន់ធ្ងរស្រដៀងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងគណៈកម្មការច្បាប់អន្តរជាតិបានអះអាងថា សកម្មភាពធ្ងន់ធ្ងរគឺជាសកម្មភាពដែលបង្ករបួសដល់ជនរងគ្រោះ ទាំងផ្លូវចិត្តឬរូបរាងកាយ និងកិត្តិយសឬសុខភាព» ។ ស្រដៀងគ្នានេះដែរ លក្ខន្តិកៈក្រុងរ៉ូមបានចែងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺ «ជាសកម្មភាពដែលបង្កការឈឺចាប់ ឬរបួសដល់រូបរាងកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរដោយចេតនា» ។

### ២.២.២) ឧទាហរណ៍នៃករណី «*សកម្មភាពអមនុស្សធម៌ផ្សេងទៀត*»

ជនត្រូវចោទត្រូវរកឃើញថាជាប់ទោសពីបទប្រព្រឹត្ត «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» កាលណាជននោះប្រព្រឹត្តសកម្មភាពសាហាវឃោរឃៅប្រឆាំងនឹងប្រជាជនស៊ីវិល ។ ឧទាហរណ៍ទាំងនោះរួមមាន ៖ ការសម្លាប់ដោយមានការប៉ុនប៉ងទុកមុន ការជម្លៀសដោយបង្ខំ «ការឃុំឃាំងដោយមិនមានអាហារទឹក ឬសម្ភារៈអនាម័យ» លើសពី៥ថ្ងៃ ការធ្វើបាបទៅលើអ្នកទោសដោយបង្ករបួសស្នាមដល់អ្នកទោសនោះ «ការវាយធ្វើបាប ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ការប្រមាថមើលងាយ ការបៀតបៀន ការប្រើអំពើហិង្សាលើរូបរាងកាយ និងការដាក់ឲ្យអ្នកទោសស្ថិតនៅក្រោមស្ថានភាពឈឺចាប់» «ការប្រើប្រាស់មនុស្សជាចំណាប់ខ្មាំង» ការបង្ខំឲ្យរៀបការ ការរំលោភផ្លូវភេទនិងរូបរាងកាយទៅលើសាកសព របួសដែលកើតឡើងនៅអំឡុងពេលបង្ខំឲ្យធ្វើការ និងការវាយប្រហារទៅលើរូបរាងកាយដែលបណ្ដាលឲ្យមានរបួស ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានអះអាងថា «ការបង្ខំឲ្យមានការជួញដូរផ្លូវភេទ» និង «ការធ្វើឲ្យមានការបាត់ខ្លួន» ត្រូវបានសន្មតថាជា «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» ។

### ២.២.៣) *ភាពស្រេកឃ្លានយ៉ាងធ្ងន់ធ្ងរជាសកម្មភាពអមនុស្សធម៌*

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» ធ្វើឲ្យមេដឹកនាំខ្មែរក្រហមដែលជាអ្នករៀបចំផែនការ និងអនុវត្តគោលនយោបាយសង្គមដែលបណ្ដាលឲ្យមានភាពស្រេកឃ្លាននៅទូទាំងប្រទេសមានពិរុទ្ធភាព ។ ការវិភាគជាច្រើនទាក់ទងនឹងបំណងពិរុទ្ធនិងអំពើពិរុទ្ធនៃ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» អាចនឹងដូចគ្នាទៅនឹងសកម្មភាពសម្លាប់ផុតពូជដែលបានពិភាក្សានៅចំណុចខាងលើ ។ ភាពខុសគ្នារវាងបទល្មើសទាំងពីរនេះពឹងផ្អែកជាខ្លាំងទៅលើការខូចខាតនិងប្រភេទនៃជនរងគ្រោះ ។ ការចោទប្រកាន់ពីបទប្រព្រឹត្ត «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» ត្រូវបានរំពឹងទុកថានឹងរួមបញ្ចូលជាមួយការឈឺចាប់ដែលបណ្ដាលមកពីការបង្អត់អាហារនិងកង្វះអាហារូបត្ថម្ភនៅក្នុង

របបកម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឲ្យមានភាពធ្ងន់ធ្ងរដូចនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ។ ជនរងគ្រោះដែលខ្វះអាហារូបត្ថម្ភរយៈពេលយូរអាចនឹងមានរោគសញ្ញាឈឺចាប់និងមានបញ្ហាសុខភាព ជាពិសេសក្មេងដែលកើតនៅពេលម្តាយមានសុខភាពខ្សោយដែលបណ្តាលមកពីកង្វះអាហារ ។ លើសពីនេះទៅទៀត ជនរងគ្រោះដែលធ្លាប់ទទួលការបង្អត់អាហារតែងតែមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ។ ជាទីបញ្ចប់ ការដាក់ឲ្យជនរងគ្រោះស្ថិតនៅក្រោមស្ថានភាពស្រេកឃ្លានគឺជាការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ អាស្រ័យហេតុនេះ មិនត្រឹមតែអ្នកដែលបានស្លាប់ដោយការបង្អត់អាហារឬដោយការសម្លាប់ផុតពូជទេ អ្នកដែលនៅរស់ក៏ជាជនរងគ្រោះនៃ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» ដែលស្ថិតនៅក្នុងបរិបទនៃការបង្អត់អាហារដែរ ។

ខណៈពេលសហព្រះរាជអាជ្ញាមិនអាចចោទប្រកាន់ទៅលើភាពមិនត្រឹមត្រូវចំពោះប្រជាជនស៊ីវិល គោលនយោបាយជាក់លាក់មួយចំនួនរបស់ខ្មែរក្រហមអាចត្រូវបានចាត់ទុកថាជា «ភាពអមនុស្សធម៌» ។ ជាងនេះទៅទៀត ការពិនិត្យយ៉ាងច្បាស់លាស់ទៅលើរបាយការណ៍របស់អ្នកនៅរស់បានបង្ហាញយ៉ាងច្បាស់ថាប្រជាជនកម្ពុជាស្ទើតែទាំងអស់ធ្លាប់បានជួបប្រទះស្ថានភាពអមនុស្សធម៌នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកនៅរស់រាប់ពាន់ ឬរាប់លាននាក់អាចអះអាងពីភាពស្រេកឃ្លាននិងភាពខ្វះខាតនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណុចសំខាន់ដែលធ្វើឲ្យការចោទប្រកាន់ទទួលបានជោគជ័យគឺមិនមែនបង្កើតថាស្ថានភាពរស់នៅមិនល្អទេ ជាពិសេសកង្វះអាហារគឺត្រូវបង្កើតថាជនត្រូវចោទមានបំណងពិរុទ្ធដោយមិនគិតទៅលើលទ្ធផលទេ ។

## ២.៣) ការធ្វើទុក្ខបុកម្នេញ

ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានរួមបញ្ចូលក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុង «ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ជាតិសាសន៍ ឬសាសនា» ។ នៅក្រោមលក្ខន្តិកៈទីក្រុងរ៉ូម ការធ្វើទុក្ខបុកម្នេញគឺជា «ការដកហូតសិទ្ធិមូលដ្ឋានយ៉ាងធ្ងន់ធ្ងរនិងដោយចេតនាដែលផ្ទុយពីច្បាប់អន្តរជាតិដោយសារតែអត្តសញ្ញាណរបស់ក្រុមនិងរួមគ្នា» ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានអនុម័តនូវនិយមន័យស្រដៀងគ្នាថា «បទល្មើសនៃការធ្វើទុក្ខបុកម្នេញរួមមានសកម្មភាពដែលមិនទទួលស្គាល់ឬរំលោភលើច្បាប់មូលដ្ឋានដែលមានចែងនៅក្នុងទំនៀមទម្លាប់អន្តរជាតិឬច្បាប់អនុសញ្ញាអំពើពិរុទ្ធ ។ ហើយមានការប្រព្រឹត្តបទល្មើសនេះដោយចេតនាដោយមូលហេតុ ជាតិសាសន៍ សាសនា ឬនយោបាយបំណងពិរុទ្ធ ។

### ២.៣.១) ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិជាមូលដ្ឋាន

អំពើពិរុទ្ធនៃការធ្វើទុក្ខបុកម្នេញទំនងជាត្រូវបានបង្កើតឡើងដើម្បីធ្វើឲ្យស្របតាមអ្វីដែលមានពីមុននៅអន្តរជាតិនិងតម្រូវឲ្យមានសកម្មភាពដែលរំលោភយ៉ាងធ្ងន់ធ្ងរទៅលើ «សិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងទំនៀមទម្លាប់អន្តរជាតិឬច្បាប់អនុសញ្ញា» ។ មានតែការមិនទទួលស្គាល់សិទ្ធិមូលដ្ឋានទេជាការធ្វើទុក្ខបុកម្នេញមានន័យវាជាអំពើដែលធ្ងន់ធ្ងរស្រដៀងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ។ អាស្រ័យហេតុនេះ អំពើពិរុទ្ធនៃការធ្វើទុក្ខបុកម្នេញអាចប្រៀបធៀបនឹង «អំពើអមនុស្សធម៌ផ្សេងទៀត» ដែលបានពិភាក្សានៅចំណុចខាងលើ ។ លើសពីនេះទៅទៀត អំពើធ្វើទុក្ខបុកម្នេញជាក់លាក់ត្រូវតែចាត់ទុកជា «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» ជាជាងការធ្វើបាបធម្មតា ។ អំពើរើសអើងផ្សេងទៀតដែលមិនមែនធ្វើឡើងដោយបុគ្គលត្រូវបានចាត់ទុកថាជាការធ្វើទុក្ខបុកម្នេញ ។

### ២.៣.២) ចេតនាធ្វើទុក្ខបុកម្នេញ និងក្រុមទទួលបានការការពារ

ចំណុចសំខាន់សម្រាប់ធ្វើការចោទប្រកាន់ទៅលើការធ្វើទុក្ខបុកម្នេញគឺត្រូវបង្កើតថាជនត្រូវចោទមាន «ចេតនាប្រព្រឹត្តនិងរើសអើងដោយហេតុផលនយោបាយ ជាតិសាសន៍ ឬសាសនា» ។ បំណងពិរុទ្ធដោយចេតនាជាចំណុចនៃការធ្វើទុក្ខបុកម្នេញខុសពីគេក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ អាស្រ័យហេតុនេះ ជនដៃដល់ដែលប្រព្រឹត្តការធ្វើទុក្ខបុកម្នេញត្រូវតែមានចេតនាធ្វើបាបយ៉ាងធ្ងន់ធ្ងរទៅលើសមាជិកក្រុម នយោបាយ ជាតិសាសន៍ ឬសាសនា ។

តាមនិយមន័យច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្រុមទទួលបានការការពារគឺជាក្រុម «នយោបាយ» ។ អង្គជំនុំជម្រះតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា

បានអះអាងថា «ហេតុផលនយោបាយមានរួមបញ្ចូលជំនឿនយោបាយរបស់បក្ស និងមនោគមន៍វិជ្ជា នយោបាយ»។ អត្តសញ្ញាណនយោបាយអាចត្រូវបានកំណត់ដោយជនដៃដល់នៃការធ្វើទុក្ខបុកម្នេញ ហើយក្នុងនោះប្រហែលជាមានជាតិពន្ធុ ឬចំណុចផ្សេងទៀត។ បន្ថែមពីលើនេះទៀត ជនត្រូវចោទនៅតែត្រូវទទួលខុសត្រូវចំពោះការធ្វើទុក្ខបុកម្នេញប្រសិនបើជននោះមានចេតនារើសអើង ប៉ុន្តែផ្អែកលើការសន្មតខុសទៅលើអត្តសញ្ញាណរបស់ជនរងគ្រោះ។

### ២.៣.៣) ការចោទប្រកាន់ការធ្វើទុក្ខបុកម្នេញដែលមានជាប់ពាក់ព័ន្ធនឹងការបង្អត់អាហារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ការចោទប្រកាន់ការធ្វើទុក្ខបុកម្នេញដោយការបង្អត់អាហារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវពឹងផ្អែកថាតើក្រុមដែលត្រូវធ្វើទុក្ខបុកម្នេញត្រូវបានគេកំណត់ដោយរបៀបណា។ វិធីសាស្ត្រមួយក្នុងការកំណត់បទល្មើសនៃការធ្វើទុក្ខបុកម្នេញត្រូវអះអាងថាក្រុមដែលទទួលការធ្វើទុក្ខបុកម្នេញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរួមមានអ្នកដែលត្រូវបានជម្លៀសដោយបង្ខំពីតំបន់ទីក្រុងទៅជនបទជាមួយប្រជាជនកម្ពុជាផ្សេងទៀតដែលត្រូវបានចាត់ទុកថាមានប្រវត្តិបដិវត្តន៍ «មិនបរិសុទ្ធ»។ បន្ទាប់ពីកំណត់ក្រុមនៃជនរងគ្រោះដែលទទួលបានការការពារសហព្រះរាជអាជ្ញាត្រូវតែបង្កើតថា សមាជិកនៃក្រុមនេះជាប្រជាជន «ថ្មី»ដែលត្រូវបានគេកំណត់គោលដៅដើម្បីធ្វើបាបដូចជាកាត់បន្ថយរបបអាហារដែលបណ្តាលឲ្យមានភាពអត់ឃ្លានជាខ្លាំង។ ការបង្ហាញពីការធ្វើបាបខុសគ្នាអាចយកមករួមបញ្ចូលជាមួយពាក្យស្លោកនិងការឃោសនារបស់ខ្មែរក្រហមដែលសំដៅលើប្រជាជន «ថ្មី» ក្នុងអត្ថន័យប្រមាថដើម្បីបង្ហាញពីចេតនារើសអើង។ ចំណុចសំខាន់ដើម្បីធ្វើការចោទប្រកាន់ឲ្យបានជោគជ័យគឺត្រូវពឹងផ្អែកទៅករណីបំណងពិរុទ្ធដែលជនត្រូវចោទប្រហែលជាអះអាងថារាល់ការឈឺចាប់ដោយភាពស្រេកឃ្លានគឺបណ្តាលមកពីផែនការទូទៅតែមួយដែលមិនមានបំណងសំដៅលើក្រុមណាមួយសម្រាប់រើសអើង។

### ៣) សេចក្តីសន្និដ្ឋាន

បទល្មើសមួយមិនអាចគ្របដណ្តប់ទៅលើការឈឺចាប់របស់ប្រជាជនកម្ពុជាដោយភាពស្រេកឃ្លាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានទេ។ ការរៀបរាប់តែមួយគត់ពីចំនួនប្រជាជនដែលត្រូវបានសម្លាប់ផុតពូជដោយការបង្អត់អាហារមិនបានគ្របដណ្តប់ទៅលើការឈឺចាប់ដែលកើតឡើងដោយសារគោលនយោបាយសង្គមដ៏តឹងរ៉ឹងរបស់ខ្មែរក្រហមឡើយ។ ប៉ុន្តែនៅពេលដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់ផុតពូជ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» និងការធ្វើទុក្ខបុកម្នេញត្រូវបានរួមបញ្ចូលគ្នា នោះនឹងមានការដាក់ឲ្យមានការទទួលខុសត្រូវដែលត្រឹមត្រូវជាងមុន។ ការឈឺចាប់ដោយភាពស្រេកឃ្លានរយៈពេលយូរគឺជាបទពិសោធន៍មួយដែលប្រជាជនកម្ពុជាស្ទើរតែទូទាំងប្រទេសធ្លាប់ជួបប្រទះ។ ដើម្បីដាក់ឲ្យមានការទទួលខុសត្រូវពេញលេញមួយនិងបង្កើតការកត់ត្រាប្រវត្តិសាស្ត្រឲ្យច្បាស់លាស់អំពីបទពិសោធន៍របស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥-១៩៧៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរតែដោះស្រាយពីការឈឺចាប់នេះ។ **រ៉ាន់ឌល ឌីហ្វាល់កូ**

## ឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមគេហទំព័រ

ដើម្បីឲ្យសាធារណជនទូទៅមានលទ្ធភាពក្នុងការតាមដានមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា គេហទំព័រ *www.cambodiatribunal.org* ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាច្បាប់នៃសាកលវិទ្យាល័យណតវេស្ទើន សហរដ្ឋអាមេរិក និងក្រោមសហប្រត្តិបត្តិការជាមួយ *Illinois Holocaust Museum and Educational* Center។ មុននិងផ្សព្វផ្សាយ គេហទំព័រនេះត្រូវបានត្រួតពិនិត្យដោយសាស្ត្រាចារ្យច្បាប់ *David Scheffer* អតីតឯកអគ្គរដ្ឋទូតគោចរណ៍របស់សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមកាលពីជំនាន់រដ្ឋការប្រធានាធិបតី ប៊ីល គ្លីនតុន និងលោកឆាំង យុ នាយក មជ្ឈមណ្ឌលឯកសារកម្ពុជា។

# ជិន ស៊ុំ : អតីតពេទ្យខ្មែរក្រហម

ជិន ស៊ុំ មានស្រុកកំណើតនៅភូមិ មឿងចារ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ សព្វថ្ងៃ ស៊ុំ មានមុខរបរធ្វើស្រែ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស៊ុំ មានអាយុ៩ឆ្នាំប៉ុណ្ណោះ ។ កាលពីកុមារភាព ស៊ុំ មិនដែលបានចូលសាលារៀនដូចក្មេងដទៃទេ ដោយគាត់បានត្រឹមតែរៀននៅក្រោមម្លប់ឈើប៉ុណ្ណោះ ។ ទោះបីជា ស៊ុំ មិនបានរៀនដល់ថ្នាក់ខ្ពស់ក៏ដោយ ប៉ុន្តែ ស៊ុំ អាចប្រកបអក្សរបានខ្លះៗដែរ ហើយ ស៊ុំ នៅតែចងចាំគ្រូឈ្មោះ អុក ដែលបានបង្រៀននៅក្នុងកងកុមារដដែល ។

នៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមទទួលជ័យជម្នះទាំងស្រុង ខ្មែរក្រហមក៏បានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ រួចបង្ខំឲ្យធ្វើការតាមជនបទនិងតាមកន្លែងផ្សេងៗទៀត ។ ពេលនោះ អង្គការបានចាត់តាំង ស៊ុំ ឲ្យចូលក្នុងកងកុមារ បំបែកឪពុកម្តាយរបស់គាត់នៅក្នុងកងមួយផ្សេងទៀត ។ ស៊ុំ ត្រូវខ្មែរក្រហមបញ្ជាឲ្យកាប់ដីដំបូក រែកដីនៅបាតត្រពាំងដាក់វាលស្រែ រើសអាចម៍គោនិងធ្វើជី ។ ស៊ុំ ធ្វើការស្ទើរគ្មានពេលសម្រាក ប៉ុន្តែមិនដែលបានហូបគ្រប់គ្រាន់ទេ ដោយអង្គការចែករបបអាហារឲ្យគាត់មួយថ្ងៃត្រឹមតែពីរពេលប៉ុណ្ណោះ ។ រៀងរាល់ថ្ងៃ ស៊ុំ ត្រូវក្រោកម៉ោង៥ព្រឹកទៅរែកដីរហូតដល់ម៉ោង១២ថ្ងៃត្រង់ទើបអាចឈប់សម្រាកបាន ។

ធ្វើការនៅក្នុងកងកុមារមិនបានដល់មួយឆ្នាំផង ស្រាប់តែថ្ងៃមួយពេលគាត់កំពុងតែរែកដី ប្រធានកងបានមកប្រកាសប្រាប់ថា អង្គការត្រូវការរើសមនុស្សទៅធ្វើពេទ្យនៅទីក្រុងភ្នំពេញ ។ នៅពេលបានឮពាក្យនេះ ស៊ុំ អរខ្លាំងណាស់ រួចបានសម្រេចចិត្តទៅតាមអង្គការ ព្រោះនៅក្នុងកងគាត់ត្រូវធ្វើការយ៉ាងធ្ងន់ធ្ងរនិងមិនបានហូបគ្រប់គ្រាន់ទៀត ។ ពេលធ្វើដំណើរទៅដល់ខេត្តតាកែវ ប្រធានកងបានប្រកាសប្រាប់ថា «កងនារីទាំងអស់សម្រាកនៅ



ជិន ស៊ុំ

ទីនេះមួយយប់សិន ចាំស្អែកយើងបន្តដំណើរទៅទីក្រុងភ្នំពេញ» ។ ដោយអស់កម្លាំងខ្លាំងពេក សុំ បានដេកលក់តាមឡានរហូតទៅដល់ភ្នំពេញទើបនារីម្នាក់ដែលអង្គុយជាប់គាត់បានដាស់ឲ្យក្រោកឡើង ហើយខ្សឹបប្រាប់ថា «សុំ យើងមកដល់ទីក្រុងភ្នំពេញហើយ» ។ សុំ បានភ្ញាក់ទាំងមមីមមើ ហើយលាន់មាត់ថា «អូ!ភ្នំពេញអីចឹង ពិតជាស្អាតមែន មានភ្លើងគ្រប់ទីកន្លែង» ។ សុំ ត្រេកអរណាស់យ៉ាងខ្លាំងព្រោះគិតថានឹងបានធ្វើការងារធូរស្រាលជាងមុន ប៉ុន្តែគាត់នៅតែព្រួយបារម្ភពីឪពុកម្តាយរបស់គាត់ដែលរស់នៅសហករណ៍ជានិច្ច ។

នៅភ្នំពេញ ខ្មែរក្រហមមិនបានឲ្យ សុំ ទៅធ្វើការនៅមន្ទីរពេទ្យភ្លាមនោះទេ ដោយឲ្យគាត់ស្នាក់នៅផ្ទះមួយរយៈសិន ។ ក្រោយមកទើបប្រធានកងអនុញ្ញាតឲ្យ សុំ ចូលធ្វើការនៅមន្ទីរពេទ្យ៦មករាដែលមានទីតាំងនៅខាងជើងវត្តភ្នំ ។ ដំបូង ប្រធានពេទ្យបានឲ្យ សុំ បោសសំរាម លាងបង្គន់ លាងកន្ថោរ ហើយនៅពេលព្រឹកត្រូវប្រមូលយកមុងភួយអ្នកជំងឺទៅបោកគក់ រៀបចំកម្រាលពូក និងចងមុងទុកឲ្យអ្នកជំងឺសម្រាក ។ នៅមន្ទីរនេះបានបែងចែកជាផ្នែកដូចជា របួស របេង និងគ្រុនក្តៅ ។ មួយរយៈក្រោយមក ប្រធានពេទ្យបានចាត់តាំង សុំ ឲ្យចូលធ្វើខាងផ្នែកលាងរបួសវិញដែលអ្នកជំងឺភាគច្រើនគឺជាទាហានដែលមានចរិតកាចសាហាវ ហើយពេលខ្លះបានស្រែកគំហកខ្លាំងៗដាក់ពេទ្យទៀតផង ។ ទោះបីបែបនេះក៏ដោយ ក៏ សុំ មិនតមាត់ជាមួយដែរ ។

នៅជិតមន្ទីរពេទ្យ៦មករាមានមន្ទីរពេទ្យផ្សេងមួយទៀត (មិនចាំឈ្មោះ) សម្រាប់ទទួលអ្នកជំងឺដែលមានសភាពធ្ងន់ធ្ងរខ្លាំង ។ មានថ្ងៃមួយ សុំ បានឃើញអ្នកបើកឡានដឹកក្មេងៗដែលមានអាយុចាប់ពី៩ឆ្នាំទៅ១០ឆ្នាំមួយឡានចេញទៅ ប៉ុន្តែ សុំ មិនដឹងថាអ្នកបើកឡាននោះដឹកយកទៅណាទេ ប៉ុន្តែឃើញពេលមានក្មេងស្លាប់លើឡាន គេនឹងទម្លាក់ចោលតាមប្រឡោះទ្រុងឡានតែម្តង ។ ចំណែកក្មេងមានជំងឺធ្ងន់គេទុកចោលនៅក្រោមដើមឈើបណ្តាលឲ្យក្មេងៗទាំងនោះស្រែកយំយ៉ាងខ្លាំងដោយសារគ្មានគ្រូពេទ្យព្យាបាលនិងអាហារហូប ។ សុំ អាណិត ក្មេងទាំងនោះណាស់ ប៉ុន្តែគាត់មិនដឹងថាត្រូវជួយក្មេងទាំងនោះ ដោយរបៀបណាទេ ។

នៅពេល សុំ ធ្វើការនៅមន្ទីរពេទ្យ៦មករា ប្រធានពេទ្យបានប្រាប់ថានៅពេលថែទាំអ្នកជំងឺត្រូវស្លៀកពាក់ពណ៌ស ហើយពេលសម្រាកពីការងារត្រូវស្លៀកពាក់ពណ៌ខ្មៅដោយក្នុងមួយខែអង្គការចែកខោអាវឲ្យមួយកំប្លេ ។ នៅពេលយប់ សុំ ដេកលើគ្រែជាមួយកុមារពេទ្យផ្សេងទៀត ហើយរៀងរាល់ថ្ងៃត្រូវងើបម៉ោង៥ព្រឹកដើម្បីរៀបចំសម្ភារៈសម្រាប់លាងរបួសឲ្យអ្នកជំងឺ ។ សុំ ធ្វើការរហូតដល់ម៉ោង១១ថ្ងៃត្រង់ទើបឈប់សម្រាកហូបបាយ ហើយម៉ោង១ត្រូវចូលធ្វើការងារបន្តទៀត ។ នៅពេលហូបបាយ កម្មាភិបាលពេទ្យទាំងអស់ត្រូវដើរទៅហូបបាយនៅរោងបាយរួម ចំណែកឯអ្នកជំងឺដែលដើរខ្លួនឯងបានត្រូវទៅហូបបាយរួមដែរ ប៉ុន្តែនៅតុផ្សេងគ្នា ។ ចំពោះអ្នកជំងឺដែលដើរមិនរួច ត្រូវមានគ្រូពេទ្យយករបបអាហារទៅឲ្យហូបដល់កន្លែងដេកតែម្តង ។

សុំ បន្តថា ប្រធានពេទ្យមិនសូវដាក់វិន័យតឹងរ៉ឹងដល់កម្មាភិបាលថ្នាក់ក្រោមទេ ដោយគ្រាន់តែណែនាំឲ្យមើលថែទាំអ្នកជំងឺឲ្យបានល្អ កុំតមាត់ជាមួយអ្នកជំងឺនិងបេះសាមគ្គីគ្នាប៉ុណ្ណោះ ។ លើសពីនេះទៅទៀត ប្រធានពេទ្យថែមទាំងអនុញ្ញាតឲ្យ សុំ និងសមាជិកដទៃទៀតទៅមើលការសម្តែងសៀករបស់ចិនបានចំនួន៤ដងដែរ ។

នៅទីនេះ សុំ មិនដែលបានឃើញមេដឹកនាំខ្មែរក្រហមចុះមកត្រួតពិនិត្យការងារទេ ។ ប៉ុន្តែថ្ងៃមួយស្រាប់តែប្រធានមន្ទីរពេទ្យបានប្រាប់ថា ប៉ុល ពត នឹងចុះមកទស្សនកិច្ចនៅមន្ទីរពេទ្យ៦មករានេះ រួចក៏ឲ្យសំពត់ហូលនិងអាវប៉ាក់មក សុំ ព្រមទាំងប្រាប់ឲ្យកាត់សក់ខ្លីត្រឹមកដើម្បីឈរទះដៃអបអរសាទរនិងកាន់ទង់ជាតិគ្រវីដើម្បីទទួលស្វាគមន៍ ។ ដូច្នេះ សុំ សង្ឃឹមថាថ្ងៃនោះនឹងបានឃើញមុខមេដឹកនាំខ្មែរក្រហមហើយ ។ ប៉ុន្តែ សុំ បែរជាមិនបានឃើញទេពីព្រោះមនុស្សច្រើនពេក ។

នៅពេលដែលវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ សុំ ក៏បានត្រឡប់ទៅស្រុកកំណើត និងប្រកបមុខរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត ។

**ចាន់ ផល្លា**

# ដំណឹងស្វែងរកប្អូនស្រី

នាងខ្ញុំឈ្មោះ ខៀវ ស៊ីផានី សព្វថ្ងៃនេះរស់នៅផ្ទះលេខ២០អា ផ្លូវលេខ៣៣៦ ក្រុមទី៥២ ភូមិទី៧ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុករបស់ខ្ញុំឈ្មោះ ខៀវ សាម និងម្តាយខ្ញុំឈ្មោះ ម៉ាយ កាន និងមានបងប្អូនចំនួន៧នាក់ ១) ខ្ញុំ, ២) ប្អូនប្រុស ខៀវ សុផាត ៣) ប្អូនប្រុស ខៀវ សាមចន្រ្ទាវុធ ៤) ប្អូនប្រុស ខៀវ តារ៉ា ៥) ប្អូនប្រុស ខៀវ សំសុផន ៦) ប្អូនស្រី ខៀវ សុផល ហៅ ម៉ៅ និង ៧) ប្អូនស្រីពៅ ខៀវ វណ្ណារី ។ នាងខ្ញុំសូមប្រកាសស្វែងរកប្អូនស្រីឈ្មោះ ខៀវ សុផល ហៅ ម៉ៅ ដែលបានបែកគ្នានៅឆ្នាំ១៩៧៨ នៅខេត្តបាត់ដំបង ។ មុនពេលបែកគ្នា សុផល ហៅ ម៉ៅ បានមកលេងផ្ទះដែលខ្ញុំស្នាក់នៅសហករណ៍ខេត្តបាត់ដំបង «ភូមិតាគង់ ស្រុកភ្នំស្រុក» បានរយៈពេលមួយយប់ទើបត្រឡប់ទៅកងចល័តបន្ទាយរំចេក «កងចល័តកុមារឈានមុខ» វិញ ។ ចាប់តាំងពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងពីប្អូនស្រីឈ្មោះ សុផល ហៅ ម៉ៅ ឡើយ ។

ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះ ខៀវ សុផល ហៅ ម៉ៅ ខាងលើនេះ សូមទំនាក់ទំនងមកទូរស័ព្ទលេខ ០១១ ២៧៨ ០៦៦ ឬ០១១ ៩១៨ ៥៥២ ឬក៏ទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ដំណឹងស្វែងរកបងប្រុសឈ្មោះ អ៊ុល ប៉ាក

នាងខ្ញុំឈ្មោះ អ៊ុល សៀម អាយុ៤៣ឆ្នាំ រស់នៅភូមិស្រែខ្វាវ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ ខ្ញុំសូមប្រកាសស្វែងរកបងប្រុសឈ្មោះ អ៊ុល ប៉ាក (បច្ចុប្បន្នអាយុ៥០ឆ្នាំជាង) ដែលបានបាត់ខ្លួនប្រហែលជាឆ្នាំ១៩៧៥ ឬ១៩៧៦ នៅពេលដែលខ្មែរក្រហមយកគាត់ទៅដាក់គុកនៅជ្រៃអូញោ ។ អ៊ុល ប៉ាក គឺជាទាហានខ្មែរក្រហមម្នាក់ ដោយគាត់បានចូលបដិវត្តន៍នៅឆ្នាំ១៩៧២ នៅភូមិស្រែខ្វាវ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនមិនដែលទទួលបានដំណឹងពីគាត់ឡើយ ។

ប្រសិនបើបងប្អូនណាបានឃើញ ឬដឹងដំណឹងអំពីឈ្មោះនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬតាមរយៈលេខទូរស័ព្ទ ០១២ ៣៣១ ៤៣១ ។ សូមអរគុណ ។

# សេចក្តីប្រកាសស្វែងរកបងប្រុសឈ្មោះ ចែម អាន

នាងខ្ញុំឈ្មោះ ចែម សុខជា អាយុ៣៦ឆ្នាំ រស់នៅភូមិទីប៉ាត់ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ ខ្ញុំមានឪពុកឈ្មោះ សឿន ម្តាយឈ្មោះ ណម និងមានបងប្អូនចំនួនបួននាក់ ស្រីម្នាក់ ប្រុសបីនាក់) ។ ខ្ញុំសូមប្រកាសស្វែងរកបងប្រុសទីបី ឈ្មោះ ចែម អាន ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៣ ឬ១៩៧៤ ដោយសារធ្វើទ័ពខ្មែរក្រហម ។ នៅឆ្នាំ១៩៨១ ខ្ញុំបានឮដំណឹងថា អាន រស់នៅប្រទេសថៃ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ឡើយ ។

ប្រសិនបើបងបានឃើញសេចក្តីប្រកាសនេះ ឬប្អូនបានទទួលដំណឹងពីគាត់ ឬបានជួបគាត់ សូមមេត្តាទំនាក់ទំនងមកខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៧ ៤៣ ៥៤ ៩១ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សូមអរគុណ ។

# សេចក្តីស្វែងរកបងប្រុស

ខ្ញុំឈ្មោះ កែវ ប៊ុនលី រស់នៅ ៧៦ Rue Rene Laennec 67200 Strasbourg-France សូមប្រកាសរកបងប្រុសឈ្មោះ កែវ ប៊ុនថុន ជាទាហានជំនាន់ លន់ នល់ បានទៅរៀននៅសហរដ្ឋអាមេរិកនៅឆ្នាំ១៩៧៣ រហូតឆ្នាំ១៩៧៦ ក៏បានទៅសិក្សានៅប្រទេសបារាំងទៀត រួចត្រឡប់ចូលមករស់នៅស្រុកខ្មែរវិញ ដោយជិះយន្តហោះចិន ។ រហូតមកដល់សព្វថ្ងៃនេះ គាត់បាត់ដំណឹងរហូត ។

ប្រសិនបើបងប្អូនណាបានឃើញសេចក្តីប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈអាសយដ្ឋានខាងលើ ឬ អ៊ីមែល : keodaniel@free.fr ។ សូមអរគុណ ។

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 124, April 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.